# សង្កេតការណ៍

២០

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែកុម្ភៈ-មេសា ឆ្នាំ២០១៣




## មាតិកា


ការស្តាប់សក្ខីកម្មសាក្សី សា វី ៣
ការស្តាប់សក្ខីកម្មសាក្សី អ៊ុង រ៉េន ៧
ការស្តាប់សក្ខីកម្មសាក្សី ឆោម សែ ១២
សវនាការដាក់ឯកសារ....... ១៦
ការស្តាប់សក្ខីកម្មសាក្សី អាល់ រ៉ុក្ហូ ៣៤
ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ ៤១
សវនាការស្តីពីការពិចារណា... ៤៨
សេចក្តីសម្រេចបំបែកសំណុំរឿង ៦៣
ការវាយតម្លៃសុខភាព នួន ជា ៦៥



ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, លឹម ជ័យទត្ត,
ឌី សុជាតា, និង ចាន់ ប្រាថ្នា


*សាលមហោស្រពចតុមុខ សាងសង់ឡើងក្នុងឆ្នាំ១៩៦១ ក្រោមជំនួយពីសហរដ្ឋអាមេរិក ។ រហូតដល់ឆ្នាំ១៩៧៥ សាលនេះត្រូវប្រើប្រាស់សម្រាប់កិច្ចប្រជុំថ្នាក់ខ្ពស់ និងសម្រាប់ការសម្តែងនានា ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាលនេះប្រើប្រាស់ជាសភាតំណាងប្រជាជន ។ ខែសីហា ឆ្នាំ១៩៧៩ អគារនេះ ប្រើប្រាស់ជាទីតាំងដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍ និងផ្តន្ទាទោសប្រហារជីវិតដោយកំបាំងមុខ ។ សព្វថ្ងៃ សាលនេះត្រូវបានស្គាល់ថាជា សាលសន្និសីទចតុមុខ និងប្រើប្រាស់សម្រាប់កិច្ចប្រជុំ និងសម្តែងសិល្បៈ ។ (ប្រភព :មជ្ឈមណ្ឌលឯកសារកម្ពុជា)*



នួន ជា កំពុងលើកដៃសំពះនៅលើផ្ទះរបស់ខ្លួន នៅដើមទសវត្សរ៍ឆ្នាំ២០០០ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២ : ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់

## ថ្ងៃទី៨ ខែមករា ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣

លឹម ជ័យរ័ត្ន, ឆាយ ឈុនលី, ចាន ប្រាថ្នា និង ឌី សុជាតា

ចាប់ពីថ្ងៃទី៨ ខែមករា ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការដោយកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥រូប ដើម្បីសួរដេញដោលអំពីព្រឹត្តិការណ៍ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនៅដំណាក់កាលទី១ និងទី២ នៅក្នុងរបបខ្មែរក្រហម និងការសម្លាប់អតីតទាហានអ្នករដ្ឋការនៃរបប លន់ នល់ ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង៥រូបនោះរួមមាន ៖ ទី១) សាក្សី សា រី អតីតកងការពារសន្តិសុខនៅមន្ទីរ-ក១ ដែលជាកន្លែងធ្វើការអចិន្ត្រៃយ៍របស់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទី២) សាក្សី អ៊ុង រ៉េន អតីតអនុប្រធានកងពល៨០១ ។ ទី៣) សាក្សី ឆោម សែ អតីតអនុមេ បញ្ជាការនៃអនុសេនាធំ ក្រោយមកជាប្រធានមន្ទីរសន្តិសុខអូរកន្សែងនៃកងពលលេខ៨០១ ។ ទី៤) សាក្សី អាល់ រ៉ុកហ្វ ជាអ្នកថតរូប និងអ្នកកាសែតជនជាតិអាមេរិកកាំងដែលស្ថិតនៅក្នុងព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថតបាននូវរូបជាច្រើនអំពីស្ថានភាពទីក្រុងភ្នំពេញនៅថ្ងៃជម្លៀស ។ ទី៥) ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ អតីតវិស្វករ នៅក្រសួងសាធារណការនៃរដ្ឋការ លន់ នល់ និងជាជនរងគ្រោះដែលបានបាត់សមាជិកគ្រួសារទាំងអស់ ដោយសាររបបខ្មែរក្រហម និងជាអ្នកនិពន្ធសៀវភៅ «ជីវិតកូនថ្ងៃ កូនត្រូវតែរស់» និងសៀវភៅ «មនោគមវិជ្ជាមហាឃាតករ» ។

ក្នុងអំឡុងពេលនៃសវនាការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង៥រូប អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបីដាច់ដោយឡែកផ្សេងទៀត ។

ទី១) សវនាការស្តីពីការបន្តបង្ហាញឯកសារ ដែលការិយាល័យ




ទិដ្ឋភាពនៃការសុំចុះចាញ់របស់ទាហាន លន់ នល់ នៅពេលដែលយោធាខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ (ប្រភពៈមជ្ឈមណ្ឌលឯកសារកម្ពុជា)

សហព្រះរាជអាជ្ញា ស្នើសុំដាក់ជាភស្តុតាង នៅក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ការសម្លាប់អតីតទាហានក្នុងរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ និងឯកសារទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ។

ទី២) សវនាការស្តីពីការពិចារណាលើផលវិបាកដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកសំណុំរឿង០០២ ។ សវនាការនេះ ធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលសម្រេចលុបចោលដីកាបំបែកនីតិវិធីក្នុងសំណុំរឿង០០២ របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ជុំវិញវិសាលភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និងបច្ច័យដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកនីតិវិធីនោះ ។

ទី៣) សវនាការស្តីពីការវាយតម្លៃសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ។ សវនាការនេះ គឺផ្តោតសំខាន់លើរបាយការណ៍ចុងក្រោយរបស់អ្នកជំនាញ ចន ខាំប៊ែល និង ស៊ីណា ហ្វាហ្សែល ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ដែលបានរកឃើញថា ជនជាប់ចោទ នួន ជា មានសម្បទា ទាំងផ្លូវកាយ និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។


ប្រជាជនចេញពីលំនៅដ្ឋានដើម្បីរកទីសុវត្ថិភាព ពេលយោធាខ្មែរក្រហមផ្លោងចូលជាយទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧២ ។ (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្របពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងរៀបចំចេញសេចក្តីសម្រេចថ្មីទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសថា នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៣ ជនជាប់ចោទ អៀង សារី បានទទួលមរណភាពនៅវេលាព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ម៉ោង៨ និង៤៥នាទី នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត ក្នុងអាយុ ៨៧ឆ្នាំ ដោយជំងឺស្ទះសរសៃឈាមបេះដូង ។ ការស្លាប់របស់ អៀង សារី នាពេលនេះ បានធ្វើឲ្យបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទ អៀង សារី ត្រូវបញ្ចប់ ។

ការស្លាប់របស់ អៀង សារី និងបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា រួមជាមួយនឹងការធ្វើពហិការពុំព្រមចូលបំពេញការងារដោយបុគ្គលិកជាតិ ខាងផ្នែកបកប្រែភាសានៅសាលាក្តីខ្មែរក្រហម ដោយសារបញ្ហាពុំទទួលបានប្រាក់បៀវត្សរ៍ បានធ្វើឲ្យសវនាការដែលគ្រោងនឹងប្រព្រឹត្តធ្វើនៅក្នុងខែមីនា ត្រូវពន្យារពេលជាបន្តបន្ទាប់ ។ ដូច្នេះក្រៅពីសវនាការស្តីពីការវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះសាលាដំបូងពុំបានបើកសវនាការជំនុំជម្រះដែលគ្រោងធ្វើ នៅក្នុងខែមីនា ឆ្នាំ២០១៣ ទេ ។

នៅក្នុងអំឡុងពេលនៃសវនាការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងរូប៥ និងសវនាការដាក់ឯកសារទាក់ទងនឹងសំណុំរឿង០០២/០១ និងសវនាការស្តីពីការពិចារណាលើផលវិបាកដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកសំណុំរឿង០០២ រួមជាមួយសវនាការស្តីពីការវាយតម្លៃលើសម្បទារបស់ នួន ជា មានការចូលរួមតាមដានដោយផ្ទាល់ពីសំណាក់ប្រជាជន សិស្ស និស្សិត និង អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ប្រមាណ៧០០០នាក់ មកពីបណ្តាខេត្តមួយចំនួនដូចជា កណ្តាល កំពង់ស្ពឺ កំពង់ចាម កំពង់ធំ ពោធិ៍សាត់ សៀមរាប តាកែវ ព្រៃវែង និងរាជធានីភ្នំពេញ ។

# សវនាការស្តាប់សក្ខីកម្មរបស់សាក្សី សា វី

## *ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣*

នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី សា វី អតីតកងការពារសន្តិសុខនៅមន្ទីរ-ក១ ដែលជាកន្លែងធ្វើការជាអចិន្ត្រៃយ៍របស់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សា វី ឈ្មោះដើមហៅថា ស សារីម មានអាយុ ៥២ ឆ្នាំ កើតនៅភូមិព្រៃតដូ ឃុំពោធិ៍អង្ក្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ បច្ចុប្បន្នរស់នៅភូមិអូរឈើក្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ។ ឪពុកឈ្មោះ ស គឹម ម្តាយឈ្មោះ ស្វាយ យន់ ប្រពន្ធឈ្មោះ ណាំ ហុន ហើយបច្ចុប្បន្នមានកូនចំនួន ៤ នាក់ ។

សវនាការបានប្រព្រឹត្តទៅអស់រយៈពេលមួយថ្ងៃពេញ ដោយមានប្រជាជនខ្មែរប្រមាណជាង ៤០០ នាក់ បានចូលរួមតាមដានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយពុំបានឃើញវត្តមានរបស់ជន ជាប់ចោទ អៀង សារី និង នួន ជា ឡើយ ។ ជនជាប់ចោទទាំងពីររូបនេះបានស្នើសុំអង្គជំនុំជម្រះ ចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ដែលត្រូវបានរៀបចំទុកក្នុងបន្ទប់រង់ចាំនៅក្រោមសាលសវនាការ ។ ដូចធ្លាប់បានអនុវត្តរួចមកហើយ មុននឹងប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលសាក្សី ប្រធានអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់សាក្សី នៅចំពោះមុខភាគី និងសាធារណជនទូទៅថា សាក្សីមានសិទ្ធិក្នុងការមិនឆ្លើយសំណួរទាំងឡាយណាដែលអាចដាក់បន្ទុកនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង (មានន័យថា តាមរយៈចម្លើយនោះ សាក្សីខ្លួនឯងអាចនឹងត្រូវបានចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌណាមួយ) ។ ប៉ុន្តែសាក្សីមានករណីកិច្ចឆ្លើយគ្រប់សំណួរទាំងអស់របស់ភាគី នូវអង្គហេតុទាំងឡាយណាដែលខ្លួនបានដឹង បានឮ ឬបានឃើញជាក់ស្តែង ពោលគឺមិនត្រូវឆ្លើយដោយធ្វើការស្មានឡើយ ។ បន្ថែមលើនេះទៀត ប្រធានអង្គជំនុំជម្រះបានព្យាយាមសួរបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុកិច្ចសម្ភាសន៍ ដែលសាក្សីបានផ្តល់ជូនអ្នកស៊ើបអង្កេតនៅដំណាក់កាលស៊ើបសួរ ។ សា វី បានបញ្ជាក់ដោយសង្ខេបថា លោកធ្លាប់បានផ្តល់បទសម្ភាសន៍ជូនអ្នកស៊ើបអង្កេតចំនួនមួយដង គឺនៅផ្ទះរបស់ខ្លួនតែម្តង ។ ក្នុងអំឡុងពេលនោះ ពោលគឺបន្ទាប់ពីបញ្ចប់នៃការធ្វើសម្ភាសន៍ អ្នកស៊ើបអង្កេតបានអានកំណត់ហេតុនៃកិច្ចសម្ភាសន៍នោះឲ្យស្តាប់ ។ សា វី បានបញ្ជាក់យ៉ាងច្បាស់ថា កំណត់ហេតុនោះ គឺពិតជាត្រឹមត្រូវតាមអ្វីដែលខ្លួនផ្តល់សក្ខីកម្មមែន ។ គួរបញ្ជាក់ថា ជារឿយៗ ក្រុមមេធាវីការពារក្តីតែងតែសួរសាក្សីអំពីបញ្ហាទាំងនេះ គឺក្នុងគោលបំណងដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការធ្វើកំណត់ហេតុស្តាប់ចម្លើយក្នុងអំឡុងពេលស៊ើបអង្កេត ។


សាក្សី សា វី

គួរបញ្ជាក់ថា ដោយសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សា វី ធ្វើការតែនៅក្នុងមន្ទីរ-ក១ ដូច្នេះក្នុងការសួរដេញដោលសាក្សីរូបនេះ ភាគីទាំងអស់ពុំបានសួរអង្គហេតុផ្សេងៗដែលឆ្ងាយចេញពីអង្គហេតុទាក់ទងនឹងមន្ទីរ-ក១នេះឡើយ ។ ដូចគ្នានេះដែរ សក្ខីកម្មរបស់ សា វី ភាគច្រើនក៏ផ្តោតតែលើអង្គហេតុដែលកើតនៅមន្ទីរ-ក១ នេះ ពោលគឺសាក្សីបានរៀបរាប់លម្អិតពាក់ព័ន្ធការងារយាមកាមរបស់ខ្លួន ការរៀបចំប្រព័ន្ធសន្តិសុខ

និងរចនាសម្ព័ន្ធគ្រប់គ្រងនៅមន្ទីរ-ក១ ។ល។

មុននឹងចូលដល់ការផ្តល់សក្ខីកម្មលើអង្គហេតុដូចបានរៀបរាប់ខាងលើនេះ សា វី បានបញ្ជាក់ ដោយសង្ខេបអំពីការងាររបស់ខ្លួន មុនពេលមកធ្វើការនៅមន្ទីរ-ក១ ។ សា វី បានរៀបរាប់ថា ក្នុងអំឡុងឆ្នាំ១៩៧៤ លោកបានធ្វើជានីរសាររត់សំបុត្រនៅក្នុងឃុំពោធិ៍អង្រ្កង ស្រុកកងពិសី ខេត្តកំពង់ស្ពឺ ដែលជាផ្នែកមួយនៃតំបន់៣៣ ។ ស្រុកនេះគឺស្ថិតក្នុងភូមិភាគមនិរតី ហើយក្នុងឆ្នាំ១៩៧៤ ស្រុកនេះ ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហមស៊ើរតែទាំងស្រុង ។ បន្ទាប់ពីវាយបែកទីក្រុងភ្នំពេញ សា វី ត្រូវបានបញ្ជូនឲ្យទៅធ្វើទ័ពរយៈពេល៦ខែនៅក្នុងស្រុកសំរោងក្នុងតំបន់៣៣ ។ ក្រោយមកនៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ សា វី ត្រូវបានចាត់តាំងឲ្យមកធ្វើការនៅមន្ទីរ-ក១ ដែលមានទីតាំងនៅមិនឆ្ងាយពីព្រះបរមរាជវាំងប៉ុន្មានឡើយ ។ សា វី បានបញ្ជាក់ថា ក្នុងអំឡុងពេលនោះ ទីក្រុងភ្នំពេញ គឺមានសភាពស្ងប់ស្ងាត់ មានមនុស្សរស់នៅតិចតួចតែប៉ុណ្ណោះ ពោលគឺមានតែយោធា កម្មកររោងចក្រ បុគ្គលិកក្រសួង និងកម្មាភិបាលខ្មែរក្រហមតែប៉ុណ្ណោះ ។

### ១) ការរៀបចំប្រព័ន្ធការពារសន្តិសុខនៅមន្ទីរក-១

សា វី បញ្ជាក់ថា មន្ទីរ-ក១ គឺជាកន្លែងស្នាក់នៅ និងធ្វើការរបស់ ប៉ុល ពត ហើយមេដឹកនាំ ធំៗ ដូចជា នួន ជា, អៀង សារី និង ខៀវ សំផន គឺបានមកមន្ទីរនេះជាញឹកញាប់ ។ ដូច្នេះ ការរៀបចំប្រព័ន្ធការពារសន្តិសុខត្រូវធ្វើឲ្យបានម៉ត់ចត់ ។ ប្រព័ន្ធការពារ ឬហៅថា ខ្សែក្រវាត់ការពារជុំវិញ មន្ទីរ-ក១ គឺមានបីជាន់ ។ ជាន់ទី១ ដែលជាជាន់នៅខាងក្នុងគេ (នៅក្នុងរបងនៃមន្ទីរ-ក១) គឺមានអ្នកយាមប្រមាណជាង១០នាក់ ដោយមាន អឿន តាន ហៅ ខៀវ ជាអ្នកទទួលខុសត្រូវ ។ ចំណែកជាន់ទី២ ដែលត្រូវយាមនៅខាងក្រៅជាប់របងនៃមន្ទីរ-ក១ គឺមានកងការពារប្រហែលពី៥០-៦០នាក់ ។ រូបលោកផ្ទាល់ (សា វី) គឺយាមនៅក្នុងជាន់នេះ ។ ជាន់ទី៣ គឺការពារនៅខាងក្រៅ ហៅថា កងការពារ "យ១០" ដែលមាន មី ជាអ្នកទទួលខុសត្រូវ ។ នៅជុំវិញអគារនៃមន្ទីរ-ក១ គឺមានប៉មចំនួន៤ ដែលប៉មនីមួយៗមានកំពស់ប្រមាណ ៧ម៉ែត្រ និងមានអ្នកយាមប្រដាប់ដោយអាវុធយ៉ាងតិច ៥នាក់ ។ សា វី បញ្ជាក់បន្ថែមថា របងព័ទ្ធជុំវិញអគារមានកំពស់យ៉ាងខ្ពស់ ។ ប្រសិនបើឈរនៅចម្ងាយ៤-៥ ម៉ែត្រពីខាងក្រៅនៃរបងនោះ គឺមិនអាចមើលឃើញតួនៃអគារមន្ទីរ-ក១ឡើយ ។ រាល់ការចេញចូលមន្ទីរ-ក១ គឺមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់ លើកលែងតែមេដឹកនាំធំៗ ។ នួន ជា, អៀង សារី និង ខៀវ សំផន បើកឡានចូលដល់ក្នុងរបងនៃអគារតែម្តង ដោយគ្មានការឆែកឆេរឡើយ ។ ចុងក្រោយ សា វី បញ្ជាក់ថា មានតែមេដឹកនាំធំៗតែប៉ុណ្ណោះដែលមានសិទ្ធិចេញចូលមន្ទីរ-ក១ ក្រៅពីនេះគឺគ្មានបុគ្គលណាម្នាក់ហ៊ានចេញចូលមន្ទីរនេះ ។

ពាក់ព័ន្ធនឹងការរៀបចំចាត់ចែងការងារវិញ សា វី បញ្ជាក់ថា អឿន តាន និង សុត ទទួលបញ្ជាពី ប៉ង់ និង លីន ហើយពេលខ្លះគឺទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត និង នួន ជា ។ គួរបបញ្ជាក់ថា បន្ទាប់ពី សា វី បញ្ជាក់ដូច្នេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានដាក់បង្ហាញកំណត់ហេតុស្តាប់សក្ខីកម្មរបស់ សុត ដែលបានផ្តល់ជូនអ្នកស៊ើបអង្កេត ។ ក្នុងឯកសារនោះ សុត បានបញ្ជាក់ថា ប៉ង់ ទទួលបញ្ជាពី ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន ។

គួរបបញ្ជាក់ថា ក្នុងការសួរដេញដោលសាក្សីពាក់ព័ន្ធនឹងការប្រើពាក្យ"ជាន់ទី១,២,៣" បានធ្វើឲ្យមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន គឺលោក អាកទួរ វែកកែន មានការភាន់ច្រឡំយ៉ាងខ្លាំង ។ មេធាវីយល់ច្រឡំថា ជាន់ទី១, ២, ៣ សំដៅទៅជាន់នៃអគារ ។ ដូច្នេះក្នុងការសួរ និងឆ្លើយ គឺមានភាពច្របូកច្របល់រហូតដល់ប្រធានអង្គជំនុំជម្រះបំភ្លឺមេធាវីថា ពាក្យជាន់ទី១ ទី២ និងទី៣ គឺសំដៅទៅលើការរៀបចំប្រព័ន្ធការពារសន្តិសុខនៅជុំវិញអគារ ។ ជាន់ទី១ មានន័យថាការពារនៅជាប់អគារ ពោលគឺនៅខាងក្នុងរបងអគារ ។ ជាន់ទី២ គឺការពារនៅខាងក្រៅរបងនៃអគារ ។ ចំណែកជាន់ទី៣ គឺប្រព័ន្ធការពារសន្តិសុខនៅខាងក្រៅគេ ពោលគឺនៅឆ្ងាយជាងគេពីតួនៃអគារមន្ទីរ-ក១ ។

### ២) កិច្ចប្រជុំនៅមន្ទីរក-១

សា វី បញ្ជាក់ថា នៅមន្ទីរ-ក១ មានកិច្ចប្រជុំជាញឹកញាប់ ដោយមានការចូលរួមពីកម្មាភិបាលមកពីភូមិភាគ និងតំបន់ ។ មុនពេលមានកិច្ចប្រជុំម្តងៗ ម្នាក់ៗត្រូវបានថ្នាក់លើណែនាំឲ្យ

ធ្វើការរៀបចំបោសសម្អាត និងពង្រឹងបន្ថែមនូវការការពារសន្តិសុខឲ្យបាន ។ ទោះបីជាយ៉ាងនេះក្តី សា វី មិនអាចបញ្ជាក់បានថា ខៀវ សំផន, នួន ជា និង អៀង សារី បានចូលរួមក្នុងកិច្ចប្រជុំទាំងនោះដែរឬយ៉ាងណានោះទេ ហើយក៏ពុំបានស្គាល់ឈ្មោះប្រធានភូមិភាគ ឬតំបន់ដែលបានមកចូលរួមប្រជុំទាំងនោះដែរ ។ ជាងនេះទៅទៀត កម្មវត្ថុ និងសេចក្តីសម្រេចនៃកិច្ចប្រជុំទាំងនោះ ក៏ពុំត្រូវបានផ្សព្វផ្សាយ ឬមានបុគ្គលណាម្នាក់យកមកប្រាប់ សាវី ដែរ ។ គួរបញ្ជាក់ថា សក្ខីកម្មទាំងនេះ គឺជាការឆ្លើយតបទៅនឹងសំណួររបស់លោក អាង ឧត្តម ជាមេធាវីការពារជនជាប់ចោទ អៀង សារី ដែលបានចោទសួរថា តើ សា វី បានដឹងថា កិច្ចប្រជុំនៅមន្ទីរ-ក១ និយាយអំពីបញ្ហាអ្វី ហើយបានសម្រេចអំពីបញ្ហាអ្វី ឬធ្លាប់មានបុគ្គលណាម្នាក់មកប្រាប់អំពីរឿងនេះដែរឬទេ ។ គួរបញ្ជាក់ផងដែរថា សំណួរទាំងនេះគឺតែងតែត្រូវបានមេធាវី អាង ឧត្តម ប្រើក្នុងការសួរដេញដោលសាក្សីផ្សេងៗទៀតដែរ ។

គឺ៣ថ្ងៃធ្វើម្តង ដោយមាន អឿន តាន ជាអ្នកបង្រៀន និងធ្វើឧទ្ទេសនាម ។ ការប្រជុំទាំងនោះ គឺភាគច្រើនផ្តោតអំពីការពង្រឹងការការពារសន្តិសុខនៅជុំវិញមន្ទីរ-ក១ និងដើម្បីអប់រំកែប្រែអ្នកដែលបានប្រព្រឹត្តកំហុស ។ អ្នកដែលមានកំហុស ដូចជា ការដើរចោលទីកន្លែង ការមិនគោរពវិន័យ នឹងត្រូវទទួលការអប់រំ ហើយក្រោយមក នឹងអាចត្រូវដកទៅឲ្យនៅមន្ទីរ ឬក្រសួងផ្សេងៗ ។

### ៣) ការរត់ភៀសខ្លួនរបស់មេដឹកនាំខ្មែរក្រហមនៅក្រោយឆ្នាំ១៩៧៩

សា វី បញ្ជាក់ថា ក្រោយពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខៀវ សំផន, នួន ជា, ប៉ុល ពត និងមេដឹកនាំមួយចំនួនទៀតបានរត់គេចខ្លួនទៅរស់នៅភាគខាងលិចនៃប្រទេសកម្ពុជា ។ ក្រៅពីនេះ គឺលោកផ្ទាល់ និងកងការពារមួយចំនួនទៀត ក៏បានទៅជាមួយមេដឹកនាំទាំងនេះដែរ ។ ពេលគឺ



ផ្ទះរបស់ នួន ជា នៅខេត្តប៉ៃលិន (ប្រភព ៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រៅពីកិច្ចប្រជុំធំៗរបស់មេដឹកនាំនៅមន្ទីរ-ក១ គឺមានកិច្ចប្រជុំផ្សេងៗទៀតដូចជា កិច្ចប្រជុំរៀនសូត្រនយោបាយ និងការប្រជុំទិតៀន ។ ការប្រជុំទិតៀនត្រូវបានធ្វើជាប្រចាំ ពេល

តាមការពារមេដឹកនាំទាំងនេះរហូតដល់ឆ្នាំ១៩៩០ ក្រោមការចាត់ចែងរបស់ សុត ។ គួរបញ្ជាក់ថា ក្នុងឆ្នាំ១៩៧៨ សុត មានតួនាទីជាអនុប្រធានសន្តិសុខនៃមន្ទីរ-ក១ ដោយមាន អឿន តាន ធ្វើជាប្រធាន ។ ប៉ុន្តែបន្ទាប់ពីរបប ប៉ុល ពត ត្រូវបានផ្តួលរំលំ ពេលគឺចាប់ពីពេលដែលមេខ្មែរក្រហមរត់ភៀសខ្លួនទៅបែកខាង

លិចនៃផ្ទៃប្រទេស សុត ទទួលបានការផ្សេងដែលជាប្រធានជំនួស តាន ។

ចុងក្រោយ សា វី បញ្ជាក់ថា ក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៩ ប៉ុល ពត បានធ្វើសុន្ទរកថា ដោយផ្ទាល់ទៅកាន់កងការពារសន្តិសុខ នៅលើភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដោយបានលើកឡើងថា ៖

«... មេដឹកនាំរបស់យើងចាប់ពីឆ្នាំ១៩៧៥ រហូតដល់ មករា ឆ្នាំ ១៩៧៩ បានមានកំហុស ទោះបីជាគាត់មិនបានបញ្ជាឲ្យសម្លាប់ប្រជាជន ឬក៏ធ្វើទារុណកម្មក៏ដោយ ក៏យើងត្រូវទទួលខុសត្រូវ ព្រោះយើងជា អ្នកដឹកនាំក្នុងអំឡុងពេលនោះ» ។

## បញ្ហាផ្សេងៗ

ក្នុងការសួរដេញដោលសាក្សី សា វី តំណាងសហព្រះរាជអាជ្ញា លោក សេង ប៊ុនឃាង តែងតែដកស្រង់សក្ខីកម្មរបស់សាក្សីរូបនេះដែលបានផ្តល់ជូនអ្នកស៊ើបអង្កេតមកសួរបញ្ជាក់ ។ ប៉ុន្តែវិធីសាស្ត្រសួរដេញដោលនេះ គឺត្រូវបានក្រុមមេធាវីរបស់ខៀវ សំផន ជាពិសេសមេធាវី អាកទួរ វែកគែន បានជំទាស់យ៉ាងខ្លាំង ។ មេធាវីបានលើកឡើងថា ក្នុងការសួរដេញដោលសាក្សី ភាគីទាំងអស់ គឺមិនត្រូវដកស្រង់យកចម្លើយដែលសាក្សីបានផ្តល់ជូនអ្នកស៊ើបអង្កេតមកសួរ ដោយគ្រាន់តែបញ្ជាក់ថាត្រឹមត្រូវដែរ ឬអត់នោះទេ គឺភាគីត្រូវសួរដេញដោលដោយផ្ទាល់ទៅកាន់សាក្សី ដើម្បីអាចផ្ទៀងផ្ទាត់បានថា តើសក្ខីកម្មដែលសាក្សីបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ និងនៅចំពោះមុខអ្នកស៊ើបអង្កេត គឺមានលក្ខណៈខុសគ្នាដូចម្តេច ។ គួរបញ្ជាក់ថា នេះគឺពុំមែនជារឿងថ្មីឡើយ ពោលគឺជាញឹកញាប់តំណាងសហព្រះរាជអាជ្ញាតែងតែដកស្រង់ចម្លើយដែលសាក្សីធ្លាប់បានផ្តល់ជូនអ្នកស៊ើបអង្កេតម្តងរួចហើយ មកសាកសួរបញ្ជាក់ជាថ្មីម្តងទៀត ហើយការអនុវត្តបែបនេះ គឺតែងតែរងការជំទាសពីមេធាវី អាកទួរ វែកគែន ។

បញ្ហាសំខាន់មួយទៀតដែលក្រុមមេធាវីការពារក្តីតែងតែលើកឡើងនោះ គឺពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃកិច្ចសម្ភាសន៍ដែលបានធ្វើដោយអ្នកស៊ើបអង្កេត ។ ក្នុងការសួរដេញដោលសាក្សី សា វី មេធាវី អាកទួរ វែកគែន បានដកស្រង់ខ្សែអាត់បទសម្ភាសន៍ដែលថា «ចុះឈ្មោះ ឆួន ដែលយើងបាននិយាយកាលពីម្សិលមិញនោះ» ហើយបានចោទសំណួរថា តើការណ៍ដែលសាក្សីបានជួបជាមួយអ្នកស៊ើបអង្កេត មុនពេលមានការធ្វើសម្ភាសន៍ដែលមានការថតជាខ្សែអាត់សម្លេង មានការពិភាក្សាគ្នាអំពីបញ្ហាអ្វីខ្លះ? ហើយមាននិយាយអំពីបញ្ហាដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ឆ្លើយតបនឹងសំណួរទាំងនេះ សាក្សីបានបញ្ជាក់ថា លោកពិតជាបានជួប



តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង

ពិភាក្សាជាមួយអ្នកស៊ើបអង្កេតមុនពេលមានការធ្វើសម្ភាសន៍ដែលមានការថតខ្សែអាត់សម្លេងមែន ។ ប៉ុន្តែលោកពុំបានចាំនូវអ្វីដែលបានពិភាក្សាក្នុងអំឡុងពេលនោះឡើយ ។

គួរបញ្ជាក់ថា ការណ៍ដែលអ្នកស៊ើបអង្កេតបានជួបពិភាក្សាជាមួយសាក្សីជាមុន មុនពេលដែលមានការសួរយកចម្លើយដោយមានថតជាខ្សែអាត់សម្លេង គឺកើតមានជាញឹកញាប់ ហើយការអនុវត្តនេះ គឺតែងតែត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស ។ មេធាវីតែងតែបង្ហាញនូវការព្រួយបារម្ភរបស់ខ្លួនដោយខ្លាចថា សក្ខីកម្មដែលទទួលបាននៅដំណាក់កាលស៊ើបអង្កេត គឺពុំបានកើតចេញពីការចងចាំពិតប្រាកដរបស់សាក្សី ពោលគឺការជួបពិភាក្សាគ្នារវាងអ្នកស៊ើបអង្កេត និងសាក្សីមុនពេលមានការសួរយកចម្លើយដែលមានការថតជាខ្សែអាត់សម្លេង គឺអាចជាវិធីសាស្ត្រមួយដើម្បីធ្វើការរំពុកដល់ការចងចាំរបស់សាក្សី ។

# សវនាការស្តាប់សក្ខីកម្មសាក្សី អ៊ុង រ៉េន

## ថ្ងៃទី៩-១១ ខែមករា ឆ្នាំ២០១៣

នៅថ្ងៃទី៩-១១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី អ៊ុង រ៉េន អតីតអនុប្រធានកងពល៨០១ ។ សវនាការបានប្រព្រឹត្តទៅអស់រយៈពេល ២ ថ្ងៃកន្លះ ដោយមានប្រជាជនខ្មែរប្រមាណ ១១០០ នាក់ មកពីខេត្តកណ្តាល និងតាកែវ ចូលរួមតាមដានផ្ទាល់នៅបន្ទប់សវនាការ ដោយពុំមានវត្តមានរបស់ជនជាប់ចោទ អៀង សារី និង នួន ជា ឡើយ ។ ជនជាប់ចោទទាំងពីរនេះបានស្នើសុំអង្គជំនុំជម្រះចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ដែលត្រូវបានរៀបចំទុកក្នុងបន្ទប់រង់ចាំនៅក្រោមសាលសវនាការ ។ ដូចធ្លាប់បានអនុវត្តរួចមកហើយ មុននឹងប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលសាក្សី ប្រធានអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិនិងករណីកិច្ចរបស់សាក្សីនៅចំពោះមុខភាគី និងសាធារណជនទូទៅថា សាក្សីមានសិទ្ធិក្នុងការមិនឆ្លើយសំណួរទាំងឡាយណាដែលអាចដាក់បន្ទុកនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង (មានន័យថាតាមរយៈចម្លើយនោះ សាក្សីខ្លួនឯងអាចនឹងត្រូវបានចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌណាមួយ) ។ ប៉ុន្តែសាក្សីមានករណីកិច្ចឆ្លើយគ្រប់សំណួរទាំងអស់របស់ភាគីនូវអង្គហេតុទាំងឡាយណាដែលខ្លួនបានដឹង បានឮ ឬបានឃើញជាក់ស្តែង ពោលគឺមិនត្រូវឆ្លើយ ដោយស្មានឡើយ ។ បន្ថែមលើនេះទៀត ប្រធានអង្គជំនុំជម្រះបានព្យាយាមសួរបញ្ជាក់អំពីភាពត្រឹមត្រូវនៃកិច្ចសម្ភាសន៍ដែលសាក្សីបានផ្តល់ជូនអ្នកស៊ើបអង្កេតនៅដំណាក់កាលស៊ើបសួរ ។ អ៊ុង រ៉េន បានបញ្ជាក់ថា លោកធ្លាប់បានផ្តល់បទសម្ភាសន៍ជូនអ្នកស៊ើបអង្កេតចំនួន ៣ដង ហើយកំណត់ហេតុនៃកិច្ចសម្ភាសន៍ទាំងនេះ គឺមានភាពត្រឹមត្រូវតាមអ្វីដែលលោកបានផ្តល់សក្ខីកម្ម ។ គួររំឭកថា ជារឿយៗ ក្រុមមេធាវីការពារក្តីតែងតែសួរសាក្សីអំពីបញ្ហាទាំងនេះ គឺក្នុងគោលបំណងដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការធ្វើកំណត់ហេតុស្តាប់ចម្លើយក្នុងអំឡុងពេលស៊ើបអង្កេត ។ បន្ទាប់ពីសួរបញ្ជាក់អំពីអត្តសញ្ញាណ និងប្រាប់អំពីសិទ្ធិរបស់សាក្សី ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនភាគីដើម្បីសួរដេញដោលសាក្សី ដោយចាប់ផ្តើមពីក្រុមតំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបី ។

គួរកត់សម្គាល់ថា ក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អ៊ុង រ៉េន បានរៀបរាប់ដោយសង្ខេបអំពីប្រវត្តិការងាររបស់គាត់មួយចំនួន ចាប់តាំងពីពេលចូលរួមក្នុងចលនាបដិវត្តរហូតដល់របបខ្មែរក្រហមត្រូវបានផ្តួលរំលំក្នុងឆ្នាំ១៩៧៩ ។ បន្ថែមលើនេះ លោកបានរៀបរាប់ត្រួសៗអំពីចំណុចជាក់លាក់មួយចំនួន ជាពិសេសទាក់ទងនឹង កងពលតូចលេខ ១៤, កងពល ៨០១, អំពីសេនាធិការកងទ័ព, ការបោសសម្អាតខ្មាំងនៅក្នុងជួរកងទ័ព និង ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាដើម ។

### ១) ប្រវត្តិសាវតាររបស់ អ៊ុង រ៉េន

អ៊ុង រ៉េន កើតក្នុងឆ្នាំ១៩៥០ នៅភូមិតាំងពោធិ៍ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ បច្ចុប្បន្ន រស់នៅភូមិផ្តៀកជ្រុំ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ឪពុកឈ្មោះ អ៊ុង ខាត់ ម្តាយឈ្មោះ ហង់ ស៊ីម ប្រពន្ធឈ្មោះ ភឿក រ័ត្ន និងមានកូនចំនួន ៤ នាក់ ។ បច្ចុប្បន្នប្រកបមុខរបរធ្វើស្រែចម្ការ និងបម្រើការងារក្នុងក្រុមប្រឹក្សាស្រុក ។

ក្នុងឆ្នាំ១៩៦៨ អ៊ុង រ៉េន បានរត់ចូលព្រៃក្រោមការណែនាំរបស់ ហេង ដើម្បីរួបរួមកម្លាំងធ្វើការតស៊ូរំដោះប្រទេសចេញពីការជិះជាន់ ។ ប៉ុន្តែក្នុងអំឡុងពេលនោះ គាត់ពុំទាន់បានចូលរួមយ៉ាងសកម្មនូវឡើយ គឺទើបតែឆ្នាំ១៩៦៩ប៉ុណ្ណោះដែលលោកបានចូលរួមក្នុងចលនាបដិវត្តពេញលេញ ។ អ៊ុង រ៉េន ត្រូវបានជ្រើសរើសឲ្យបម្រើជាយោធារបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧០ ពោលគឺបន្ទាប់ពីមានការទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ ចេញពីដំណែង ។ បន្ទាប់ពីចូលបម្រើការជាយោធាខ្មែរក្រហម លោក ត្រូវបាន ចេង អន ដែលជាអ្នកទទួលខុសត្រូវតំបន់ និងកងទ័ពនៅក្នុងភូមិភាគពិសេស ណែនាំឲ្យបង្កើតកងតូច ដែលមានគ្នា

៣០នាក់ ។ ក្រោយមកបង្កើតជាកងវរៈសេនាធំ ដោយមានការចូលរួមពីកងទ័ពមកពីភូមិភាគនិរតី ។ លោកមានតួនាទីជាប្រធានវរៈសេនាធំ កាន់កាប់កងទ័ព៥០០នាក់ ដោយមានឈ្មោះ សឿន ជាអនុប្រធាន ។ ក្រោយមកវរៈសេនាធំនេះត្រូវបានបញ្ចូលជាមួយកងវរៈសេនាធំផ្សេងៗទៀត បង្កើតបានជាកងពលតូចលេខ១៨ ដែលមានភារកិច្ចផ្តោតសំខាន់ក្នុងការវាយយកទីក្រុងភ្នំពេញ ។ អ៊ុង វ៉ែន បានដឹកនាំកងទ័ពរបស់ខ្លួនវាយចូលទីក្រុងតាមផ្លូវពោធិ៍ចិនតុង ប៉ុន្តែដោយត្រូវរបួស លោកត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅវត្តតាំងក្រសាំង ។ បន្ទាប់ពីវាយបានទីក្រុងភ្នំពេញ កងពលតូចលេខ១៨ ត្រូវបានរំសាយចោលដើម្បីបង្កើតកងពល ៨០១ ។ អ៊ុង វ៉ែន ត្រូវបានចាត់តាំងឲ្យធ្វើជាលេខាកងវរៈសេធំលេខ៨២ នៃកងពល៨០១ ។ ក្នុងតួនាទីនេះ លោកត្រូវបានបញ្ជូនទៅឈរជើងការពារនៅ វើនសៃ ក្នុងខេត្តរតនៈគិរី ។ បន្ទាប់មក អ៊ុន វ៉ែន ក្លាយជាអនុប្រធានកងពល ៨០១ ជំនួស សាន ហៅ “បង០៦” ។ ចុងក្រោយ អ៊ុង វ៉ែន ត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញដើម្បីបម្រើការនៅសេនាធិការកងទ័ព ។ ក្នុងអំឡុងពេលនេះដែរ អ៊ុង វ៉ែន និង សូ សារឿន (ជាលេខាកងពល៨០១) បានក្លាយជាសមាជិកសភាតំណាងឲ្យផ្នែកកងទ័ព ។ អ៊ុង វ៉ែន បានបញ្ជាក់ថា ក្នុងឋានៈជាសមាជិកសភា លោកពុំដែលឃើញមានការកោះប្រជុំ ការអនុម័តច្បាប់ ឬបទបញ្ញត្តិអ្វីទាំងអស់ ។

### ២) កងពលតូចលេខ១៨

អ៊ុង វ៉ែន បញ្ជាក់ថា កងពលតូចលេខ១៨ គឺជាលទ្ធផលនៃការបញ្ចូលគ្នារវាងកងវរៈសេនាធំរបស់លោកផ្ទាល់ និងកងវរៈសេនាធំជាច្រើនទៀតមកពីភូមិភាគនិរតី ។ មេបញ្ជាការកងពលនេះ គឺ សូ សារឿន ហៅ ០៥ និង សាន ហៅ ០៦ ជាអនុប្រធាន ។ មុខព្រួញសំខាន់របស់កងពលតូចលេខ១៨ គឺវាយដណ្តើមយកទីក្រុងភ្នំពេញពីទាហាន លន់ នល់ ។ អ៊ុង វ៉ែន ជាប្រធានវរៈសេនាធំមួយក្នុងចំណោមប្រធានវរៈសេនាធំផ្សេងៗទៀតនៃកងពលនេះ និងមាន សឿន ជាអនុប្រធានរបស់ខ្លួន ទទួលបន្ទុកដឹកនាំកងទ័ពចំនួន ៥០០នាក់ ប្រយុទ្ធជាមួយទាហាន លន់ នល់ នៅបាសិត, ខដុគ្គ និងកន្លែងផ្សេងៗទៀត ។ ក្នុងការវាយចូលទីក្រុងភ្នំពេញ កងពលតូចលេខ១៨ បានវាយចូលតាមផ្លូវពូនភ្នំ និងតាំងក្រសាំង ហើយពេលនោះកងទ័ពរបស់ អ៊ុង វ៉ែន បានវាយចូលតាមពោធិ៍ចិនតុង ។ ចំណែកកងទ័ពរបស់ភូមិភាគនិរតី គឺវាយចូលតាមភាគខាងត្បូងទីក្រុងភ្នំពេញ ។ បន្ទាប់ពីវាយបានទីក្រុងភ្នំពេញភ្លាម កងពលតូចលេខ១៨ ត្រូវបានចាត់តាំងឲ្យយាមការ ចាប់ពីមន្ទីរពេទ្យលោកសង្ឃរហូតដល់ស្តាតអូឡាំពិក ។ ប៉ុន្តែ បន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរបស់ អ៊ុង វ៉ែន គឺត្រូវបានចាត់តាំងឲ្យដើរល្បាត, រៀបចំ និងបោសសម្អាតទីក្រុង ។

### ៣) ការប្រជុំបង្កើតកងពល៨០១

ពាក់ព័ន្ធនឹងការប្រជុំបង្កើតកងពល ៨០១ អ៊ុង វ៉ែន បានបញ្ជាក់ថា បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញបានប្រមាណ ២-៣ ខែ បក្សបានរៀបចំកិច្ចប្រជុំធំមួយនៅស្តាតអូឡាំពិច ដោយមានការចូលរួមពីថ្នាក់ដឹកនាំធំៗរួមមាន៖ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន លើកលែង ខៀវ សំផន គឺពុំមានវត្តមាននៅក្នុងពេលនោះ ។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងក្នុងគោលបំណងរៀបចំកងពលតូចលេខ១៨ សារជាថ្មី ពោលគឺដើម្បីរំសាយកងពលតូចលេខ១៨ ចោល រួចបង្កើតកងពលលេខ ៨០១ ជំនួសវិញ ។ ទោះបីជាយ៉ាងនេះក្តី សមាសភាពដឹកនាំគឺពុំមានការកែប្រែច្រើនឡើយ គឺ សូ សារឿន ហៅ ០៥ នៅតែជាប្រធានកងពល និង សាន ហៅ ០៦ ជាអនុប្រធានដដែល ។ កងពលនេះត្រូវបានបែងចែកជា ៣ កងវរៈសេនាធំ គឺកងវរៈសេនាធំលេខ៨១ ដឹកនាំដោយ ម៉ូត, កងវរៈសេនាធំលេខ៨២ ដឹកនាំដោយ អ៊ុង វ៉ែន ផ្ទាល់ និងកងវរៈសេនាធំលេខ៨៣ ដឹកនាំដោយ ធិន ។ នៅក្នុងវរៈសេនាធំនីមួយៗមានអ្នកទទួលខុសត្រូវផ្នែកនយោបាយ យោធា និងភស្តុភារ ។ ចុងក្រោយ អ៊ុង វ៉ែន បញ្ជាក់ថា តួនាទីសំខាន់របស់កងពល ៨០១ ឈរជើងការពារនៅខេត្តរតនៈគិរី និង ស្ទឹងត្រែង ។ កងវរៈសេនាធំរបស់ អ៊ុង វ៉ែន មានគ្នាប្រមាណជាង ៤០០ នាក់ ត្រូវបានចាត់តាំងឲ្យឈរជើងនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។

ពាក់ព័ន្ធនឹងសមាសភាពចូលរួម និងកាលបរិច្ឆេទជាក់លាក់នៃកិច្ចប្រជុំបង្កើតកងពលលេខ៨០១ គឺសាក្សីពុំបានបញ្ជាក់ច្បាស់លាស់

ឡើយ ។ ទោះបីជាយ៉ាងណាក្តី តំណាងសហព្រះរាជអាជ្ញាបាន ព្យាយាមបញ្ជាក់អំពីបញ្ហាទាំងនេះ តាមរយៈការបង្ហាញឯកសារ ទស្សនាវដ្តីទង់បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះខែសីហា ឆ្នាំ១៩៧៥ ។ តាមរយៈទស្សនាវដ្តីបានបញ្ជាក់ថា កិច្ចប្រជុំបង្កើតកងពល៨០១ គឺត្រូវបានធ្វើឡើងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ដោយមានកងទ័ពចូលរួមប្រមាណ៣០០០នាក់ ក្រោមអធិបតីភាពរបស់មេដឹកនាំសំខាន់ៗបក្សកុម្មុយនីស្តកម្ពុជា ។

### ៤) ប្រព័ន្ធទំនាក់ទំនងការងារផ្នែកយោធា

ពាក់ព័ន្ធនឹងការទទួលបញ្ជាពីថ្នាក់លើ អ៊ុង រ៉េន បញ្ជាក់ថា ជាទូទៅ ថ្នាក់លើ កោះហៅប្រធានកងពលឲ្យទៅជួបដើម្បីដាក់បញ្ជា ។ បន្ទាប់ពីទទួលបានបញ្ជាពីថ្នាក់លើ ប្រធានកងពល កោះហៅប្រធានវរៈសេនាធំទាំងអស់នៅក្នុងកងពលឲ្យមកជួបដើម្បីដាក់បញ្ជាបន្ត ។ ប៉ុន្តែមានករណីខ្លះ ថ្នាក់លើបានកោះហៅទាំងប្រធានកងពល និងប្រធានកងវរៈសេនាធំទាំងអស់ឲ្យមកជួប ដើម្បីទទួលបញ្ជាព្រមគ្នាតែម្តង ។

ចំពោះការរាយការណ៍វិញ អ៊ុង រ៉េន បានបញ្ជាក់ថា ប្រធានកងវរៈសេនាធំត្រូវរាយការណ៍ទៅប្រធានកងពល ហើយប្រធានកងពលត្រូវរាយការណ៍ទៅថ្នាក់លើរបស់ខ្លួនបន្តទៀត ។ សម្រាប់ អ៊ុង រ៉េន ផ្ទាល់ ដែលជាប្រធានកងវរៈសេនាធំ គឺត្រូវរាយការណ៍ទៅ សូ សារឿន ដែលជាប្រធានកងពល ហើយ សូ សារឿន នឹងរាយការណ៍បន្តទៅ សុន សេន ។ ប៉ុន្តែ ក្នុងករណីមានស្ថានការណ៍ចាំបាច់ ហើយ សូ សារឿន មិននៅ ត្រូវរាយការណ៍ទៅ សុន សេន ដោយផ្ទាល់ ។ មធ្យោបាយក្នុងការរាយការណ៍ ឬទំនាក់ទំនង គឺតាមរយៈសារទូរលេខវិទ្យុទាក់ទង ឬធ្វើដំណើរទៅដល់កន្លែងរាយការណ៍ ។ អ៊ុង រ៉េន បានបញ្ជាក់បន្ថែមថា ជារៀងរាល់ខែ លោកបានរាយការណ៍ទៅ សូ សារឿន (តាមរយៈសារទូរលេខ ឬទៅដល់មូលដ្ឋានកងពលផ្ទាល់) អំពីស្ថានការណ៍ផ្សេងៗដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយកងវរៈសេនាធំរបស់គាត់ ។ ទោះបីជាយ៉ាងណាលោកពុំបានដឹងថា ប្រធានកងពលបានរាយការណ៍បន្តទៅថ្នាក់មជ្ឈិមដែរ ឬយ៉ាងណានោះទេ គឺគ្រាន់តែដឹងថា កងពលគឺមានទូរលេខសម្រាប់បញ្ជូនរបាយការណ៍ ហើយជាញឹកញាប់ ប្រធានកងពលរបស់គាត់បានមកទីក្រុងភ្នំពេញដើម្បីជួបថ្នាក់លើជាញឹកញាប់ ។ គួរបញ្ជាក់ថា ពាក់ព័ន្ធចំណុចទាំងនេះ តំណាងសហព្រះរាជអាជ្ញា គឺលោក ឌេល លីសាក់ បានបង្ហាញសារទូរលេខមួយចំនួនដើម្បីឲ្យសាក្សីពិនិត្យចំណារ និងហត្ថលេខាដែលបានចុះនៅលើឯកសារទាំងនោះ ។ សារទូរលេខទាំងនោះ ភាគច្រើនគឺជារបាយការណ៍ដែល សូ សារឿន បានរាយការណ៍ទៅ បង៨៩ អំពីបាតុភាពនៅតាមព្រំប្រទល់ប្រទេសឡាវ ហើយ បង៨៩ បានផ្តល់យោបល់មកវិញ ។ ទោះបីជាយ៉ាងណា ខ្លឹមសារនៃឯកសារទាំងនោះ គឺពុំត្រូវបានយកមកសួរដេញដោលលម្អិតឡើយ ព្រោះគោលបំណងរបស់ លោក ឌេល លីសាក់ គឺគ្រាន់តែសួរបញ្ជាក់ពីអត្តសញ្ញាណរបស់ឯកសារតែប៉ុណ្ណោះ ។ អ៊ុង រ៉េន អះអាងថា ចំណារ និង ហត្ថលេខាទាំងនោះ គឺពិតជារបស់ សូ សារឿន ហើយពាក្យ "បង៨៩" គឺសំដៅទៅ សុន សេន ។

### ៥) សេនាធិការកងទ័ព

អ៊ុង រ៉េន បានបញ្ជាក់ថា បន្ទាប់ពីគាត់ត្រូវបានចាត់តាំងឲ្យបំពេញការងារជាអនុប្រធានកងពល ៨០១ ជំនួស សាន ហៅ ០៦ គាត់បានមកទទួលការបណ្តុះបណ្តាលបន្ថែមនៅទីក្រុងភ្នំពេញ ហើយ ចាប់ពីពេលនោះមកក៏ចូលបម្រើការងារនៅសេនាធិការតែម្តង ។ នៅក្នុងសេនាធិការនេះមានកម្មាភិបាលធំៗមួយចំនួនដូចជា សោម, ណាត និង ឆាន ។ អ្នកទាំងបីនេះក៏ជាកម្មាភិបាលបម្រើការងារនៅក្នុងអគ្គសេនាធិការផងដែរ ។ នៅក្រោមសេនាធិការ គឺមានមន្ទីរសេនាធិការ ។ មន្ទីរនេះមានទីតាំងនៅក្រោយក្រសួងការពារជាតិ ហើយមានបុគ្គលិក និងកម្មាភិបាលបម្រើការងារប្រមាណជាង ៣០នាក់ ព្រមទាំងមានម៉ាស៊ីនសារទូរលេខសម្រាប់ទាក់ទង ។ លើសពីនេះទៀត សម្ភារៈយោធា រួមមានគ្រាប់រំសេវ ។ល ។ គឺត្រូវបានរក្សាទុកនៅទីនេះដើម្បីចែកចាយទៅតាមកងពលផ្សេងៗ ។

ទោះបីជាយ៉ាងណា អ៊ុង រ៉េន ពុំបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីតួនាទី ឬភារកិច្ចរបស់សេនាធិការ រួមទាំងតួនាទី និងមុខដំណែងរបស់ខ្លួននៅក្នុងសេនាធិការនេះ ។ អ៊ុង រ៉េន អះអាងថា ខ្លួនពុំមានតួនាទី និងភារកិច្ចច្បាស់លាស់ឡើយ ពោលរាល់ការបំពេញការងារផ្សេងៗ គឺធ្វើតាមការណែនាំរបស់ សោម ។ ជាទូទៅ សោម ចាត់តាំងឲ្យលោកទៅចូលរួមប្រជុំជាមួយគណៈ

លេខាកងពលផ្សេងៗ ពាក់ព័ន្ធនឹងស្ថានភាពខ្មាំងនៅក្នុងជួរកងពលនីមួយៗ រួចរាយការណ៍ប្រាប់សេនាធិការវិញ ។ អ៊ុន វ៉េន បញ្ជាក់ថា គ្រប់ការចូលរួមប្រជុំទាំងនោះ គឺលោករាយការណ៍ឲ្យ សោម ហើយ សោម រាយការណ៍បន្តទៅថ្នាក់លើ ។

គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងពេលវេលាដែល អ៊ុន វ៉េន មកបំពេញការងារនៅសេនាធិការ មិនមានភាពច្បាស់លាស់ឡើយ ។ អ៊ុន វ៉េន អះអាងថាខ្លួនមកបំពេញការងារនៅអង្គភាពនេះ គឺក្នុងអំឡុងឆ្នាំ១៩៧៧ ។ ផ្ទុយពីការអះអាងនេះ តំណាងសហព្រះរាជអាជ្ញា គឺលោក ឌេល លីសាក់ លើកឡើងថា សាក្សីបានមកបំពេញការងារក្នុងអំឡុងឆ្នាំ១៩៧៦ ។ លោក ដេលី សាក់ បានព្យាយាមបង្ហាញឯកសារជាច្រើនដែលបញ្ជាក់ថា អ៊ុន វ៉េន បានមកបំពេញការងារនៅសេនាធិការតាំងពីឆ្នាំ១៩៧៦មកម៉្លេះ ។ ឯកសារទាំងនេះ គឺជារបាយការណ៍ដែល អ៊ុន វ៉េន បានផ្ញើរឲ្យ សោម នៅពេលដែលខ្លួនចូលរួមប្រជុំជាមួយលេខាកងពលផ្សេងៗក្នុងអំឡុងឆ្នាំ១៩៧៦ ។ បន្ទាប់ពីបានពិនិត្យមើលឯកសារទាំងនោះ អ៊ុន វ៉េន ពុំបានបង្ហាញជំហរយល់ស្រប ឬបដិសេធណាមួយចំពោះកាលបរិច្ឆេទនៃឯកសារទាំងនោះឡើយ ។ គួរបញ្ជាក់បន្ថែមថា ភាពខុសគ្នានៃកាលបរិច្ឆេទដែល អ៊ុន វ៉េន ចូលមកបំពេញការងារនៅសេនាធិការមានសារៈសំខាន់ចំពោះតំណាងសហព្រះរាជអាជ្ញា ព្រោះឯកសារជាច្រើនដែលលោក ឌេល លីសាក់បានបង្ហាញពាក់ព័ន្ធនឹងឈ្មោះបុគ្គលដែលត្រូវចាប់ខ្លួន ដែល អ៊ុន វ៉េន បានរាយការណ៍ឲ្យ សោម ភាគច្រើន ធ្វើក្នុងឆ្នាំ១៩៧៦ ។

### ៦) ការចាប់ខ្លួន និងការបោសសម្អាតខ្មាំងនៅក្នុងកងពល ៨០១

ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការបោសសម្អាតអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំងនៅក្នុងកងពល៨០១ អ៊ុន វ៉េន បានបញ្ជាក់ថា ក្នុងអំឡុងពេលផ្លាស់មកទីក្រុងភ្នំពេញ សារទូរលេខមួយ ត្រូវបានផ្ញើរមកមន្ទីរ៨៧០ ដោយប្រធានកងពល សូ សារឿន ។ សារទូរលេខនេះបានរាយការណ៍ថា កែវ សារឿន ដែលជាសមាជិកម្នាក់របស់គណៈវរៈសេនាធំ ខូចសីលធម៌ជាមួយនារី ។ អ៊ុន វ៉េន បានអះអាងថា ថ្វីត្បិតលោកពុំបានដឹងអំពីជោគវាសនារបស់ កែវ សារឿន នៅពេលនោះ ប៉ុន្តែលោកជឿជាក់ថា បុគ្គលនេះនឹងត្រូវបានចាប់ខ្លួន ព្រោះនៅក្នុងរបបនោះអ្នកដែលត្រូវបានចោទប្រកាន់ថាខុសសីលធម៌ គឺមិនរួចខ្លួនឡើយ ។ រំពេចនោះ លោក ឌេល លីសាក់ បានបង្ហាញបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានបញ្ជូនមកមន្ទីរស-២១ ដែលក្នុងនោះមានឈ្មោះ កែវ សារឿន ហៅ សេង ។ បន្ថែមលើនេះទៀត លោកបង្ហាញចម្លើយសារភាពរបស់អ្នកទោសម្នាក់នេះនៅចំពោះមុខអង្គជំនុំជម្រះ ។ នៅលើចម្លើយសារភាពនេះ គឺមានចំណាររបស់ ឌុច ។ ចំណារនោះ ឌុច បានបញ្ជាក់ថា កែវ សារឿន បានសារភាពថា នៅក្នុងកងពល៨០១ គឺមានជនក្បត់ ៥៨នាក់ផ្សេងទៀត ។ ក្រៅពីនេះ លោក ដេលី សាក់ បង្ហាញបញ្ជីឈ្មោះបុគ្គលមួយចំនួនទៀតដែលត្រូវបានចាប់ខ្លួនមកពីកងពល ៨០១ រួមមាន ធឿន, ធី (អ្នកទាំងពីរ នេះគឺជាសមាជិកនៃគណៈវរៈសេនាធំលេខ៨១) , ទូច សន (ទទួលខាងកស្តុភារ) ជាដើម ។ ឯកសារចុងក្រោយដែលលោក ឌេល លីសាក់ បានដាក់បង្ហាញ គឺពាក់ព័ន្ធនឹងវិធានការមួយចំនួនដែលត្រូវអនុវត្តនៅតាមអង្គភាពនីមួយៗ ។ វិធានការទាំងនោះរួមមានៈ ទី១) ជនណាដែលត្រូវបានសង្ស័យថាជាខ្មាំង គឺត្រូវចាប់ខ្លួន ។ ទី២) អ្នកដែលខ្មាំងឆ្លើយដាក់ត្រូវពិនិត្យ និងស្នើចាប់ខ្លួន ។ ទី៣) អ្នកណាដែលល្មើសនឹងវិន័យ ត្រូវដកចេញ ឬចាប់ខ្លួន ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារទាំងនេះ អ៊ុន វ៉េន បញ្ជាក់ថា នៅក្នុងអំឡុងពេលនៃការបោសសម្អាតសមាសភាពមិនល្អនៅក្នុងកងពល៨០១ គឺពិតជាមានវិធានការទាំង៣ចំណុចនេះមែន ហើយ សូ សារឿន ក៏ធ្លាប់បានប្រជុំនៅរើនសៃ ដោយបានលើកឡើងអំពីខ្មាំង សេ.អ៊ី.អា, កា.ហ្សេ.បេ និងខ្មាំងយួន ព្រមទាំងប្រាប់ឲ្យអង្គភាពនីមួយៗ ធ្វើការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ។ ដូច្នេះកងវរៈសេនាធំ និងកងវរៈសេនាតូចនីមួយៗ ត្រូវធ្វើការពិនិត្យតាមដាននៅក្នុងអង្គភាពរបស់ខ្លួន ហើយអ្នកដែលធ្វើខុស គឺត្រូវធ្វើការអប់រំ ២-៣ដង ឬត្រូវបានចាប់ខ្លួនតែម្តង ។ ទោះបីជាយ៉ាងណា អ៊ុន វ៉េន ពុំអាចបញ្ជាក់បានថាវិធានការទាំងនេះ គឺចេញពី សូ សារឿន ឬមកពីថ្នាក់មជ្ឈិមឡើយ ។

### ៧) ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពី

ទីក្រុងភ្នំពេញ និងស្ថានភាពអមនុស្សធម៌ផ្សេងៗដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនោះ គឺសាក្សីពុំបានរៀបរាប់លម្អិតនោះទេ ព្រោះក្នុងពេលនោះ អ៊ុង រ៉េន កំពុងត្រូវរបួសនិងសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅវត្តតាំងក្រសាំង ។ ដូច្នេះរាល់ព័ត៌មានទាក់ទងនឹងការជម្លៀសនេះ គឺលោកដឹងតាមរយៈ សឿន ដែលជាអនុប្រធានតែប៉ុណ្ណោះ ។ សឿន បានប្រាប់ថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញបានប្រមាណជា ២-៣ ម៉ោងប៉ុណ្ណោះ ប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ។ បញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺចេញមកពីប្រធានកងពល ហើយការជម្លៀសនេះគឺក្នុងគោលបំណងកុំឲ្យប្រជាជនលាក់ខ្លាំង ។ ប្រជាជនភាគច្រើនគឺធ្វើដំណើរចេញពីទីក្រុងដោយថ្មើរជើង ហើយមានមួយភាគតូចតែប៉ុណ្ណោះ ដែលមានម៉ូតូឡាន និងរទេះ ។

ពាក់ព័ន្ធនឹងមូលហេតុនៃការជម្លៀសនេះដែរ មេធាវីការពារជនជាប់ចោទ នួន ជា គឺលោក វ៉ិចទ័រ កុបប៉េ បានចោទសំណួរថា «តើមានការត្រៀមរៀបចំទប់ទល់នឹងការទម្លាក់គ្រាប់បែករបស់អាមេរិកដែរឬទេ បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ?» ឆ្លើយតបនឹងសំណួរនេះ អ៊ុង រ៉េន បញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាពុំបានត្រៀមអ្វីទាំងអស់ ហើយក៏ពុំមានការព្រួយបារម្ភអ្វីដែរ ព្រោះគ្មានលទ្ធភាពណាមួយដែលសហរដ្ឋអាមេរិកអាចមកទម្លាក់គ្រាប់បែកទៀតឡើយ ។

## បញ្ហាផ្សេងៗ

ក្នុងការសួរសាក្សី អ៊ុង រ៉េន អង្គជំនុំជម្រះផ្តល់ពេលវេលា ១ថ្ងៃ សម្រាប់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី និងមួយថ្ងៃទៀតសម្រាប់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។ ប៉ុន្តែ សហព្រះអាជ្ញាបានប្រើប្រាស់ពេលអស់មួយថ្ងៃពេញ ដូច្នេះក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានឱកាសសួរដេញដោលសាក្សី អ៊ុង រ៉េន ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានធ្វើការជំទាស់អ្វីឡើយ ។

បន្ទាប់ពីសវនាការស្តាប់សក្ខីកម្មរបស់ អ៊ុង រ៉េន បានចប់សព្វគ្រប់អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ លើកឡើងអំពីជំហររបស់ខ្លួនពាក់ព័ន្ធនឹងសំណើរបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យកូនក្តីរបស់ខ្លួន មានរហស្សនាម TCCP-94 មកផ្តល់សក្ខីកម្មទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន និង អៀង សារី ។ នៅក្នុងសំណើរបស់ខ្លួន មេធាវី សំ សុគង់ បានលើកឡើងថា កូនក្តីរបស់លោកអាចផ្តល់សក្ខីកម្មពាក់ព័ន្ធគោលនយោបាយទូទៅនៃជម្លៀសប្រជាជន ស្ថានភាពនៅមន្ទីរបឹងត្របែក និងគោលនយោបាយរបស់ខ្មែរក្រហមទាក់ទងអ្នកដែលត្រឡប់មកពីបរទេសវិញ បន្ថែមលើសក្ខីកម្មពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ។ សំណើនេះត្រូវបានគាំទ្រដោយតំណាងសហព្រះរាជអាជ្ញា ឌេល លីសាក់ ដោយលោកបានបញ្ជាក់ថា យោងតាមព័ត៌មានចេញផ្សាយដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ដែលបានធ្វើសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺបានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីមានព័ត៌មានដ៏សំខាន់ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី និង ខៀវ សំផន ។

ចំណែកមេធាវីការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បានស្នើសុំអង្គជំនុំជម្រះបដិសេធចោលនូវសំណើនេះ ។ មេធាវីបានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺពុំបានអាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញបានឡើយ ព្រោះគាត់ពុំបានជាប់ពាក់ព័ន្ធដោយផ្ទាល់ចំពោះការជម្លៀសនេះ ។ បន្ថែមលើនេះទៀត សក្ខីកម្មរបស់គាត់ពាក់ព័ន្ធនឹងមន្ទីរបឹងត្របែកក៏ពុំមានភាពចាំបាច់ដែរ ។ មេធាវីបានបន្ថែមថា កន្លងមកខ្លួនបានដាក់សំណើសុំទៅអង្គជំនុំជម្រះម្តងហើយម្តងទៀតឲ្យកោះហៅសាក្សីដែលមានរហស្សនាម TCW-243 និង TCW-292 មកផ្តល់សក្ខីកម្មពាក់ព័ន្ធមន្ទីរបឹងត្របែក ប៉ុន្តែអង្គជំនុំជម្រះនៅមិនទាន់សម្រេចនៅឡើយ ។ ដូច្នេះប្រសិន បើអង្គជំនុំជម្រះនៅតែមានបំណងស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរបឹងត្របែក នោះគប្បីដាក់បញ្ចូលសាក្សីទាំងពីររូបនេះដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហានេះ គឺអង្គជំនុំជម្រះពុំបានសម្រេច ក្នុងអំឡុងពេលដេញដោលនោះឡើយ ។ អង្គជំនុំជម្រះជូនដំណឹងដល់ភាគីទាំងអស់ថា ខ្លួននឹងយកបញ្ហានេះទៅសម្រេចនៅពេលក្រោយ ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ឆោម សែ

## ថ្ងៃទី១១ ខែ មករា និងថ្ងៃទី៨ ខែមេសា ឆ្នាំ ២០១៣

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី ឆោម សែ អតីតអនុមេបញ្ជាការនៃអនុសេនាធំ (អនុប្រធានកងវរយ) ក្រោយមកជាប្រធានមន្ទីរសន្តិសុខអូរកន្សែងនៃកងពល៨០១ ។ សវនាការនេះត្រូវបានធ្វើឡើងនៅក្នុងថ្ងៃតែមួយជាមួយនិងសាក្សី អ៊ុង រ៉េន អតីតអនុប្រធានកងពល៨០១ ពោលគឺបន្ទាប់ពីការស្តាប់សក្ខីកម្មរបស់ អ៊ុង រ៉េន បានចប់សព្វគ្រប់ភ្លាមៗ ។ នៅពេលល្ងាចថ្ងៃដដែលនោះ ប្រធានអង្គជំនុំជម្រះប្រកាសថា សវនាការស្តាប់សក្ខីកម្មរបស់ ឆោម សែ នឹងត្រូវធ្វើបន្តនៅថ្ងៃទី១៤ ។ ប៉ុន្តែដោយថ្ងៃទី១៤ ខែមករា នោះ ជនជាប់ចោទ នួន ជា មានបញ្ហាសុខភាពពុំអាចចូលរួមសវនាការបាន (ជនជាប់ចោទត្រូវបានបញ្ជូនទៅទទួលការសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត) និងមានបញ្ហាជាក់លាក់មួយចំនួនដែលអង្គជំនុំជម្រះត្រូវដោះស្រាយ ដូច្នេះការស្តាប់សក្ខីកម្មរបស់ ឆោម សែ ត្រូវបានពន្យារពេលរហូតមកដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ។

ឆោម សែ កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥០ នៅភូមិដីក្រហម ឃុំព្រៃរំដេង ស្រុកគិរីវង្ស ខេត្តតាកែវ ។ បច្ចុប្បន្នរស់នៅនិងប្រកបរបរធ្វើស្រែចម្ការនៅភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ឪពុកឈ្មោះ សោម សំ ម្តាយឈ្មោះ គឹម មន ប្រពន្ធឈ្មោះ អន សុភាព និងមានកូន ៤នាក់ ។ ឆោម សែ ចូលរួមចលនាបដិវត្តក្នុងឆ្នាំ១៩៧០ គឺបន្ទាប់ពីមានការអំពាវនាវរបស់ព្រះបាទសម្តេច នរោត្តម សីហនុ និង ចំពេលដែលស្រុកភូមិរបស់លោកកំពុងទទួលការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងពីសហរដ្ឋអាមេរិក ។ នៅមុនឆ្នាំ១៩៧៥ ឆោម សែ បម្រើការជាយោធាខ្មែរក្រហមនៅក្នុងកងពលលេខ១១ បន្ទាប់មកកងពលលេខ១៤ ពោលគឺសុទ្ធសឹងតែជាកងពលដែលមានតួនាទីសំខាន់ក្នុងការវាយដណ្តើមយកទីក្រុងភ្នំពេញ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកត្រូវបានបញ្ជូនទៅភូមិភាគឦសាន្តនៃប្រទេសកម្ពុជា ដើម្បីបម្រើការងារក្នុងកងពលលេខ៨០១ ក្រោយមកក្លាយជាប្រធានមន្ទីរសន្តិសុខអូរកន្សែងប្រចាំនៅក្នុងកងពលមួយនេះ ។

មុននឹងផ្តល់វេទិកាជូនភាគីទាំងអស់ឲ្យសួរដេញដោលសាក្សី ប្រធានអង្គជំនុំជម្រះប្រាប់អំពីសិទ្ធិរបស់សាក្សីក្នុងការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ពោលគឺសាក្សីមានសិទ្ធិមិនឆ្លើយតបនឹងសំណួរទាំងឡាយណាដែលអាចដាក់បន្ទុកលើខ្លួនឯងនាំឲ្យមានពិរុទ្ធភាព ។ ទន្ទឹមគ្នានេះដែរ អង្គជំនុំជម្រះបានផ្តល់មេធាវីជូនសាក្សីមួយរូបគឺលោក លឹម ប៊ុនហេង ដើម្បីប្រឹក្សាយោបល់


សាក្សី ឆោម សែ

មុននឹងផ្តល់សក្ខីកម្មលើអង្គហេតុទាំងឡាយណាដែលអាចដាក់បន្ទុកលើខ្លួនឯង ។ ក្នុងអំឡុងពេលនោះដែរ ប្រធានអង្គជំនុំជម្រះបានសួរសាក្សីនូវសំណួរមួយចំនួន ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុកិច្ចសម្ភាសន៍ ដែលសាក្សីបានផ្តល់ជូនអ្នកស៊ើបអង្កេតនៅដំណាក់កាលស៊ើបសួរ ។ ឆ្លើយតបនឹងសំណួរទាំងនោះ ឆោម សែ បានបញ្ជាក់ថា ខ្លួនធ្លាប់បានផ្តល់បទសម្ភាសន៍ជូនអ្នកស៊ើបអង្កេតចំនួន ៤ដង គឺពីរដងធ្វើនៅក្នុងឆ្នាំ២០០៩ និងពីរដងទៀតនៅក្នុងឆ្នាំ២០១០ ហើយជាការកត់សម្គាល់កំណត់ហេតុនៃកិច្ចសម្ភាសន៍ទាំងនោះ គឺមានភាពត្រឹមត្រូវតាមអ្វីដែលខ្លួនបានផ្តល់សក្ខីកម្ម ។ ក្នុងការផ្តល់សក្ខីកម្ម ឆោម សែ បានផ្តោតសំខាន់អំពីតួនាទី និងរចនាសម្ព័ន្ធយោធារបស់ភូមិភាគនិរតី ដែលដឹកនាំដោយ

ឈិត ជឿន ហៅ ម៉ុក មុនវាយបែកទីក្រុងភ្នំពេញ ។ បន្ថែមលើនេះទៀត សាក្សីបានរៀបរាប់គ្រួសៗអំពីការរៀបចំ និងតួនាទីរបស់កងពល៨០១ ព្រមទាំងតួនាទីរបស់ខ្លួនក្នុងឋានៈជាប្រធានមន្ទីរសន្តិសុខអូរកន្សែង ដែលត្រូវបានបង្កើតនៅក្នុងកងពលនេះ ។

### ១) រចនាសម្ព័ន្ធ និងតួនាទីយោធានៃយុទ្ធភូមិភាគពិសេស

មុនពេលផ្តល់សក្ខីកម្មពាក់ព័ន្ធរចនាសម្ព័ន្ធ និងតួនាទីរបស់កងពលនៃយុទ្ធភូមិភាគពិសេស សាក្សីបានរៀបរាប់ខ្លះៗអំពីទំនាក់ទំនងរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ។ ឆោម សែ បានបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ១៩៧០ (គឺជាពេលវេលាដែលសាក្សីបានចាប់ផ្តើមចូលព្រៃ ដើម្បីចូលរួមក្នុងចលនាបដិវត្តលើកដំបូងនៅក្នុងឃុំព្រះបាទជាន់ជុំ) កម្លាំងរបស់ខ្មែរក្រហមបានធ្វើការសហការជាមួយកងទ័ពរបស់វៀតណាមខាងជើងដែលមានស្រាប់នៅក្នុងព្រៃនៃប្រទេសកម្ពុជា ដើម្បីវាយរំដោះប្រទេសចេញពីការគ្រប់គ្រងរបស់របប លន់ នល់ ។ ក្នុងអំឡុងពេលនោះ កម្លាំងរបស់ខ្មែរក្រហមនៅពុំទាន់មានការរៀបចំច្បាស់លាស់នូវឡើយ ។ ប៉ុន្តែបន្ទាប់ពីសហការជាមួយវៀតណាមបានរយៈពេលប្រហែល១ឆ្នាំ ទើបខ្មែរក្រហមបង្កើតបានជាកងទ័ពតស៊ូមួយមានឈ្មោះថា កងលេខ៦ ហៅ ១៦០ ។ កងទ័ពនេះប្រចាំការនៅក្នុងតំបន់កំពង់ស្ពឺ និងតាកែវ នៃភូមិភាគនិរតី ហើយធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយកងទ័ពវៀតណាមដើម្បីធ្វើការតស៊ូរំដោះទឹកដី ។ ចុងក្រោយ ឆោម សែ បញ្ជាក់ថា សម្រាប់ភូមិភាគនិរតីទាំងមូលគឺមាន កង១១០, ១២០, ១៤០, ១៥០, ១៦០, ១៧០ និងកង១៩០ ។

ចំពោះរចនាសម្ព័ន្ធ និងតួនាទីរបស់កងទ័ពនៃយុទ្ធភូមិភាគពិសេស ឆោម សែ បានបញ្ជាក់ថា កងទ័ពរបស់យុទ្ធភូមិភាគនេះគឺត្រូវបានបង្កើតឡើងដោយមានការរួមបញ្ចូលពីកងកម្លាំងមកពីភូមិភាគផ្សេងៗទៀត ។ ទិសដៅសំខាន់របស់កងទ័ពនៃភូមិភាគនេះ គឺវាយចូលទីក្រុងភ្នំពេញពីទិស ខាងកើត ខាងត្បូង និងភាគខាងជើងឈៀងខាងលិច ដោយស្ថិតនៅក្រោមការដឹកនាំរួមរបស់ វ៉ន វ៉េត ។ ភូមិភាគនេះមាន ៣កងពល គឺកងពលលេខ១១ ទទួលបន្ទុកវាយចូលទីក្រុងពីទិសខាងត្បូង, កងពលលេខ១២ វាយចូលពីទិសខាងកើត និងកងពល១៤ វាយចូលទីក្រុងពីទិសខាងជើងឈៀងខាងលិច ។ នៅចុងឆ្នាំ១៩៧៤ កម្លាំងយោធានៅក្នុងកងពល១១ ចំនួនពាក់កណ្តាល គឺត្រូវបានដកមកបញ្ចូលជាមួយ កងពល១៤ ដើម្បីវាយសម្រុកចូលទីក្រុងពីទិសខាងជើងខាងលិច ក្រោមការដឹកនាំរបស់ សូ សារឿន ។ ចំណែកកម្លាំងដែលនៅសល់ពាក់កណ្តាលក្នុងកងពល១១ គឺមានតួនាទីវាយចូលទីក្រុងពីទិសខាងត្បូងដដែល ។ បន្ទាប់ពីវាយបែកទីក្រុងភ្នំពេញ កងពល១៤ បានប្តូរឈ្មោះមកជាកងពល៨០១, កងពល១១ ប្រែទៅជាកងពល៦០៥ ចំណែកកងពល១២ ប្រែទៅជាកងពល៧០៣ ។ ក្នុងអំឡុងពេលនោះដែរ កងពលទាំងនេះ គឺត្រូវបានបញ្ចូលជាមួយកងទ័ពរបស់ភូមិភាគផ្សេងៗទៀត (សរុបទាំងអស់មាន១២កងពល) បង្កើតបានជាកងទ័ពរបស់មជ្ឈិម ដែលមានសិទ្ធិចលតនៅទូទាំងប្រទេស ។

ពាក់ព័ន្ធនឹង សូ សារឿន ហៅ ០៥ ឆោម សែ បានបញ្ជាក់ថា ដើមឡើយបុគ្គលនេះជាប្រធានកងពល១១ ប៉ុន្តែបន្ទាប់ពីមានការបញ្ចូលកម្លាំងគ្នានៅចុងឆ្នាំ១៩៧៤ សូ សារឿន បានក្លាយជាប្រធានកងពល១៤ ហើយក្រោយមកក្លាយជាប្រធានកងពល៨០១ ។

### ២) ការវាយចូល និងការកាន់កាប់ទីក្រុងភ្នំពេញ

ពាក់ព័ន្ធនឹងការវាយចូលទីក្រុងភ្នំពេញ ឆោម សែ បានបញ្ជាក់ថា កងកម្លាំងរបស់លោកបានធ្វើការសហការជាមួយកងកម្លាំងរបស់ វ៉ាន់ (ស្រី) វាយចូលទីក្រុងភ្នំពេញតាមទំនប់កប់ស្រូវរួចចូលមកតាមផ្លូវពោធិ៍ចិនតុង ហើយបានចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងអំឡុងពេលនោះដែរ ទាហានរបស់របប លន់ នល់ ជាច្រើនគឺត្រូវបានចាប់ខ្លួនហើយបញ្ជូនមកក្រោយ ប៉ុន្តែលោកពុំអាចបញ្ជាក់បានថា ជោគវាសនារបស់ឈ្លើយសឹកទាំងនោះ បានក្លាយជាយ៉ាងណាឡើយ ។ បន្ទាប់ពីដណ្តើមបានទីក្រុងភ្នំពេញ ប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងដោយគ្មានការលើកលែងឡើយ ពោលគឺទាំងមនុស្សចាស់ជរា អ្នកមានជំងឺ... គឺត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះដោយគ្មានលក្ខខណ្ឌ ។ ប្រជាជនទាំងនោះអាចយកសំភារៈឬទ្រព្យសម្បត្តិបានតែមួយសំពាយតូចៗតែប៉ុណ្ណោះ ហើយធ្វើដំណើរដោយខ្លួនឯង ដោយបក្សពុំមានមធ្យោបាយដឹកជញ្ជូនឡើយ ។ ឆោម សែ បានអះអាងថា ការជម្លៀសប្រជាជនចេញ

ពីទីក្រុងភ្នំពេញ គឺមានការគ្រោងទុកជាមុន ពោលគឺពុំមែនជារឿងចៃដន្យឡើយ ព្រោះតាមបទពិសោធកន្លងមក រាល់ការវាយបានទីកន្លែងណាមួយគឺត្រូវបោសសម្អាតឲ្យអស់ ព្រោះខ្លាចមានខ្មាំងលាក់ខ្លួន ឬខ្មាំងលាក់អាវុធ ដែលអាចធ្វើឲ្យប៉ះពាល់ដល់កម្លាំងរបស់បដិវត្ត ។ គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងចំណុចនេះដែរ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា បានសួរម្ដងហើយម្ដងទៀតថា តើពិតជាមានការព្រួយបារម្ភណ៍អំពីសន្តិសុខសម្រាប់យោធារបស់ខ្មែរក្រហមពិតឬទេ? ប៉ុន្តែសាក្សីពុំបានបួរចម្លើយរបស់ខ្លួនឡើយ ពោលការជម្លៀសនេះ គឺដើម្បីកុំឲ្យមានការលាក់ខ្មាំង ឬអាវុធ ដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់កម្លាំងរបស់បក្ស ។

### ៣) ការបង្កើត និងតួនាទីរបស់កងពល៨០១

ពាក់ព័ន្ធនឹងការបង្កើតកងពល៨០១ ឆោម សែ បានបញ្ជាក់ថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញបានតែប៉ុន្មានខែ កងពល៨០១ ត្រូវបានបង្កើតឡើង ហើយកងពល១៤ ត្រូវបានរំសាយចោល ។ កិច្ចប្រជុំបង្កើតកងពលនេះ ត្រូវបានធ្វើឡើងនៅស្ដាតអូឡាំពិច ក្រោមអធិបតីភាពរបស់ ប៉ុល ពត, នួន ជា, សុន សេន ព្រមទាំងមានការចូលរួមពីសំណាក់យោធាខ្មែរក្រហមផ្សេងៗទៀត ដែលមានឋានៈចាប់ពីអនុសេនាធំឡើងទៅប្រមាណជាង១០០០នាក់ ។ ឆោម សែ បញ្ជាក់បន្ថែមថា ក្នុងអំឡុងពេលនោះ ប៉ុល ពត, សុន សេន, តាន់ ចក្រី, ខៀវ សំផន និង នួន ជា បានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងសន្និបាតនោះ ។ ទោះបីជាយ៉ាងណាក្ដី គាត់ពុំចាំថា អ្នកទាំងនោះបានថ្លែងអំពីបញ្ហាអ្វីឡើយ គឺគ្រាន់តែចាំថា បញ្ហាខ្មាំងនៅក្នុងជួរ និងក្រៅជួរ និងការរំឭកអំពីប្រវត្តិកងទ័ពបដិវត្តកម្ពុជា ត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំនោះ ។ ក្រៅពីនេះ ក៏មានការប្រកាសសមាសភាពបុគ្គលចំនួន២១រូប ដែលជាថ្នាក់ដឹកនាំ និងបំពេញការងារនៅថ្នាក់មជ្ឈិម ។ បុគ្គលទាំងនោះរួមមាន៖ ប៉ុល ពត, នួន ជា, ឈិត ជឿន ហៅ តាម៉ុក, សុន សេន, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, ក្រៅពីនេះ គឺមកពីភូមិភាគ ដូចជា កុយ ធួន, យ៉ា, រស់ ញឹម, កង ចាប, វ៉ន វេត, ជ័យ សួន, ចេង អន ។ល ។ គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងសមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ មេធាវី អាកទួរ វែកកែន សួរបញ្ជាក់ថា តើកូនក្ដីរបស់ខ្លួន ខៀវ សំផន ពិតជាមានវត្តមាននៅក្នុងកិច្ចប្រជុំនោះដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ ឆោម សែ បានបញ្ជាក់យ៉ាងច្បាស់ថា លោកពិតជាបានឃើញវត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំនោះប្រាកដមែន ។

តួនាទីសំខាន់របស់កងពល៨០១ គឺការពារព្រំដែននៅជាប់វៀតណាម និងឡាវ ក្រោមការដឹកនាំរួមរបស់ សូ សារឿន (ជាប្រធានកងពល) និងប៉ោ សំអុល ។ កងពលនេះត្រូវបានបែងចែកជា៣វរៈសេនាធំ ៣វរៈសេនាតូច និង៤កងដឹកជញ្ជូន ។ វរៈសេនាធំ៨១ មានភារកិច្ចការពារនៅអូរយ៉ាដាវ រហូតដល់ក្បាលអូរសេដ្ឋី ។ កងវរៈសេនាធំ៨៣ ការពារពីអូសេដ្ឋីដល់កន្ទុយនាគ ហើយចុះពីកន្ទុយនាគមកដល់ឡាវ ការពារដោយកងវរៈសេនាធំ៨២ ។ ចំណែកបីកងវរៈសេនាតូច និង ៤កងដឹកជញ្ជូន នៅការពារជុំវិញទីបញ្ជាការកងពលនៅវើនសៃ ។ គួរបញ្ជាក់ថា កងពល៨០១ ត្រូវបានបញ្ជូនទៅដល់ស្ទឹងត្រែង និងរតនគិរីនៅចុងឆ្នាំ១៩៧៥ ដែលក្នុងអំឡុងពេលនោះ វៀតណាមត្រូវបានចាត់ទុកថា "ពាក់កណ្ដាលមិត្ត ពាក់កណ្ដាលសត្រូវ" ។

### ៤) ការបង្កើតមន្ទីរសន្តិសុខអូរកន្សែង និងវិធានការបោសសម្អាតខ្មាំងក្នុងកងពល៨០១

ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង ឆោម សែ បញ្ជាក់ថា មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងសម្រាប់អប់រំ កែប្រែ និងដាក់អ្នកទោសដែលចាប់មកពីកងពលលេខ៨០១ ។ ពោលគឺបង្កើតឡើងនៅចំពេលដែលមានការសង្ស័យថា ចលនាខ្មាំងបានកើតឡើងនៅក្នុងកងពល៨០១ និងនៅទូទាំងប្រទេស ។ នៅចុងឆ្នាំ១៩៧៦ ឆោម សែ ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរសន្តិសុខនេះ ដោយទទួលបន្ទុកអប់រំកែប្រែអ្នកទោស និងរាយការណ៍ទៅថ្នាក់លើអំពីស្ថានភាពអ្នកទោសដែលចាប់បាន ។ សម្រាប់កិច្ចការរដ្ឋបាល ឆោម សែ រាយការណ៍ទៅអគ្គភាព៨០៦ (ជាអគ្គភាពគ្រប់គ្រងភស្ដុភាររបស់កងពល៨០១ ប៉ុន្តែសម្រាប់កិច្ចការនយោបាយ យោធា ចម្លើយសារភាព ត្រូវរាយការណ៍ដោយផ្ទាល់ទៅប្រធានកងពល សូ សារឿន ។ ការរាយការណ៍នេះក្នុងគោលបំណងឲ្យថ្នាក់លើដោះស្រាយ ឬចាត់វិធានការផ្សេងៗ ដូចជា ចាប់ខ្លួនឬដោះលែងអ្នកទោសជាដើម ។ លោកបានបំពេញតួនាទីនេះជិតពីរឆ្នាំដែលក្នុងអំឡុងពេលនោះ មានអ្នកទោស

ជាច្រើនត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខមួយនេះ ។ អ្នកទោសទាំងនោះ ភាគច្រើនជាប្រជាជនស៊ីវិល និងយោធា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល៨០១ ។ ក្រៅពីនេះមានអ្នកទោសជនជាតិបរទេសចំនួន៦នាក់ទៀត ត្រូវបានបញ្ជូនមក និងសម្លាប់ចោលនៅមន្ទីរសន្តិសុខអូរកន្ទែង ។ ឆោម សែ បានអះអាងថា សម្រាប់អ្នកទោសដែលជាប្រជាជនស៊ីវិល ពុំត្រូវបានសម្លាប់ឡើយ ពោលគឺបន្ទាប់ពីសួរយកចម្លើយហើយ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ។ ចំណែកអ្នកទោសដែលជាយោធាមួយចំនួនធំ ក៏ត្រូវបានដោះលែងឲ្យទៅបម្រើកងទ័ពវិញដែរ ព្រោះក្នុងអំឡុងពេលនោះយោធាជាច្រើននៅក្នុងកងពល៨០១ ត្រូវចាប់ខ្លួនរហូតដល់ខ្វះកម្លាំងប្រយុទ្ធ ។ ដូច្នេះ ទើបបង្ខំចិត្តឲ្យមានការដោះលែងអ្នកទោសមួយចំនួនដែលមានកំហុសតូចតាច ។

ពាក់ព័ន្ធនឹងអ្នកទោសនៅមន្ទីរសន្តិសុខនេះដែរ មេធាវីការពារក្តីជនជាប់ចោទ នួន ជា លោក សុន អរុណ បានចោទសំណួរមួយចំនួនដោយសង្កត់ធ្ងន់អំពីការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោសនៅក្នុងអំឡុង និងក្រោយពេលសួរចម្លើយ ។ ឆ្លើយតបនឹងសំណួរទាំងនោះ សាក្សីបានបញ្ជាក់ថា អ្នកទោសនឹងត្រូវទទួលរងទារុណកម្ម ប្រសិនបើអ្នកទោសនោះមិនព្រមឆ្លើយសារភាព ហើយមានភស្តុតាង ឬចម្លើយរបស់បុគ្គលណាម្នាក់ដែលបញ្ជាក់ថាអ្នកទោសនោះពិតជាបានប្រព្រឹត្តកំហុសមែន ។ ចំពោះវិធីសាស្ត្រក្នុងការសួរចម្លើយអ្នកទោស គឺការសួរចុះសួរឡើងរហូតដល់អាចចាប់បានចម្លើយណាមួយដែលលេចចេញនូវអង្គហេតុពិត ។ ដូច្នេះប្រសិនបើអ្នកទោសមានបំណងលាក់កំបាំងនោះនឹងត្រូវទទួលរងទារុណកម្ម ។ ចំពោះសំណួររបស់លោក សុន អរុណ ដែលចោទសួរថា តើសាក្សីធ្លាប់បានសម្លាប់អ្នកទោសដែរឬទេ? ប៉ុន្តែ សំណួរនេះត្រូវបានមេធាវីរបស់សាក្សីធ្វើការជំទាស់ភ្លាមៗ ដោយផ្តល់ហេតុផលថា នេះគឺជាប្រភេទសំណួរដែលធ្វើឲ្យសាក្សីឆ្លើយដាក់បន្ទុកលើខ្លួនឯង ។ ស្របពេលជាមួយគ្នានេះដែរ ឆោម សែ បានស្នើសុំរក្សាសិទ្ធិមិនឆ្លើយតបសំណួរ ហើយសំណើនេះពុំត្រូវបានអង្គជំនុំជម្រះបដិសេធឡើយ ។

ចំពោះវិធានការបោសសម្អាតខ្មាំងនៅក្នុងកងពល ៨០១ ឆោម សែ បានបញ្ជាក់ថា សូ សារឿន បានដាក់វិធានការមួយដែលមាន៥ចំណុច ឲ្យប្រធានអង្គភាពនីមួយៗអនុវត្តនៅក្នុងអង្គភាពរបស់ខ្លួន ។ វិធានការទាំងនោះរួមមាន៖

- អ្នកដែលសង្ស័យថាជាខ្មាំងត្រូវចាប់ខ្លួន ។
- អ្នកដែលត្រូវឆ្លើយដាក់ដោយខ្មាំង បន្ទាប់ពីពិនិត្យឯកសារគឺត្រូវស្នើចាប់ខ្លួនជាបណ្តោះអាសន្ន ។
- អ្នកសេរី ដើរហើរ ឬល្មើសវិន័យអប់រំ ហើយមិនស្តាប់ ត្រូវមានវិធានការណ៍ដកទុកមួយជុំ ហើយតាមដាន ។
- កម្មាភិបាល អនុសេនាធំ អនុសេនាតូច ដែលខ្ជិល ពុតត្បុតមិនសកម្ម ត្រូវដកចេញដាច់ខាត ។
- អ្នកមាននិន្នាការពាក់ព័ន្ធផ្នែកនយោបាយ ត្រូវដកជាបណ្តើរៗ ហើយអ្នកដែលអប់រំមិនស្តាប់២-៣ដង ត្រូវដកចេញ ឬចាប់ខ្លួន ។

ឆោម សែ បានបញ្ជាក់បន្ថែមថា បន្ទាប់ពីទទួលបានវិធានការទាំងនេះ ប្រធានអង្គភាពនីមួយៗបានពិនិត្យតាមដាននៅក្នុងអង្គភាពរបស់ខ្លួន ហើយអ្នកទោសជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខអូរកន្សែង ។ លើកលែងអ្នកទោសដែលមានឋានន្តរស័ក្តិខ្ពស់ ត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ ។ ជាក់ស្តែង កែវ សារឿន មានឋានៈជាប្រធានវរៈសេនាធំលេខ៨១ ហើយក៏ជាសមាជិករបស់គណៈកងពល៨០១ ត្រូវបាននាំខ្លួនទៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៧ ដើម្បីរៀនសូត្រ ហើយបានបាត់ខ្លួនរហូត ។ ភ្លាមនោះ តំណាងព្រះរាជអាជ្ញា បង្ហាញបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់មន្ទីរស-២១ ។ បញ្ជីនេះមានឈ្មោះ កែវ សារឿន, ប៉ៅ សំអុន និង ទូច សន ដែល ឆោម សែ បានស្គាល់ ។ បន្ថែមលើនេះទៀត តំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារចម្លើយសារភាពរបស់ កែវ សារឿន ដែលទទួលបានមកពីមន្ទីរស-២១ ។ ឯកសារនេះមានចំណាររបស់ ឌុច ដែលបានចារថា *«នៅពេលសួរអំពីសភាពការណ៍កង អា កែវ សារឿន វាបានរាយការណ៍មនុស្សនៅក្នុងខ្សែ ដែលវាបង្កប់នៅក្នុង៨០១ មានរហូតដល់ទៅ៥៨នាក់ ដែលក្នុងនោះមានឈ្មោះ ឆោម, ឡែម, ណាត, ណន, កែវ ណាវ៉ុង ហៅ ប៉ាវ»* ។ ឆោម សែ បញ្ជាក់បន្ថែមថាឈ្មោះ ឆោម មានឋានៈជាវរៈសេនាតូច ត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញពោល គឺពុំបានបញ្ជូនទៅមន្ទីរសន្តិសុខអូរកន្សែងទេ ។

# សវនាការស្តីពីការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ដោយសហព្រះរាជអាជ្ញា

## ថ្ងៃទី២១-២៤, ៣០-៣១ ខែមករា ដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣

ចាប់ពីថ្ងៃទី២១-២៤,៣០-៣១ ខែមករា ដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបន្តសវនាការលើការដាក់ឯកសារ ដែលភាគីដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងដើម្បីឲ្យភាគីធ្វើការជំទាស់ទៅនឹងឯកសារទាំងនោះ បន្ទាប់ពីអង្គជំនុំជម្រះបានពន្យារពេលសវនាការអស់រយៈពេលមួយសប្តាហ៍កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ ។ សវនាការត្រូវបានពន្យារពេល ដោយសារបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា ហើយជនជាប់ចោទរូបនេះពុំបានលះបង់សិទ្ធិក្នុងការចូលរួមសវនាការក្នុងអំឡុងពេលសួរដេញដោលសាក្សី ។ ដើម្បីធានាដល់និតិវិធីក្នុងការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះបានសម្រេចបើកសវនាការដោយមិនពន្យារពេល ដើម្បីពិភាក្សាលើឯកសារទាំងឡាយនៅក្នុងសំណុំរឿង០០២ ដែលនៅសេសសល់កាលពីសវនាការលើកមុន ។

អង្គជំនុំជម្រះបានបន្តថា ឯកសារដែលលើកយកមកពិភាក្សានៅពេលនេះ គឺជាឯកសារដែលមាននៅក្នុងជើងទំព័រនៃដីការដំណោះស្រាយក្នុងកថាខណ្ឌ២០៥-២០៩, ៦៩៨-៧១១, ៩៧៥- ៩៧៧, ១១០៥-១១១៣, ១១៩១-១១៩៣, ១៣៧៣, ១៣៧៥, ១៣៧៧, ១៣៧៩-១៣៨១, ១៣៨៧-១៣៨៩, ១៤១៥-១៤១៨ និង ១៤២៣-១៤២៥ ។ ក្រៅពីនោះ អង្គជំនុំជម្រះនឹងស្តាប់ការជំទាស់តវ៉ារបស់ភាគីលើឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញា គឺមានឯកសារពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំនៅដំណាក់កាលទី១ និងដំណាក់កាលទី២, ការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ, រចនាសម្ព័ន្ធយោធា និងតួនាទីរបស់ជនជាប់ចោទ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ វ៉ាយជ័ ដេស្នាឯល បានបញ្ជាក់ថា នៅក្នុងចំណោមឯកសារទាំងនោះ មានឯកសារចំនួន៨ដែលស្នើសុំដោយមេធាវីការពារក្តី អៀង សារី, ឯកសារចំនួន២១ត្រូវបានស្នើសុំដោយមេធាវីការពារក្តី ខៀវ សំផន និងឯកសារចំនួន១១ត្រូវបានស្នើឡើងដោយមេធាវី នួន ជា ។

ភ្លាមនោះ មេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានលើកឡើងថា ក្រុមរបស់ខ្លួនពុំមានលទ្ធភាពធ្វើការឆ្លើយតបភ្លាមៗចំពោះឯកសារដែលនឹងដាក់បង្ហាញដោយសហព្រះរាជអាជ្ញាបានទេ ដោយសារសវនាការនេះរៀបចំឡើងលឿនពេក ។ ម្យ៉ាងទៀតខ្លួនស្នើសុំឲ្យមានការពិភាក្សាទៅលើតម្លៃនៃភស្តុតាង បន្ទាប់ពីមានការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ។ ដោយសារតែមានការលើកឡើងដោយភាគីទាក់ទងនឹងវិសាលភាពនៃសវនាការ លោកស្រីចៅក្រម ស៊ីលវៀ ខាត្រ៉ាយត៍ បានបញ្ជាក់ជាថ្មីអំពីវិសាលភាពនៃសវនាការនៅថ្ងៃទី២១ ខែមករា ដោយផ្តោតសំខាន់តែទៅលើការបង្ហាញឯកសារទាំង៤៨របស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។

### ១) ការបង្ហាញឯកសារចំនួន៤៨របស់សហព្រះរាជអាជ្ញា

ជាការចាប់ផ្តើម តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ វ៉ាយជ័ ដេស្នាឯល បានបង្ហាញឯកសារទាំង៤៨ជាមុន ដើម្បីផ្តល់ឱកាសឲ្យក្រុមមេធាវីការពារក្តីជំទាស់នៅពេលក្រោយ ។ ឯកសារទាំងនោះរួមមាន៖

**ឯកសារទាក់ទងនឹងការជម្លៀស និងទួលពោធិ៍ជ្រៃ**

១) ចម្លើយសារភាពរបស់ មូល សម្បត្តិ ហៅ រស់ ញឹម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨

២) ឯកសាររបាយការណ៍ភូមិសាស្ត្រទាក់ទងនឹងទួលពោធិ៍ជ្រៃរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងជើងទំព័រលេខ៣២៥ ។

**ឯកសារទាំង៦របស់សហព្រះរាជអាជ្ញា**

៣) ការដកស្រង់សៀវភៅសរសេរដៃទាក់ទងនឹងប្រវត្តិរូប

របស់ សួង ស៊ីគឿន

៤) សៀវភៅរបស់ ថេត សម្បត្តិ ដែលមានចំណងជើងថា «នៅពីក្រោយវាលពិឃាត»

៥) ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ ឡុង នរិន្ទ ហៅ រិទ្ធ

៦) វីដេអូសម្ភាសន៍ ខៀវ សំផន និងប្រតិចារឹកនៃឃ្លីបវីដេអូ

៧) វីដេអូឃ្លីបនៅក្នុងសន្និសិតកាសែតរបស់ នួន ជា និង ខៀវ សំផន នៅឆ្នាំ១៩៩៨

៨) វីដេអូរបស់ ថេត សម្បត្តិ សម្ភាសន៍ជាមួយ នួន ជា និងប្រតិចារឹក

**ឯកសារបីដែលលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

៩) សៀវភៅរបស់លោក ភ៉ាអ៊ូល ម៉ាកចេនណា «ខៀវ សំផន និងខ្មែរក្រហម»

១០) ខ្សែភាពយន្តឯកសាររបស់ រ៉ូសាន «ការត្រេដរស់នៅក្នុងរបបខ្មែរក្រហម»

**ឯកសារលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា**

១១) ខ្សែភាពយន្តវីដេអូរដែលថតដោយ ថេត សម្បត្តិ «សត្រូវប្រជាជន»

**ឯកសារ៤ដែលលើកឡើងដោយមេធាវីរបស់ អៀង សារី**

១២) សៀវភៅរបស់លោក ដេវីដ ឆេនដល័រ“Transformation in Cambodia”

១៣) សៀវភៅរបស់ ម៉ៃខល វីកឃើរី “Democratic Kampuchea”

១៤) សៀវភៅរបស់ មីលតុន អូស្បូន “Sihanouk: Prince of Light, Prince of Darkness”

១៥) អត្ថបទការសែតរបស់ ដូក្លាស ហ្គីលសុន និង ហ៊ា មានចំណងជើងថា “177 Released from S-21, DC-Cam Records Show”

**ឯកសារដែលស្នើដោយមេធាវីការពារក្តី ខៀវ សំផន**

១៦) អត្ថបទដែលមានចំណងជើងថា “Bombs over Cambodia”

១៧) សៀវភៅរបស់ ប៊ែន ឃៀនិន (Ben Kiernan) ដែលមានចំណងជើងថា “US Bombardment of Cambodia: 1969 to 1973, Vietnam Generation”

១៨) សៀវភៅរបស់ គីមម៉ូ គីលជុន (Kimmo Kiljunen) មានចំណងជើងថា “Kampuchea: Decade of Genocide-Report of a Finnish Inquiry Commission”

**ឯកសាររបស់ក្រសួងការបរទេសអាមេរិក**

១៩) ឯកសារប្រតិចរិកនៃការសន្ទនារបស់ប្រធានាធិបតី និច សុន និង ឃីសស៊ីងហ្គ័រ

២០) ឯកសារមានចំណងជើងថា “I beg your pardon”

២១) ឯកសារមានចំណងជើងថា “Memorandum of a Conversation between Indonesian Suharto and Ford and Kissinger”

២២) អនុស្សរណៈនៃកិច្ចសន្ទនាររបស់ ឃីសស៊ីងហ្គ័រ និងរដ្ឋមន្ត្រីការបរទេសថៃឆាត ឆៃ

២៣) ឯកសាររបស់អ្នកការទូតបារាំង «កិច្ចសន្ទនារបស់លោក ពេជ លីមគួន» ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦

២៤) សេចក្តីសម្រេចរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិស្តីអំពីស្ថានភាពនៃ ប្រទេសកម្ពុជា

**អត្ថបទសារព័ត៌មានអន្តរជាតិ**

២៥) New York Review of book

២៦) Arrival of Laotian Delegation, visiting Cambodia

២៧) Defecting Khmer Rouge Helicopter Pilot Tells of Life in Phnom Penh

២៨) Escape Because of Khmer Brutality

២៩) Cambodia: Two Views from Inside

៣០) Cambodia: The Verdict is Guilty on Nixon and Kissinger

**សំបុត្រចំនួន៤ដែលនិយាយអំពី ខៀវ សំផន**

៣១) សំបុត្ររបស់ ហ្វីលីព ហ្សូលីយ៉ង់

៣២) សំបុត្ររបស់ សំ សុខ

៣៣) សំបុត្ររបស់ រ៉ូឡង់ ឌុយម៉ាស

៣៤) សំបុត្ររបស់ ក្លូត កាតហ្ស៍

**ឯកសារដែលលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន**

៣៥) បទសម្ភាសន៍ជាមួយ ឡូរ៉េង់ ប៉ិច

៣៦) អត្ថបទកាសែតមានចំណងជើងថា “Noam Chomsky”

៣៧) អត្ថបទរបស់ ប៉ែន យៀនិន “Root of the US Trouble in Afghanistan: Civilian bombing Casualties and the Cambodian Precedent”

**ឯកសារចំនួន១១ ស្នើរដោយក្រុមមេធាវីការពារក្ដី នួន ជា**

៣៨) ឯកសាររបស់ ស៊ីវ ហេដឌ័រ មានចំណងជើងថា “Racism, Marxism, Labelling and Genocide”

៣៩) សៀវភៅរបស់ ចូអែល ប្រ៊ីន្កលី “Cambodia’s Curse: The Modern skull and modern history”

៤០) របាយការណ៍ “Report to the subcommittee on refugees and escapees committee on the judiciary United State Senate”

៤១) ឯកសាររ “Saigon prodded by US, Lend Rice to Cambodia”

៤២) ឯកសារ “The Cambodian Anniversary Marked only by Misery”

៤៣) អត្ថបទ “Phnom Penh New Ruler”

៤៤) អត្ថបទរបស់ ស៊ីដនី សាន់ប៊ឺដ “Children starving in Once Lust land”

៤៥) អត្ថបទរបស់ អាល្ហម៉ាន មានចំណងជើងថា“Sihanouk’s sideshow”

៤៦) “US Air Operation in Cambodia: April 1973”

៤៧) របាយការណ៍របស់គណៈរដ្ឋមន្ត្រីនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា អំពីការបង្កើតគម្រោងក-៥ សម្រាប់ពន្ធអាករឆ្នាំ១៩៨៧

៤៨) របាយការណ៍ស្ដីអំពី«ទស្សនកិច្ចរបស់សម្ដេច ហ៊ុន សែន នៅប្រទេសថៃ» ។

បន្ទាប់ពីបញ្ចប់ការអាននូវឯកសារទាំង៤៨រួចមក លោកប្រធានអង្គជំនុំជម្រះថ្នាក់ក្រុម និល ណុន បានផ្ដល់វេទិការបន្តជូនតំណាងសហព្រះរាជអាជ្ញាដើម្បីជំទាស់នឹងឯកសារដែលខ្លួនបានបង្ហាញ និងមូលហេតុនៃការជំទាស់មុនពេលផ្ដល់វេទិកាជូនភាគីផ្សេងៗទៀត ។

តំណាងសហព្រះរាជអាជ្ញាលោក វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល បានបញ្ជាក់ថា ឯកសារ៤ដែលខ្លួនជំទាស់គឺជាឯកសារដែលលើកឡើងដោយក្រុមមេធាវី ខៀវ សំផន ដែលមាននិយាយអំពីកិរិយា



ខៀវ សំផន កំពុងចាប់ដៃជាមួយកម្មាភិបាលនារី នៅអំឡុងពេលនៃការតស៊ូនៅ

មាយាទល្អរបស់ ខៀវ សំផន ។ លោកបានផ្ដល់អំណះអំណាងថា អត្ថបទទាំង៤ គឺជាសក្ខីកម្មរបស់អ្នកនិពន្ធ ដែលសរសេរឡើងក្រោមការផ្ដួចផ្ដើមរបស់ក្រុមមេធាវីការពារក្ដី ដោយពុំបានឆ្លង

កាត់ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតឡើយ ។ ដូច្នេះ ខ្លួនទាមទារឲ្យមានការកោះហៅអ្នកនិពន្ធអត្ថបទទាំងនោះមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ម្យ៉ាងទៀត ឯកសារទាំងនោះត្រូវបានដាក់នៅក្នុងសំណុំរឿងដោយក្រុមមេធាវីខ្លួនឯងតែប៉ុណ្ណោះ ។



ក្នុងព្រៃនាតំបន់រំដោះ ដើមទសវត្ស៧០ (ប្រភពៈមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តលើកឡើងអំពីការជំទាស់របស់ខ្លួនទៅនឹងឯកសារ ៤ របស់ក្រុមមេធាវី នួន ជា ដែលមានដូចជា សៀវភៅរបស់ ចូអែល ប្រ៊ែន្គលី, អត្ថបទរបស់អាល្ម៉ាន, របាយការណ៍របស់គណៈរដ្ឋមន្ត្រីនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងរបាយការណ៍ស្តីអំពីដំណើរទស្សនកិច្ចរបស់លោក ហ៊ុន សែន នៅប្រទេសថៃ។ តំណាងសហព្រះរាជអាជ្ញាបានផ្តល់អំណះអំណាងថា ឯកសារទាំងនោះនិយាយអំពីព្រឹត្តិការណ៍ក្រោយឆ្នាំ១៩៧៥-១៩៧៩ ដោយពុំមានភាពពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវយកមកពិភាក្សានោះឡើយ ។ បន្ទាប់ពីបញ្ចប់ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា លោកចៅក្រម និល ណុន បានផ្ទេរវេទិកាជូនសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីលើកឡើងនូវការជំទាស់ ប៉ុន្តែសហមេធាវីបានបញ្ជាក់ថា ខ្លួនមានរក្សាជំហរគាំទ្រចំពោះការជំទាស់ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា ។

**បញ្ជាក់៖** បន្ទាប់ពីបញ្ចប់ការបង្ហាញឯកសាររបស់សហ-ព្រះរាជអាជ្ញា អង្គជំនុំជម្រះបានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្តីដើម្បីធ្វើការជំទាស់លើឯកសារទាំងនោះ ។ ខណៈពេលនោះដែរ ក្រុមមេធាវីការពារក្តីរបស់ នួន ជា ពុំមានការជំទាស់ទៅនឹងឯកសារទាំង៤៨ ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាឡើយ ។ ដូច្នេះ អង្គជំនុំជម្រះបានផ្ទេរវេទិកាបន្ទាប់ជូនក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ។

មេធាវីអន្តរជាតិ ម៉ៃឃើល ការណាវ៉ាស បានលើកឡើងជំទាស់ដោយសង្ខេបលើរាល់ឯកសារដែលតំណាងសហព្រះរាជអាជ្ញាបានបង្ហាញ និងបដិសេធលើរាល់សេចក្តីសង្ខេបដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ។ លោកបានបន្តថា ខ្លួនបដិសេធចំពោះខ្សែវីដេអូដែលផលិតឡើងដោយមានលក្ខណៈសិល្បៈ និងមានការរៀបរាប់តាមការយល់ឃើញរបស់អ្នកផលិតលើកលែងតែខ្សែវីដេអូរមួយដែលថតដោយលោក ថេត សម្បត្តិមួយគត់ដោយសារវីដេអូនោះមានបង្ហាញអំពីភស្តុតាងដោះបន្ទុក ។ មេធាវីបានបន្តអះអាងថា ចំពោះឯកសារចម្លើយសារភាពវិញ ពុំអាចទទួលយកបានឡើយ ដោយសារអត្ថន័យនៅក្នុងឯកសារទាំងនោះបានមកពីការធ្វើទារុណកម្មតែប៉ុណ្ណោះ ។ បន្ទាប់មក លោក មេធាវី ការណាវ៉ាស បានបង្ហាញពីជំហរជំទាស់ដាច់ខាតចំពោះរបាយការណ៍របស់អង្គការសហប្រជាជាតិប៉ុន្តែចំពោះ

ឯកសាររបាយការណ៍ដែលចេញដោយក្រសួងសហរដ្ឋអាមេរិក សៀវភៅ និងសារព័ត៌មានផ្សេងៗទៀតខ្លួននៅតែទាមទារឲ្យមានការផ្តល់សក្ខីកម្មពីអ្នកសរសេរ ដើម្បីបញ្ជាក់អំពីភាពអាចទទួលយកបាននៃឯកសារទាំងនោះ ។ ជាចុងក្រោយ មេធាវី កាណាវ៉ាស បានបន្ថែមថា ខ្លួននឹងដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ ដោយភ្ជាប់នូវអំណះអំណាងលំអិតនៅពេលក្រោយ ។

ចំណែកមេធាវីអន្តរជាតិ អង់តា ហ្គីសេ បានពីគោលជំហររបស់ខ្លួនក្នុងការគាំទ្រចំពោះសេចក្តីជំទាស់របស់មេធាវី ម៉ៃឃើល កាណាវ៉ាស ព្រមទាំងស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារដែលក្រុមខ្លួនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីជាប្រយោជន៍បញ្ជាក់អំពីអត្តចរិករបស់កូនក្តីខ្លួន ។ ជាងនេះទៅទៀត មេធាវីបានបដិសេធចំពោះឯកសារខ្សែវីដេអូដែលលើកឡើងដោយសហព្រះរាជអាជ្ញា ព្រមទាំងផ្តល់អំណះអំណាងថា ខ្សែវីដេអូទាំងនោះពុំមានបញ្ជាក់ពីប្រភព និងអ្នកនិពន្ធច្បាស់លាស់ ។ មុនពេលបញ្ចប់ មេធាវីនៅតែស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកោះហៅអ្នកនិពន្ធទាំងនោះ មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដូចសហភាគីរបស់ខ្លួនដែរ ។

បន្ទាប់ពីបានស្តាប់ការជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុមរួចមក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ដេស្នាឯល បានច្រានចោលការជំទាស់របស់មេធាវីការពារក្តី អៀង សារី ដោយសារការជំទាស់នោះពុំមានមូលដ្ឋានច្បាស់លាស់ ព្រមទាំងបដិសេធចំពោះការជំទាស់ដែលនឹងធ្វើឡើងដោយលាយលក្ខណ៍អក្សរទាក់ទងបញ្ហានេះ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តបដិសេធការជំទាស់របស់មេធាវីជនជាប់ចោទ អៀង សារី ចំពោះការប្រើប្រាស់របាយការណ៍សង្ខេបរបស់សហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយទាក់ទងនឹងទីតាំងភូមិសាស្ត្រទួលពោធិ៍ជ្រៃដោយអះអាងថា រាល់របាយការណ៍ទាំងនោះត្រូវចាត់ទុកថា យកជាការបាន ដោយសាររបាយការណ៍ទាំងនោះកើតចេញពីការស៊ើបអង្កេត ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា បានបន្តលើកឡើងថា ចំពោះសៀវភៅ និងអត្ថបទផ្សេងៗពុំចាំបាច់តម្រូវឲ្យមានការកោះហៅអ្នកនិពន្ធមកផ្តល់សក្ខីកម្មឡើយ ដោយសារនៅក្នុងច្បាប់ស្តីពីការបង្កើតតុលាការមិនតម្រូវឲ្យភាគីធ្វើដូច្នោះឡើយ ។ ម្យ៉ាងទៀត ឯកសារចម្លើយសារភាព គឺអាចជឿជាក់បានដោយសារឯកសារទាំងនោះមានចំណារដែលបញ្ជាក់ពីភាពស៊ីសង្វាក់គ្នា ហើយថែមទាំងមានការបញ្ជាក់អំពីភាពគួរឲ្យទុកចិត្តបានតាមរយៈការផ្តល់សក្ខីកម្មរបស់ប្រធាន និងអនុប្រធាននៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចំណែកខ្សែវីដេអូសម្ភាសន៍ដែលថតដោយ ថេត សម្បត្តិ ជាមួយ នួន ជា គឺជាឯកសារពិតដូចមាននៅក្នុងខ្លឹមសារនៃខ្សែវីដេអូនោះស្រាប់ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា បានបដិសេធចំពោះការជំទាស់របស់មេធាវីការពារក្តីនឹងខ្សែវីដេអូដែលនិយាយអំពី ខៀវ សំផន ដោយអះអាងថា ឯកសារទាំងនោះពិត ជាមានសំឡេងរបស់ ខៀវ សំផន ដែលអាចឲ្យអង្គជំនុំជម្រះយកមកពិចារណាបាន ។

បន្ទាប់ពីបញ្ចប់ការឆ្លើយតបរបស់តំណាងសហព្រះរាជអាជ្ញា សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានក្រោកឡើងដើម្បីបញ្ជាក់អំពីគោលជំហររបស់ខ្លួនបដិសេធលើការជំទាស់របស់មេធាវីការពារក្តីទាក់ទងនឹងខ្សែវីដេអូដែលនិយាយអំពី នួន ជា និង ខៀវ សំផន ។ លោកបានអះអាងថា ឯកសារទាំងនោះសុទ្ធសឹងតែបាននិយាយអំពីព្រឹត្តិការណ៍នៅចន្លោះ ឆ្នាំ១៩៧៥-១៩៧៩ ដែលអាចឲ្យអង្គជំនុំជម្រះយកមកប្រើប្រាស់ជាភស្តុតាងបាន ។ សហមេធាវីអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានថ្លែងបន្តថា ខ្លួនមិនយល់ស្របចំពោះការជំទាស់របស់មេធាវីការពារក្តី ដោយអះអាងថា ការជំទាស់របស់មេធាវីការពារក្តីធ្វើឡើងយឺតពេល និងមានលក្ខណៈទូលំទូលាយ ។ ដូច្នេះខ្លួនស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធការជំទាស់ដែលនឹងធ្វើឡើងជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្តី ។

### ២) ការជំទាស់ដោយក្រុមមេធាវីការពារក្តីលើឯកសារចំនួន ៩៨របស់សហព្រះរាជអាជ្ញាទាក់ទងនឹងទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជន

បន្ទាប់ពីបញ្ចប់ការជំទាស់របស់ក្រុមមេធាវីការពារក្តីទៅលើឯកសារទាំង៩៨ របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យក្រុមមេធាវីទាំងបីក្រុមធ្វើការជំទាស់ទៅលើឯកសារ

ចំនួន ៩៤ទៀតទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១, ការជម្លៀសនៅដំណាក់កាលទី២ និង ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ។ នៅក្នុងការជំទាស់នេះគឺមានតែមេធាវីការពារក្តី ខៀវ សំផន និង អៀង សារី តែប៉ុណ្ណោះដែលបានលើកឡើងខណៈពេលដែលមេធាវី នួន ជា បានបង្ហាញជំហរមិនធ្វើការជំទាស់នៅដំណាក់កាលនេះ ដោយសារខ្លួនពុំមានឱកាសពិភាក្សាជាមួយកូនក្តីខ្លួន និងរង់ចាំការដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍វិញ ។

ក្នុងចំណោមឯកសារទាំងនោះ មេធាវីអន្តរជាតិ ម៉ៃឃើល ការណាវ៉ាស បានធ្វើការជំទាស់ទៅ នឹងឯកសាររូបថត និងសាព័ត៌-មានដែលបានប្រើប្រាស់រូបថតដោយអះអាងថា តុលាការត្រូវតែកោះហៅអ្នកថតរូប ឬអ្នកសរសេរព័ត៌មានទាំងនោះមកផ្តល់សក្ខីកម្ម ដើម្បីបញ្ជាក់អំពីរូបថតទាំងអស់នោះ ។ បន្ទាប់មក មេធាវីបានធ្វើការជំទាស់បន្តទៅទៀតលើឯកសារដែលទាក់ទងនឹងស្រុកត្រាំកក់ដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវីរូបនេះបានអះអាងថា ឯកសារទាំងនោះពុំមានឯកសារដើម ដើម្បីបញ្ជាក់ពីយថាភាពនោះឡើយ បើទោះបីជាឯកសារទាំងនោះមានការផ្តល់ភាពគួរឲ្យជឿជាក់តាមរយៈការផ្តល់សក្ខីកម្មពីនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដោយ ។

ដូចគ្នានឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី ដែរ មេធាវីអន្តរជាតិការពារជនជាប់ចោទ ខៀវ សំផន កញ្ញា អង់តា ហ៊ុសសេ បានជំទាស់នឹងយថាភាព និងភាពអាចទទួលយកបាននៃឯកសាររបាយការណ៍ពីស្រុកត្រាំកក់ ដោយសារតែឯកសារទាំងនោះពុំមានបញ្ជាក់ពីឈ្មោះរបស់អ្នកសរសេរច្បាស់លាស់ ។ ដូចច្នេះ មេធាវីបានស្នើសុំមិនឲ្យសហព្រះរាជអាជ្ញាដាក់ឯកសារទាំងនោះនៅក្នុងសំណុំរឿងឡើយ ។

ខណៈពេលបញ្ចប់ការជំទាស់របស់មេធាវីការពារក្តីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិវ៉ាំងសង់ ដេស្វាឯល បានបដិសេធលើការជំទាស់ទាំងឡាយដែលលើកឡើងដោយក្រុមមេធាវីការពារក្តី ដោយប្រកាន់ជំហរថា ឯកសារដែលខ្លួនបានបង្ហាញគឺសុទ្ធតែជាឯកសារដែលមានបង្ហាញព័ត៌មានពិតប្រាកដដូចជា រូបថតដែលបង្ហាញពីស្ថានភាពជម្លៀសប្រជាជន និងមន្ទីរសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃជាដើម ។ ចំណែកឯកសារផ្សេងទៀត គឺជារបាយការណ៍ស្តីពីមន្ទីរសន្តិសុខត្រាំងតាចាន់ ដែលថ្នាក់ឃុំផ្ញើទៅកាន់ថ្នាក់ស្រុក គឺសុទ្ធសឹងតែមានបញ្ជាក់ពីឈ្មោះ និងតួនាទីរបស់អ្នកទោសទាំងនោះយ៉ាងច្បាស់លាស់ ។ ម្យ៉ាងទៀតឯកសារទាំងនោះសុទ្ធតែត្រូវបានបញ្ជាក់ពីយថាភាពរួចមកហើយពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើការស្រាវជ្រាវអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះ ។

**៣) ការបង្ហាញឯកសារពាក់ព័ន្ធជាក់លាក់នឹងការជម្លៀសប្រជាជន នៅដំណាក់កាលទី១ និងដំណាក់កាលទី២ ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ រចនាសម្ព័ន្ធយោធា គោលនយោបាយ សហខក្រិដ្ឋរួម និងតួនាទីរបស់ជនជាប់ចោទ**

ជាការចាប់ផ្តើមតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានបង្ហាញនូវឯកសារមួយចំនួនដោយអានលើកយកតែព័ត៌មានសំខាន់ៗ ដែលពាក់ព័ន្ធជាក់លាក់ទៅនឹងអង្គហេតុដែលត្រូវធ្វើសវនាការ ។ នៅក្នុងចំណោមឯកសារទាំងនោះមានដូចជាឯកសារទង់បដិវត្តន៍ដែលនិយាយអំពីតួនាទី និងរចនាសម្ព័ន្ធរបស់កងទ័ពបដិវត្តន៍កម្ពុជា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍ និងឯកសារបទសម្ភាសន៍ជាមួយមេដឹកនាំខ្មែរក្រហម ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានបន្តលើកយកឯកសារដែលទាក់ទងនឹងការបញ្ជាកងទ័ពដោយ សុន សេន, ឯកសារសារទូរលេខដែលទាក់ទងនឹងការប្រយុទ្ធជាមួយវៀតណាម, កំណត់ហេតុកិច្ចប្រជុំរបស់កងវរៈសេនាតូច និងកងវរៈសេនាធំ ព្រមទាំងរបាយការណ៍ ដែលទាក់ទងនឹងការជម្លៀសប្រជាជននៅតាមជនបទ ។ ក្រោយពេលបញ្ចប់ការបង្ហាញឯកសារទាំងនោះ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្តីទាំងបីក្រុម ដើម្បី មានឱកាសជំទាស់នឹងឯកសារដែលតំណាងសហព្រះរាជអាជ្ញាលើកឡើង ។

**បញ្ជាក់៖** បន្ទាប់ពីបានស្តាប់ការបង្ហាញឯកសារមួយចំនួនរបស់តំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីដើម្បីជំទាស់លើឯកសារទាំងនោះ ។ ជាដំបូងមេធាវីជាតិការពារក្តី នួន ជា គឺលោក សុន អរុណ បានឡើងថ្លែង

សេចក្តីជំទាស់របស់ខ្លួនលើឯកសារទស្សនៈដិវត្តន៍ សៀវភៅ និង ការសែតសារព័ត៌មានដែលបានលើកបង្ហាញ ហើយមេធាវី បានទាមទារឲ្យមានការបង្ហាញឯកសារដើម និងតម្រូវឲ្យមានការ កោះហៅអ្នកនិពន្ធមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ដូចគ្នានឹងការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ដែរ លោក មេធាវីអន្តរជាតិ ម៉ៃឃើល កាណាវ៉ាស ការពារក្តី អៀង សារី បាន ប្រកាន់ជំហររបស់ខ្លួនក្នុងការជំទាស់នឹងការលើកឡើងរបស់ តំណាងសហព្រះរាជអាជ្ញា ដោយអះអាងថា ឯកសារដែលត្រូវ បានបង្ហាញនោះពុំមានតម្លៃជាភស្តុតាងឡើយ ហើយទាមទារឲ្យ អង្គជំនុំជម្រះកំណត់ពេលវេលាឲ្យបានច្បាស់លាស់ ដើម្បីពិភាក្សា លើបញ្ហានេះសារជាថ្មី ។ ម្យ៉ាងទៀតខ្លួនក៏ទាមទារឲ្យមានការ បង្ហាញអំណះអំណាងបញ្ជាក់ពីយថាភាព និងភាពអាចទទួលយក បាននៃឯកសារទាំងនោះថែមទៀត ។ ចំណែកមេធាវីអន្តរជាតិ ការពារក្តី ខៀវ សំផន បានធ្វើការកត់សម្គាល់ខ្លីដោយបង្ហាញ ពីជំហររបស់ខ្លួនគាំទ្រការអះអាងរបស់មេធាវីការពារក្តី អៀង សារី ហើយនឹងត្រៀមខ្លួនក្នុងការបង្ហាញអំណះអំណាងនៅក្នុង ពេលដំណើរការសវនាការនៅពេលខាងមុខ ។

ឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តី តំណាង សហព្រះរាជអាជ្ញា ឌេល លីសាក់ បានអះអាងថា ឯកសារទស្សនៈ ដិវត្តន៍ដែលខ្លួនបានលើកឡើង គឺជាឯកសារដែលអាចឲ្យតុលាការ យកមកប្រើប្រាស់បានដោយសារឯកសារទាំងនោះត្រូវបានថត ចម្លងចេញពីឯកសារដើមដែលមានពណ៌រួចមកហើយ ។ ដូច្នេះ ខ្លួនពុំអាចរកភស្តុតាងណាមួយមកបញ្ជាក់ថា ឯកសារទាំងនោះ ជាឯកសារដែលត្រូវបានប្រឌិតឡើងបានទេ ។ ម្យ៉ាងទៀត តំណាង សហព្រះរាជអាជ្ញាបានបន្តអះអាងថា ឯកសារទស្សនៈដិវត្តន៍ទាំង នោះត្រូវបានឆ្លើយថាភាពរួចហើយ តាមរយៈការសួរដេញដោល សាក្សីមួយចំនួន ។

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលា ដំបូងបានបន្តសវនាការដាក់បង្ហាញឯកសារដោយតំណាងសហ ព្រះរាជអាជ្ញាទាក់ទងនឹងអង្គហេតុខាងលើ ។ នៅពេលចាប់ផ្តើម សវនាការនេះ តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ត់ បានអាន នូវមាតិកាសំខាន់ៗនៃឯកសារមួយចំនួនដែលទាក់ទងនឹងព្រឹត្តិ- ការណ៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលរួមមានការ វាយប្រហារមកលើទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហម ការ ចូលមកដល់ទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនចេញពីទីក្រុង ការ ជម្លៀសប្រជាជនទៅកាន់សហករណ៍នានានៅតាមទីជនបទ ការ ធ្វើអត្តសញ្ញាណកម្មបំបែក និងការសម្លាប់អតីតមន្ត្រីរដ្ឋការ និង ទាហាននៃរបបសាធារណៈរដ្ឋខ្មែរនៅទីតាំងខេត្តក្រិដ្ឋកម្មទួលពោធិ៍ ជ្រៃ ការផ្លាស់ទីប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ និងផល វិបាករបស់ប្រជាជនក្រោយពេលជម្លៀស ។ ចំណែកឯកសារ មួយចំនួនទៀត ទាក់ទងនឹងរបាយការណ៍របស់សេវាកម្មផ្សាយ ព័ត៌មានសម្ងាត់អន្តរជាតិរបស់សហរដ្ឋអាមេរិក ឯកសារមកពី បណ្ណសាររបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ការដកស្រង់ សេចក្តីសង្ខេបនានារបស់តំណាងខ្មែរក្រហមសេចក្តីរាយការណ៍ របស់ប្រព័ន្ធផ្សព្វផ្សាយផ្សាយព័ត៌មានអន្តរជាតិ សារទូរលេខ ចេញ-ចូលរបស់ស្ថានទូតបារាំងនៅទីក្រុងភ្នំពេញ ការបោះពុម្ព ផ្សាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលរួមមានកំណត់ហេតុ ស្តីពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យនៅ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ និងរបាយការណ៍របស់ ភូមិភាគពាយ័ព្យចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧ ។

បន្ទាប់ពីបញ្ចប់ការអាននូវមាតិកាសំខាន់ៗនៃឯកសារទាំង នោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រ៉ៃន័រ បានបន្ត ដោយការអានលម្អិតអំពីខ្លឹមសារនៅក្នុងឯកសារដែលលើកឡើង ដោយសហភាគីរបស់ខ្លួន ។ ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកយកឯកសារដែលមានប្រភពចេញពីបណ្ណសារនៃ ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលទាក់ទងនឹងស្ថានភាព ប្រទេសកម្ពុជាក្នុងរយៈពេលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ អត្ថបទនោះមានខ្លឹមសារថា “*នៅក្នុងប្រទេសយើងត្រូវដឹងអំពី របាយការណ៍នៅថ្ងៃទី២៤-២៥ ខែកុម្ភៈ គឺ ខៀវ សំផន បានធ្វើ ជាអធិបតីនៅក្នុងសន្និបាតស្តីអំពីការរំដោះបូរណភាពទឹកដី ។ ...គណៈរដ្ឋមន្ត្រីរបស់ហ្រ្គុង (GRUN) ដែលមានតំណាងចំនួន ២២៣នាក់ នៃតំណាងរបស់ហ្រ្គុង (GRUN) ចូលរួមប្រជុំរួម ទាំងកងទ័ពផងដែរ....នោះ គឺជាការចាំបាច់បំផុតដែលត្រូវ*

ប្រហារជីវិតជនក្បត់ទាំងប្រាំពីរនាក់មាន លន់ នល់, សិរិមតៈ, សឺងង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែណង់ដេស ។ អ្នកនយោបាយដទៃទៀត និងអ្នកដែលមានឋានន្តរស័ក្តិខ្ពស់ដទៃទៀតអាចនឹងចូលរួមជាមួយរណសិរ្សរួបរួមជាតិ ប្រសិនណាគេឈប់សហការជាមួយពួកក្បត់ទាំងប្រាំពីរនាក់ចាប់ពីពេលនេះតទៅ» ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានលើកឡើងអំពីស្ថានភាពទីក្រុងភ្នំពេញ ដែលទទួលរងនូវការទម្លាក់គ្រាប់រ៉ុក្កែតជាច្រើនគ្រាប់នៅអំឡុងខែកុម្ភៈ រហូតដល់ខែមីនា ឆ្នាំ១៩៧៥ ដែលព័ត៌មាននេះត្រូវបានដកស្រង់ចេញពីការផ្សព្វផ្សាយរបស់ទីភ្នាក់ងារសេវាសហរដ្ឋអាមេរិក (FBIS) ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តលើកឡើងទាក់ទងនឹងអត្ថន័យនៅក្នុងការសែតហ៊ុំប៊ីស ដែលមានខ្លឹមសារថា «គឺរណសិរ្សរួបរួមជាតិកម្ពុជាបានរំដោះអ្នកលឿង ហើយជោគជ័យនេះមានសារៈសំខាន់ដោយសារទីនោះ គឺជាមូលដ្ឋានដ៏សំខាន់របស់ខ្មាំង ហើយជាទីតាំងដ៏មាំរបស់ពួកខ្មាំង ។ ការលើកឡើងនេះបានន័យថា ពួក ស៊ី.ភី.អិន.អិល.អេ.អេហ្វ គឺសំដៅលើប្រជាជនកម្ពុជា ដែលបានគ្រប់គ្រងទាំងស្រុងទៅលើតំបន់ទន្លេមេគង្គចាប់ពីទីក្រុងភ្នំពេញ រហូតទៅដល់ព្រំដែនវៀតណាមខាងត្បូង» ។ តំណាងសហព្រះរាជអាជ្ញាបានបន្តអានសម្រង់លិខិតទាក់ទងនឹងអនុស្សរណៈមួយដែលផ្សាយចេញមកពីសេតវិមាននៅទីក្រុងវ៉ាស៊ីនតោន ដែលជាកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ រាយការណ៍ដោយលោក ឃីសស៊ីងហ្គ័រ ។ នៅក្នុងលិខិតនោះ លោក ឃីសស៊ីងហ្គ័រ បានអានអត្ថន័យនៅក្នុងលិខិតនោះក្នុងអំឡុងពេលកិច្ចប្រជុំទាក់ទងនឹងសំបុត្រដែលព្រះអង្គម្ចាស់ សិរិមតៈ ផ្ញើជូនលោកឯកអគ្គរដ្ឋទូតអាមេរិកក្រោយពេលលោកឯកអគ្គរដ្ឋទូតបានយាងទ្រង់ សិរិមតៈ ឲ្យចាកចេញពីប្រទេសកម្ពុជាជាមួយជនភៀសខ្លួនមុនពេលខ្មែរក្រហមវាយផ្តាច់ព្រ័ត្រ ។ លិខិតនោះបានសរសេរថា «ខ្ញុំសូមសម្តែងការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះសំបុត្រ និងការផ្តល់ជូនរបស់លោកដើម្បីនាំខ្ញុំទៅកាន់សេរីភាព ។ ប៉ុន្តែ ពុទ្ធោអើយ ខ្ញុំមិនអាចចាកចេញក្នុងសភាពដ៏កំសាកបែបនេះបានទេ ។ ចំពោះលោក ហើយជាពិសេសចំពោះប្រទេសដ៏អស្ចារ្យរបស់លោក ខ្ញុំមិនដែលជឿមួយវិនាទីណាឡើយថា លោកបោះបង់ ដាច់ចិត្តបោះបង់ចោលមនុស្សដែលបានជ្រើសរើសយកសេរីភាព ។ លោកបានបដិសេធមិនផ្តល់ការការពារដល់យើងខ្ញុំ ហើយយើងខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ។ លោកបានចាកចេញ ហើយវាជាសេចក្តីប្រាថ្នារបស់ខ្ញុំដែលថា លោក និងប្រទេសរបស់លោកនឹងរកឃើញសុភមង្គលនៅក្រោមមេឃ ។ ប៉ុន្តែ សូមកត់ចំណាំឲ្យបានល្អថា ប្រសិនបើខ្ញុំត្រូវស្លាប់នៅទីនេះ នៅទីកន្លែងនេះគឺនៅក្នុងប្រទេសរបស់ខ្ញុំ ដែលខ្ញុំស្រឡាញ់ ខ្ញុំក៏មិនដឹងធ្វើម៉េចដែរ ពីព្រោះមនុស្សយើងគ្រប់រូបកើតមកហើយត្រូវតែស្លាប់នៅថ្ងៃណាមួយមិនខាន ។ ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់ គឺការជឿជាក់ទៅលើសហរដ្ឋអាមេរិក ។ សូមទទួលនូវមនោសញ្ចេតនារាប់អានអំពីខ្ញុំ ឯកឧត្តម មិត្តជាទីស្រឡាញ់ មិត្តដ៏ស្មោះត្រង់ និងរួសរាយរាក់ទាក់របស់ខ្ញុំ» ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វ៉េន័រ បានដាក់បង្ហាញឯកសារមួយទៀតដែលមានប្រភពពីក្រសួងការបរទេសសហរដ្ឋអាមេរិក ទាក់ទងនឹងស្ថានភាពនៅក្នុងឆ្នាំ១៩៧៣ ស្តីអំពីយន្តហោះសហរដ្ឋអាមេរិក និងឯកសារមួយទៀតស្តីអំពីជនភៀសខ្លួននៅទីក្រុងភ្នំពេញ ដែលស្ថិតនៅក្នុងសភាពអត់ឃ្លាន ហើយប្រជាជនភាគច្រើនបានបាត់ខ្លួន ។ អត្ថបទនោះមានខ្លឹមសារថា «...ជំនួយពីភ្នាក់ងារស្ម័គ្រចិត្ត និងកាកបាទក្រហមដែលដាក់នៅវៀតណាមបានដឹកជញ្ជូនមកជួយផ្គត់ផ្គង់នៅកម្ពុជា បានរយៈពេល១៩ថ្ងៃ គឺនៅថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី៣ ខែមីនា ។ ...អង្ករ និងត្រីបានឡើងថ្លៃជាង ១០ ភាគរយ» ។ ព្រះរាជអាជ្ញាបានលើកឡើងពីអត្ថបទដកស្រង់មួយស្តីអំពីការវាយសម្រុកដោយយោធាខ្មែរក្រហមសារជាថ្មីរួមជាមួយនឹងការទម្លាក់គ្រាប់ដែលបានធ្វើឲ្យមនុស្សស្លាប់ជាច្រើននាក់ គឺកើនឡើង ២ដង បើប្រៀបធៀបទៅនឹងពេលមុន ។ ក្រោយមកទៀត សហព្រះរាជអាជ្ញាបានលើកឡើងពីរបាយការណ៍របស់ប្រទេសបារាំងចុះនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៥ ដែលនិយាយអំពីការជម្លៀសបុគ្គលិកចេញពីស្ថានទូត ។ ឯកសារមួយទៀតគឺជាឯកសារទាក់ទងនឹង លន់ នល់ និង ឡុង បូរ៉េត ដែលត្រៀមចុះចេញពីតំណែងដើម្បីបុព្វហេតុសន្តិភាព ។ បន្ទាប់មក មានការដាក់បង្ហាញឯកសារដែលនិយាយអំពីការលើកឡើងរបស់សម្តេច សីហនុ ដែលសរសេរថា «មិន

ពាក់ព័ន្ធនឹងការសម្លាប់ជនទាំង៧រូបនោះទេ» និងឯកសារដែលនិយាយអំពីការចែកស្បៀងអាហារជូនប្រជាជននៅភ្នំពេញ ។ ចំណែកឯកសារមួយទៀត គឺជាឯកសារហ្វីប៊ីសចុះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ ដែលមានសរសេរថា «ខៀវ សំផន គាំទ្រឲ្យមានការប្រយុទ្ធគ្នាដើម្បីវាយប្រហារពួកក្បត់ពីខាងក្នុង» ។

ឯកសារបន្ទាប់មកទៀតដែលត្រូវបង្ហាញ គឺឯកសារមួយចំនួនរបស់អ្នកការសែត ហ្សង់ហ្សាក់ កាហ្សូ ដែលទាក់ទងនឹងព្រឹត្តិការណ៍នៅពេលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ និងការគេចខ្លួនរបស់ព្រះអង្គម្ចាស់សិរិមតៈ ទៅកាន់ទីតាំងមានសុវត្ថិភាព និងការបង្ខំឲ្យប្រជាជនចាកចេញពីសណ្ឋាគារ ដើម្បីទៅជ្រកកោននៅតាមស្ថានទូតនានាដូចជាស្ថានទូតបារាំងជាដើម ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញសារទូរលេខដែលបញ្ជូនចេញ-ចូលនៅក្នុងស្ថានទូតបារាំង ទាក់ទងនឹងការច្រានចោលការស្នើសុំសិទ្ធិជ្រកកោននៅក្នុងស្ថានទូតបារាំងរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ និង អ៊ុំង ប៊ុនហូ ព្រមទាំងបុគ្គលដទៃទៀតមួយចំនួន ។ ឯកសារដដែលនេះក៏មាននិយាយទាក់ទងនឹងក្រសួងការបរទេសសហរដ្ឋអាមេរិក ។ ឯកសារដដែលនេះក៏មាននិយាយទាក់ទងនឹងក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីអំពីគោលជំហររបស់ខ្មែរក្រហម និងព្រឹត្តិការណ៍នៅថ្ងៃទី២០ ខែមីនា និងព្រឹត្តិ-ការណ៍ផ្ទោងគ្រាប់ចូលទៅក្នុងផ្ទះនាយករដ្ឋមន្ត្រី ឡុង បូរ៉េត ។ ខណៈពេលនោះដែរ សហព្រះរាជអាជ្ញាបានស្នើសុំចាក់ផ្សាយវីដេអូ ដែលនិយាយអំពីការប្រយុទ្ធរបស់កងទ័ពខ្មែរក្រហម និងការរងរបួសរបស់ប្រជាជនកម្ពុជាដោយសារការផ្ទោងគ្រាប់របស់កងទ័ពខ្មែរក្រហម និងការធ្វើដំណើររបស់ លន់ នល់ ទៅក្រៅប្រទេស ដោយនាំយកប្រាក់យ៉ាងច្រើនទៅជាមួយ ។ តំណាងព្រះរាជអាជ្ញាបានលើកឡើងនូវការចុះផ្សាយក្នុងការសែត ហ្វីប៊ីស និងរបាយការណ៍របស់ភ្នាក់ងារ រ៉យទ័រ ស្តីអំពីការធ្វើដំណើររបស់លោក ឡុង បូរ៉េត ។ នៅក្នុងរបាយការណ៍របស់ភ្នាក់ងារ រ៉យទ័រ ចុះផ្សាយអំពីការធ្វើដំណើរត្រឡប់មកពីទីក្រុង ហ្សាការតា របស់អតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត មកកាន់ប្រទេសកម្ពុជាវិញ ហើយនៅក្នុងការវិលត្រឡប់នោះ លោក ឡុង បូរ៉េត បានអំពាវនាវឲ្យមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ដោយមានច្បាប់គ្រប់គ្រង ដើម្បីជ្រើសរើសមេដឹកនាំរបស់ខ្លួន ។ ឯកសារមួយទៀត និយាយអំពីការលើកឡើងរបស់ ខៀវ សំផន ដែលថា «យោងតាមប្រភពពីលោកខាងលិចមួយចំនួនប៉ុន្មានថ្ងៃមុន អាឡុងបូរ៉េត បានថ្លែងថា ខ្លួនបានស្វែងរកការចរចាជាមួយភាគីផ្សេងទៀតរួចហើយ...» ។ អត្ថបទដកស្រង់ចេញពីឯកសាររបស់ទីភ្នាក់ងារ បារាំងឈ្មោះ ហ្សង់សាក់ កាហ្សូ បានលើកឡើងពីការវាយលុកទីក្រុងភ្នំពេញយ៉ាងឆាប់រហ័ស នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឆ្ពោះទៅរកការរំដោះទីក្រុងទាំងមូល ។

**បញ្ជាក់** : ខណៈពេលដែលតំណាងសហព្រះរាជអាជ្ញាកំពុងបង្ហាញឯកសារបន្តបន្ទាប់នោះ មេធាវី កាណាវ៉ាស បានលើកឡើងអំពីអលទ្ធភាពដែល អៀង សារី អាចតាមដានសវនាការពីបន្ទប់ឃុំឃាំង ដែលបំពាក់ដោយប្រព័ន្ធសោតទស្សន៍ ហើយ អៀង សារី ស្នើសុំលះបង់សិទ្ធិជាផ្លូវការក្នុងការតាមដានសវនាការនេះ ។ មេធាវីបានលើកឡើងទៀតថា វេជ្ជបណ្ឌិតដែលកំពុងពិនិត្យ អៀង សារី ពុំអាចផ្តល់យោបល់អ្វី ឬចេញសេចក្តីសម្រេចណាមួយបានឡើយទាក់ទងនឹងស្ថានភាពសុខភាពរបស់កូនក្តី ។ ជាងនេះទៅទៀត ខ្លួនក៏បានស្នើសុំឲ្យវេជ្ជបណ្ឌិតមានការផ្លាស់ប្តូរវេនគ្នាក្នុងការពិនិត្យសុខភាព អៀង សារី ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា បានបន្តលើកឡើងអំពីស្ថានភាពទីក្រុងភ្នំពេញនៅពេលខ្មែរក្រហមកំពុងវាយលុកដោយលើកឡើងនូវអត្ថបទមួយចំនួនទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាននៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងអត្ថបទទាំងនោះបានរៀបរាប់អំពីការវាយចូលទីក្រុងភ្នំពេញ ព្រមទាំងបានលើកឡើងនូវអត្ថបទដែលសរសេរថា «បុរសម្នាក់កាន់កាំភ្លើងនៅកណ្តាលផ្លូវ ហើយគេសន្និដ្ឋានថាជាសមាជិកខ្មែរក្រហម គឺឈ្មោះ ហែម កេតដារ៉ា ដែលជាកូនប្រុសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបប លន់ នល់» ។ នៅក្នុងអត្ថបទចុះផ្សាយផ្សេងទៀតក៏មាននិយាយថា «...បើតាមការសន្និដ្ឋាន លោក ដារ៉ា និងក្រុមរបស់គាត់ ជាជនឱកាសនិយមដែលបានវិនិច្ឆ័យខុសអំពីលក្ខណៈពិតប្រាកដរបស់ខ្មែរក្រហម» ។ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងអំពីការជម្លៀសភ្ញៀវចេញពីសណ្ឋាគារឡឺភ្នំ ហើយនៅពេលនោះមានប្រជាជនខ្លះលោត និងបោះវ៉ាលីចូលពេញក្នុងស្ថានទូត ។ រួច

ហើយសហព្រះរាជអាជ្ញា ស្នើសុំចាក់ផ្សាយវីដេអូទី២ ស្ដីអំពីការជម្លៀស និងភាពស្ងប់ស្ងាត់នៃទីក្រុងភ្នំពេញ ។ ចំពោះវីដេអូទី៣ គឺទាក់ទងនឹងព្រឹត្តិការណ៍ជម្លៀសនៅទីក្រុងភ្នំពេញ ។ ឯកសារបន្ទាប់ ទាក់ទងនឹងឯកសាររបស់លោក ហ្វង់ហ្សាក់ កាហ្វ ដែលបានរាយការណ៍ថា «...ការជម្លៀសប្រជាជនធ្វើដំណើរទៅទិសខាងជើង ។ ......ព្រឹត្តិការណ៍ទីមួយ គឺផ្ទះខ្លះត្រូវបានសម្អាត និងផ្ទះជាច្រើនទៀតត្រូវបានបោះគ្រាប់បែកដើម្បីដុតបំផ្លាញចោល» ។ ចំណែកឯកសារដែលបានមកពីកុងស៊ុលបារាំងបានរៀបរាប់ថា «ពួកគេសុំចូលស្ថានទូតរបស់យើងដើម្បីពិនិត្យ យើងធ្វើការយ៉ាងភិតភ័យជាខ្លាំង» ។ «...ស្ថានទូតបារាំងបានផ្ដល់ការជ្រកកោនដល់ព្រះអង្គម្ចាស់ សិរិមតៈ និងទាហានពីរនាក់របស់ព្រះអង្គព្រមទាំងបុគ្គលមួយចំនួនទៀត ។ នៅពេលនោះ គេបានបង្ខំឲ្យលោកផ្ដល់បញ្ជីឈ្មោះនោះឲ្យគេ» ។ តំណាងសហព្រះរាជអាជ្ញាបានដាក់ឯកសារបន្ទាប់ ទាក់ទងនឹងទុក្ខវេទនាដ៏ធ្ងន់ធ្ងរនៃការជម្លៀសប្រជាជនចេញពីទីក្រុង និងចេញពីមន្ទីរពេទ្យនានាដូចបានរៀបរាប់ថា «អ្នកជំងឺត្រូវបានប្រៀបធៀបទៅនឹងសំរាមដែលគេបោះចោលនៅតាមផ្លូវ ។ បុរសស្ត្រីដែលកំពុងរងរបួសបានដើរទ្រេតទ្រោតទៅកាន់ស្ថានទូតបារាំង ។ ភរិយាបានគ្រាប្ដីរបស់ខ្លួន ដែលជាទាហានរងរបួសចុះចេញពីគ្រែពេទ្យដាក់លើរទេះរុញ ហើយអ្នកជំងឺមួយចំនួនកំពុងព្យួរសេរ៉ូមជាប់នៅនឹងដៃនៅឡើយ» ។ «រយៈពេល៥ឆ្នាំនៃសង្គ្រាម គឺជាទុក្ខវេទនាដ៏ធ្ងន់ធ្ងរបំផុតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលមិនធ្លាប់បានជួបប្រទះ ។ ខ្មែរក្រហមត្រូវតែដឹងថា អ្នករបួសមួយចំនួនក្នុងចំណោម ២០០០០នាក់ត្រូវការការជួយសង្គ្រោះ ។ គេអាចសន្និដ្ឋានថា ពួកខ្មែរក្រហមគ្មានសភាវគតិជាមនុស្សឡើយ ។ ទីក្រុងទាំងមូលកំពុងក្លាយទៅជាកន្លែងស្ងប់ស្ងាត់គ្មានមនុស្សរស់នៅ ទោះបីជាមនុស្សចាស់ ជាអ្នកជំងឺក្ដី ជាមនុស្សទន់ខ្សោយ ជាអ្នកអត់ឃ្លាន និងជាក្មេងកំព្រា ក៏ពួកគេមិនត្រូវបានលើកលែងដែរ» ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដាក់ឯកសារមួយចំនួនទៀតទាក់ទងនឹងស្ថានភាពនៅក្នុងស្ថានកុងស៊ុលបារាំងបន្ទាប់ពីមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលសរសេរដោយអ្នកសារព័ត៌មាន ហ្សាក់ហ្សេរ៉ាក់ ។

ចំណែកឯកសារផ្សេងទៀត ជាឯកសារខ្សែវីដេអូ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេយ៍ន័រ បានស្នើសុំចាក់ផ្សាយទាក់ទងនឹងទិដ្ឋភាពនៅតាមទីរួមខេត្តដែលមានសភាពស្ងាត់ជ្រងំ ។ អត្ថបទបន្ទាប់ ដែលត្រូវបានបង្ហាញគឺមានសរសេរថា «ឧត្ដមសេនីយ៍ សរ ប៊ុន បានបែងចែកការកាប់សម្លាប់របស់ពួកខ្មែរក្រហមជាបីប្រភេទ ។ ទី១) ការកាប់សម្លាប់ភ្លាមៗនៅនឹងកន្លែង, ទី២) ការកាប់សម្លាប់ជាប្រព័ន្ធ និងទី៣) ការសម្លាប់ដោយផ្ដាច់ជីវិតសន្សឹមៗ» ។ រួចហើយ តំណាងសហព្រះរាជអាជ្ញាបានបន្តទៀតថា «យោងតាមលោកឧត្ដមសេនីយ៍ នៅពេលដែលភ្នំពេញត្រូវបានដណ្ដើមយកដោយខ្មែរក្រហមភ្លាមនោះ ការកាប់សម្លាប់នៅនឹងកន្លែងគឺត្រូវបានមើលឃើញច្រើន ។ គាត់ត្រូវគេប្រាប់ថា ជនទាំងឡាយដែលប្រឆាំងនឹងបញ្ជាឲ្យចាកចេញពីលំនៅដ្ឋានជាច្រើនលើកច្រើនសារនឹងត្រូវសម្លាប់ចោល ។ ដូចគ្នានេះដែរ ជនទាំងឡាយណាដែលមិនចង់ ឬមិនអាចធ្វើដំណើរក្នុងពេលជម្លៀសជននោះនឹងត្រូវសម្លាប់ចោលដែរ ។ ម្យ៉ាងទៀត អតីតទាហាន លន់ នល់ ដែលជម្លៀសចេញទៅជាមួយគ្រួសារត្រូវគេស្គាល់អត្តសញ្ញាណយ៉ាងងាយបំផុតនៅពេលដែលទាហានទាំងនោះឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ពួកខ្មែរក្រហមជាហូរហែរ ។ ទាហានទាំងនោះត្រូវបានបញ្ជាឲ្យដោះស្បែកជើង និងឯកសណ្ឋានចេញបន្ទាប់មកត្រូវបាញ់សម្លាប់ភ្លាមៗតែម្ដង» ។

តំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារបន្ទាប់ទាក់ទងនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ដែលឯកសារនោះជាអត្ថបទការសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ។ អត្ថបទនោះបានសរសេរថា «ពួកកុម្មុយនិស្តបានសម្លាប់គ្រួសារទាំងមូលរបស់មន្ត្រីរដ្ឋការនៅក្នុងរបបមុន» ។ បន្ទាប់មក គឺឯកសារដែលមានប្រភពចេញពីអង្គការលើកលែងទោសអន្តរជាតិ ដែលសរសេរអំពាវនាវសុំឲ្យតុលាការអន្តរជាតិកាត់ទោសលើអំពើសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ តាមរយៈការរាយការណ៍របស់ជនភៀសខ្លួន ។ នៅក្នុងអត្ថបទនោះជនភៀសបានរៀបរាប់អំពីទិដ្ឋភាពនៃការសម្លាប់មនុស្សជាច្រើន និងមានសាកសព ដែលស្លៀកពាក់ឯកសណ្ឋានទាហាន ។ ទាក់ទងនឹងទួលពោធិ៍ជ្រៃនេះដែរ ក៏មានវីដេអូមួយរយៈពេល ៩នាទី ដែលថត ដោយលោក ថេត សម្បត្តិ ។ ខ្សែ

វីដេអូនោះនិយាយអំពីការសម្លាប់ប្រជាជននៅទួលពោធិ៍ជ្រៃ ប្រហែល ១ម៉ឺននាក់ ហើយនៅក្នុងនោះក៏មានការសម្ភាសន៍ជាមួយសាក្សីដោយ ថេត សម្បត្តិ ដែរ ។ ក្រៅពីនោះទៀត តំណាងសហព្រះរាជអាជ្ញាបានបន្តបង្ហាញឯកសារមួយចំនួនទៀត ដែលទាក់ទងនឹងសភាពការណ៍ សេដ្ឋកិច្ចបង្កបង្កើនផល កិច្ចដំណើរការការពារប្រទេស តួនាទីរបស់កម្មាភិបាលខ្មែរក្រហម ក្រោយពេលរំដោះប្រទេសបានទាំងស្រុង ស្ថានភាពប្រជាជននៅភូមិភាគពាយ័ព្យ ។ អត្ថបទបន្ទាប់ គឺស្តីអំពីបញ្ហាសេដ្ឋកិច្ចបង្កបង្កើនផលនៅភូមិភាគពាយ័ព្យដែលមានខ្លឹមសារថា «...ទុនជាស្រូវសម្រាប់ចិញ្ចឹមប្រជាជន និងមានទុនឧបករណ៍ផ្សេងៗសម្រាប់ចិញ្ចឹមប្រជាជនទូទាំងប្រទេស ហើយដីក៏ល្អមិនបាច់ប្រើជី មានដីស្រួលក្នុងការគ្រប់គ្រងទឹក ។ នៅតំបន់នោះត្រូវថែមមនុស្ស៤-៥សែននាក់ទៀតទើបគ្រប់គ្រាន់...» ។ ឯកសារបន្ត គឺជាឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជាដែលនិយាយអំពីការត្រួតពិនិត្យសេដ្ឋកិច្ច និងការអនុវត្តមាគ៌ានយោបាយ ដើម្បីជម្រុញកសិកម្មឲ្យបានជាអតិបរមា ដែលមានខ្លឹមសារថា «យើងត្រូវត្រៀមខ្លួនពីកសិកម្មដើរថយក្រោយទៅកសិកម្មទំនើបនៅក្នុងសង្គមនេះឲ្យបានឆាប់រហ័ស ។ យើងត្រូវធ្វើឲ្យប្រញាប់មែនទែន ។ បន្ថែមលើនេះ យើងមានសហករណ៍ ដែលងាយស្រួលឲ្យយើងចាត់ចែងដែលមានតែកម្ម-សិទ្ធិសហករណ៍និងរដ្ឋតែប៉ុណ្ណោះ» ។ ទាក់ទងនឹងចលនាប្រជាជនក្នុងការអនុវត្តមាគ៌ារបស់បក្សបានបញ្ជាក់ថា «នៅក្នុងនេះនៅខ្វះសំភារៈ បន្តិចបដាដើម...ត្រូវបង្កើតចលនាផុសផុលដែលនៅឆ្នាំក្រោយ និងអាចបង្កើតចលនាទាំងប្រជាជនចាស់ និងថ្មីធ្វើយ៉ាងសស្រាក់សស្រាំ» ។

## ៤) ការបង្ហាញឯកសារដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានបន្តកិច្ចដំណើរការសវនាការរបស់ខ្លួន ដោយផ្តល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសបង្ហាញនូវឯកសារជាក់លាក់មួយចំនួនទាក់ទងនឹងអង្គហេតុខាងលើ ។ ជាការចាប់ផ្តើម សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានបង្ហាញឯកសារមួយចំនួនដែលជាសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅក្នុងនោះមាននិយាយរៀបរាប់អំពីមន្ទីរសន្តិសុខដែលបង្កើតបានជាធាតុផ្សំនៃរបនាសម្ព័ន្ធយោធា ។ ឯកសារទាំងនោះបានបង្ហាញព័ត៌មានអំពីមន្ទីរសន្តិសុខមួយចំនួនដូចជា គុកនៅក្នុងខេត្តសៀមរាប មន្ទីរសន្តិសុខនៅកោះកុង មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខកោះខ្សែ មន្ទីរសន្តិសុខគោកក្តួច មន្ទីរសន្តិសុខនៅភ្នំប្រុសភ្នំស្រី គុកសង់ និងមន្ទីរសន្តិសុខស-២១ ។ នៅក្នុងសេចក្តីថ្លែងការណ៍ទាំងនោះមានរៀបរាប់អំពីសកម្មភាពរបស់យោធាខ្មែរក្រហមក្នុងការចាប់ខ្លួនខ្មាំង និងប្រជាជនស្លូតត្រង់ដែលត្រូវចាត់ទុកថាជាខ្មាំងរបស់អង្គការ ។ នៅក្នុងសេចក្តីថ្លែងការណ៍ទាំងនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីស្ថានភាពរស់នៅ និងការធ្វើការងាររលត់ដំ បន្ទាប់ពីមានការចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខនីមួយៗ ។ ក្រៅពីនោះដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីស្ថានភាពនៃការចូលមកដល់ទីក្រុងភ្នំពេញដោយយោធាខ្មែរក្រហម និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសនៅក្នុងដំណាក់កាលទី២បន្តទៀត ។

បន្ទាប់មក សហមេធាវីជាតិ ពេជ អង្គ បានបន្តលើកបង្ហាញឯកសារពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥នាក់ក្នុងចំណោមពាក្យសុំជាច្រើន ដែលបញ្ជាក់អំពីព័ត៌មានជាក់លាក់នៃអង្គហេតុ ។ នៅក្នុងពាក្យបណ្តឹងទាំងនោះ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយរៀបរាប់អំពីស្ថានភាពនៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការជម្លៀសនៅដំណាក់កាលទី២ ស្ថានភាពរស់នៅ និងការបាត់បង់សមាជិកគ្រួសារដោយសារខ្វះអាហារហូបចុក និងការសម្លាប់ជាដើម ។

## ៥) ការជំទាស់លើឯកសាររបស់សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយក្រុមមេធាវីការពារក្តី

បន្ទាប់ពីបញ្ចប់ការបង្ហាញឯកសាររបស់តំណាងសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួចមក ប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្តីដើម្បីធ្វើការជំទាស់ទៅលើឯកសារទាំងនោះ ។ ក្នុងចំណោមមេធាវីទាំងបីក្រុមនោះ ក្រុមមេធាវីការពារក្តី នួន ជា ពុំបានឆ្លើយតបនឹងការបង្ហាញឯកសារទាំងនោះរបស់សហព្រះរាជអាជ្ញា

ឡើយ ដោយគ្រាន់តែបញ្ជាក់ថា ខ្លួននឹងដាក់សេចក្តីឆ្លើយតបជាលាយលក្ខណ៍អក្សរវិញជូនអង្គជំនុំជម្រះ ។ ដោយឡែកក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងជាដំបូងអំពីរបាយការណ៍របស់វេជ្ជបណ្ឌិត ដែលបញ្ជាក់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ដោយមេធាវីបានអះអាងថា ការផ្តល់របាយការណ៍បញ្ជាក់ថា អៀង សារី មានលទ្ធភាពអាចចូលរួមសវនាការនោះមិនអាចទទួលយកបានទេ ដោយសាររបាយការណ៍នោះត្រូវបានធ្វើឡើងដោយវេជ្ជបណ្ឌិតតែម្នាក់ និងពុំមានការចូលរួមពីក្រុមប្រឹក្សាវេជ្ជបណ្ឌិត ។ ទាក់ទងនឹងបញ្ហាឯកសារវិញ មេធាវីបានបង្ហាញពីជំហរក្នុងការជំទាស់នឹងឯកសារវីដេអូដែលតំណាងសហព្រះរាជអាជ្ញា បានបង្ហាញដោយអះអាងថា ព្រឹត្តិការណ៍នៅក្នុងវីដេអូនោះពុំមានភាពស៊ីសង្វាក់គ្នា ដូច្នេះខ្លួនស្នើសុំឲ្យមានការកោះហៅអ្នកផលិតនោះមកផ្តល់សក្ខីកម្ម ។ ដូចគ្នានេះដែរ ចំពោះឯកសារសេចក្តីថ្លែងការណ៍ និងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីមេធាវី ម៉ៃយើល កាណាវ៉ាស បានស្នើឲ្យអង្គជំនុំជម្រះកោះហៅដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ មកផ្តល់សក្ខីកម្មបញ្ជាក់ មុនពេលតុលាការទទួលយកឯកសារទាំងនោះ ។ ចំណែកក្រុមមេធាវីការពារក្តី ខៀវ សំផន បានគាំទ្រចំពោះការជំទាស់របស់មេធាវីការពារក្តី អៀង សារី ទាំងស្រុងចំពោះឯកសារវីដេអូដោយបញ្ជាក់ថា វីដេអូដែលសហព្រះរាជអាជ្ញាលើកឡើងនោះគឺពុំមានការបង្ហាញអំពីកាលៈទេសៈ ឬស្ថានភាពនៃព្រឹត្តិការណ៍នោះច្បាស់លាស់ឡើយ ។

បន្ទាប់ពីបញ្ចប់ការជំទាស់របស់មេធាវីទាំងបីក្រុម តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រ៉េន័រ បានឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីថា ភាពអាចទទួលយកបាននៃឯកសារ និងតម្លៃនៃភស្តុតាងគឺអង្គជំនុំជម្រះជាអ្នកសម្រេចតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតភាពស៊ីសង្វាក់គ្នានៅក្នុងខ្សែវីដេអូ ដែលខ្លួនបានបង្ហាញនោះ គឺមានតែអង្គជំនុំជម្រះទេដែលអាចពិចារណាទៅលើកាលៈទេសៈនៃព្រឹត្តិការណ៍នៅក្នុងវីដេអូនោះបាន ហើយខ្លួនគាំទ្រឲ្យមានការកោះហៅអ្នកផលិតនោះមកផ្តល់សក្ខីកម្ម ប្រសិនបើតុលាការសម្រេចធ្វើដូច្នោះ ។

សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្តី ដោយបង្ហាញពីជំហរគាំទ្រឲ្យមានការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើការបញ្ជាក់ទៅលើឯកសារ និងខ្សែវីដេអូដែលមេធាវីការពារក្តីបានជំទាស់នោះ ។ បន្ថែមលើការលើកឡើងនេះ សហមេធាវីអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានឆ្លើយតបថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល គឺពុំចាំបាច់តម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីស្បថមុនពេលធ្វើសេចក្តីថ្លែងការណ៍នោះឡើយ ហើយសក្ខីកម្មទាំងនោះអាចមានតម្លៃជាភស្តុតាងបាន ។ ម្យ៉ាងទៀតខ្លួននៅប្រកាន់ជំហរថា សេចក្តីថ្លែងការណ៍ដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី គឺជារឿងពិតនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។

ដើម្បីដោះស្រាយបញ្ហាដែលលើកឡើងដោយភាគីទាក់ទងនឹងរបាយការណ៍ស្តីពីសុខភាពរបស់ អៀង សារី និងគុណភាពនៃដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានបញ្ជាក់ថា របាយការណ៍ស្តីអំពីសុខភាព អៀង សារី ត្រូវបានកំណត់ឲ្យមានអ្នកជំនាញរាយការណ៍ជូនអង្គជំនុំជម្រះ តែក្នុងករណីសុខភាពជនជាប់ចោទប្រែប្រួលចាំបាច់តែប៉ុណ្ណោះ ។ ដូច្នេះ ពុំចាំបាច់តម្រូវឲ្យមានការរាយការណ៍អ្វីផ្សេងទៀតឡើយ ។ ចំណែកបញ្ហាមួយទៀតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីចៅក្រមបានបញ្ជាក់ថា បញ្ហានោះត្រូវបានអង្គជំនុំជម្រះដោះស្រាយរួចហើយ ដូច្នេះអង្គជំនុំជម្រះពុំលើកយកមកពិភាក្សាជាថ្មីទៀតទេ ។

### ៦) សវនាការដាក់ឯកសារទាក់ទងនឹងភស្តុតាងគន្លឹះស្តីពីតួនាទីជនជាប់ចោទ និងការជំទាស់របស់ភាគី

ថ្ងៃទី៣០-៣១ ខែមករា ដល់ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការដាក់ឯកសារទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ និងការជំទាស់នានារបស់ភាគីទៅលើឯកសារទាំងនោះ ។ ជាការចាប់ផ្តើមតំណាងសហព្រះរាជអាជ្ញា វីលៀម ស្មីត បានដាក់ឯកសារចំនួនទៀត ទាក់ទងនឹងជនជាប់ចោទ អៀង សារី គឺឯកសារពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់ អៀង សារី ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជាសមាជិកសាមញ្ញ ឯកសារពាក់ព័ន្ធនឹងតួនាទីរបស់ អៀង សារី ក្នុងនាមជាសមាជិកអចិន្ត្រៃយ៍ ឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ អៀង សារី នៅក្នុងក្រសួងការបរទេស និងឯកសារបទសម្ភាសន៍ជាមួយ អៀង សារី

ស្តីអំពីតួនាទីភ្នាមៗ និងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយរបបនោះ ។

បន្ទាប់មកព្រះរាជអាជ្ញា វីលៀម ស្មីត បានអានឯកសារលម្អិតទាក់ទងនឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាស្តីអំពីរចនាសម្ព័ន្ធ តួនាទី ការទទួលខុសត្រូវរបស់បក្ស គោលការណ៍នៃការរៀបចំសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកបក្ស, វិន័យរបស់សមាជិកបក្ស, លក្ខណៈវិនិច្ឆ័យសម្រាប់បុគ្គលិកចូលជា សមាជិក និងចំណុចផ្សេងទៀត ។ នៅក្នុងឯកសារនោះ វីលៀម ស្មីត បានអាននូវកថាខណ្ឌមួយចំនួន ដែលមានខ្លឹមសារថា “បក្សបំពាក់ និងប្រកាន់យកនូវលោកទស្សនៈអធន ត្រឹមត្រូវ និងរឹងមាំ និងតស៊ូ ដាច់ខាតនឹងលោកទស្សនៈ និងជីវៈមិនអធនប្រឆាំងបដិវត្តន៍របស់អនុធននាយទុនសក្តិភូមិ បក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់ ។ តាមគោលជំហរនេះបក្សកុម្មុយនិស្តកម្ពុជា តស៊ូប្រឆាំងដាច់ខាតនឹងគំនិតនិយម ពិសោធនិយម គម្ពីនិយម និងសេរីនិយម ។ ...បក្សកុម្មុយនិស្តយល់ច្បាស់នូវភារកិច្ចដ៏ធ្ងន់ធ្ងរក្រៃលែងរបស់ខ្លួន ។ តែជាភារកិច្ចខត្តុង្គខត្តមបំផុត ។ សមាជិកនៃបក្សយើងគ្រប់រូបត្រូវខិតខំ កសាង ពង្រឹងពង្រីកសាមគ្គីភាពឯកភាពផ្ទៃក្នុងឲ្យខ្លាំងឡើងទាំងខាងនយោបាយ ទាំងខាងសតិអារម្មណ៍ ទាំងខាងចាត់តាំងគ្រប់កាលៈទេសៈ ។ ត្រូវវាយសម្រុកជាប់លត់ដំជាប់ដុតកម្តៅជាប់ បំផុសបំផុលជាប់ វាយជម្រុញជាប់ក្នុងមហាចលនាបដិវត្តន៍ដ៏ក្តៅគគុក និងដ៏ជ្រាលជ្រៅបំផុតរបស់មហាជនកម្មករកសិករក្នុង សហជីព សហករណ៍ និងកងទ័ពបដិវត្ត ដើម្បីបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមបានសម្រេចផលល្អប្រពៃ និងឆាប់រហ័សបំផុត ហើយបន្តឈានទៅកុម្មុយនិស្តនិយមទៀតនៅលើកម្ពុជាជាទី ស្នេហាបំផុតរបស់យើង ។ តាមរយៈនោះក៏រួមវិភាគទានយ៉ាងសំខាន់ក្នុងចលនាបដិវត្តក្នុងសកលលោក” ។ សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បន្តអានមាត្រា២នៃលក្ខន្តិកៈដដែលនេះ ដែលមានខ្លឹមសារថា “ភារកិច្ចរបស់បក្សជនមានដូចតទៅ៖ ភារកិច្ចក្នុងមហាជនចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជិតស្និតក្នុងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ។ ត្រូវទទួលខុសត្រូវខ្ពស់ចំពោះមហាជន បម្រើមហាជនអស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ រាបសារនឹងមហាជន ហើយខិតខំរៀនសូត្រពីមហាជន ។ បំផុសបំផុលចលនាមហាជន ជាពិសេស គឺមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ឲ្យក្តៅគគុក និងជាប់ជានិច្ចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសដៅនៃបដិវត្តសង្គមនិយម និងការកសាងសង្គម និយម” ។

សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានបន្ថែមថា តួនាទីរបស់ អៀង សារី ក្នុងនាមជាសមាជិកគណៈកម្មាធិកាមជ្ឈិម មានចែងនៅក្នុងមាត្រា២៣ នៃលក្ខន្តិកៈបក្សដែលបានកំណត់តួនាទីដូចខាងក្រោម ៈ

១) អនុវត្តមាគ៌ានយោបាយបក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល

២) ណែនាំអង្គការភូមិភាគ តំបន់ ក្រុងទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងតាម ភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស ។

៣) គ្រប់គ្រងនិងចាត់ចែងកម្មាភិបាល និងបេក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ដោយក្តាប់ប្រវត្តិរូបជំហរនយោបាយសតិ និងចាត់តាំងខ្លួនឲ្យច្បាស់ និងឲ្យជាប់ជានិច្ចហើយចាត់តាំងអប់រំសតិអារម្មណ៍ និងចាត់តាំងឲ្យជាប់ជានិច្ច ។ តាងនាមបក្សក្នុងការទាក់ទងបណ្តាញបក្សម៉ាក្ស-ឡេនីន ជាបងប្អូន ។

បន្ទាប់មក សហព្រះរាជអាជ្ញា វីលៀម ស្មីត បានដាក់បង្ហាញឯកសារបទសម្ភាសន៍ ដែល អៀង សារី បានធ្វើជាមួយលោក ជេមស៍ ព្រីងហ្គល ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ នៅក្នុងបទសម្ភាសន៍នោះ អៀង សារី បានបញ្ជាក់ថា “មូលហេតុនៃការជម្លៀសមានពីរ ។ មូលហេតុទី១ គឺកត្តាស្បៀង យើងបានគិតថា មានប្រជាជនជិត២លាននាក់នៅទីក្រុងភ្នំពេញ ប៉ុន្តែពេលដែលយើងបានចូលមកដល់ យើងបានដឹងថាមានចំនួន ៣លាននាក់ ។ កាលពីមុនសហរដ្ឋអាមេរិកបានដឹកជញ្ជូនស្បៀងចំនួន៣០-៤០ លានតោនក្នុងមួយខែៗចូលភ្នំពេញ ។ យើងពុំ

មានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនស្បៀងចូលទៅទីក្រុង ដូច្នេះប្រជាជនត្រូវតែធ្វើដំណើរទៅកាន់ទីកន្លែងមានស្បៀង ។ ហើយយើងត្រូវតែផ្គត់ផ្គង់ស្បៀងដោយឯករាជ្យ មិនពឹងពាក់ប្រទេសដទៃ ។ មូលហេតុទី២ គឺយើងបានរកឃើញឯកសារមួយដែលនិយាយលម្អិតអំពីផែនការនយោបាយយោធាសម្ងាត់មួយរបស់ភ្នាក់ងារសម្ងាត់កណ្តាលសហរដ្ឋអាមេរិក និងរបប លន់ នល់ ដួលរលំក្នុងការធ្វើឲ្យមានការភ័ន្តច្រឡំ បន្ទាប់ពីជ័យជម្នះរបស់យើង ។ ផែនការនោះមានបីចំណុច៖ ១) ប្រសិនបើពុំអាចដោះស្រាយបញ្ហាក្រពះរបស់ប្រជាជន ពួកវានឹងបង្កបញ្ហាដោយឲ្យភ្នាក់ងារជ្រៀតចូលក្នុងចំណោមប្រជាជន ២) ទាហាន នល់ នល់ ភាគច្រើនដែលត្រូវទង់ជ័យស តាមការពិតពួកវាបានលាក់អាវុធទុក ពួកវាមានចេតនាវាយយើងក្រោយរំដោះភ្នំពេញរួច ៣) ពួកវាមានផែនការធ្វើឲ្យកងទ័ពពុករលួយ ធ្វើឲ្យស្មារតីតស៊ូពួកយើងចុះខ្សោយ ដោយយកស្រីស្រា និងមាសប្រាក់មកបំពុល» ។

តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មិត បានបង្ហាញឯកសារមួយចំនួនទៀតទាក់ទងនឹងរបាយការណ៍របស់ អៀង សារី ដែលបានរាយការណ៍អំពីជំនួយរបស់ប្រទេសស៊ុយអែត ។ សារទូរលេខផ្សេងៗទៀតដែលអាចសន្និដ្ឋានថា អៀង សារី បានដឹងពីការងារយោធា ។ សារទូរលេខជាច្រើនបានរាយការណ៍មកមន្ទីរ៨៧០ ហើយបានចម្លងជូន នួន ជា និង អៀង សារី ។ សារទូរលេខទាំងនោះ ភាគច្រើននិយាយអំពីការប៉ះទង្គិចគ្នាជាមួយវៀតណាម និងការកម្ទេចគិញនៅតាមព្រំដែន ។ សារទូរលេខរបៀបនេះ គឺមានចំនួនប្រហែល១០០ ដែលអាចសន្និដ្ឋានថា អៀង សារី គឺជាមេដឹកនាំជាន់ខ្ពស់ និងទទួលខុសត្រូវចំពោះកិច្ចការរដ្ឋ ។ ឯកសារបន្ទាប់ដែលតំណាងព្រះរាជអាជ្ញាបានដាក់ គឺជាកំណត់ហេតុបទសម្ភាសន៍ដែលជនជាប់ចោទ ខៀវ សំផន បានផ្តល់ពាក់ព័ន្ធនឹងការបាត់ខ្លួន និងការសម្រេចទៅលើការដាក់ទោស ។ នៅក្នុងបទសម្ភាសន៍នោះ ខៀវ សំផន បានបញ្ជាក់ថា ខ្លួនពុំដឹងអំពីការបោសសម្អាតបុគ្គលិកមជ្ឈិមឡើយ ។ ខៀវ សំផន បានឆ្លើយថា «សុន្ទរកថា ដែលលោកបានធ្វើនៅកូឡុំបូ គឺអៀង សារី ជាអ្នកសរសេរជូនលោក ដូច្នេះវាចង្អុលបង្ហាញពីតួនាទីរបស់ អៀង សារី ក្នុងការរៀបចំសុន្ទរកថាទាក់ទងនឹងការងារបរទេស ។

សហព្រះរាជអាជ្ញារង ក៏បានដាក់ឯកសារទាក់ទងនឹងសិទ្ធិកម្ទេចនៅក្នុង និងក្រៅជួរ ដែលមានបែងចែកពីអំណាចរបស់មជ្ឈិម និងអចិន្ត្រៃយ៍នៅក្នុងការសម្រេចថា «សិទ្ធិកម្ទេចនៅក្នុង និងក្រៅជួរ មានលក្ខខណ្ឌ ដាច់ខាតក្នុងការអនុវត្តបដិវត្តន៍របស់យើង គឺត្រូវពង្រឹងប្រជាធិបតេយ្យសង្គមនិយម និងពង្រឹងអំណាចរដ្ឋរបស់យើង ។ ប្រសិនបើនៅមូលដ្ឋានត្រូវសម្រេចដោយគណៈភូមិភាគជុំវិញមន្ទីរ ត្រូវសម្រេចដោយមជ្ឈិម តំបន់ឯករាជ្យត្រូវសម្រេចដោយអចិន្ត្រៃយ៍ ហើយកងទ័ពមជ្ឈិម ត្រូវ



ប៉ុល ពត កំពុងជួបពិភាក្សាជាមួយលោក សុន ហួរ ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លេខា សម្រេច» ។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា នៅក្នុងអត្ថបទនេះបានបង្ហាញថា គឺមានការផ្តល់អំណាចឲ្យគណៈអចិន្ត្រៃយ៍ក្នុងការកម្ទេច និងសម្លាប់ចោល ដែលពេលនោះ អៀង សារី ជាសមាជិករបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ដែរ ។

សហព្រះរាជអាជ្ញារងបានដាក់ឯកសារមួយចំនួនទៀតដូចជា៖ ទី១) ឯកសារបទសម្ភាសន៍ជាមួយ តាម៉ុក ដែលជាសមាជិកអចិន្ត្រៃយ៍ ។ នៅក្នុងឯកសារនេះ តាម៉ុក បានពន្យល់អំពីទំនាក់ទំនងអំណាចនៅក្នុងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ថា «ប៉ុល ពត ដែលខ្ញុំថា ទទួលខុសត្រូវនៅកម្ពុជា ប៉ុល ពត គឺជាបុគ្គលទី១, នួន ជា ជាបុគ្គលទី២, អៀង សារី ជាបុគ្គលទី៣, សោ ភឹម ជាបុគ្គលទី៤, ខ្ញុំ(តាម៉ុក) ជាបុគ្គលទី៥» ។ ទី២) គឺឯកសារខ្សែវីដេអូ ដែលនិយាយអំពីការប្រជុំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានវត្តមាន នួន ជា, អៀង សារី និងបុគ្គល

មួយចំនួននៅស្តាតអូឡាំពិក ។ ទី៣) គឺជាឯកសារកាលវិភាគដែលបញ្ជាក់ថា អៀង សារី បានស្ថិតនៅក្នុងប្រទេសកម្ពុជាប្រហែល៨០ភាគរយ ហើយនៅក្រៅប្រទេសប្រហែល២០ភាគរយ ។

បន្ទាប់ពីការដាក់ឯកសារភស្តុតាងទាក់ទងនឹងជនជាប់ចោទ អៀង សារី តំណាងសហព្រះរាជអាជ្ញាជាតិ វេង ហឺត់ បានចាប់ផ្តើមដាក់បង្ហាញឯកសារបន្ទាប់ពីសហភាតារបស់ខ្លួនពាក់ព័ន្ធនឹងជនជាប់ចោទ ខៀវ សំផន៖ ទី១) សមាសភាពរបស់ ខៀវ សំផន នៅក្នុងអង្គការជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាដូចជាគណៈមជ្ឈិមបក្ស និងការចូលរួមរបស់ ខៀវ សំផន នៅក្នុងអង្គប្រជុំនានារបស់គណៈអចិន្ត្រៃយ៍បក្ស ទី២) ឯកសារផ្សេងៗទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យការផ្តល់សច្ចានុម័តលើច្បាប់រដ្ឋធម្មនុញ្ញ ដែលអនុញ្ញាតឲ្យសម្តេចព្រះនរោត្តម សីហនុ លាលែងដំណែងពីប្រធានរដ្ឋ និងការបង្កើតគណៈប្រធានរដ្ឋថ្មីដែលមាន ខៀវ សំផន ជាប្រធាន ទី៣) ប្រភេទឯកសារដែលបង្ហាញអំពីការត្រួតត្រារបស់ ខៀវ សំផន នៅក្នុងក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ និងមានរបាយការណ៍ជាច្រើនរបស់ក្រសួងនេះផ្ញើទៅឲ្យ ខៀវ សំផន ទី៤) ឯកសារទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលនៅក្រសួងពាណិជ្ជកម្ម ដែលធ្វើការនៅក្នុងមន្ទីរនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន ទី៥) ឯកសារសុន្ទរកថារបស់ ខៀវ សំផន ដែលនៅក្នុងនោះមានការគាំទ្រនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ក្នុងឯកសារនេះ គឺឆ្លុះបញ្ចាំងអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងបក្ស និងនៅក្នុងរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ទី៦) លិខិតឆ្លើយឆ្លងនានារបស់អង្គការលើកលែងទោសអន្តរជាតិផ្ញើជូន ខៀវ សំផន នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លិខិតទាំងនោះនិយាយពីសំណើសុំឲ្យជួយគិតគូរ និងយកចិត្តទុកដាក់ចំពោះឧក្រិដ្ឋកម្មនានាជាទ្រង់ទ្រាយធំដែលកំពុងត្រូវបានប្រព្រឹត្តនៅប្រទេសកម្ពុជា ទី៧) បទសម្ភាសន៍ និងឯកសារចេញផ្សាយនានារបស់ ខៀវ សំផន ក្នុងនោះរួមទាំងវីដេអូជាច្រើន ដែលជនជាប់ចោទលើកមកពិភាក្សាអំពីតួនាទីរបស់ខ្លួននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងនៃរបបនេះ និងអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងក្រុមមេដឹកនាំបក្សដទៃទៀត ។ ទី៨) ចម្លើយរបស់ ខៀវ សំផន នៅចំពោះមុខចៅក្រមស៊ើបអង្កេត ដែលក្នុងនោះ ខៀវ សំផន បានលើកយកមកពិភាក្សាបន្ថែមអំពីតួនាទីរបស់គាត់ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា អាប់ឌុលហាក់ ថារីក បានដាក់ឯកសារលម្អិតដែលបញ្ជាក់ថា ខៀវ សំផន បានស្នាក់នៅទីបញ្ជាការរបស់ ប៉ុល ពត ជាមួយ នួន ជា និង អៀង សារី និងការស្នាក់នៅក្បែរថភ្លើង វិហារព្រះកែវមរកត និងនៅមាត់ទន្លេក្រោយពេលចូលទីក្រុងភ្នំពេញ ។ ខៀវ សំផន បានទទួលស្គាល់ថា ខ្លួនពិតជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ នៅឆ្នាំ១៩៧៦ ។ ឯកសារបន្ទាប់ គឺទាក់ទងនឹងសុន្ទរកថារបស់ ខៀវ សំផន និងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបស្តីអំពីការបញ្ឈប់ការប្រើប្រាស់លុយ និងហេតុផលដែលខ្លួនមិនអាចទម្លាយពីបញ្ហាទំនាស់ផ្ទៃក្នុងបក្ស ដោយសារមានគំរូរបស់ ហ៊ូ នឹម និង ហ៊ូ យន់ ស្រាប់ ។ ចំពោះឯកសារទាក់ទងនឹងការជម្លៀសប្រជាជន ខៀវ សំផន បានបង្ហាញឆន្ទៈថាខ្លួនមិនមានការគាំទ្រឲ្យមានការជម្លៀសប្រជាជនឡើយ និងបង្ហាញពីភាពអាណិតអាសូររបស់ខ្លួនក្នុងករណីជម្លៀសនេះ ។ ឯកសារបន្ទាប់ គឺជាកំណត់ហេតុប្រជុំអចិន្ត្រៃយ៍នៅឆ្នាំ១៩៧៥ ទាក់ទងនឹងការបែងចែកការងារដែលរួមមាន នួន ជា, អៀង សារី និង ខៀវ សំផន ។ នៅចុងបញ្ចប់នៃការដាក់ឯកសារនេះ សហសហព្រះរាជអាជ្ញារង បានស្នើដាក់បញ្ចាំងវីដេអូដែលនិយាយអំពីការវិលត្រឡប់មកវិញរបស់សម្តេចព្រះបាទ នរោត្តម សីហនុពីប្រទេសចិន ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានអានសេចក្តីដកស្រង់ទាក់ទងនឹងការថ្លែងសុន្ទរកថារបស់ ខៀវ សំផន ក្នុងពេលសន្និបាតដែលរៀបចំកាលពីខែកុម្ភៈ ឆ្នាំ១៩៧៥ ស្តីពីការថ្កោលទោសជនក្បត់ទាំង៧នាក់ ការថ្លែងសុន្ទរកថារបស់ ខៀវ សំផន នៅក្នុងសមាជលើកទី២ ស្តីពីនយោបាយក្នុងស្រុក និងបរទេស ។ កថាខណ្ឌផ្សេងទៀត ខៀវ សំផន បានលើកឡើងស្តីអំពីបញ្ហាវប្បធម៌ថា « មើល៍ ពួកក្បត់ លន់ នល់ ធ្វើចំពោះអ្នកដែលជាប្រជាជនរបស់ខ្លួនយ៉ាងម៉េច ។ ផ្ទះទាំងឡាយនៅទីក្រុងភ្នំពេញ

ពោរពេញទៅដោយរឿងរ៉ាវដែលមិននឹកស្មានដល់ ខ្ញុំមិនដឹងរៀបរាប់យ៉ាងដូចម្តេចទេ ដូះទាំងនេះគ្មានលក្ខណៈជាតិអ្វីទាំងអស់ ។ ហេតុដូច្នេះហើយ ទើបយើងប្រឆាំងជាដាច់ខាតនឹងវប្បធម៌បែបនេះ ពីព្រោះប្រសិនបើយើងអនុញ្ញាតឲ្យវប្បធម៌ពុករលួយប្រភេទនេះបំផ្លិចបំផ្លាញប្រទេសជាតិយើង វាប្រាកដជាធ្វើឲ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់យើងក្នុងការការពារប្រទេស ការការពារឯករាជ្យ និងអធិបតេយ្យភាពយើងជាមិនខាន» ។ ព្រះរាជអាជ្ញាក៏បានអានអត្ថបទដកស្រង់ស្តីពីការបញ្ជូនសារទូរលេខរាយការណ៍ពីសភាពការណ៍នៅតាមតំបន់នីមួយៗ និងចម្លើយសារភាពរបស់បុគ្គលមួយចំនួន ។

តំណាងសហព្រះរាជអាជ្ញាបានស្នើសុំចាក់បញ្ចាំងខ្សែវីដេអូដែលមានកាលបរិច្ឆេទនៅឆ្នាំ១៩៧៧ ។ នៅក្នុងវីដេអូនោះ មានវត្តមាន ខៀវ សំផន, នួន ជា, អៀង សារី, និងវ៉ន វ៉េត ។ ចំពោះឯកសារបន្តបន្ទាប់ សហព្រះរាជអាជ្ញាបានដាក់ឯកសារជាច្រើនទាក់ទងនឹងការថ្លែងសុន្ទរកថានានារបស់ជនជាប់ចោទ ខៀវ សំផន រួមទាំងការអប់រំកម្មាភិបាលផ្នែកនយោបាយជាដើម ។ ព្រះរាជអាជ្ញាបានបង្ហាញឯកសារ និងវីដេអូ ស្តីពីការសម្ភាសន៍ជាមួយសម្តេចព្រះបាទ នរោត្តម សីហនុ ទាក់ទងនឹងការលាលែងពីតំណែងជាប្រធានរដ្ឋរបស់ព្រះអង្គ ដែលពុំមែនលាលែងដោយព្រះទ័យរបស់ព្រះអង្គនោះឡើយ គឺដោយសារផលប្រយោជន៍របស់ប្រទេសជាតិទាំងមូល ។ តំណាងសហព្រះរាជអាជ្ញាបានដាក់បញ្ចាំងវីដេអូ និងឯកសារដែលសម្តេចព្រះបាទ នរោត្តម សីហនុ បានលើកឡើងថា ព្រះអង្គបានធ្វើដំណើរជាមួយ ខៀវ សំផន នៅខែមករា ឆ្នាំ១៩៧៦ ។ ព្រះរាជអាជ្ញាបានលើកយកអត្ថបទកាសែតបារាំងឈ្មោះ ឡឺម៉ុងដ៍ មកដកស្រង់នៅចំពោះមុខអង្គជំនុំជម្រះ ។ នៅក្នុងឯកសារនោះនិយាយថា «ទោះជាមានការទទួលស្គាល់ដោយយឺតពេលទៅហើយនូវការប្រល័យពូជសាសន៍ ខៀវ សំផន បានបញ្ចេញឲ្យដឹងគំនិតនិន្នាការផ្ទុយគ្នាចំពោះមេដឹកនាំខ្មែរក្រហមដដែល ។ ខៀវ សំផន បានរំឭកថាចំពោះខ្ញុំ ប៉ុល ពត នៅតែជាមនុស្សដែលគួរឲ្យស្រលាញ់ចូលចិត្ត ហើយខ្ញុំអាចនិយាយថា គាត់កោតសសើរខ្ញុំជាបញ្ញវន្តស្នេហាជាតិ ។ ចំពោះខ្ញុំ ប៉ុល ពត បានប្រៀបធៀបទំនាក់ទំនងរបស់យើងទៅនឹងទំនាក់ទំនងរវាង ឡេនីន និងហ្គកគី ដែលហាក់ដូចជាពួកបញ្ញវន្តមិនដែលយកជើងជាន់ដីទេ» ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តដាក់ឯកសារដែលជាសៀវភៅ និពន្ធដោយ ខៀវ សំផន មានចំណងជើងថា «ការពិចារណាពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ» ។ ការដកស្រង់របស់សហព្រះរាជអាជ្ញា បានផ្តោតទៅលើការច្រានចោលរបស់ ខៀវ សំផន ទៅលើការនូវការលើកឡើងរបស់លោក ហ្វីលីព ស្ប៉ត ថា «ភស្តុតាងដែល ហ្វីលីព ស្ប៉ត ផ្តល់អំពីចលនាខ្មែររំដោះនោះរួមជាមួយភស្តុតាងផ្សេងទៀត ព្រមទាំងការស្រាវជ្រាវ ដែលបញ្ជាក់ថា ការតាមដានទាំងនេះ ប៉ុល ពត មានគោលការណ៍៣៨៧៨ របស់ចក្រី, ឈូក, យ៉ា ហើយនឹងកម្មាភិបាលផ្សេងទៀត បានរួមជាមួយវៀតមិញ គឺជាគោលការណ៍ត្រឹមត្រូវ ។ ដូច្នេះ ហ្វីលីព ស្ប៉ត មិនត្រឹមត្រូវទេ ដែលគាត់សរសេរថា តួនាទីរបស់គុកស-២១ ហើយនិងសេចក្តីសារភាព មិនមែនសម្រាប់ផ្តល់ព័ត៌មានជាសំខាន់នោះទេ គឺសម្រាប់តែផ្តល់ភស្តុតាងនៃអំពើក្បត់ដែលត្រូវការដើម្បីចាប់អ្នកណាដែលសម្រេចចាប់ ។ គោលការនយោបាយឯករាជ្យពីវៀតណាមនោះ តម្រូវឲ្យអនុវត្តនយោបាយដាច់ខាតនៅក្នុងប្រទេស» ។ ព្រះរាជអាជ្ញាបានបន្តអាននូវការដកស្រង់បន្ថែម ដែល ខៀវ សំផន បានលើកឡើងថា «មានមតិមួយចំនួនបន្ទាប់ពីមានការចាប់ខ្លួន ឌឿន ទៅ ខ្ញុំបានឡើងធ្វើប្រធាន៨៧០ ដែលថា អង្គហេតុនេះ គឺមិនពិតទេ ។ ខ្ញុំមិនដឹងថា អ្នកណាជាអ្នកណាដែលត្រូវបានចាត់តាំងជំនួស ឌឿន ទេ នេះជាការសម្ងាត់ខ្លាំងណាស់នៅពេលនោះ ។ ទោះបីជាក្នុងអង្គភាពដដែលក៏ដោយ នៅក្នុងមន្ទីរ៨៧០ក្តី ក៏តែងតែមានការសម្ងាត់ដដែល ។ ខ្ញុំមិនចង់ដឹង ឬក៏ពុំអ្វីនោះទេ អំពីអ្វី ឌឿន បានធ្វើ ឬក៏ឌឿន ទៅណានោះទេ ។ ដូច្នេះហើយគឺគាត់មិននៅក្នុងមន្ទីរនោះញឹកញាប់នោះទេ ។ ប្រពន្ធរបស់ខ្ញុំគឺទទួលបន្ទុកនៅក្នុងបន្ទ្រានបាយ ហើយគាត់ទុកបាយឲ្យគាត់នៅលើតុ ។ ដោយសង្ខេបគឺថា ក្រោយមកគេមិនឃើញគាត់នោះទេ គឺថាយូៗទៅហាក់ដូចជាស៊ាំនឹងសភាពការណ៍នេះហើយ ។ លោក ឌឿន ទៅណាមកណាក៏មិនបានជាគិតនោះដែរ ។ ដូច្នេះ ទាំងប្រពន្ធខ្ញុំ និងខ្ញុំមិនដឹងថា គេចាប់ខ្លួនផងទេ ។

យើងគិតថា ក៏មិនបានដឹងថា អ្នកណាទទួលការងារតពីគាត់នោះដែរ» ។ ទាក់ទងនឹងសហករណ៍ តំណាងសហព្រះរាជអាជ្ញាបានលើកយកអត្ថបទសម្រង់ថា «បន្ទាប់ពីជ័យជម្នះ ឆ្នាំ១៩៧៥ រហូតមកដល់ពេលនេះ ខៀវ សំផន អាចជាប្រជាជនតែមួយគត់នៅក្នុងប្រទេសដែលមិនដឹងពីលក្ខណៈសហករណ៍នេះ ។ ភស្តុតាងឯកសារបង្ហាញផ្ទុយពីការមិនដឹងមិនឮដែលថា គោលនយោបាយផ្ទាក់លើ ដែល ខៀវ សំផន អះអាងនោះ ។ ខៀវ សំផន បានទទួលអះអាងថា គាត់គឺជាសមាជិកពេញសិទ្ធិ គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាឆ្នាំ១៩៧៦ ប៉ុន្តែមិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ ដ៏មានអំណាចទេ ។ ខៀវ សំផន និយាយថា ខ្លួនគ្រាន់តែចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ជាទ្រង់ទ្រាយធំ ប៉ុន្តែទោះជាយ៉ាងណាកំណត់ហេតុអង្គប្រជុំធ្វើឡើងក្នុងរយៈពេលពីឆ្នាំ១៩៧៥-១៩៧៦ បានកត់ត្រាវត្តមាន ខៀវ សំផន ចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចំនួន១២ដង ក្នុងចំណោម១៤ដង» ។

តំណាងសហព្រះរាជអាជ្ញា បានដាក់ឯកសារវីដេអូទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ដែលជាបទសម្ភាសន៍របស់ ខៀវ សំផន ។ នៅក្នុងអត្ថបទដកស្រង់នោះគឺ ខៀវ សំផន បានលើកឡើងថា ក្នុងឋានៈជាប្រមុខរដ្ឋខ្លួនបានដឹងអំពីការសម្លាប់រង្គាលយ៉ាងសម្បើម នៅពេលខ្លួនត្រឡប់ទៅប៉ៃលិនក្នុងឆ្នាំ១៩៩៨ ។ នៅពេលនោះ ខៀវ សំផន បានឮការនិយាយពីការកាប់សម្លាប់រង្គាលរួចទៅហើយ ក៏ប៉ុន្តែក្រោយពេលមើលខ្សែភាពយន្តរបស់ បូទី ប៉ាន់ ទើបខ្លួនបានដឹងថាមានមន្ទីរសន្តិសុខស-២១ ។ ខៀវ សំផន បញ្ជាក់ថា ខ្លួនមានការភ្ញាក់ផ្អើលនៅពេលដឹងថា មានការកាប់សម្លាប់កុមារ និងមនុស្សចាស់ និងថា ហេតុអ្វីបានជាមានការសម្លាប់ក្រោយពេលទទួលជ័យជម្នះបែបនេះ ។ ខៀវ សំផន បានបន្តទៀតថា «តើអ្នកណាជាអ្នកសម្លាប់? នេះជាសំណួរដែលខ្ញុំចង់ដឹង ។ ជាចុងក្រោយខ្ញុំមិនអាចស្រម៉ៃថា ប៉ុល ពត ជាអ្នកសម្លាប់កុមារនោះទេ ។ តើលោកឃើញប៉ុលពតសម្លាប់កុមារនៅឯណា? តើលោកឃើញប៉ុលពតធ្វើទារុណកម្មកុមារនៅឯណា? កន្លែងណា? មើលបង្ហាញខ្ញុំមើ! សូមលោកជ្រាប ខ្ញុំបាននិយាយប្រាប់លោកពីកុមារក្រីក្រកម្ពុជានៅទសវត្សរ៍ឆ្នាំ៧០ ដែលស្នើសុំចុះឈ្មោះចូលធ្វើទាហាន ហើយដោយមានការជម្រុញអំពីឪពុកម្តាយរបស់ពួកគេ ។ ហើយពួកគេបានចូលរួមក្នុងចលនារំដោះប្រទេសជាតិ ។ ពួកគេយល់ថា ត្រូវការយុត្តិធម៌សង្គម ដែលពួកគេបាត់បង់តាំងពីសម័យកាលក្រោយអង្គរមកម្ល៉េះ»...«ខ្ញុំពុំបានដឹងពីមូលហេតុដែលកុមារអាយុ១០ឆ្នាំ ចង់សម្លាប់កុមារដទៃទៀតនោះទេ ។ យើងត្រូវជីកកកាយ ។ ហេតុនេះហើយបានជាខ្លួននិយាយថា ត្រូវតែធ្វើការស្រាវជ្រាវជាច្រើនទៀត ។ ខៀវ សំផន បានរំឮកទៀតថា «លោកត្រូវយល់ថា បើគ្មាន ប៉ុល ពត បើគ្មានខ្មែរក្រហមនោះទេ ចាប់តាំងពីសម័យក្រោយរដ្ឋប្រហារឆ្នាំ៧០ នោះ កម្ពុជាធ្លាក់ក្នុងកណ្តាប់ដៃពួកកុម្មុយនិស្តវៀតណាមបាត់ទៅហើយសូមកុំភ្លេចរឿងនេះឲ្យសោះ ។ ចំពោះយើងជាជនកម្ពុជា តើធ្លាក់ក្នុងកណ្តាប់ដៃវៀតណាមមានន័យយ៉ាងម៉េច? តើមានន័យថា យ៉ាងម៉េច? មានន័យថាមិនចាំបាច់ត្រូវការពេលច្រើនទេ ដើម្បីឲ្យកម្ពុជាបច្ចុប្បន្នក្លាយជាកម្ពុជាដូចកម្ពុជាក្រោមនោះ ។ តើលោកដឹងថា ប្រជាជនប៉ុន្មានលាននាក់នៅកម្ពុជាក្រោមរស់នៅយ៉ាងម៉េចនាពេលបច្ចុប្បន្ននេះ? ខ្ញុំសូមប្រាប់លោកថា នេះគឺជាស-២១ដ៏សម្បើម ហើយកម្ពុជាក្រោមនោះ តើមែនទេ? បើប្រៀបធៀបនៅស-២១ ដ៏តូចនៅកម្ពុជានេះ តើលោកចង់បំភ្លេចស-២១ ដ៏ធំសម្បើមនៅកម្ពុជាក្រោមមែនទេ? នេះជាល្បិចកលដ៏ឈ្លាសវៃនៅក្នុងការបំភ័ន្តភ្នែកមតិពិភពលោក ការបង្ហាញអំពីកម្ពុជា បង្ហាញប៉ុល ពត ថា ជាបិសាចដើម្បីបំភ្លេចស-២១នៅកម្ពុជាក្រោម ។ ចោទ ប៉ុល ពត ថា ជាជនផ្តាច់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះ គឺមិនត្រឹមត្រូវទេ ។ មេដឹកនាំចលនាដ៏ធំបែបនេះ មិនអាចធ្វើអ៊ីចឹងបានទេ បើគាត់ធ្វើអ៊ីចឹងមែននោះ គាត់មិនអាចបង្កើតចលនាតស៊ូបែបនេះបានទេ ។ ខ្ញុំនឹងស្រែកបែបនេះនៅមុខតុលាការ» ។

បន្ទាប់ពីការដាក់ឯកសារទាក់ទងនឹងតួនាទីរបស់ជាប់ចោទដោយសហព្រះរាជអាជ្ញារួចមក អង្គជំនុំជម្រះបានផ្តល់វេទិកាជូនភាគីទាំងអស់ ដើម្បីផ្តល់យោបល់ទៅលើឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញា ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុណូហ្វត បានលើកឡើងថា យើងមិនអាចដាក់ឯកសារដោយមិនឲ្យមេធាវីជនជាប់ចោទ ឬជនជាប់ចោទប្រឈមមុខនឹងអ្នកសរសេរឯកសារទាំងនោះបានទេ ។ ក្រុមរបស់

ខ្លួននឹងដាក់ឯកសារបន្ទាប់ពីអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ហើយខ្លួនពុំមានយោបល់អ្វីទៅលើការដាក់ឯកសាររបស់សហព្រះរាជអាជ្ញានោះទេ ។ ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងថា ក្រុមរបស់ខ្លួននៅតែរក្សាគោលជំហរជំទាស់លើឯកសារមួយចំនួន ទៅតាមប្រភេទនៃឯកសារដោយមិនបញ្ជាក់អំពីឯកសារណាមួយជាក់លាក់នោះទេ ។ លោកមេធាវីក៏បានធ្វើការជំទាស់នឹងការលើកយកឯកសារកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានស្លាប់ទៅហើយ ។ អង់តា ហ្គីសេ មេធាវីការពារក្តី ខៀវ សំផន បានធ្វើអត្ថាធិប្បាយថា ជាការលំបាកនៅក្នុងការផ្តល់យោបល់លើឯកសារទាំងនោះ ដោយសារដំណាក់កាលនេះពុំទាន់ឈានដល់ការបញ្ចប់សវនាការ និងការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះទេ ។ មេធាវីក៏បានផ្តល់នូវការកត់សម្គាល់ចំនួនបីចំណុចគឺ ទី១) ឯកសារទាក់ទងនឹងព្រះបាទ នរោត្តម សីហនុ ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា អាប់-ឌុលហាក់ ថារីក ថាជាឯកសារមានសារសំខាន់នោះ គឺជាការលើកឡើងយឺតពេលទៅហើយ ដោយសារតុលាការពុំអាចចោទសួរទៅកាន់ព្រះអង្គបាននៅពេលនេះ ។ ទី២) ឯកសារទាក់ទងនឹងតួនាទីខៀវ សំផន ជាពិសេសឯកសារពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្ម គឺមានលក្ខណៈសង្ខេបពេក ពុំអាចធ្វើការកត់សម្គាល់ឲ្យស៊ីជម្រៅបាននោះទេ ។ ទី៣) នៅក្នុងដំណាក់កាលនេះ មេធាវីការពារក្តីចង់បញ្ជាក់ជូនសហមេធាវីនាំមុខដំណាងដើមបណ្តឹងរដ្ឋប្បវេណីថាឯកសារមានខ្លឹមសារសំខាន់បានលុះត្រាតែមានការប្រឈមមុខជាមួយសាក្សី ។ ដូច្នេះ រហូតដល់ពេលសាក្សីមកបង្ហាញមុខនៅចំពោះមុខអង្គសវនាការទើបយើងអាចមើលឃើញអំពីខ្លឹមសារនៃឯកសារទាំងអស់នោះបាន ។ ម្យ៉ាងទៀត មេធាវីការពារក្តី ខៀវ សំផន បានបង្ហាញជំហររបស់ខ្លួន គឺជំទាស់ទៅនឹងចម្លើយរបស់សាក្សីដែលស្លាប់ ឬក៏អវត្តមាន ។

សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តី អៀង សារី ចំនួនពីរចំណុច ។ ចំណុចទី១) ព្រះរាជអាជ្ញាបានលើកឡើងថា គោលបំណងនៃសវនាការនេះ គឺបង្ហាញពីតម្លៃភស្តុតាងនៃវត្ថុតាងទាំងអស់ដែលដាក់ជូនតុលាការពុំមែនដើម្បីលើកបញ្ហាអំពីការទទួលយកឯកសារនោះទេ ។ ឯកសារដែលព្រះរាជអាជ្ញាបានយោងតុលាការបានទទួលយករួចហើយនៅក្នុងសេចក្តីសម្រេចខែមិថុនា ឆ្នាំ២០១២ ។ ដូច្នេះ យោបល់របស់មេធាវីការពារក្តី អៀង សារី ដែលថារក្សាសិទ្ធិក្នុងការជំទាស់ចំពោះប្រភេទឯកសារមួយចំនួនអំពីភាពអាចទទួលយកបាននោះ គឺពុំអាចធ្វើទៅបានទេ ដោយសារតុលាការបានចេញសេចក្តីសម្រេចរួចហើយ ។ សហព្រះរាជអាជ្ញារង វីលៀម ស្មីត បានបន្ថែមថា ការលើកឡើងរបស់មេធាវីការពារក្តី អៀង សារី ដែលថា ការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាមិនពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ គឺជារឿងមិនត្រឹមត្រូវនោះទេ ដោយសារខ្លួនមានចេតនាគាំទ្រនូវជំហរមួយចំនួនរួមមាន៖ តួនាទីរបស់ អៀង សារី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, កម្រិតនៃអំណាចរបស់ អៀង សារី នៅក្នុងគណៈអចិន្ត្រៃយ៍, កម្រិតនៃការចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍និងក្រសួងការបរទេស, ទំហំនៃតួនាទីដែល អៀង សារី បានចូលរួម និងខ្លឹមសារនៃគោលបំណងនៃការចូលរួម និងសកម្មភាពការងាររបស់ អៀង សារី ។ ដូច្នេះ ភាគីសហព្រះរាជអាជ្ញានឹងពិនិត្យមើលតម្លៃភស្តុតាងនៃឯកសារទាំងអស់នេះ ដើម្បីបញ្ជាក់ពីសក្តានុពលនៃតួនាទី អៀង សារី គឺការពង្រឹងនូវដំណើរការចូលរួមក្នុងការកសាងសង្គមនិយម កសិករ ពលករពីដំណាក់កាលមួយឲ្យលឿនបំផុត ។ អៀង សារី ជាអ្នកការពារដំណើរការនៃការបង្កើតសង្គមនិយម ដោយការលុបបំបាត់ខ្មាំងសត្រូវខាងក្រៅ ឬក្នុងដែលពិត ឬក៏តាមការសន្និដ្ឋានរបស់បក្ស ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានធ្វើការឆ្លើយតបនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយលើកឡើងអំពីការខកចិត្តរបស់មេធាវីការពារក្តីចំពោះភាគីខ្លួន ដែលបានផ្អែកទៅលើឯកសារជាសម្ភារៈដែលចងក្រងឡើងដោយសម្តេច នរោត្តម សីហនុ ។ តំណាងសហព្រះរាជអាជ្ញាក៏បានបដិសេធចំពោះការលើកឡើងរបស់មេធាវីការពារក្តីដោយអះអាងថា ខ្លួនបានយោងទៅលើឯកសារនេះតាំងពីពេលចាប់ផ្តើម គឺខែសីហា ឆ្នាំ២០១០ បន្ទាប់ពីបញ្ចប់ការស៊ើបសួរមកម្ល៉េះ ។ ដូច្នេះ ឯកសារនេះត្រូវបានដាក់បញ្ចូល និងស្នើនៅក្នុងបញ្ជីភស្តុតាងរបស់ព្រះរាជអាជ្ញា ។

# សវនាការស្តាប់សក្ខីកម្មសាក្សី អាល់ រ៉ុក្ហូហ្វ

## ថ្ងៃទី២៨-២៩ ខែមករា ឆ្នាំ២០១៣

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបន្តសវនាការលើសំណុំរឿង០០២ ដោយកោះហៅសាក្សីមកផ្តល់សក្ខីកម្ម ខណៈពេលដែលមានតែជនជាប់ចោទ អៀង សារី ម្នាក់ប៉ុណ្ណោះបានចូលរួមក្នុងកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម ។ ចំណែកជនជាប់ចោទ នួន ជា និង ខៀវ សំផន កំពុងតែសម្រាកព្យាបាលសុខភាពនៅឯមន្ទីរពេទ្យនៅឡើយ ។ សាក្សីដែលត្រូវបានកោះហៅនោះមានរហស្សនាម TCW-565 ជាអ្នកថតរូប និងអ្នកកាសែតជនជាតិអាមេរិកកាំង ។ សក្ខីកម្មរបស់សាក្សីបានផ្តោតសំខាន់ទៅលើស្ថានភាពទូទៅក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងការសួរដេញដោលនោះ ភាគីបានសួរបញ្ជាក់អំពីរូបថតមួយចំនួន ដែលសាក្សីបានថតនៅទីតាំងផ្សេងៗ បន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ។

មុនពេលផ្តល់វេទិកាជូនភាគីផ្សេងទៀត លោកចៅក្រម និល ណុន បានសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី ព្រមទាំងបញ្ជាក់អំពីសិទ្ធិ និងករណីកិច្ចរបស់សាក្សីក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ។ បន្ទាប់មក អង្គជំនុំជម្រះបានផ្ទេរវេទិកាជូនភាគីផ្សេងទៀតតាមលំដាប់លំដោយចាប់ផ្តើមពីសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដោយ ហេតុថា ក្រុមមេធាវីការពារក្តី អៀង សារី បានបង្ហាញជំហរមិនសួរដេញដោលសាក្សីរូបនេះ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

ឆ្លើយតបនឹងសំណួរមួយចំនួនរបស់ចៅក្រម និល ណុន សាក្សីបានរៀបរាប់ថា ខ្លួនមានឈ្មោះ អាល់ រ៉ុកូហ្វ អាយុ៦៨ឆ្នាំ មានរបរជាអ្នកថតរូប ហើយសព្វថ្ងៃលោករស់នៅក្នុងរដ្ឋហ្វរីដា សហរដ្ឋអាមេរិក ។ លោកបានបន្តថា ឪពុករបស់លោកឈ្មោះ លុីស រ៉ុកូហ្វ ម្តាយឈ្មោះ ម៉ារី រ៉ុកូហ្វ និងប្រពន្ធឈ្មោះ វ៉ិចតូរៀ បូណើស ។

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

#### ២.១) ការចូលមកដល់ទីក្រុងភ្នំពេញរបស់យោធាខ្មែរក្រហម

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានចាប់ផ្តើមសួរសាក្សីទាក់ទងនឹងមុខរបរថតរូប និងស្ថានភាពទូទៅនៅទីក្រុងភ្នំពេញ នៅពេលយោធាខ្មែរក្រហមចូលមកដល់ ។ សាក្សីបានបញ្ជាក់ថា ខ្លួន គឺជាអ្នកថតរូបនៅប្រទេសអាល្លឺម៉ង់ ហើយក្រោយមកលោកបានផ្លាស់ទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៣ និងបន្តធ្វើជាអ្នកថតរូបឲ្យកាសែតរហូតដល់ឆ្នាំ១៩៧៥ ។ លោក អាល់ រ៉ុកូហ្វ បានបន្តថា នៅពេលមកដល់ប្រទេសកម្ពុជាឆ្នាំ១៩៧៣ ស្ថានភាពទម្លាក់គ្រាប់បែកនៅតែបន្តរហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ទើបយុទ្ធនាការនោះត្រូវបានបញ្ចប់ ។ នៅពេលនោះ ផ្លូវជាតិលេខ៣ ត្រូវបានបិទ ដូច្នេះ ខ្លួនបានទៅថតរូបនៅតាមទីជនបទដោយធ្វើដំណើរជាមួយពួកយោធា ។ សាក្សីបានរំឭកទៀតថា នៅពេលខ្លួនទៅដល់ខេត្តក្នុងឆ្នាំ១៩៧០ ទាហានអាមេរិកាំងបានចូលមកដល់ ហើយបានទម្លាក់គ្រាប់បេ-៥២ នៅកន្លែងទីប្រជុំជនដែលបណ្តាលឲ្យប្រជាជនស្លាប់អស់ជាច្រើននាក់ ។ លោកបានបន្តថា មានពេលមួយលោកបានធ្វើដំណើរទៅខេត្តកំពង់ឆ្នាំងជាមួយអ្នកកាសែតម្នាក់ទៀតជនជាតិកូរ៉េ ដែលបម្រើការនៅការសែត អា.អែហ្វ.ប៉េ (AFP) ។ ប៉ុន្តែពេលនោះ ខ្លួននិងមិត្តម្នាក់ទៀតបានរងរបួសដោយសារគ្រាប់បេ-៥២ ហើយត្រូវបានដឹកយកទៅព្យាបាលនៅប្រទេសវៀត-ណាម ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានអានអត្ថបទមួយដែលបានផ្សព្វផ្សាយដោយ ហ៊ុង ដែលបានកំណត់អំពីជនក្បត់ទាំង៧នាក់រួមមានលន់នល់, ឡុងបូរ៉េត, សិរីមតៈ, សឺងង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ និង សូស្ថែន ហ្វែណង់ដែស ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនពុំធ្លាប់បានទទួលដំណឹងពីការសម្លាប់នោះទេ រហូតដល់ខែមេសាឆ្នាំ១៩៧៥ ។ សាក្សីបានពន្យល់ទៀតថា នៅមុនថ្ងៃទី១៧ ខែមេសា ខ្លួនបានស្នាក់នៅម៉ុសណ្ឋាគារ ឡឺភ្នំ តាមបណ្តោយផ្លូវព្រះមុន្នីវង្ស ដោយសារទីនោះនៅជិតក្រសួងព័ត៌មាន ហើយមានការប្រជុំគ្នារវាងអ្នកកាសែតជាច្រើននាក់ ។ ក្រៅពីនោះ ក៏មានបុគ្គលិកកាកបាទក្រហមមួយក្រុមចូលទៅស្នាក់នៅទី

នោះដែរ ដោយប្រកាសថា កន្លែងនោះជាកន្លែងសុវត្ថិភាព និង មានគ្រូពេទ្យគ្រប់គ្រាន់ ។

## ២.២) ការបញ្ជាក់អំពីព័ត៌មានលម្អិតលើរូបថតដែលថតដោយសាក្សី

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញឯកសាររូបថត ដែលនិយាយអំពីកាកបាទក្រហមមកឲ្យសាក្សីពិនិត្យ ។ សាក្សីបានរៀបរាប់ថា រូបថតនោះត្រូវបានថតនៅ អូតែលឡឺរ៉ូយ៉ាល់ ដែលមានដាក់បដាកាកបាទក្រហម ។ សាក្សីបានបន្តថា នៅពេលយប់ថ្ងៃទី១៦ ខែមេសា ខ្លួនបានស្នាក់នៅជិតការិយាល័យប្រៃសណីយ៍ជាមួយ ស៊ីដនី សាន់ប៊ឺជ ដែលជាអ្នកកាសែតញូវយ៉កថែមស៍ និង ចន ស្វេន ដើម្បីបញ្ជូនឯកសារចេញទៅក្រៅ ខណៈពេលដែលម៉ាស៊ីនបញ្ជូនឯកសារនោះនៅអាចដំណើរការ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងស្ថានភាពទម្លាក់គ្រាប់បែកវិញ សាក្សីបានរៀបរាប់ថា នៅយប់នោះ មានការបាញ់កាំភ្លើងធំនៅផ្លូវមុនីវង្ស និងនៅស្ពានជ្រោយចង្វារ លុះដល់ម៉ោង៨ព្រឹក ទើបខ្លួនបានត្រឡប់មកសណ្ឋាគារវិញ ។ ប៉ុន្តែនៅពេលនោះ មានរថក្រោះពាសដែកជាច្រើនបានមកដល់សណ្ឋាគារ ដោយមានយោធាប្រកាសថា “...សង្គ្រាមបានបញ្ចប់ហើយ!” ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានចំណាយពេលពី២-៣ម៉ោងដើម្បីធ្វើដំណើរចូលមកក្នុងទីក្រុងជាមួយយោធា ហើយនៅពេលនោះខ្លួនបានថតរូបកាំភ្លើងដែលដាក់ជាគំនរ និងទាហានដែលកំពុងធ្វើដំណើរទៅស្តាតអូឡាំពិកថែមទៀត ។ នៅទីនោះ ខ្លួនបានឈរនៅក្បែរយោធាម្នាក់ដែលកំពុងនិយាយភាសាបារាំងទៅកាន់ លោក រ៉ូឡង់ ណឺវ៉ឺ ហើយលោក រ៉ូឡង់ ណឺវ៉ឺ បានឆ្លើយប្រាប់យោធានោះថា ខ្លួនគាត់ គឺជាអ្នកកាសែត ។ ចំណែករូបលោក បានព្យាយាមគេចពីខ្មែរក្រហមទាំងនោះ ដោយសារខ្លួនមិនចង់ឲ្យខ្មែរក្រហមសួរនាំច្រើន ហើយក៏បានធ្វើដំណើរត្រឡប់ទៅសណ្ឋាគារវិញ ទើបបានជួបជាមួយ ឌិត ប្រាន ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសាររូបថតមួយសន្លឹកទៀតដើម្បីឲ្យសាក្សីបញ្ជាក់ពីអាយុរបស់យោធាម្នាក់ ដែលនៅក្នុងរូបថតនោះ ប៉ុន្តែសំណើនោះត្រូវបានមេធាវី វ៉ិចទ័រ កូប៉េ ជំទាស់ភ្លាមៗ ។ ប៉ុន្តែទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យសាក្សីធ្វើការបញ្ជាក់នៅលើចំណុចនេះ ។ សាក្សី បានបញ្ជាក់ថា យោធានោះមានអាយុប្រហែល១៦ឆ្នាំ មានស្ពាយជំពុះទង់ និងកាំភ្លើងអឹមសិដូចទាហាន លន់ នល់ ដែរ ។ ក្រៅពីនោះ យោធាខ្មែរក្រហមបានប្រើអាវុធប្រភេទអាកា៤៧, កាំភ្លើង អឹមសិ, គ្រាប់បេ-៤០ និងរថពាសដែក បន្ទាប់ពីដណ្តើមបានទីក្រុងនៅពេលព្រឹក ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាក៏បានបង្ហាញរូបថតមួយទៀត ដែលថតដោយលោក រ៉ូឡង់ ណឺវ៉ឺ ។ នៅក្នុងរូបនោះ គឺមានទាហានលីកាំភ្លើង“សេរិនធីណាញ” ដើម្បីឲ្យសាក្សីបញ្ជាក់ថា តើទាហាននោះជាទាហាន លន់ នល់ ឬក៏ជាយោធាខ្មែរក្រហម? សាក្សីបានបញ្ជាក់ថា ការបែងចែកប្រភេទទ័ពទាំងនោះ គឺមានការភាន់ច្រឡំគ្នា ប៉ុន្តែ ទាហាន លន់ នល់ អាចឲ្យលោកសំគាល់បានដោយសារទាហានទាំងនោះ ពុំមានពាក់ស្បែកជើងកង់ឡានបែបហូជីមិញ ។ ចំណែកយោធាខ្មែរក្រហមវិញ គឺមានពាក់ស្បែកជើងកង់ឡាន និងប្រើវិទ្យុទាក់ទងម៉ាក “ម៉ូតូរ៉ូឡា” ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបង្ហាញរូបថតមួយទៀតរបស់លោក រ៉ូឡង់ ណឺវ៉ឺ ដែលថតនៅខាងត្បូងផ្លូវព្រះមុន្នីវង្ស ហើយសាក្សីគ្រាន់តែបញ្ជាក់ថា ទិដ្ឋភាពនៅពេលនោះមិនមានការបណ្តេញប្រជាជនចេញនៅឡើយទេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងលោក ចនស្វេន វិញ សាក្សីបានបញ្ជាក់ថា លោក ចន ស្វេន គឺជាអ្នកសរសេរសៀវភៅមួយរូប ហើយនៅរសៀលថ្ងៃទី ១៧មេសា លោកបានឃើញលោក ចន ស្វេន កំពុងកត់ត្រាអំពីស្ថានភាពដែលបានកើតឡើងនោះ យ៉ាងច្រើន ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានអាននូវការដកស្រង់មួយចេញពីសៀវភៅដែលមានចំណងជើងថា “River of Time” ដែលនៅក្នុងផ្នែកដកស្រង់នោះនិយាយអំពីការដួលរលំនៃទីក្រុងភ្នំពេញ ការដកហូតអាវុធរបស់ទាហាន លន់ នល់ និងការបណ្តេញទាហានទាំងនោះចេញពីទីក្រុងភ្នំពេញ ។ លោក អាល់ រ៉ុក្កូហ្វ បានបញ្ជាក់ថា នៅពេលនោះខ្លួនពុំបានដឹងព័ត៌មានទាក់ទងនឹងបញ្ហានេះទេ ប៉ុន្តែលោកគ្រាន់តែបានឃើញខ្មែរក្រហមបណ្តើរទាហានលន់នល់ ចេញទៅទិសខាងលិចខណៈ ពេលដែលខ្លួនកំពុងពួននៅក្បែររថយន្តមួយតែប៉ុណ្ណោះ ។

រូបថតបន្ទាប់ដែលត្រូវបានដាក់បង្ហាញឲ្យសាក្សីបញ្ជាក់ គឺ

ជារូបថតរបស់ទាហានដែលសាក្សីបានថតនៅត្រង់កែងផ្លូវព្រះមុន្នីវង្ស និងផ្លូវព្រះសីហនុ វេលាជិតថ្ងៃត្រង់ ។ ចំណែករូបថតទីពីរគឺជារូបទាហានដែលថតពីខាងក្រោយ ប៉ុន្តែសាក្សីបានបញ្ជាក់ថាខ្លួនមិនចាំទីតាំងរូបថតនោះឡើយ ដោយគ្រាន់តែពន្យល់ថា រូបទាំងនោះគឺបានបង្ហាញអំពីទាហាន លន់ នល់ ដែលត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនបញ្ជូនទៅ ប៉ុន្តែលោកពុំបានដឹងអំពីទិសដៅនៃការបញ្ជូននោះច្បាស់លាស់នោះទេ ខណៈពេលដែលប្រជាជនកំពុងតែចាកចេញពីទីក្រុង ដោយសារភ័យខ្លាចការទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិក ។

## ២.៣) ស្ថានភាពនៅមន្ទីរពេទ្យព្រះកេតុមាលា

សាក្សីបានរៀបរាប់ថា ក្នុងស្ថានភាពច្របូកច្របល់នោះខ្លួនបានចូលទៅមន្ទីរពេទ្យព្រះកេតុមាលា ជាមួយ ឌិត ប្រេន និង ចន ស្វេន ប៉ុន្តែខ្លួនបានចូលទៅទីនោះតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ នៅពេលទៅដល់មន្ទីរពេទ្យ លោកបានឃើញស្នាមប្រឡាក់ឈាម សាកសព និងអ្នកជំងឺជាច្រើននាក់ ។ អ្នកជំងឺនៅទីនោះមានការភ័យខ្លាចជាខ្លាំង ហើយប្រហែលជា៥នាទីក្រោយមកខ្មែរក្រហមប្រហែល៦-៧នាក់បានចូលទៅដល់មន្ទីរពេទ្យ និងបណ្តេញក្រុមរបស់ខ្លួន(សាក្សី) ឲ្យចាកចេញដោយភ្ជង់កាំភ្លើងចាប់ដាក់រថពាសដែក និងដឹកយកទៅដាក់នៅក្រសួងព័ត៌មាន ។ សាក្សីបានបន្តថានៅពេលចាប់ខ្លួននោះ ឌិត ប្រេន បានប្រាប់មិនឲ្យខ្លួន និង ចន ស្វេន និយាយអ្វីទាំងអស់ ហើយក៏ចេញដំណើរទៅដល់ទីនោះ ។

## ២.៤) ស្ថានភាពក្នុងអំឡុងពេលជម្លៀសប្រជាជន និងវាសនាទាហាន លន់ នល់

តំណាងសហព្រះរាជអាជ្ញា ខេល លីសាក់ បានបន្តដាក់បង្ហាញឯកសារដែលនិយាយអំពីការធ្វើដំណើររបស់សាក្សីទៅជាមួយទាហាន លន់ នល់ បន្ទាប់ពីខ្មែរក្រហមបានចាប់ខ្លួនទៅដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានរៀបរាប់ថា នៅពេលខ្មែរក្រហមចាប់បញ្ជូនលោកទៅក្រសួងព័ត៌មាន លោកបានឃើញយោធាខ្មែរក្រហមចាប់ខ្លួនទាហាន លន់ នល់ ចំនួនពីរនាក់ ដោយដកយកប័ណ្ណ និងលិខិតផ្សេងៗពីទាហានទាំងនោះទៀតផង ។ តំណាងសហព្រះរាជអាជ្ញា ខេល លីសាក់ បានបន្តសួរដេញដោលទាក់ទងនឹងការប្រើកម្លាំងរបស់ខ្មែរក្រហមទៅលើប្រជាជននៅពេលជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ទាក់ទងនឹងបញ្ហានេះសាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនពុំបានឃើញខ្មែរក្រហមប្រើកម្លាំងទៅលើប្រជាជនដោយផ្ទាល់ភ្នែកឡើយ ប៉ុន្តែខ្លួនបានឮដំណឹងនេះតាមរយៈជនជាតិបារាំងស្គាល់បីនាក់ដែលបានភៀសខ្លួនចេញពីទីក្រុងភ្នំពេញ ហើយបានត្រឡប់មកស្នាក់នៅក្នុងស្ថានទូតបារាំងវិញ ។ អ្នកទាំងបីបានប្រាប់លោកថា នៅតាមផ្លូវពិតជាមានការសម្លាប់ប្រជាជនពិតមែន ។ សាក្សីបានបន្ថែមថា ទាក់ទងនឹងការចាប់ខ្លួនមន្ត្រីរដ្ឋការនៅក្នុងរបប លន់ នល់ វិញ គឺលោកបានឃើញដោយខ្មែរក្រហមចាប់ខ្លួន ឡុង បូរ៉េត និងគ្រួសារចេញទៅបន្ទាប់ពីមានការចរចាគ្នារួច ។ ខណៈពេលនោះដែរលោកបានព្យាយាមយកកាមេរ៉ាមកថតយករូបភាពនៃការចាប់ខ្លួននោះ ប៉ុន្តែត្រូវខ្មែរក្រហមឆក់យកកាមេរ៉ាពីដៃ និងចាប់បញ្ជូនទៅស្ថានទូតបារាំងដែរ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានដាក់បញ្ចាំងខ្សែវីដេអូមួយ ដែលនិយាយអំពីស្ថានភាពចលាចលនៅពេលទាហានខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំ-ពេញ ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សី អាល់ រ៉ុកហ្វ បានរៀបរាប់ថាខ្សែវីដេអូនោះបានបង្ហាញពីទិដ្ឋភាពនៅក្នុងក្រសួងព័ត៌មាន ដែលមានទាំងយោធាខ្មែរក្រហម និងទាហាន លន់ នល់ ប៉ុន្តែក្រោយមកទាហានទាំងនោះត្រូវបានយោធាខ្មែរក្រហមដឹកបញ្ជូនចេញពីក្រសួងទាំងគ្រួសារ ។ ក្រោយមក លោកបានទទួលដំណឹងថា អ្នកទាំងនោះត្រូវបានយកទៅសម្លាប់នៅខាងក្រោយស្ថានទូតបារាំង ។ តំណាងសហព្រះរាជអាជ្ញាបាន អានអត្ថបទសារព័ត៌មានមួយដែលបានចុះផ្សាយនៅក្នុងកាសែតបាងកកប៉ុស្តិ៍ ។ អត្ថបទនេះ ចុះផ្សាយអំពីសម្តីរបស់ អៀង សារី ដែលនិយាយថា "ឡុង បូរេត និង លន់ ណុន ត្រូវបានសម្លាប់" បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានសួរថា តើសាក្សីធ្លាប់បានដឹងអំពីព័ត៌មានទាក់ទងនឹងការស្លាប់របស់អ្នកទាំងពីរនោះដែរឬទេ ។ សាក្សីបានបញ្ជាក់ថា ចំពោះសំណួរនេះខ្លួនពុំអាចឆ្លើយបានទេ ដោយសារខ្លួនពុំបានដឹងព័ត៌មាននេះច្បាស់លាស់ ហើយខ្លួនបានទទួលព័ត៌មាននេះនៅពេលក្រោយមកទៀតតែប៉ុណ្ណោះ ។ សាក្សីបានបន្តរៀបរាប់ថា នៅពេលចាកចេញពីក្រសួងព័ត៌មានវិញ ខ្លួនបានត្រឡប់ទៅសណ្ឋាគារឡឺរ៉ូយ៉ាល់

ហើយក៏បានជួបនឹងក្មេងម្នាក់ ។ ខ្លួនបានឲ្យនំទៅក្មេងនោះបរិភោគ ហើយក្រោយមកបានត្រឡប់ទៅស្ថានទូតបារាំងវិញដោយយកក្មេងនោះទៅជាមួយដែរ ។ នៅពេលធ្វើដំណើរទៅនោះ ខ្លួនបានឯកសារវីដេអូមួយទៀត ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានរៀបរាប់ថា ទិដ្ឋភាពនៅក្នុងខ្សែវីដេអូនោះ គឺបង្ហាញពីសកម្មភាពនៅក្នុងស្ថានទូតបារាំង ដែលមានការចរចាគ្នារវាងខ្មែរក្រហម



**ទិដ្ឋភាពនៃការចូលមកដល់ទីក្រុងភ្នំពេញនៃយោធាខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។**
**(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)**

ឃើញខ្មែរក្រហមកាន់កាំភ្លើង និងដើរនៅលើផ្លូវម្ខាង ចំណែកប្រជាជនបានដើរនៅលើផ្លូវម្ខាងទៀត ។ លុះទៅដល់ស្ថានទូតបារាំង ខ្លួនបានឃើញប្រជាជនជាច្រើននាក់ នាំគ្នាឡើងផ្លោះរបងចូលទៅក្នុងស្ថានទូត ហើយក៏បានថតរូបភាពនៅពេលនោះដែរ ។

ទាក់ទងនឹងការជម្លៀសប្រជាជនវិញ សាក្សីបានបញ្ជាក់ថា នៅពេលនោះលោកបានឃើញមនុស្ស ជាច្រើននាក់ធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ ដោយពុំមានផ្តល់ម្ហូបអាហារអ៊ីដល់ប្រជាជនទាំងនោះឡើយ ។ ចំណែកក្រុមកាកបាទក្រហមវិញក៏ត្រូវបានចាប់បញ្ជូនចេញពីសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ទៅកាន់ស្ថានទូតបារាំងដែរ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញនិងបុគ្គលិកនៅក្នុងស្ថានទូត ប៉ុន្តែខ្លួនពុំបានដឹងថា ការចរចានោះមានខ្លឹមសារយ៉ាងណាទេ ។ ប៉ុន្តែក្រោយមក លោកបានទទួលដំណឹងថា មានទាហាន លន់ នល់ ប្រមាណ៣០០នាក់ត្រូវបានខ្មែរក្រហមបញ្ជូនចេញពីស្ថានទូតដើម្បីយកទៅសម្លាប់ចោលរួមទាំងជនជាតិភាគតិចមួយចំនួននៅទីនោះដែរ ។

### ៣) ការសួរដេញដោលសាក្សីដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វូត បានចាប់ផ្តើមដោយសួរបញ្ជាក់ឡើងវិញអំពីការធ្វើដំណើររបស់សាក្សីទៅតំបន់រំដោះផ្សេងៗក្នុងអំឡុងឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៥ ។

សាក្សីបានបញ្ជាក់ថា នៅពេលនោះលោកបានចុះទៅដល់ខេត្តកំពង់ឆ្នាំង និងទៅអង្គរវត្តក្នុងខេត្តសៀមរាប ។

ចំណែកនៅកន្លែងផ្សេងៗទៀត លោកពុំបានទៅដល់ទេ ដោយសារផ្លូវមួយចំនួនត្រូវបានខ្មែរក្រហមកាត់ផ្ដាច់ ។ ឆ្លើយតបនឹងសំណួរបន្ទាប់អំពីស្ថានភាពនៅពេលជម្លៀសប្រជាជនចេញពីមន្ទីរពេទ្យ សាក្សីបានពន្យល់ថា អ្នកជំងឺនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ត្រូវខ្មែរក្រហមជម្លៀសចេញទាំងអស់មិនថាអ្នក ជំងឺនោះឈឺធ្ងន់ឬស្រាល ចាស់ឬក្មេង ។ សហមេធាវីអន្តរជាតិបានបន្តសំណួរទាក់ទងនឹងការផ្សព្វផ្សាយវិទ្យុអំពីការជម្លៀសប្រជាជន ប៉ុន្តែសាក្សីបានបញ្ជាក់ថា នៅពេលដែលខ្មែរក្រហមចូលមកដល់ភ្នំពេញ លោកពុំបានដឹងថា វិទ្យុខ្មែរក្រហមបានផ្សព្វផ្សាយដែរឬក៏អត់នោះទេ ប៉ុន្តែខ្លួនបានអានប្រតិចារិកព័ត៌របស់បណ្ដាញព័ត៌មាន ប៊ី.ប៊ី.ស៊ី (BBC) ស្ដីអំពីការវាយយកទីក្រុងភ្នំពេញនៅក្នុងស្ថានទូតបារាំង ប៉ុន្តែក្រោយមក ខ្មែរក្រហមដឹងថា ក្នុងស្ថានទូតមានការទទួលព័ត៌មានមកពីក្រៅប្រទេស យោធាទាំងនោះក៏ បានចូលទៅចាប់ និងបំផ្លាញឧបករណ៍ទាក់ទងព័ត៌មាននោះតែម្ដង ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់សហមេធាវីអន្តរជាតិពាក់ព័ន្ធនឹងការជម្លៀសក្រុមអ្នកកាសែតចេញពីទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា ខ្លួនពុំមានចម្លើយច្បាស់លាស់នោះទេ ដោយពន្យល់ថា នៅពេលនោះមានយន្តហោះរបស់ចិនបានមកចតនៅព្រលានយន្តហោះពោធិ៍ចិនតុង អមដំណើរដោយកម្មាភិបាលខ្មែរក្រហម និងមន្ត្រីនៅស្ថានទូតបារាំងបានមកជួបក្រុមអ្នកកាសែតនៅក្នុងស្ថានទូត ។ នៅពេលនោះ មានអ្នកកាសែតម្នាក់បានមកសួរខ្លួនថា តើយន្តហោះនោះនឹងមកទទួលក្រុមខ្លួនឬយ៉ាងណា ប៉ុន្តែមានបុគ្គលម្នាក់នៅក្នុងចំណោមគណៈប្រតិភូទាំងនោះបានបញ្ជាក់ថា ក្រុមខ្លួននឹងត្រូវជម្លៀសចេញដែរ ប៉ុន្តែត្រូវជម្លៀសទៅតាមផ្លូវគោកវិញ ។

## ៨) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ

លោកចៅក្រម ឡាវ៉ែញ បានបន្តសួរសាក្សីទាក់ទងនឹងទីតាំងនៃក្រសួងព័ត៌មាន ហើយសាក្សីបានបញ្ជាក់ថា នៅពេលជម្លៀសខ្លួនពុំដឹងពីស្ថានភាពនៅកន្លែងផ្សេងទៀតទេ ប៉ុន្តែនៅមុំស្ពានជ្រោយចង្វារវិញ មានការជម្លៀសប្រជាជនចេញទៅកន្លែងផ្សេងៗ ។ នៅពេលនោះ ប្រជាជនហាក់មានការព្រួយបារម្ភ និងមានទុក្ខសោកជាខ្លាំង ។ ឆ្លើយតបនឹងសំណួរបន្ទាប់ដែលទាក់ទងនឹងក្រុមចលនាជាតិនិយមដែលបានបន្ទំខ្លួននៅពេលជម្លៀសនោះ សាក្សីរៀបរាប់ថា នៅពេលព្រឹក ខ្លួនបានទៅជួប ឌិត ប្រន នៅក្នុងក្រសួងព័ត៌មានស្រាប់តែមានមនុស្សមួយចំនួនបានបន្ទំខ្លួនដោយស្លៀកពាក់ស្អាតបាតជាងយោធាខ្មែរក្រហម ហើយបានបញ្ជាឲ្យខ្លួនចូលទៅក្នុងក្រសួង ។ លោកបានបន្តថា ក្រុមនោះពិតជាខុសពីក្រុមយោធាខ្មែរក្រហមដែលចាប់ខ្លួនលោកនៅឯមន្ទីរពេទ្យព្រះកេតុមាលា ។

បន្ទាប់មក ចៅក្រម ឡាវ៉ែញ បានចាក់បញ្ចាំងខ្សែវីដេអូបង្ហាញអំពីសកម្មភាពក្រុមមនុស្សដែលបន្ទំខ្លួននៅក្នុងក្រសួងព័ត៌មានដើម្បីឲ្យសាក្សីបញ្ជាក់ ។ បន្ទាប់មក ចៅក្រម ឡាវ៉ែញ បានបង្ហាញរូបថតរបស់ សាឡុត ឆាយ ដើម្បីឲ្យសាក្សីអំពីអត្តសញ្ញាណ ។ សាក្សីបានបញ្ជាក់ថា លោកបានជួបបុគ្គលម្នាក់ឈ្មោះ សាឡុត ឆាយ នៅឯក្រសួងឃោសនា ហើយ សាឡុត ឆាយ បានប្រាប់លោកថា ខ្លួន (សាឡុត ឆាយ) មានបងធ្វើការធំនៅទីក្រុងភ្នំពេញ ប៉ុន្តែបុគ្គលនោះពុំបានបញ្ជាក់ថា បងរបស់ខ្លួន ជា សាឡុត ស ឬជានរណាផ្សេងនោះឡើយ ។ បន្ទាប់មក ចៅក្រម ឡាវ៉ែញ បានបន្តសួរទាក់ទងនឹងការបំបែកគ្រួសារនៅពេលជម្លៀសប្រជាជន ។ ទាក់ទងនឹងករណីនេះ សាក្សី អាល់ រ៉ុក្កូហ្វ បានរៀបរាប់ថា នៅក្នុងស្ថានទូតបារាំង លោកបានឃើញប្ដីប្រពន្ធមួយគូរដែលមានប្រពន្ធជាជនជាតិបារាំង និងប្ដីជាជនជាតិខ្មែរត្រូវបានខ្មែរក្រហមបំបែកអ្នកទាំងពីរ ដោយឲ្យប្រពន្ធជាជនជាតិបារាំងចូលទៅក្នុងស្ថានទូតបារាំង ដើម្បីចាកចេញទៅប្រទេសកំណើតវិញ ។ ចំណែកប្ដីជាជនជាតិខ្មែរមិនត្រូវបានអនុញ្ញាតឲ្យទៅជាមួយឡើយ ។ ប៉ុន្តែប្រហែលជា១៥នាទីក្រោយមក ខ្មែរ-ក្រហមក៏បានអនុញ្ញាតឲ្យបុរសជាប្ដីនោះត្រឡប់ទៅស្ថានទូតបារាំងវិញ ប៉ុន្តែបុរសនោះបានចាកចេញពីស្ថានទូតបាត់ទៅហើយ ។

លោកចៅក្រមបានបង្ហាញរូបថតមួយចំនួនដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឲ្យសាក្សីបញ្ជាក់ ។ រូបទីមួយ សាក្សីបានបញ្ជាក់ថា គឺជារូបដែលខ្លួនបានថតពីការជម្លៀសនៅស្ថានទូតអាមេរិក ហើយខ្លួនពេញចិត្តនឹងរូបនេះជាខ្លាំង ។ រូបថតនោះ គឺជារូបដែលមានឧទ្ធម្ភាគចក្រចុងក្រោយ បង្ហូសមកដឹកទាហានជើងទឹកនៅស្ថានទូតអាមេរិកត្រឡប់ទៅវិញ ។ ចំណែក

រូបបន្ទាប់ គឺជារូបដែលបង្ហាញអំពីសកម្មភាពក្មេងៗជួយប្រមូលកាំភ្លើងដាក់ជាគំនរដែលដកហូតបានពីទាហាន លន់ នល់ ។ សាក្សីបានបញ្ជាក់ថា ក្មេងៗទាំងនោះ គឺជាអ្នកដែលរស់នៅភ្នំពេញ ប៉ុន្តែពុំមានផ្ទះសម្បែងពិតប្រាកដទេ គឺពួកគេគ្រាន់តែជួយប្រមូលកាំភ្លើងតែប៉ុណ្ណោះ ។ ចំណែករូបថតបន្ទាប់ គឺជារូបដែលថតបាននៅឯស្ពានទូតបារាំង ព្រមទាំងមានឡានក្រុមកាកបាទក្រហមដែលបានជម្លៀសចេញពីសណ្ឋាគារឡឺរ៉ូយ៉ាល់ដែរ ។ សាក្សីបានបញ្ជាក់ថា រូបឡាននោះពិតជាឡានរបស់កាកបាទក្រហមដែលអស់សាំងបន្ទាប់ពីបរចេញពីសណ្ឋាគារឡឺរ៉ូយ៉ាល់ ។ នៅក្នុងរូបថតដដែលនោះ មានរូបប្រជាជនជាច្រើនបានឡើងតាមរបងនៃស្ពានទូតបារាំងដើម្បីលាក់ខ្លួន ។ រូបថតចុងក្រោយ សាក្សីបានបញ្ជាក់ថា ជារូបថតសាកសពទាហាន លន់ នល់ ដែលត្រូវបានគេបាញ់ចំក្បាលក្នុងពេលមានការច្បាំងគ្នារវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហម មុនពេលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញប្រហែលមួយខែទៅពីរខែ ។ ទាក់ទងនឹងស្ថានភាពរស់នៅរបស់ប្រជាជនដែលភៀសខ្លួនមកទីក្រុងភ្នំពេញមុនថ្ងៃ១៧មេសាវិញ សាក្សី បានបញ្ជាក់ថា នៅមុនថ្ងៃទី១៧ ខែមេសា មានជំរំជនភៀសខ្លួនមួយចំនួននៅជាយទីក្រុងភ្នំពេញ ។ ចំណែកនៅក្នុងទីក្រុងវិញក៏មានជំរំជនភៀសខ្លួនមួយដែលគ្រប់គ្រងដោយអង្គការវើលវីសិន (World Vision) ដែលមានទីតាំងនៅសណ្ឋាគារកាំបូឌីយ៉ាណា មានចំនួនជនភៀសខ្លួនចាប់ពី២១,០០០ទៅ២៣,០០០នាក់ ។ ចៅក្រម ឡាវើញ បានបន្តសួរទាក់ទងនឹងការបណ្តេញឥស្សរៈជនធំៗចេញពីស្ថានទូតបារាំង ។ សាក្សី បានរៀបរាប់ថា នៅពេលនោះមានការជម្លៀសខ្លួនឥស្សរៈជនជាច្រើននាក់រួមទាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែរ ។ ជាចុងក្រោយ ចៅក្រម ឡាវើញ បានបង្ហាញរូបថតពីរសន្លឹក ដើម្បីឲ្យសាក្សីបញ្ជាក់បន្តទៀត ។ សាក្សីបានរៀបរាប់ថា រូបទី១ ថតនៅឆ្នាំ១៩៧៣ ដែលនៅក្នុងនោះ មានរូបទាហានស្ពាយកាំភ្លើង អឹមសិ និងពាក់មួកផ្កា ។ ចំណែករូបទីពីរ គឺជារូបទាហាន លន់ នល់ ម្នាក់ស្ពាយកាំភ្លើងដែលថតនៅឆ្នាំ១៩៧៤ ។

## ៥) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ

## ៥.១) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តសួរទាក់ទងនឹងការទម្លាក់គ្រាប់បេ-៥២ នៅឆ្នាំ១៩៧៣, ស្ថានភាពទូទៅនៅក្នុងទីក្រុងភ្នំពេញនៅពេលមានការទម្លាក់គ្រាប់បែក សាក្សីបញ្ជាក់ថាខ្លួនមិនមានបទពិសោធន៍ក្នុងស្ថានភាពទម្លាក់គ្រាប់បែកនៅពេលនោះទេ ប៉ុន្តែប្រជាជនដែលរស់នៅទីក្រុងភ្នំពេញបានរងរបួសជាច្រើននាក់ ហើយខ្លួនបានឃើញតែទិដ្ឋភាពដែលកើតឡើងរួចហើយតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត លោកពុំធ្លាប់បានសម្ភាសន៍ជនភៀសខ្លួនពីការទម្លាក់គ្រាប់បែកនៅពេលនោះទេ ហើយរហូតមកដល់ពេលនេះលោកបានបន្សល់ទុកនូវ ហ្វីល ដែលមិនទាន់បានផ្តិតជាច្រើនដុំ ហើយហ្វីលទាំងនោះមានខូចគុណភាពមួយចំនួនដែរ ។ ចំណែកប្រជាជនផ្សេងៗទៀតបានរស់នៅពាសពេញសួនច្បារនិងទីដែលមានដើមឈើ ។ បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរឲ្យសាក្សីប្រៀបធៀបរវាងទិដ្ឋភាពនៅឆ្នាំ១៩៧០-១៩៧៣ និងពីឆ្នាំ១៩៧៣-១៩៧៥ ។ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧០ទីក្រុងភ្នំពេញមានទេសភាពស្រស់ស្អាត ហើយពុំមានជនភៀសខ្លួនឡើយ ។ ប៉ុន្តែ នៅឆ្នាំ១៩៧៣ សង្គ្រាមបានចាប់ផ្តើម និងមានជនភៀសខ្លួនចូលមកទីក្រុងភ្នំពេញជាច្រើននាក់ ។ ដូច្នេះតម្លៃទំនិញនៅក្នុងទីក្រុងកាន់តែឡើងថ្លៃ ហើយមានប្រជាជនខ្លះបានចូលទៅលួចអង្ករនៅតាមឃ្លាំងដើម្បីយកមកចិញ្ចឹមជីវិត ។ រហូតមកដល់ឆ្នាំ១៩៧៥ ស្ថានភាពកាន់តែតឹងតែងឡើង ដោយសារខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យចេញពីទីក្រុងដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ បន្ទាប់មកមេធាវីអន្តរជាតិបានបន្តសួរអំពីការជួបគ្នារវាងសាក្សី និងយោធាខ្មែរក្រហម ។ សាក្សីបានបញ្ជាក់ថា លោកពិតជាបានដើរជាមួយយោធាខ្មែរក្រហមនៅមុំស្តាតអូឡាំពិច ប៉ុន្តែលោកពុំបាននិយាយអ្វីច្រើនទេ ដោយសារលោកមិនអាចនិយាយភាសាខ្មែរបានច្រើន ។ សាក្សីបានធ្វើការកត់សម្គាល់ថា យោធាខ្មែរក្រហមបានធ្វើដំណើរមកពីតំបន់ផ្សេងៗគ្នា ។ យោធាខ្លះមានស្ពាយកាំភ្លើងអឹមសិ ហើយយោធាខ្លះទៀតកាន់កាំភ្លើងអាកា និងស្លៀកពាក់ឯកសណ្ឋានផ្សេងៗគ្នា ។ ក្រៅពីនោះទៀត យោធាដែលចូលមកពីទិសខាងត្បូងហាក់ដូចជា មានវិន័យតឹងរឹងជាងយោធាផ្សេងៗទៀត ។ មេធាវីអន្តរជាតិបានបន្ត

សួរទាក់ទងនឹងបុគ្គលម្នាក់ឈ្មោះ ដាកក្លេស សាបភឺ (Douglas Sapper) ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានរៀបរាប់ថា បុគ្គលនោះ គឺជាទាហានជើងអាកាសរបស់អាមេរិកដែលខ្លួនបានជួបនៅឯស្ថានទូតបារាំង ។ ឆ្លើយតបនឹងសំណួរបន្ទាប់ពាក់ព័ន្ធនឹងខ្សែភាពយន្តដែលមានចំណងជើងថា “វាលពិឃាដ” វិញ សាក្សីបានបញ្ជាក់ថាខ្សែភាពយន្តនោះខ្លួនបានចូលរួមចំណែកផ្តល់ព័ត៌មានខ្លះៗដែរ ដោយសារតែកុននោះបាននិយាយរៀបរាប់អំពីសោកនាដកម្មនៅប្រទេសកម្ពុជា ។

សហមេធាវីជាតិ សុន អរុណ បានបន្តសួរទាក់ទងនឹងតួនាទីរបស់សាក្សីថាតើសាក្សី គឺជាអ្នកថតរូបឯកជនឬយ៉ាងណា ។ សាក្សីបានបញ្ជាក់ថា ខ្លួនជាអ្នកថតរូបឯករាជ្យ ដោយមិនបម្រើការងារឲ្យក្រុមហ៊ុនណាមួយឡើយ ។ លោកបានបន្តថា លោកបានមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៥ពេលដែលខ្មែរក្រហមចូលមកដល់ភ្នំពេញទើបត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ។ សំណួរចុងក្រោយ មេធាវី សុន អរុណ បានសួរឲ្យសាក្សីពន្យល់អំពីក្រុមយោធាខ្មែរក្រហមដែលមានពីរក្រុមផ្សេងគ្នា ។ សាក្សីបានរៀបរាប់ថា នៅពេលខ្មែរក្រហមចូលមកដល់ភ្នំពេញមានយោធាមួយក្រុមបានក្លែងបន្លំធ្វើជាយោធាខ្មែរក្រហម ប៉ុន្តែយោធាទាំងនោះស្លៀកពាក់ឯកសណ្ឋានស្អាតបាតខុសប្លែកពីយោធាខ្មែរក្រហមពិតប្រាកដ ហើយមានចំនួនតិចជាងយោធាខ្មែរក្រហម ។ លោកបានបន្តថា លោកពុំបានដឹងច្បាស់ថាក្រុមនោះចូលមកភ្នំពេញដំណាលគ្នានឹងយោធាខ្មែរក្រហម ឬអត់នោះទេ ប៉ុន្តែលោកគ្រាន់តែដឹងច្បាស់ថា អ្នកទាំងនោះបានចូលទៅក្រសួងព័ត៌មាន ហើយប្រកាសថា ប្រសិនបើទាហានខាងណាដណ្តើមបានជ័យជំនះបរទេសនឹងផ្តល់ជំនួយឲ្យជាមិនខាន ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយមេធាវីការពារក្តី នួន ជា ចៅក្រម និល ណុន បានផ្ទេរវេទិការជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយសារមេធាវីការពារក្តី អៀង សារី បានបញ្ជាក់ពីជំហរមិនសួរដេញដោលសាក្សីរូបនេះទេ ។

### ៥.២) ក្រុមមេធាវីការពារក្តី ខៀវ សំផន

ជាការចាប់ផ្តើម សហមេធាវីអន្តរជាតិ អង់គា ហ្គីសសេ បានសួរសំណួរដើម្បីឲ្យសាក្សីបញ្ជាក់ឡើងវិញអំពីតួនាទីរបស់ខ្លួន ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា លោកជាទាហានអាមេរិកដែលទទួលបន្ទុកខាងថតរូប បន្ទាប់ពីលោកបានទៅរៀនថតរូបនៅប្រទេសអាល្លឺម៉ង់ ។ សាក្សីបានបន្តថា ខ្លួនបានចូលធ្វើទាហានតាំងពីអាយុ១៧ឆ្នាំមកម៉្លេះ ។ សាក្សីបានបន្តថា នៅពេលខ្លួនបានមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៧៣-១៩៧៥ ខ្លួនបានរួមដំណើរជាមួយទាហាន លន់ នល់ ដោយចុះទៅដល់មូលដ្ឋានសមរភូមិប្រយុទ្ធ និងនៅតាមមន្ទីរពេទ្យដើម្បីទៅថតយករូបភាពទាហានទាំងនោះ ។ មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងកងទ័ពអាកាសរបស់ លន់ នល់ ថា តើការទម្លាក់គ្រាប់បែកនៅឆ្នាំ១៩៧៣នោះមានការចូលរួមពីកងអាកាសរបស់ លន់ នល់ ដែរឬទេ? ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា នៅពេលនោះទាហាន លន់ នល់ មិនទាន់មានលទ្ធភាពប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកនៅឡើយទេ ។ ម្យ៉ាងទៀត ការទម្លាក់គ្រាប់បែកនៅជំនាន់នោះ គឺមានតែយន្តហោះម៉ាកសេ-៤៧ និងស-១២៣របស់អាមេរិកតែប៉ុណ្ណោះ ។ បន្ទាប់មកមេធាវីអន្តរជាតិបានលើកយករូបថត មានរូបស្ត្រីម្នាក់កំពុងតែយំនៅជិតសាកសពរបស់ប្តី ដែលចៅក្រមឡាវើញ បានលើកបង្ហាញម្តងរួចមកហើយ ។ សាក្សីបានបញ្ជាក់ជាថ្មីម្តងទៀតថា រូបថតនោះ ជារូបទាហាន លន់ នល់ ហើយត្រូវបានថតនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់មកមេធាវីអន្តរជាតិបានសួរទាក់ទងនឹងបញ្ហាអនាម័យនៅពេលមានកំណើនជនភៀសខ្លួននៅទីក្រុងភ្នំពេញ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលដែលមានជនភៀសខ្លួនកើនឡើងកាន់តែច្រើននោះ បញ្ហាអនាម័យកាន់តែអាក្រក់ទៅៗនៅចន្លោះឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ។ មេធាវីអន្តរជាតិបានសួរបន្តថា តើសាក្សីបាននិយាយអ្វីខ្លះនៅពេលខ្លួនធ្វើដំណើរទៅដល់ប្រទេសថៃ និងពេលស្នាក់នៅក្នុងស្ថានទូតអាមេរិកនៅទីនោះ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនមិនបាននិយាយច្រើនជាមួយអ្នកនៅទីនោះអំពីស្ថានភាពក្នុងប្រទេសកម្ពុជាឡើយ ។ ជាចុងបញ្ចប់សហមេធាវីអន្តរជាតិបានសួរបញ្ជាក់ឡើងវិញនូវសំណួរ ដែលសួរដេញដោលដោយសហព្រះរាជអាជ្ញាទាក់ទងនឹងការទទួលបានព័ត៌មាននៅក្នុងស្ថានទូតបារាំង ដើម្បីឲ្យសាក្សីធ្វើការបញ្ជាក់សារជាថ្មី ។

សវនាការស្តាប់សក្ខីកម្មរបស់សាក្សី អាល់ រ៉ូកូហ្វ បានបញ្ចប់នៅរសៀលថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ។

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ

## ថ្ងៃទី៧ ខែកុម្ភៈ ២០១៣

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-116 ខណៈពេលដែលជនជាប់ចោទ នួន ជា និង ខៀវ សំផន កំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងបានបោះបង់សិទ្ធិក្នុងការចូលរួមសវនាការ ។ ចំណែកជនជាប់ចោទ អៀង សារី ក៏ជួបប្រទះនឹងបញ្ហា



ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ

សុខភាពដែរ ដោយពុំអាចចូលរួមសវនាការដោយផ្ទាល់បាន ប៉ុន្តែអាចចូលរួមពីចម្ងាយនៅក្នុងបន្ទប់ដែលមានបំពាក់ដោយឧបករណ៍សោតទស្សន៍ ។ សវនាការបានប្រព្រឹត្តទៅដោយមានប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន បានចាប់ផ្តើមសួរដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងប្រវត្តិសាវតា ព្រមទាំងបញ្ជាក់អំពីសិទ្ធិក្នុងការថ្លែងទុក្ខសោកដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លងកាត់ ។ បន្ទាប់មក វេទិកាត្រូវបានផ្ទេរជាបន្តបន្ទាប់ជូនសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី, សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ កើតនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៤ មានស្រុកកំណើត នៅក្នុងស្រុកខត្តុង ខេត្ត កំពង់ស្ពឺ ។ សព្វថ្ងៃ លោកជាវិស្វករចូលនិវត្តន៍ រស់នៅក្នុងប្រទេសបារាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ ឆោ ម្តាយឈ្មោះ ស៊ីវ លន និងប្រពន្ធឈ្មោះ ម៉ាលីកា និងមានកូនប្រុសបីនាក់ ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានបញ្ជាក់ ប្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី និងការធ្វើសេចក្តីថ្លែងអំពីទុក្ខសោកដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ លោក ពិន យ៉ាថៃ ជាវិស្វករសាធារណៈការនៅក្រសួងសាធារណៈការ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់បន្តថា លោកបានទទួលសញ្ញាបត្រវិស្វករនៅឆ្នាំ១៩៦៥ នៅសាលាបច្ចេកទេសមួយក្នុងទីក្រុងម៉ុងរេអាល់ ប្រទេសកាណាដា ។

ភ្លាមៗនៅថ្ងៃទី១៧ ខែមេសា ១៩៧៥ លោក ពិន យ៉ាថៃ បានបញ្ជាក់ថា លោក និងក្រុមគ្រួសារបានចាកចេញពីផ្ទះនៅពីម្តុំទឹកល្អក់ដែលលោកបានរស់នៅជាមួយឪពុកម្តាយក្មេក ដើម្បីមកស្នាក់នៅម្តុំផ្សារស៊ីឡឹបជាមួយបងប្អូនជីដូនមួយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលដែលលោកបានមកដល់ផ្សារស៊ីឡឹប លោកបានទទួលដំណឹងថា ប្រជាជននៅក្នុងទីក្រុងទាំងអស់ត្រូវឲ្យចាកចេញពីទីក្រុង ដូច្នេះលោកក៏បានចាកចេញពីផ្សារស៊ីឡឹប ដើម្បីទៅស្នាក់នៅវត្តខណ្ឌលោមវិញ ដោយសារនៅទីនោះមានព្រះសង្ឃរាជ ហួត តាត ដែលជាឪពុកមារ ។ លោកបានបន្តទៀតថា ខណៈពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា នោះ មានការចរចារវាងមន្ត្រីជាន់ខ្ពស់នៃរបប លន់ នល់ ជាមួយខ្មែរក្រហមដែរ ប៉ុន្តែការចចារនោះពុំទទួលបានលទ្ធផលល្អសោះឡើយ ។ បន្ទាប់ពីស្នាក់នៅក្នុងវត្តបានមួយ

យប់ ខ្លួន និងក្រុមគ្រួសារបានធ្វើដំណើរតាមផ្លូវមុន្នីវង្សទៅដល់ស្រុកកោះធំ និងបានស្នាក់នៅកន្លែងមួយឈ្មោះថា ឈើខ្មៅ ។ លោកបានបន្តទៀតថា បន្ទាប់ពីបានស្នាក់នៅទីនោះអស់រយៈពេលបីខែមក ខ្មែរក្រហមបានប្រកាសថា "មានអ្នកណាចង់ទៅស្រុកកំណើតទេ? ស្រុកកំណើតអ្នកណានៅខេត្តកំពត និងនៅកំពង់ស្ពឺអាចចេញដំណើរបាន" ។ នៅពេលឮដូច្នោះ លោក និងក្រុមគ្រួសារដែលមានសមាជិក១៨នាក់ក៏បានលើកដៃ ដោយសារមានស្រុកកំណើតនៅក្នុងខេត្តកំពង់ស្ពឺ ។ ផ្ទុយទៅវិញ ខ្មែរក្រហមពុំបានដឹកប្រជាជនទាំងនោះទៅតាមទិសដៅ ដែលបានរំពឹងទុកនោះទេ ដោយសារផែនការរបស់អង្គការ គឺដឹកអ្នកទាំងនោះទៅដាក់នៅខេត្តតាកែវ ។ នៅពេលទៅដល់ខេត្តតាកែវ លោកបានស្នាក់នៅក្នុងស្រុកស្រម៉ូលាវ ។ លោកបានបន្តទៀតថា បន្ទាប់ពីស្នាក់នៅទីនោះបាន២សប្តាហ៍ លោក និងគ្រួសារក៏ដូចជាប្រជាជនផ្សេងទៀតត្រូវបានអង្គការបញ្ជូនឲ្យទៅនៅបាត់ដំបងវិញ ។ ការធ្វើដំណើរនៅពេលនោះ គឺត្រូវជិះរថយន្តដូចពេលជម្លៀសមុនៗដែរ ហើយនៅក្នុងរថយន្តនីមួយៗ មានគ្នាប្រហែលមួយរយនាក់ ។ ទាក់ទងនឹងការធ្វើដំណើរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ស្ថានភាពនៅលើរថយន្តមានការលំបាក ដោយសារការធ្វើដំណើរនោះបាន បន្តរហូតពុំមានពេលសម្រាកឡើយ ដូច្នេះមានប្រជាជនខ្លះបានបន្ទោរបង់នៅលើរថយន្តនោះទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ថា នៅពេលធ្វើដំណើរមកដល់ខេត្តពោធិ៍សាត់ រថយន្តទាំងនោះបានបត់ចុះពីលើផ្លូវជាតិលេខ៥ សំដៅទៅកាន់ស្រុកភ្នំក្រវាញ ។ បន្ទាប់មក រថយន្តនោះបានបន្តរហូតទៅដល់ឃុំលាច និងឡើងទៅដល់ភូមិវាលវង់ ទើបខ្មែរក្រហមអនុញ្ញាតិឲ្យប្រជាជនចុះ ហើយស្នាក់នៅទីនោះតែម្តង ។ វាលវង់គឺជាតំបន់នៅតាមជើងភ្នំ ហើយពុំមានផ្ទះសម្បែងអ្វីឡើយ ដូច្នេះប្រជាជននាំគ្នាធ្វើខ្ទមដើម្បីស្នាក់នៅរៀងៗខ្លួន ។ ដោយសារនៅទីនោះពុំមានអាហារហូបចុកគ្រប់គ្រាន់ គ្មានថ្នាំព្យាបាល និងមានការកាប់សម្លាប់មួយរយៈក្រោយមក ប្រជាជនច្រើននាក់បានស្លាប់ និងបាត់ខ្លួនជាបន្តបន្ទាប់រួមទាំងសមាជិកគ្រួសាររបស់លោកចំនួន៤នាក់ដែរ ។

## ២) ការសួរដេញដោលដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺលោក ពេជ អង្គ បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ខ្លួនបានផ្ទេរសិទ្ធិឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឹម ម៉េងឃី និងសហមេធាវីអន្តរជាតិ គ្រីស៊ីន ម៉ាទីណូ ជាអ្នកសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

### ២.១) ការសួរដេញដោលដោយសហមេធាវីជាតិ

សហមេធាវីជាតិ គឹម ម៉េងឃី បានចាប់ផ្តើមសួរដោយឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឡើង វិញអំពីតួនាទីរបស់ខ្លួននៅក្នុងរបប លន់ នល់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះខ្លួនមានតួនាទីជាវិស្វករនៅក្រសួងសាធារណៈការ, ជានាយករងនៃក្រសួងសម្ភារៈ, ជាចៅក្រសួង សម្ភារៈ និងការងារថ្មីដែលនៅទីនោះមានបុគ្គលិកជាវិស្វករ និងអ្នកបច្ចេកទេសចំនួន១០០០នាក់ ។ បន្ទាប់មក សហមេធាវីជាតិបានបន្តសួរទាក់ទងនឹងស្ថានភាពប៉ះទង្គិចគ្នារវាងខ្មែរក្រហម និងទាហាន លន់ នល់ ។ លោក ពិន យ៉ាថៃ បានបញ្ជាក់ថា ទាក់ទងនឹងបញ្ហានេះ លោកគ្រាន់តែបានឮព័ត៌មានតាមរយៈវិទ្យុតែប៉ុណ្ណោះ ដោយលោកពុំដែលឃើញព្រឹត្តិការណ៍នោះផ្ទាល់ភ្នែកឡើយរហូតដល់ពេលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ នៅពេលនោះ លោកបានទទួលដំណឹងថា នាយករដ្ឋមន្ត្រីទី១ ឡុង បូរ៉េត បានទៅជួបចរចារជាមួយខ្មែរក្រហមនៅឯប្រទេសថៃ ហើយជាលទ្ធផលបានបញ្ជាក់ថា សង្គ្រាមនឹងត្រូវបញ្ចប់នៅពេលឆាប់ៗ ។

ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងការចូលមកដល់នៃយោធាខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា យោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញតាមផ្លូវមុន្នីវង្សដោយមានទឹកមុខធម្មតា ចំណែកប្រជាជនវិញបាននាំគ្នាទះដៃអបអរសាទរទទួលកងទ័ពទាំងនោះដោយនឹកស្មានថា ប្រទេសជាតិនឹងទទួលបានសន្តិភាពពិតប្រាកដជាមិនខាន ។ បន្ទាប់មក នៅថ្ងៃ១៨ មេសា ខ្លួន និងក្រុមគ្រួសារក៏បានចាកចេញពីវត្តខណ្ឌលោមដោយសារខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនចេញពីទីក្រុងក្នុងរយៈពេលបីថ្ងៃដើម្បីសំអាតទីក្រុង និងគេចចេញពីការទម្លាក់

គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ សាក្សីបានបញ្ជាក់ថា ហេតុផលនេះធ្វើឲ្យលោកពុំសូវមានជំនឿទេ ដោយសារតែទាហានរបស់អាមេរិកបានចាកចេញពីប្រទេសកម្ពុជាតាំងពីថ្ងៃទី២ ខែមេសា មកម្ល៉េះ ។ បើទោះបីជាយ៉ាងណា លោកបានចាកចេញពីទីក្រុងដោយធ្វើដំណើរតាមបណ្តោយផ្លូវមុនីវង្សឆ្ពោះទៅកាន់ស្រុកកោះធំ ។ នៅតាមដងផ្លូវ លោកបានធ្វើដំណើរជាមួយប្រជាជនដែលជម្លៀសមានចំនួនច្រើនណែនណាន់តាន់តាប់ ហើយលោកក៏បានធ្វើដំណើរអស់រយៈពេលបីថ្ងៃទើបទៅដល់ស្ពានមុន្នីវង្ស និងឆ្លងទៅនៅកន្លែងមួយឈ្មោះឈើខ្មៅ ស្ថិតក្នុងស្រុកកោះធំ ។ នៅទីនោះ ប្រជាជនទាំងអស់ត្រូវបានខ្មែរក្រហមសួរនាំអំពីឈ្មោះ អាយុ និងមុខរបរ ព្រមទាំងដកហូតយកលិខិតស្នាមផ្សេងៗទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលនោះ លោកបានយកឡានមួយ និងម៉ូតូពីរគ្រឿងទៅជាមួយ ប៉ុន្តែខ្មែរក្រហមបានដកយកឡាន និងសរសេរលិខិតឲ្យមួយច្បាប់ដើម្បីឲ្យខ្លួនមកយកពេលត្រឡប់មកវិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ថា ស្ថានភាពនៅពេលនោះមានការលំបាកជាខ្លាំង ហើយខ្លួនបានឃើញស្ត្រីពីរនាក់ចងកសម្លាប់ខ្លួន ដោយសារអ្នកទាំងពីរពុំអាចទ្រាំនឹងការលំបាកបាន ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីការជម្លៀសជាបន្តបន្ទាប់ ដូចដែលបានឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះនៅផ្នែកខាងលើដែរ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីជាតិទាក់ទងនឹងស្ថានភាពរស់នៅក្នុងភូមិវាលវង់វិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅទីនោះប្រជាជនត្រូវធ្វើខ្ទមសម្រាប់ជ្រកកោនរៀងៗខ្លួន ។ ចំណែករបបអាហារវិញ អង្គការបានយកអង្ករមកចែកឲ្យតែបន្តិចបន្តួចប៉ុណ្ណោះ ម្ល៉ោះហើយប្រជាជនទាំងអស់ត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកខ្លះដើម្បីទៅរកត្រី និងអាហារនៅក្នុងព្រៃដែលជាហេតុធ្វើឲ្យប្រជាជនជាច្រើននាក់បានពុលអាហារស្លាប់ទៀតផង ។ លោកបានបន្ថែមថា គ្រួសាររបស់លោកបានរួចជីវិត ដោយសារតែគ្រួសារលោកមានរបស់របរខ្លះដែលអាចដោះដូរនឹងអង្ករជាមួយខ្មែរក្រហមបាន ។ សាក្សីបានបន្ថែមថា អំពើទាំងនេះបានបង្ហាញឲ្យឃើញពីចេតនារបស់ខ្មែរក្រហមដែលចង់ឲ្យប្រជាជនស្លាប់ដោយការយកប្រជាជនទៅរស់នៅកន្លែងពិបាក ។ ជាងនេះទៅទៀត អំពើពុករលួយរបស់ខ្មែរក្រហម គឺជាមូលហេតុដែលធ្វើឲ្យអ្នកមានអាចរស់រានមានជីវិត ចំណែកប្រជាជនដែលក្រីក្របានស្លាប់បាត់បង់ជីវិតអស់ជាច្រើននាក់ ។

## ២.១) ការសួរដេញដោលដោយសហមេធាវីអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសួររបស់សហមេធាវីជាតិ សហមេធាវីអន្តរជាតិ គ្រីស៊ីន ម៉ាទីណូ បានបន្តការសួរថា តើអ្នកណាជាអ្នកគ្រប់គ្រងនៅក្នុងភូមិឈើខ្មៅ? ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះអ្នកគ្រប់គ្រង គឺមានតែកម្មាភិបាលខ្មែរក្រហមតែប៉ុណ្ណោះ ពុំមានប្រជាជនមកពីទីក្រុងភ្នំពេញណាម្នាក់អាចធ្វើជាអ្នកគ្រប់គ្រងបានឡើយ ។ ក្រោយពេលដែលប្រជាជនថ្មីបានទៅរស់នៅទីនោះ មេភូមិបានរៀបចំឲ្យមានការប្រជុំដើម្បីណែនាំប្រជាជនថ្មីខិតខំធ្វើការឲ្យបានល្អនៅក្នុងសង្គម ។ បន្ទាប់មក សហមេធាវីអន្តរជាតិបានបន្តសួរថា តើដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានជួបជាមួយមេដឹកនាំធំៗនៅរបបខ្មែរក្រហមដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានបញ្ជាក់ថា នៅពេលដែលខ្លួនត្រូវបានជម្លៀសទៅកាន់ខេត្តតាកែវ ខ្លួនបានឃើញកម្មាភិបាលខ្មែរក្រហមថ្នាក់ខេត្តដែរ ប៉ុន្តែលោកពុំស្គាល់ឈ្មោះរបស់កម្មាភិបាលទាំងនោះទេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ដែល និយាយអំពីការបង្ក្រាប ការប្រើហឹង្សា និងការសម្លាប់នៅភូមិវាលវង់ សាក្សី ពិន យ៉ាថៃ បានរៀបរាប់ថា បន្ទាប់ពីរស់នៅទីនោះបានមួយរយៈ ខ្មែរក្រហមបានបន្ថយរបបអង្ករដែលជាហេតុធ្វើឲ្យប្រជាជនកាន់តែមានការលំបាក ។ ថ្ងៃមួយ អង្គការពុំមានអង្ករបើកឲ្យប្រជាជនរយៈពេល២ថ្ងៃ ស្រាប់តែមានគ្រូបង្រៀន៩នាក់ និងប្រជាជន ប្រហែល២០០នាក់ទៀតបាននាំគ្នាមកសួរប្រធានភូមិថា «*តើនៅពេលណាទើបអាចបើកអង្ករបាន?*» ។ នៅពេលនោះ ប្រធានភូមិក៏បានប្រាប់ថា «*មិត្ត! មិត្តឯងអប់រំរាប់ខែមកហើយ ម៉េចក៏មិនចោលរបបតវ៉ាហ្នឹង ។ តាមពិតអង្គការមានបញ្ហាក្នុងការដឹកនាំយឺត ពេលតែពីរថ្ងៃ មិត្តឯងមិនសប្បាយចិត្ត ។ មិត្តធ្វើនេះ គឺថាមិនមែនជាអ្នកបដិវត្តន៍ទេ ដែលគេខំអប់រំយូរហើយ មិត្តមិនមែនជាអ្នកបដិវត្តន៍ទេ ។ មិត្ត ធ្វើឲ្យខូចសណ្តាប់ធ្នាប់ប្រជាពលរដ្ឋនៅវាលវង់ ។ ដូច្នេះ សូមមិត្តអត់បន្តិចទៅមួយថ្ងៃពីរថ្ងៃ អង្ករនឹងមកដល់ហើយ*» ។ ប្រហែលពីរសប្តាហ៍ក្រោយ

ពេលដែលខ្មែរក្រហមយកអង្ករមកចែកឲ្យប្រជាជន ស្រាប់តែគ្រូបង្រៀនទាំង៩នាក់បានបាត់ខ្លួនជារៀងរហូត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីព្រឹត្តិការណ៍មួយទៀតថា នៅពេលប្រជាជនមកពីភូមិភាគនិរតីចូលមក មានពាក្យចចាមអារ៉ាមមួយនិយាយថា សម្តេច សីហនុ បានយាងត្រឡប់មកប្រទេសកម្ពុជាវិញ ហើយទ្រង់នឹងបង្កើតរដ្ឋាភិបាលថ្មីដើម្បីដឹកនាំប្រទេស ។ នៅពេលនោះ មេភូមិបានប្រកាសជ្រើសរើសអ្នកបច្ចេកទេសចំនួន៤០នាក់ ដើម្បីទៅធ្វើការ ហើយអ្នកទាំងនោះ ត្រូវបានខ្មែរក្រហមដឹកយកទៅបាត់រហូតមិនដែលឃើញត្រឡប់មកវិញឡើយ ។ ព្រឹត្តិការណ៍មួយទៀតបានកើតឡើងនៅខែមករា ឆ្នាំ១៩៧៦ គឺខ្មែរក្រហមបានជ្រើសរើសប្រជាជនឲ្យទៅនៅភូមិដូនអី ខេត្តពោធិ៍សាត់ ដែលនៅពេលនោះ គ្រួសារខ្លួនក៏បានស្នើសុំទៅជាមួយដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅទីនោះមានប្រជាជនស្លាប់អស់ជាច្រើននាក់ ដោយសារតែមានជំងឺរាគរូស ។ សំណួរបន្ទាប់របស់មេធាវីជាតិបានផ្តោតទៅលើរឿងរ៉ាវដែលទាក់ទងនឹងកូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សូដាត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលកូនប្រុសរបស់លោកមានអាយុ ១០ឆ្នាំ ហើយមានជំងឺហើមជើង ពុំអាចទៅធ្វើការងារបាន ។ ដូច្នេះហើយ សូដាត មានការភ័យខ្លាច និងតែងតែរត់ទៅពួននៅពេលឃើញកម្មាភិបាលខ្មែរក្រហមម្តងៗ ។ ដោយឃើញស្ថានភាពដូច្នេះ កម្មាភិបាលខ្មែរក្រហមបានមកហៅឲ្យកូនរបស់ខ្លួនទៅធ្វើការវិញដោយអះអាងថា “បើកូននោះឈឺជើង ហេតុអ្វីក៏រត់លឿនម្ល៉េះ?” ដោយភាពភ័យខ្លាច លោកក៏បានបញ្ជូនឲ្យកូនទៅធ្វើការវិញ ប៉ុន្តែបីថ្ងៃក្រោយមកលោកបានទទួលដំណឹងថា សូដាត បានស្លាប់បាត់ទៅហើយ ។ សំណួរចុងក្រោយ សហមេធាវីអន្តរជាតិបានសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អំពីគោលដៅរបស់ខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា តាមរយៈការឆ្លងកាត់នៅក្នុងរបបនោះផ្ទាល់ លោកយល់ឃើញថា គោលដៅសំខាន់ៗរបស់ខ្មែរក្រហមមានពីរគឺ៖ ទី១) គោលដៅក្នុងការជម្លៀសនៅដំណាក់កាលទី១ គឺការលុបបំបាត់របបចាស់តាមរយៈការលុបបំបាត់មិនឲ្យចាយលុយ ហើយអ្វីៗត្រូវបាត់បង់ទាំងអស់ ។ ទី២) គោលដៅសាងសង់គ្រឹះសង្គមថ្មីដែលគ្មានវណ្ណៈ ហើយបំបាត់អ្នកទន់ខ្សោយដែលពុំមានសុខភាពល្អ ហើយបន្ទាប់មកលុបបំបាត់អ្នកដែលបាក់ស្មារតីជាបន្តទៅទៀត ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

នៅពេលចាប់ផ្តើម តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វ៉ែន័រ បានអានសៀវភៅដែលសរសេរដោយដើមបណ្តឹងរដ្ឋប្បវេណីមានចំណងជើងថា “ជីវិតកូនថ្លៃកូនត្រូវតែរស់” ដោយលើកឡើងនូវចំនុចសំខាន់ៗមួយចំនួនដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឡើងវិញ ។ សំណួរទាំងនោះគឺទាក់ទងនឹងស្ថានភាពជម្លៀស, ស្ថានភាពរស់នៅក្នុងភូមិវាលវង់, ការស្លាប់របស់ប្រជាជនដោយសារពុំមានអាហារបរិភោគ និងការស្លាប់សមាជិកក្រុមគ្រួសារដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ជូនអង្គជំនុំជម្រះពីខាងលើ ។ ជាចុងក្រោយ តំណាងសហព្រះរាជអាជ្ញាបានអានឈ្មោះសមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបាត់បង់ជីវិតមានដូចជា៖

១ - សម្តេចសង្ឃរាជ ហួត តាត (ឪពុកមារ)
២ - ពិន សូដាត (កូន)
៣ - ពិន ដារ៉ាត់ (កូន)
៤ - ពិន ភូរិន្ទ (កូន)
៥ - ពិន ខេមអានី (ប្រពន្ធ)
៦ - លាន ឆោ (ឪពុក)
៧ - លាន លន (ម្តាយ)
៨ - លាន ថេង និងប្រពន្ធឈ្មោះ ឡៅ ព្រមទាំងកូនពីរនាក់ (ប្អូន)
៩ - លាន កេង និងប្តីឈ្មោះ សារុន ព្រមទាំងកូនម្នាក់ (ប្អូន)
១០ - លាន វួច (ប្អូន) និង
១១ - ស៊ីម (ប្អូនជីដូនមួយ)

### ៤) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺញ

ចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវ៉ឺញ បានបន្តសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅពេលធ្វើដំណើរទៅដល់សាលាច្បាប់ (បច្ចុប្បន្នជាសាកល

វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) លោកបានសម្រាកនៅក្នុងសាលាចំនួនបីថ្ងៃទើបបន្តដំណើរទៅទៀត ។ នៅទីនោះ លោកបានជួបជាមួយរដ្ឋមន្ត្រីក្រសួងការពារជាតិឈ្មោះ ឋាបនា ងិន និងរដ្ឋមន្ត្រីក្រសួងសាធារណការដែលលោកធ្លាប់ធ្វើការជាមួយ ប៉ុន្តែលោកពុំទទួលបានដំណឹងអំពីកិច្ចប្រជុំរវាងខ្មែរក្រហម និងមន្ត្រីនៃរបប លន់ នល់ ឬព័ត៌មានផ្សេងៗទាក់ទងនឹងការជម្លៀសប្រជាជនឡើយ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងមេដឹកនាំធំៗ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខណៈពេលដែលខ្លួនកំពុងធ្វើដំណើរមកដល់សាលាច្បាប់ ខ្លួនបានឃើញបុគ្គលម្នាក់ជិះនៅក្នុងឡាន និងពាក់វ៉ែនតាខ្មៅ ហើយបុគ្គលនោះបានបង្ហាញនូវការពេញចិត្តជាខ្លាំងនៅពេលឃើញស្ថានភាពជម្លៀសដូច្នោះ ។ បន្ទាប់មក លោកចៅក្រម ឡាវ៉ែញ បានបន្តសួរទាក់ទងនឹងស្ថានភាពភៀសខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៧៧ ។ ឆ្លើយតបនឹងសំណួរនេះ លោក ពិន យ៉ាថៃ បានរៀបរាប់ថា លោកបានភៀសខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ហើយត្រូវបានប៉ូលីសថៃចាប់ដាក់គុកមួយរយៈ និងបញ្ជូនទៅនៅជំនុំម៉ៃរ៉ុតនៅជិតសមុទ្រថៃ ដោយសារលោកពុំមានលិខិតឆ្លងដែន ។ លោកបានបន្តថា នៅទីនោះលោកបានផ្សព្វផ្សាយអំពីសោកនាដកម្មនៅក្នុងប្រទេសកម្ពុជាដោយធ្វើឡើងនៅតាមជំរុំជនភៀសខ្លួន និងមានអ្នកការសែតថៃ, ជប៉ុន, កូរ៉េ, អាមេរិក, បារាំង និងអ្នកសារព័ត៌មានផ្សេងទៀតបានមកសម្ភាសន៍លោក ។ នៅខែតុលា ឆ្នាំ១៩៧៧ លោកបានចេញដំណើរទៅរស់នៅក្នុងប្រទេសបារាំង និងទៅធ្វើការផ្សព្វផ្សាយនៅតាមបណ្តាប្រទេសផ្សេងៗទៀតដូចជា នៅអូតាវ៉ា, ប៉ារីស, វ៉ាស៊ីនតោន, និងនៅប្រ៊ុចសែលតាមរយៈសន្និសីទការសែត និងការនិយាយអំពីរឿងរ៉ាវដែលកើតឡើងចំពោះគ្រួសាររបស់លោក និងប្រជាជនកម្ពុជាទាំងមូល ។ លោកបានបន្តទៀតថា ក្រោយពីបានឆ្លងកាត់របបខ្មែរក្រហម លោកបានសរសេរសៀវភៅពីក្បាល ដែលសៀវភៅទី១មានចំណងជើងថា "មនោគមវិជ្ជា មហាឃាតករ" ជាភាសាបារាំង និងសៀវភៅទី២មានចំណងជើងថា "ជីវិតកូនថ្ងៃ កូនត្រូវតែរស់" ជាភាសាអង់គ្លេសនិងមានបកប្រែជាច្រើនភាសាទៀតផង ។

### ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ អង្គជំនុំជម្រះបានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្តី អៀង សារី និងមេធាវីការពារក្តី ខៀវ សំផន ។ ដោយឡែកមេធាវីការពារក្តី នួន ជា ពុំមានសំណួរសម្រាប់សួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។

### ៤.១) ការសួរដេញដោលដោយមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិ ម៉ៃឃើល ការណាវ៉ាស បានចាប់ផ្តើមសួរទាក់ទងនឹងការស្រាវជ្រាវក្នុងការសរសេរនៅក្នុងសៀវភៅទី១ និងទី២របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោក ពិន យ៉ាថៃ បានរៀបរាប់ថា សៀវភៅទី១របស់លោកត្រូវបានបោះពុម្ពនៅឆ្នាំ ១៩៧៩ ហើយការសរសេរនោះមិនមានការស្រាវជ្រាវអ្វីច្រើនទេដោយសារលោកបានរៀបរាប់ពីអង្គហេតុពិតដែលកើតឡើងតាមការយល់ឃើញរបស់លោក ។ ចំណែកឯសៀវ ភៅទី២ត្រូវបានបោះពុម្ពលើកទី១នៅឆ្នាំ១៩៨៧ ហើយត្រូវបានកែសម្រួលសារជាថ្មីនៅឆ្នាំ២០០០ ។ លោកបានបន្ថែមថា ការកែសម្រួលនោះ គឺមានតែនៅក្នុងផ្នែកសេចក្តីផ្តើមតែប៉ុណ្ណោះ ចំណែកសាច់រឿងខាងក្នុងវិញ គឺផ្តោតសំខាន់ទៅលើជីវិតគ្រួសាររបស់លោកច្រើនជាងសៀវភៅទី១ ។ បន្ទាប់មក មេធាវីបានសួរដេញដោលឡើងវិញទាក់ទងនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរបប លន់ នល់ និងស្នើឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អំពីឈ្មោះរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងក្រសួងសាធារណការ ។ បន្ទាប់មក មេធាវីអន្តរជាតិបានសួរទាក់ទងនឹងអំពើពុករលួយនៅក្នុងរបប លន់ នល់ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានសរសេរ ។ ចំពោះករណីនេះ លោក ពិន យ៉ាថៃ គ្រាន់តែបានបញ្ជាក់ថា អំពើពុករលួយកើតឡើងនៅពេលដែលមនុស្សមានអំណាចកាន់តែច្រើន ។ លោកបានបន្តថា នៅពេលមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ប្រជាជនខ្លះមានការសប្បាយរីករាយ ដោយសារប្រជាជនទាំងនោះមិនពេញចិត្តនឹងការឈ្លានពានរបស់វៀតណាមខាងជើង និងអំពើពុករលួយដែលកើតឡើងនៅក្នុងទីក្រុងភ្នំពេញ ហើយនៅក្នុងរបប លន់ នល់ ប្រទេសកម្ពុជា ពុំទទួលបានសេរីភាពឡើយ ដោយសារសង្គ្រាមចេះតែបន្តរហូតដល់ពេលដែលខ្មែរក្រហមចូល

មកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ។

មេធាវីអន្តរជាតិបានបន្តសំណួរ ដោយលើកយកនូវចំណុចមួយចំនួននៅក្នុងសៀវភៅដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់សារជាថ្មី ។ ចំនុចទាំងនោះរួមមានមូលហេតុដែលនាំឲ្យមានការជួលរលំទីក្រុងភ្នំពេញ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងក្រោយពេលបានជួបជាមួយរដ្ឋមន្ត្រីក្រសួងការពារជាតិ និងក្រសួងសាធារណៈការ ។ ជាថ្មីម្តងទៀត ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានឆ្លើយបញ្ជាក់ថា ទាក់ទងនឹងការជួលរលំនៃទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនចេញពីទីក្រុង គឺលោកពុំដែលទទួលបានដំណឹងនោះទាល់តែសោះ ។

### ៩.២) ការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយមេធាវីការពារក្តី អៀង សារី លោកមេធាវីជាតិ គង់ សំអុន បានបន្តសួរដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងឈ្មោះឪពុកម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសសេរនៅក្នុងសៀវភៅរបស់លោកថា ឪពុកឈ្មោះ ពិន ធោយ និងម្តាយឈ្មោះ ហាយ ថាង ។ ទាក់ទងនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា តាមការពិតអ្នកទាំងពីរគឺជាបងជីដូនមួយរបស់ខ្លួនតែប៉ុណ្ណោះ ។ លោកបានពន្យល់ថា កាលពីពេលដែលលោកមានអាយុ៧ឆ្នាំ ម្តាយរបស់លោកបានបញ្ជូនលោកឲ្យមករៀននៅទីក្រុងភ្នំពេញ និងស្នាក់នៅជាមួយបងជីដូនមួយទាំងពីរនាក់ ប៉ុន្តែដោយសារលោកមិនទាន់មានសំបុត្រកំណើតនៅឡើយ ដូច្នេះបងជីដូនរបស់លោកក៏បានចុះឈ្មោះលោកធ្វើជាកូនរបស់គាត់តែម្តង ។ មេធាវីបានបន្តសួរទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅរបស់លោក ពីកន្លែងមួយទៅកន្លែងមួយថាតើការផ្លាស់ប្តូរទីលំនៅនោះ គឺជាការស្ម័គ្រចិត្តរបស់លោកដែរឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះ លោកបានស្ម័គ្រចិត្តផ្លាស់ទីលំនៅដោយខ្លួនឯងពិតមែន ប៉ុន្តែលោកធ្វើនេះដោយសារតែលោកពុំបានយល់អំពីគោលបំណងរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត លោកក៏មិននឹកស្មានថា ខ្មែរក្រហមយកអ្នកដែលមានជំនាញខាងបច្ចេកទេស និងអ្នកដែលចេះដឹងជាច្រើននាក់ទៅធ្វើបាបដូច្នោះដែរ ។ បន្ទាប់មក មេធាវីបានបន្តសំណួរទាក់ទងនឹងការដោះដូរទ្រព្យសម្បត្តិជាមួយនឹងអាហារដែលលោកបានលើកឡើងពីខាងលើ ។ ជាការឆ្លើយតប លោក ពិន យ៉ាថៃ បានបញ្ជាក់ថា នៅពេលជម្លៀសក្នុងដំណាក់កាលទីមួយ លោកបានយកទ្រព្យសម្បត្តិមួយចំនួនដូចជា សំលៀកបំពាក់ និងចានឆ្នាំងជាដើមទៅដូរយកអង្ករជាមួយប្រជាជនមូលដ្ឋាន ដោយសារតែនៅពេលនោះ អង្គការពុំទាន់មានការបែងចែកឲ្យហូបបាយរួមនៅឡើយទេ ដូច្នេះអ្នកដែលមានទ្រព្យសម្បត្តិ ទើបអាចទទួលបានអាហារហូបចុកគ្រប់គ្រាន់ ។ ប៉ុន្តែ បន្ទាប់ពីមានការជម្លៀសនៅក្នុងដំណាក់កាលទី២មក លោកអាចដោះដូររបស់របរបានតិចតួចប៉ុណ្ណោះ ដោយសារនៅពេលនោះខ្មែរក្រហមបានបង្កើតរោងបាយរួមនៅឆ្នាំ១៩៧៦ ។

មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានប្រគល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ ធ្វើថ្លែងអំពីទុក្ខសោកដែលបានទទួលរងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

### ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

បាទ!សូមអគុណលោកប្រធាន ។ សូមគោរពលោកប្រធានអង្គជំនុំជម្រះ សូមគោរពលោក លោកស្រីចៅក្រម ។ សូមគោរពអង្គសវនាការទាំងមូល ។

ខ្ញុំដឹងហើយ យើងដឹងហើយថា មនុស្សយើងស្លាប់ច្រើនណាស់បាទ!តើគ្រួសារប្រជាជនថ្មីណាដែលគ្មានអ្នកស្លាប់? មានគ្រួសារច្រើនណាស់ដែលបានស្លាប់ទាំងពូជតែម្តង ដូចជាគ្រួសារប្អូនប្រុសខ្ញុំដែលមានគ្នាប្រាំនាក់ និងគ្រួសារប្អូនស្រីខ្ញុំដែលមានគ្នាបីនាក់ជាដើម ។

ក្នុងចំណោមគ្រួសារតូចរបស់ខ្ញុំដែលមានគ្នាប្រាំនាក់ ខ្ញុំ ប្រពន្ធខ្ញុំ និងកូនបីនាក់ ហើយនឹងគ្រួសារធំរបស់ខ្ញុំ ដែលមានគ្នា១៨នាក់ដែលខ្ញុំបានជម្រាបតាំងពីដើម ពេលដែលខ្ញុំនិយាយពីការជម្លៀសប្រជាជនយើងតាំងពីភ្នំពេញមកនោះ ដែលនៅជាប់គ្នារហូត១៨នាក់ហ្នឹង ទាំងអស់ហ្នឹងស្លាប់អស់នៅតែខ្ញុំម្នាក់ទេបាទ ។ ខ្ញុំម្នាក់គត់ដែលបានរស់រានមានជីវិត ហើយដែលបានមានឱកាសមកជម្រាបជាសក្ខីកម្មជូនអង្គសវនាការនៅពេលនេះ ។

ដូច្នេះជាបឋម ខ្ញុំសូមសម្តែងសេចក្តីសោមនស្សរីករាយ ចំពោះការបង្កើតឲ្យមានអង្គជំនុំជម្រះពិសេសនេះ ដែលបានឲ្យឱកាសខ្ញុំជាអ្នករងគ្រោះមកជម្រាបព័ត៌មានទាំងអស់ដែលខ្ញុំ

បានរស់នៅក្នុងរបបខ្មែរក្រហម ហើយនិងអ្វីខ្លះដែលខ្ញុំបាត់ មិនមែនតែសម្ភារៈផ្ទះសម្បែងទេ ។ បាត់ធំបំផុត គឺវិជ្ជាជីវៈរបស់យើង ការរស់នៅធម្មតារបស់យើងអស់រលីង អស់កូន ទាំងប្រពន្ធ ទាំងម៉ែ ទាំងឪ ទាំងបងប្អូន ។ ថ្វីត្បិតតែ មានការយឺតយ៉ាវ និងការមានការខ្វះខាត ឬការរំរកូសខ្លះៗកន្លងមក ខ្ញុំយល់ថា អង្គជំនុំជម្រះវិសាមញ្ញនេះមានសារៈសំខាន់ជាប្រវត្តិសាស្ត្រសម្រាប់ស្វែងរកការពិត និង យុត្តិធម៌ជូនប្រជាជនខ្មែរយើងបាទ ។

ជាពិសេស ដោយអង្គជំនុំជម្រះនេះបានដំណើរការដោយតម្លាភាព និងមានមធ្យោបាយគ្រប់គ្រាន់មកដល់ពេលនេះ ដើម្បីបំពេញកិច្ចការរបស់ខ្លួនក្រោមចក្ខុ និងការពិនិត្យតាមដានរបស់អ្នកអង្កេតការណ៍ជាតិ និងអន្តរជាតិទូទៅ ។ នៅពេលនេះ ខ្ញុំមានសំណូមពរតែមួយគត់ គឺធ្វើយ៉ាងណាឲ្យការកាត់ក្តីបានដល់ទីដៅយ៉ាងឆាប់បំផុត ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ ទាំងខ្ញុំទាំងគេឲ្យបានជាស្ថាពរ ។ ដើម្បីសម្រេចគោលបំណងនេះ ខ្ញុំសូមធ្វើការអំពាវនាវដោយស្មោះ និងដោយទទូចដល់អស់ លោកជាជនជាប់ចោទទាំងបីនាក់ ដែលធ្លាប់ជាអ្នកបដិវត្តន៍ដ៏ឆ្នើម មានមនសិការនយោបាយដ៏មោះមុត សូមលោកប្រកាន់ការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្រយើងដោយស្ម័គ្រចិត្ត ធ្វើស្វ័យទិតៀនចំពោះការដឹកនាំអង្គការបដិវត្តន៍ក្នុងរយៈពេលដែលអស់លោកនៅកាន់អំណាចទាំងស្រុង ។

បើអស់លោកជាជនជាប់ចោទ សុខចិត្តធ្វើការស្វ័យទិតៀន អស់លោកនឹងឃើញច្បាស់នៅលទ្ធផលជាក់ស្តែងឥតប្រកែកបានតាមរយៈភស្តុតាងរាប់មិនអស់ដូចជា រណ្តៅរួមកប់ខ្មោចដែលមានទូទាំងប្រទេស និងសក្ខីកម្មរបស់ជនរងគ្រោះរាប់មិនអស់ដែរ នៃមហាឧក្រិដ្ឋកម្មរបស់អង្គការបដិវត្តន៍ ។ អង្គការបដិវត្តន៍បានបំផ្លាញ កម្ទេចចោលជីវិតមនុស្សរាប់សែនលាននាក់ដែលជាជាតិខ្មែរដូចគ្នា ដោយឥតប្រយោជន៍ដើម្បីអភិវឌ្ឍគំនិតនៃមនោគមវិជ្ជាកុម្មុយនិស្តដែលមានទ្រឹស្តីពិរោះស្តាប់ តែមនុស្សធម្មតាមិនអាចទទួលយកបាន ។ ការដឹកនាំរបស់អង្គការបដិវត្តន៍ បានបំផ្លាញប្រទេសមួយដែលមានសោភ័ណភាព និងសម្បូរសប្បាយដោយសម្បត្តិធម្មជាតិឲ្យចុះក្រីក្រ គោកយ៉ាក ហើយប្រជាពលរដ្ឋទាំងអស់ក៏បានត្រូវទទួលមហាវិនាសកម្មគ្រប់ប្រភេទ ហួសពីការស្មាន ។

កំហុសធំបំផុតមួយរបស់អង្គការបដិវត្តន៍ គឺការលើកតម្កើងហួសហេតុចំពោះការអនុវត្តមនោគមវិជ្ជាសមូហភាពនេះ ជាជាងការយកចិត្តទុកដាក់រិះរកសុភមង្គលជូនប្រជាជនឯងដែលជាភារកិច្ចចម្បងបំផុតរបស់អ្នកដឹកនាំប្រទេសជាទូទៅ ។

អស់លោកមិនអាចប្រកែកថា មិនដឹងមិនឮនោះទេ ព្រោះអង្គការប្រកាសខ្លួនឯងថា អង្គការមានត្រចៀកគ្រប់ទិសទី មានភ្នែកដូចភ្នែកម្នាស់នៅក្នុងប្រទេសកម្ពុជាយើងទាំងមូល ។ បន្ទាប់ពីធ្វើការទិតៀននេះ អស់លោកជនជាប់ចោទទាំងបី គួរតែសារភាពកំហុស និងឧក្រិដ្ឋកម្មទាំងឡាយនោះដោយសុទ្ធចិត្ត និងដោយស្មោះស្ម័គ្រឲ្យសមជាអ្នកបដិវត្តន៍គំរូ ដែលហ៊ានទទួលខុសត្រូវទាំងស្រុងចំពោះអំពើមិនគប្បី ដែលខ្លួនបានប្រព្រឹត្ត ។ ហើយនៅទីបំផុតក្រោយពីបានសារភាពរួចហើយ អស់លោកច្បាស់ជាមិនជំទាស់ទេនឹងការសម្តែងការសុំទោសជាឧឡារិកដល់វិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ ដែលបានទទួលមរណៈភាព និងជនរងគ្រោះជាច្រើនទៀតដែលកំពុងរស់នៅសព្វថ្ងៃនេះ ។ បើអស់លោកធ្វើដូច្នេះបានអង្គជំនុំជម្រះនឹងអាចបញ្ចប់ក្នុងរយៈពេលខ្លីខាងមុខនេះដោយគោលដៅរកការពិត ហើយគោលដៅរកការពិត និងយុត្តិធម៌ជូនប្រជាជន ខ្មែរយើងក៏នឹងត្រូវបានសម្រេចជាស្ថាពរក្នុងពេលនោះដែរ ។

៣៨ឆ្នាំបានកន្លងបាត់ទៅហើយ តាំងពីសោកនាដកម្មដ៏ធំធេងបានកើតឡើងនៅស្រុកខ្មែរយើង ។ យើងភាគច្រើនក៏កាន់តែចាស់ជរាគ្រប់គ្នាដែរ តើយើងត្រូវធ្វើអ្វីមួយ ដើម្បីឲ្យអារម្មណ៍យើងបាត់កង្វល់ទុក្ខឲ្យបានស្ងប់ស្ងាត់ចិត្តក្នុងប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតយើងនោះ? ខ្ញុំមានជំនឿយ៉ាងមុតមាំថា បើសេចក្តីអំពាវនាវរបស់ខ្ញុំនេះត្រូវបានអស់លោកទាំងបីទទួលយកទៅធ្វើការរែកញែកពិចារណាឲ្យបានជ្រាលជ្រៅ រួចធ្វើការសម្រេចជាវិជ្ជមាន យើងជនរងគ្រោះច្បាស់ជាអាចបានធូរចិត្តខ្លះដែរ ។ អនុស្សាវរីយ៍ជូរចត់ទាំងឡាយ កំហឹង ការសោកស្តាយវិប្បដិសារីនានាច្បាស់ជារលត់ និងរសាយទៅបន្តិចម្តងៗពីសតិអារម្មណ៍យើងគ្រប់គ្នា ។ ហើយការផ្សះផ្សាទៀតក៏អាចសម្រួលនិងពង្រឹកថែមទៀតដើម្បីអនាគតកូនចៅយើង និងមាតុភូមិយើងជានិច្ចតទៅ ។ សូមអគុណ ។

# សវនាការស្តីពីការពិចារណាលើផលវិបាកដែលកើតចេញពី សេចក្តីសម្រេចលុបចោលដីកាបំបែកសំណុំរឿង០០២

## ថ្ងៃទី១៨ និង២០-២១ ខែកុម្ភៈ ឆ្នាំ២០១៣

អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចលុបចោលដីកាបំបែកនីតិវិធីក្នុងសំណុំរឿង០០២របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កន្លងទៅអង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការរយៈពេលបីថ្ងៃ នៅថ្ងៃទី១៨ និងថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ជុំវិញវិសាលភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និងបច្ច័យដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកនីតិវិធី ។

ភាគីទាំងអស់ត្រូវបានស្នើឲ្យលើកឡើងនូវសំណើជាក់លាក់ និងឆ្លើយតបនឹងសំណួរមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យមានការបញ្ជាក់ច្បាស់លាស់ ក្រោយពេលមានការលុបចោលដីកាបំបែកនីតិវិធីសំណុំរឿង០០២ ។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបចំពោះសំណួរចំនួន៤ ។ បន្ទាប់មកភាគីទាំងអស់ក៏ត្រូវបានស្នើឲ្យឆ្លើយតបនឹងសំណួរចំនួន៤ដែរ ហើយអង្គជំនុំជម្រះមានសំណួរ១ផ្សេងដាច់ដោយឡែកសម្រាប់ក្រុមមេធាវីការពារក្តីទាំងបីក្រុម ។ រាល់ចម្លើយនីមួយៗនៃសំណួរទាំង៩ដែលភាគីបានឆ្លើយ អង្គជំនុំជម្រះផ្តល់ឱកាសឲ្យភាគីផ្សេងទៀតដែលពុំជាមែនជាអ្នកត្រូវឆ្លើយនឹងសំណួរ អាចធ្វើការឆ្លើយតបនឹងចម្លើយទាំងនោះបាន ។ ដើម្បីភាពងាយស្រួលចម្លើយ និងការឆ្លើយតបចំពោះចម្លើយនីមួយៗរបស់ភាគី ត្រូវបានដាក់បញ្ចូលគ្នាទៅតាមលំដាប់នៃសំណួរពីទី១ រហូតដល់ទី៩ ។

ចម្លើយដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបចំពោះសំណួររបស់អង្គជំនុំជម្រះភាគច្រើនបានភ្ជាប់ជាមួយនឹងសំណើសុំឲ្យមានការដាក់បញ្ចូលបន្ថែមនូវបទចោទប្រកាន់ពាក់ព័ន្ធនឹងអង្គហេតុនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ចូលក្នុងសំណុំរឿងដែលកំពុងតែជំនុំជម្រះនាពេលបច្ចុប្បន្នគឺសំណុំរឿង០០២/០១ ។

ក្រៅពីការឆ្លើយតបខ្លីៗចំពោះចម្លើយទាំងអស់របស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមបានដាក់សំណើសុំផ្ទាល់មាត់ជូនអង្គជំនុំជម្រះ ដោយស្នើសុំឲ្យមានការជំនុំជម្រះលើសំណុំរឿង០០២ទាំងមូល ដោយពុំចាំបាច់ធ្វើការបំបែកកិច្ចដំណើរការនីតិវិធីបន្តទៀតទេ ។ ដោយឡែកក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើសុំផ្ទាល់ជូនអង្គជំនុំជម្រះចំនួនពីរចំណុចទី១ គឺស្នើឲ្យអង្គជំនុំជម្រះសម្រេចបំបែកជនជាប់ចោទ ខៀវ សំផន ចេញពីការជំនុំជម្រះរួមគ្នាជាមួយជនជាប់ចោទ នួន ជា និង អៀង សារី មកជាការជំនុំជម្រះតែលើ ខៀវ សំផន ម្នាក់ឯង ។ ទី២ គឺ ស្នើឲ្យតុលាការដោះលែងជនជាប់ចោទ ខៀវ សំផន ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ។

អង្គជំនុំជម្រះបានផ្តល់វេទិកាជូនសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការបញ្ជាក់អំពីគោលជំហររបស់ខ្លួន មុនភាគីមេធាវីការពារក្តីទាំងបីក្រុម ។

អំឡុងពេលសវនាការនេះ ចៅក្រមអន្តរជាតិ គឺលោកស្រីស៊ីលវៀ ខាតវ្រ៉ាយត៍ បានអវត្តមាន ដោយសារមានភារកិច្ចផ្ទាល់ខ្លួន ដូច្នេះអង្គជំនុំជម្រះសម្រេចតែងតាំងលោកស្រីចៅក្រមក្លោឌៀ ហ្វិនជំនួស ជាបណ្តោះអាសន្ន ។

### ១) សំណួរ៤ដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយបញ្ជាក់

**សំណួរទី១** : ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចពាក់ព័ន្ធផ្សេងទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ឆ្លុះបញ្ចាំងពីសេចក្តីបារម្ភដែលថា បទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ទំនងជាមិនអាចត្រូវបានជំនុំជម្រះចប់សព្វគ្រប់នៅក្នុងរយៈពេលដែលជនជាប់ចោទទំនងជានៅមានជីវិតរស់នៅ ឬក៏នៅមុនពេលដែលជនជាប់ចោទទាំងនោះវិវត្តទៅជាមិនមានកាយសម្បទា និងប្រាជ្ញា

ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះឡើយ ។ តើលោក ឬលោកស្រីមានការយល់ឃើញបែបណាចំពោះសេចក្តីបារម្ភនេះ?

### ១.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

មុនពេលឆ្លើយតបនឹងសំណួរទី១របស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញាជាតិគឺលោកស្រី ជា លាង បានឡើងថ្លែងអំពីការយល់ឃើញរបស់ការិយាល័យសហព្រះរាជអាជ្ញាថា បច្ច័យដែលកើតចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានលុបចោលដីកាបំបែកនីតិវិធីរបស់អង្គជំនុំជម្រះសាលា



សហព្រះរាជអាជ្ញាជាតិ ជា លាង

ដំបូង គឺពុំបានធ្វើឲ្យគ្មានសុពលភាពដល់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ទេ ហើយពេលវេលា និងកស្តុតាងដែលប្រើ-ប្រាស់នៅក្នុងសវនាការនាពេលកន្លងមកក៏មិនឥតប្រយោជន៍ដែរ ។ សហព្រះរាជអាជ្ញា ជា លាង បានបន្ថែមទៀតថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគ្រាន់តែចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងចេញនូវដីកាបំបែកនីតិវិធីមួយដែលមានសំអាងហេតុគ្រប់គ្រាន់តែប៉ុណ្ណោះ ។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនៅតែអាចចេញសាលក្រមលើសំណុំរឿង០០២/០១ នៅត្រឹមឆ្នាំ២០១៣បានដដែល ។ ការិយាល័យសហព្រះរាជអាជ្ញាពុំជំទាស់នឹងការបំបែកនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងទេ ប៉ុន្តែគ្រាន់តែចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាចំពោះលទ្ធភាពក្នុងការដាក់បញ្ចូលបន្ថែមនូវបទចោទ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅក្នុងសំណុំរឿង០០២/០១តែប៉ុណ្ណោះ ។

សហព្រះរាជអាជ្ញា ជា លាង បានពន្យល់ទៀតថា ការដែលការិយាល័យសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការដាក់បញ្ចូលនូវអង្គហេតុបន្ថែមទៅក្នុងសំណុំរឿង០០២/០១ គឺដោយសារតែខ្លួនបារម្ភថា ទំនងជានឹងពុំអាចមានសវនាការក្រោយៗបន្ទាប់ពីសំណុំរឿង០០២/០១ទេ ។ ដូច្នេះវិសាលភាពនៃសំណុំរឿង ០០២/០១ គប្បីត្រូវតែតំណាងឲ្យបទចោទនានាដែលមាននៅក្នុងដីកាដំណោះស្រាយ ។

បន្ទាប់មក សហព្រះរាជអាជ្ញាជាតិ ជា លាង បានផ្ទេរវេទិកាជូនសហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ដើម្បីឆ្លើយតបនឹងសំណួរទាំងឡាយរបស់អង្គជំនុំជម្រះ ។

ឆ្លើយតបនឹងសំណួរទី១របស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានបង្ហាញពីជំហរថា បទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ទំនងជាមិនអាចត្រូវបានជំនុំជម្រះចប់សព្វគ្រប់ឡើយ នៅក្នុងរយៈពេលដែលជនជាប់ចោទនៅមានជីវិតរស់នៅ ឬក៏នៅមុនពេលដែលជនជាប់ចោទវិវត្តទៅជាមិនមានកាយសម្បទា និងប្រាជ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ ដូច្នេះ សហព្រះរាជអាជ្ញាពុំយល់ស្របជាមួយនឹងការកំណត់វិសាលភាពសំណុំរឿង០០២/០១របស់អង្គជំនុំជម្រះសាលាដំបូងទេ ដោយសារតែខ្លួនយល់ថាសវនាការលើសំណុំរឿង០០២/០២ទំនងជានឹងពុំអាចកើតមាន ។ សហព្រះរាជអាជ្ញា ខេលី បានបន្តទៀតថា ការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះតុលាការកំពូលឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើវិសាលភាពនៃសំណុំរឿង០០២/០១ឡើងវិញ គឺជារឿងដែលសំខាន់ ។ ប្រសិន បើអង្គជំនុំជម្រះសាលាដំបូងនឹងកំណត់ថា សវនាការនឹងមានដល់សំណុំរឿង០០២/០២ ឬ ០០២/០៣ នោះ អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ឲ្យបានច្បាស់អំពីគម្រោងសកម្មភាពជារួមដែលខ្លួនមានបំណងចង់ធ្វើ ។ ក្នុងករណីដែលអង្គជំនុំជម្រះនឹងកំណត់ថា សវនាការនឹងមានត្រឹមតែសំណុំរឿង០០២/០១នោះ អង្គជំនុំជម្រះគប្បីត្រូវកំណត់ឲ្យបានច្បាស់នូវវិសាលភាពនៃសំណុំរឿង ដើម្បីឲ្យស្របតាមបទដ្ឋានដែលកំណត់អំពីភាពជាតំណាង ឬការចោទប្រកាន់ដែលនឹងត្រូវលើកយកមកចោទនៅក្នុងសំណុំរឿង០០២/០១នេះ ។

បន្ទាប់ពីសហព្រះរាជអាជ្ញាបញ្ចប់ការឆ្លើយសំណួរ អង្គជំនុំជម្រះបានប្រគល់វេទិកាបន្តទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឆ្លើយសំណួរទី១ ។

### ១.ខ) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វុត បានបញ្ជាក់ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ គឺបានឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភរបស់ខ្លួន ដែលធ្លាប់បានលើកឡើងកាលពី១៦ខែមុន


មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ូណូហ្វុត

នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ។ មេធាវីរូបនេះបានបន្តទៀតថា រាល់បទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះចាំបាច់ត្រូវតែលើកយកមកជំនុំជម្រះ ។ ប៉ុន្តែបានទទួលស្គាល់ថាការដែលត្រូវកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១កន្លងមក ឲ្យមកផ្តល់សក្ខីកម្មសារជាថ្មីទាក់ទងនឹងសំណុំរឿង០០២ទាំងមូល គឺជារឿងដែលពុំអាចទៅរួច ។ ដូច្នេះ ដើម្បីកុំឲ្យពេលវេលាដែលបានប្រើប្រាស់នាពេលកន្លងមកក្លាយជាឥតប្រយោជន៍ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងពុំស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលឡើយ ប៉ុន្តែអាចជ្រើសរើសយកដំណោះស្រាយណាមួយដែលសមហេតុផល ។

បន្ថែមលើការលើកឡើងរបស់សហមេធាវីនាំមុខអន្តរជាតិ លោក ពេជ អង្គ ដែលជាសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីជំហររបស់ខ្លួនថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រចំពោះការព្រួយបារម្ភដែលថា លទ្ធភាពក្នុងការជំនុំជម្រះសំណុំរឿង០០២ទាំងមូល ទំនងជាពុំអាចធ្វើទៅបាននៅពេលដែលជនជាប់ចោទនៅរស់រានមានជីវិត ទោះបីជាខ្លួនចង់ឲ្យមានការជំនុំជម្រះមួយដែលមានលក្ខណៈទូលំទូលាយក៏ដោយ ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះគួរតែកំណត់អំពីវិសាលភាពនៃសវនាការដំណាក់កាលដំបូងនេះជាជាងជំនុំជម្រះលើសំណុំរឿង០០២ទាំងមូល ។

**សំណួរទី២** : ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធនានារបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានជំរុញយ៉ាងច្បាស់ដោយក្តីបារម្ភមួយក្នុងការរក្សាឲ្យបាននូវសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីចេញសាលក្រមឲ្យបានទាន់ពេលវេលានៅក្នុងសំណុំរឿង០០២ ។ ជាបញ្ហាទូទៅ តើលោក លោកស្រី ចង់ឲ្យអង្គជំនុំជម្រះបន្តជំនុំជម្រះលើបទចោទ និងការចោទប្រកាន់ផ្អែកអង្គហេតុយ៉ាងច្រើនក្នុងលក្ខណៈទូលំទូលាយនៃសំណុំរឿង០០២ទាំងមូល ដោយលទ្ធផលចុងក្រោយប្រឈមនឹងការ មិនទទួលបានសាលក្រម ឬក៏លោក លោកស្រីពិចារណាចង់ឲ្យកិច្ចដំណើរការនីតិវិធីដោយពាក់ព័ន្ធត្រឹមតែបទចោទ និងការចោទប្រកាន់ផ្អែកអង្គហេតុមួយចំនួន ហើយដូច្នេះវានឹងបង្កើតភវនីយភាពនៃការចេញសាលក្រមមួយបាន?

### ២.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

ឆ្លើយតបនឹងសំណួរទី២ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានបញ្ជាក់អំពីជំហររបស់ការិយាល័យសហព្រះរាជអាជ្ញាថា នៅក្នុងដំណាក់កាលនេះ ការលើកយកបទចោទប្រកាន់បន្ថែមមកជំនុំជម្រះ គឺជារឿងចាំបាច់ ។ ប៉ុន្តែត្រូវកម្រិតវិសាលភាពនៃការជំនុំជម្រះដំណាក់ដំបូងនេះ ដោយធ្វើយ៉ាងណាឲ្យបទចោទដែលលើកយកមកជំនុំជម្រះនោះតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល និងបន្ទាប់មកអង្គជំនុំជម្រះអាចចេញសាលក្រមបាន ។ សហព្រះរាជអាជ្ញា លេវី បានបន្តទៀតថា ទោះបីជា

សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចេញមកហាក់បីដូចជាយឺតពេលបន្តិចហើយក៏ដោយ ប៉ុន្តែភាគីនានាចាំបាច់ត្រូវតែគោរពតាមការណែនាំរបស់តុលាការសាលាកំពូល ។ ម្យ៉ាងវិញទៀត ភាគីនានាគួរតែបានបង្ហាញមតិយោបល់ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី ។

**២.១) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

មេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ បានឆ្លើយតបនឹងសំណួរទី២របស់អង្គជំនុំជម្រះដោយបញ្ជាក់



មេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ

អះអាងថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីពុំចង់ឲ្យមានការជំនុំជម្រះលើសំណុំរឿង០០២ ទាំងមូលទេ គឺចង់មានការចេញសាលក្រមមួយក្នុងរយៈពេលខ្លី និងចង់ឲ្យជនរងគ្រោះទទួលបានយុត្តិធម៌ទោះបីក្នុងមួយចំណែកតូចក៏ដោយ ។ ប៉ុន្តែឲ្យការជំនុំជម្រះនោះត្រូវសមាមាត្រទៅនឹងទិដ្ឋភាពជាក់ស្ដែងដែលកំពុងគំរាមកំហែងដល់កិច្ចដំណើរការនីតិវិធី ដូចជា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងស្ថានភាពថវិការបស់តុលាការ ។

មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សា-ប៊ែត ស៊ីម៉ូណូហ្វត បានបន្ថែមលើការលើកឡើងរបស់សហភាគាជាតិរបស់ខ្លួនថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីពុំជំទាស់ទៅនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែប្រឆាំងនឹងការជ្រើសរើសអង្គហេតុមួយចំនួនមកជំនុំជម្រះតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណា ចាំបាច់ត្រូវមានការពិចារណាអំពីតុល្យភាពរវាងពេលវេលាសមស្រប និងភាពជាតំណាងនៃអង្គហេតុទាំងមូលដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

**សំណួរទី៣** : *ខណៈពេលដែលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចរបស់ខ្លួននោះ អង្គជំនុំជម្រះសាលាដំបូងកំពុងតែជិតឈានដល់ការបញ្ចប់សំណុំរឿង០០២/០១ ។ មានការប្រមាណថា មានតម្រូវការចំនួនថ្ងៃសវនាការបន្តិចបន្ថែមទៀត ជាមួយនឹងវត្តមានជនជាប់ចោទទាំងបីនាក់ ដើម្បីបញ្ចប់សវនាការលើភស្តុតាងនៅក្នុងការជំនុំជម្រះលើកដំបូង ។ ដោយសារតែការដាក់បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងដូចដែលបានប្រមើលដឹងជាមុនដោយអ្នកជំនាញវេជ្ជសាស្ត្រ ដែលបានពិនិត្យឡើងវិញលើសម្បទារបស់ជនជាប់ចោទទាំងអស់ក្នុងការចូលរួមសវនាការនោះ អង្គជំនុំជម្រះធ្លាប់បានជួបប្រទះនូវការពន្យារពេល និងផលវិបាកបន្ថែមទៀតក្នុងការទទួលបានវត្តមានរបស់ជនជាប់ចោទទាំងបីនាក់តាមពេលវេលា ដែលបានកំណត់ដោយសារតែការចុះដុនដាបផ្នែករាងកាយរបស់ពួកគាត់ ។ ដោយផ្អែកលើកាលៈទេសៈ ដែលមានការផ្លាស់ប្ដូរនេះ និងផលវិបាកនានានៃការអនុវត្តវិធីសាស្ត្រណាមួយផ្សេង នៅដំណាក់កាលយឺតពេលទៅហើយនេះ តើលោក លោកស្រីនៅតែជំទាស់ទៅនឹងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទីមួយរបស់ខ្លួន តាមរបៀបដែលត្រូវបានកំណត់ដោយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្ដីសម្រេចដែលពាក់ព័ន្ធនានាកន្លងមកដែរឬទេ?*

មុនពេលប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីឆ្លើយតបនឹងសំណួរ ប្រធានអង្គជំនុំជម្រះ និល ណុន បានប្រគល់វេទិកាជូនចៅក្រមអន្តរជាតិ គឺលោកស្រី ក្លូឌា ហ្វេនស៍ ដើម្បីធ្វើការកត់សម្គាត់លើបញ្ហាទាក់ទងនឹងលទ្ធភាពក្នុងការចេញសាលក្រមឲ្យបានឆាប់រហ័ស ។ លោកស្រីចៅក្រមបានគូសបញ្ជាក់ថា ដោយសារតែដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ពុំទាន់បានបញ្ចប់នៅឡើយ ដូច្នេះអង្គជំនុំជម្រះពុំអាចប៉ាន់ស្មានពីថេរវេលាក្នុងការចេញសាលក្រមបាននៅឡើយទេ ។ លោកស្រី

ចៅក្រមបានលើកឧទាហរណ៍ជាក់ស្តែងទាក់ទងនឹងសំណុំរឿង ០០១ ថា នៅក្នុងសំណុំរឿង០០១អង្គជំនុំជម្រះបានចំណាយរយៈពេល៨ខែដើម្បីសរសេរសាលក្រមទាក់ទងនឹងឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរសន្តិសុខស-២១ ហើយអង្គជំនុំជម្រះតុលាការកំពូលបានចំណាយរយៈ៧ខែដើម្បីសរសេរសាលដីការបស់ខ្លួន ។

### ៣.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

ឆ្លើយតបនឹងការកត់សម្គាល់របស់ចៅក្រម ហ្វេនស៍ សហព្រះរាជអាជ្ញាអន្តរជាតិ អេនទ្រូ លេខី បានបញ្ជាក់ថា ដោយសារតែរយៈពេលនៃការសរសេរសាលក្រមអាចនឹងចំណាយពេលយូរ ដូច្នេះការស្នើឲ្យអង្គជំនុំជម្រះបន្តធ្វើសវនាការលើសំណុំរឿងបន្ទាប់ នៅខណៈពេលដែលអង្គជំនុំជម្រះកំពុងរៀបចំធ្វើសេចក្តីសម្រេច គឺជាបញ្ហាដែលត្រូវពិចារណា ។ ការិយាល័យសហព្រះរាជអាជ្ញានៅតែគោរពចំពោះរបស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ប៉ុន្តែគ្រាន់តែសំណូមពរឲ្យអង្គជំនុំជម្រះលើកយកមកជំនុំជម្រះនូវអង្គហេតុនៃបទចោទដែលតំណាងសមស្របឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ ។ ចំពោះសំណួរទី៣របស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា ខេលី បានបញ្ជាក់ថា សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទេ ប៉ុន្តែ អ្វីដែលសហព្រះរាជអាជ្ញាពុំយល់ស្រប គឺវិសាលភាពដែលមានកំណត់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ ដោយសារដីកានេះពុំបានគោរពតាមយុត្តិសាស្ត្រអន្តរជាតិ ។ ដូច្នេះអង្គជំនុំជម្រះត្រូវតែជ្រើសរើសអង្គហេតុមកជំនុំជម្រះដែលអាចតំណាងឲ្យដីកាដំណោះស្រាយទាំងមូល និងពិចារណាលើកាលៈទេសៈជាក់ស្តែង ដូចជាស្ថានភាពសុខភាពរបស់ជនជាប់ចោទដែរ ។

### ៣.ខ) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានឆ្លើយតបនឹងសំណួរទី៣របស់អង្គជំនុំជម្រះ ដោយបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រចំពោះសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការដាក់បន្ថែមអង្គហេតុមួយចំនួនទៅក្នុងសំណុំរឿង០០២/០១ ដោយត្រូវមើលលើស្ថានភាពជាក់ស្តែងទាក់ទងនឹង ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងហិរញ្ញវត្ថុដើម្បីដំណើរការនីតិវិធីជំនុំជម្រះ ។

**សំណួរទី៤ :** ប្រសិនបើលោក លោកស្រីនៅតែរក្សាការស្នើសុំរបស់ខ្លួនក្នុងការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ តើការស្នើសុំនេះកម្រិតត្រឹមការបន្ថែមលើការចោទប្រកាន់ផ្នែកអង្គហេតុដែលទាក់ទងនឹងមន្ទីរស-២១ និងស្រុក១២ ដែរឬទេ? ឬក៏លោក លោកស្រីពិចារណាអំពីការណែនាំក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការធានាអំពីភាពជាតំណាងបទចោទឲ្យបានគ្រប់គ្រាន់ ដើម្បីតម្រូវឲ្យមានបទចោទជាច្រើនក្នុងលក្ខណៈទូលំទូលាយដែរឬទេ? ដោយសារតែមន្ទីរស-២១ និងស្រុក១២សំដៅលើវិសាលភាពភូមិសាស្ត្រមានកម្រិតមួយ និងបញ្ចូលតែផ្នែកតូចមួយនៃការវង្គ្រោះទាំងមូលនៅក្នុងសំណុំរឿង០០២ ព្រមទាំងបង្ខំឲ្យអង្គជំនុំជម្រះស្តាប់សា-ជាថ្មីនូវការចោទប្រកាន់ទាក់ទិនតែនឹងទីតាំងឧក្រិដ្ឋកម្មតែមួយដែលត្រូវបានសម្រេចនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារហូតមកទល់ពេលនេះ ។ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតសំណុំរឿង០០២/០១ ជាសំខាន់ទៅលើការផ្លាស់ទីលំនៅដោយបង្ខំ ដោយផ្អែកលើមូលដ្ឋានដែលថា បាតុភូតនេះប៉ះពាល់ជាសំខាន់ចំពោះជនរងគ្រោះស្ទើរតែទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជាអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សូមលោកលោកស្រីផ្តល់យោបល់ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីសេចក្តីតម្រូវដែលបានកំណត់អំពីភាពជាលក្ខណៈតំណាងនេះ ។

### ៤.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

ទោះបីជានៅក្នុងសំណើជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាធ្លាប់បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យដាក់បញ្ចូលបន្ថែមអង្គហេតុទាក់ទងនឹងការសម្លាប់មនុស្សនៅមន្ទីរស-២១ និងស្រុក១២ចូលក្នុងសំណុំរឿង០០២/០១ក៏ដោយ នៅក្នុងសវនាការសហព្រះរាជអាជ្ញាបានផ្លាស់ប្តូរជំហរដោយស្នើសុំឲ្យដាក់បញ្ចូលត្រឹមតែអង្គហេតុទាក់ទងនឹងមន្ទីរស-២១តែមួយប៉ុណ្ណោះ ។

ចំពោះសំណួរទី៤របស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញាបានឆ្លើយតបយ៉ាងច្រើន ដោយពន្យល់អំពីហេតុផលដែលនាំឲ្យ

មានការស្នើសុំដាក់បញ្ចូលបន្ថែមអង្គហេតុទាក់ទងនឹងការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខស-២១ ចូលក្នុងសំណុំរឿង០០២/០១ ។ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានអះអាងថា ការដាក់អង្គហេតុទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខស-២១ ចូលទៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី នឹងធ្វើឲ្យមានការកើនឡើងនូវភាពជាតំណាងឲ្យបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ ។ម្យ៉ាងវិញទៀត មន្ទីរសន្តិសុខស-២១ ក៏មានការជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានលក្ខណៈទូលំទូលាយ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពាន់យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ដូច្នេះការដាក់បន្ថែមនូវមន្ទីរសន្តិសុខស-២១ចូលក្នុងសំណុំរឿង០០២/០១ នឹងអនុញ្ញាតឲ្យមានការចោទប្រកាន់បន្ថែមទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ សហព្រះរាជអាជ្ញា ខេលី បានផ្ដល់ហេតុផលទៀតថា មន្ទីរសន្តិសុខស-២១ គឺជាទីតាំងមួយដែលមានឧក្រិដ្ឋកម្មកើតឡើងយ៉ាងច្រើនជាងទីតាំងផ្សេងទៀតនៅទូទាំងប្រទេស ដោយសារតែមានជនរងគ្រោះជាច្រើនដែលត្រូវបានចាប់ខ្លួនមកពីភូមិភាគផ្សេងៗ ហើយបញ្ជូនទៅទីនោះ ។ ជាងនេះទៅទៀត មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខ ដែលសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា, របាយការណ៍ស្ដីពីការគ្រប់គ្រងនៅទីនោះត្រូវបានបញ្ជូនទៅមេដឹកនាំជាន់ខ្ពស់, សកម្មភាពដែលបានប្រព្រឹត្តមានទំហំជាលក្ខណៈជាតិ ហើយមេដឹកនាំជាន់ខ្ពស់ និងកម្មាភិបាលសំខាន់ៗត្រូវបានចាប់ខ្លួនបញ្ជូនទៅទីនោះ ។

សហព្រះរាជអាជ្ញា ខេលី បានបញ្ជាក់ចុងក្រោយថា សារសំខាន់នៃសំណុំរឿង០០២ គឺទាក់ទងនឹងការចាប់ខ្លួន ការធ្វើទារុណកម្ម និងអំពើមនុស្សឃាត ដែលបានកើតឡើងនៅតាមបណ្ដាមន្ទីរសន្តិសុខនានា ។ ជនជាប់ចោទទាំងអស់ត្រូវបានចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលកើតឡើងនៅតាមមន្ទីរសន្តិសុខចំនួន១១កន្លែង ហើយមន្ទីរសន្តិសុខស-២១ក៏ស្ថិតនៅក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់នោះដែរ និងមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

## ៤.១) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ជាថ្មីម្ដងទៀត សហមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ បានគាំទ្រការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណួរទី៤នេះ និងបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងគួរតែដាក់បញ្ចូលនូវអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ដោយសារតែជនរងគ្រោះដែលបានជាប់ឃុំឃាំងនៅទីនោះ រួមមាន លោក ជុំ ម៉ី និងលោក ប៊ូ ម៉េង ទន្ទឹមរង់ចាំយុត្តិធម៌ជាយូរណាស់មកហើយ ។ ម្យ៉ាងវិញទៀត អ្នកទាំងពីរសុទ្ធតែមានវ័យចាស់ជរា ដូច្នេះការដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខចូលក្នុងសំណុំរឿង០០២/០១អាចនឹងផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះដែលធ្លាប់ជាប់ឃុំឃាំងនៅទីនោះបានឆាប់រហ័សនៅពេលដែលអ្នកទាំងនោះកំពុងនៅរស់រានមានជីវិត ។

**បញ្ជាក់** ៖ ដូចមានរៀបរាប់នៅខាងដើម ក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុមត្រូវបានអង្គជំនុំជម្រះផ្ដល់ឱកាសដើម្បីឆ្លើយតបនឹងចម្លើយរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយចំពោះសំណួរទាំងបួនខាងលើ ប៉ុន្តែក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុមហាក់បីដូចជា ពុំបានឆ្លើយតបជាក់លាក់ចំពោះចម្លើយទាំងនោះឡើយ ។ ជំនួសមកវិញ ក្រុមមេធាវីការពារក្ដីទាំងបីក្រុម បានធ្វើការកត់សម្គាល់ចំពោះចំណុចផ្សេងៗជាច្រើនដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយ និងបានស្នើសុំអង្គជំនុំជម្រះឲ្យបើកសវនាការលើសំណុំរឿង០០២ទាំងមូលតែម្ដងដោយពុំចាំបាច់មានការបំបែកកិច្ចដំណើរការនីតិវិធី ។

មេធាវីអន្តរជាតិការពារក្ដីឲ្យជនជាប់ចោទ នួន ជា គឺលោក វិចទ័រ កុបប៉េ បានជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យមានការដាក់បន្ថែមអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខយកមកជំនុំជម្រះនៅក្នុងសវនាការដំណាក់កាលដំបូង ដោយសារតែការដាក់ចូលបន្ថែមមន្ទីរសន្តិសុខតែមួយពុំបានតំណាងឲ្យបទចោទទាំងមូលដែលមាននៅក្នុងដីកាដំណោះស្រាយដូចការលើកឡើងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ។ ដូច្នេះ ដើម្បីភាពងាយស្រួល គប្បីពុំចាំបាច់ធ្វើការបំបែកកិច្ចដំណើរការនីតិវិធីទេ គួរតែជំនុំជម្រះលើសំណុំ

រឿង០០២ទាំងមូលតែម្តង ដើម្បីឲ្យការចោទប្រកាន់តំណាងឲ្យដីកាដំណោះស្រាយទាំងស្រុង ។ ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្លួនក៏អាចការពារខ្លួនពេញលេញចំពោះរាល់បទចោទប្រកាន់ទាំងអស់តែម្តង ។ មេធាវី កុបប៉េ បានលើកឡើងទៀតថា ប្រសិនបើតុលាការធ្វើការបំបែកសំណុំរឿងជាផ្នែកៗ នោះបទចោទប្រកាន់ក៏នឹងត្រូវបំបែកចេញពីគ្នាដែរ ។ ដូច្នេះបទចោទប្រកាន់ទាក់ទងនឹងអំពើប្រល័យពូជសាសន៍នឹងពុំត្រូវបានលើកយកមកដេញដោលនៅក្នុងសវនាការទេ ។ ការដែលពុំដាក់បញ្ចូលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចូលក្នុងសំណុំរឿងវគ្គដំបូងនេះ នឹងធ្វើឲ្យសាធារណជនទូទៅពុំអាចយល់បានអំពីឧក្រិដ្ឋកម្មមួយនេះ ថាតើពិតជាបានកើតឡើងនៅកម្ពុជា ដែរឬយ៉ាងណានោះទេ ។

មេធាវី កុបប៉េ បានអះអាងបន្ថែមទៀតថា ប្រសិនបើអង្គជំនុំជម្រះលើកយកអង្គហេតុទាក់ទងនឹងស-២១មកជំនុំជម្រះនៅក្នុងតំណាក់កាលដំបូងនេះ អាចនឹងធ្វើឲ្យមានការពិចារណាថា អង្គជំនុំជម្រះសាលាដំបូងមានការលម្អៀងចំពោះការសម្រេចម្តងរួចទៅហើយ ដោយសារនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានជឿទាំងស្រុងលើសក្ខីកម្មរបស់ ឌុច ប៉ុន្តែសម្រាប់កូនក្តីរបស់ខ្លួនមិនអាចទទួលយកអ្វីដែល ឌុច និយាយបានទេ ។ ដើម្បីស្នើឲ្យអង្គជំនុំជម្រះទទួលយកសំណើរបស់ខ្លួន មេធាវី កុបប៉េ បានលើកឡើងបន្ថែមទៀតទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយអះអាងថា ប្រសិនបើតុលាការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី នោះសវនាការដំណាក់កាលដំបូងនេះនឹងមានដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតែ១០៦៦នាក់ប៉ុណ្ណោះដែលអាចចូលរួម និងទទួលបានសំណង គឺប្រហែល១ភាគ៤នៃដើមបណ្តឹងរដ្ឋប្ប-វេណីទាំងអស់ ។ ដូច្នេះ ការដែលអង្គជំនុំជម្រះសម្រេចមិនជំនុំជម្រះលើសំណុំរឿង០០២ទាំងមូល អាចនឹងកើតមាននូវការមិនពេញចិត្តសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលពុំទាន់បានចូលរួម ។ ហេតុនេះអង្គជំនុំជម្រះគួរតែជំនុំជម្រះលើអង្គហេតុនៃសំណុំរឿង០០២ទាំងមូល ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលបានសំណងទាំងអស់គ្នា ។

សម្រាប់ក្រុមមេធាវីការពារក្តី អៀង សារី គឺបានគាំទ្រចំពោះការសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី នួន ជា និងបានសង្កត់ធ្ងន់បន្ថែមទាក់ទងនឹងការយល់ឃើញរបស់អ្នកប្រាជ្ញច្បាប់អន្តរជាតិមួយចំនួនចំពោះ កាតព្វកិច្ចរបស់តុលាការជាន់ទាប ដែលត្រូវតែគោរពការបង្គាប់របស់តុលាការជាន់ខ្ពស់ ។ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស បានអះអាងថា តុលាការជាន់ទាបអាចរិះគន់ការសម្រេចសេចក្តីរបស់តុលាការជាន់ខ្ពស់បាន នៅពេលដែលខ្លួនយល់ឃើញថាសេចក្តីបង្គាប់នោះមានកំហុសឆ្គង ហើយមេធាវីក៏អាចបញ្ចេញមតិយោបល់របស់ខ្លួនអំពីបញ្ហានេះបានដែរនៅពេលណាដែលខ្លួនយល់ថា តុលាការកំពូលមានកំហុស ។ មេធាវី កាណាវ៉ាស លើកឡើងចំណុចនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺហាក់បីដូចជាកំពុងបង្ហាញអំពីការមិនពេញចិត្តរបស់ខ្លួនចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលកន្លងទៅខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងហៀបនឹងឈានទៅដល់ការបិទបញ្ចប់ការជំនុំជម្រះសវនាការដំណាក់កាលដំបូងនេះទៅហើយ ។

ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការដាក់បញ្ចូលបន្ថែមអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ដោយសារការព្រួយបារម្ភថាមិនអាចមានសវនាការបន្តបន្ទាប់ពីសំណុំរឿង០០២/០១ ព្រោះជនជាប់ចោទសុទ្ធតែមានវ័យចាស់ជរា ត្រូវបានមេធាវី កាណាវ៉ាស បានឆ្លើយតបខ្លាំងៗថា នៅពេលធ្វើដីកាចោទប្រកាន់លើជនជាប់ចោទនៅក្នុងឆ្នាំ២០០៦ សហព្រះរាជអាជ្ញាខ្លួនឯងបានដឹងហើយថា អាយុប្រជាជនកម្ពុជាជាមធ្យមគឺមានត្រឹមតែ៦០ឆ្នាំ តើហេតុអ្វីបានជាសហព្រះរាជអាជ្ញាព្យាយាមចោទប្រកាន់បទល្មើសយ៉ាងច្រើនលើជនជាប់ចោទធ្វើឲ្យសំណុំរឿង០០២កាន់តែធំ និងស្មុគស្មាញ ដោយមិនគិតអំពីបញ្ហាអាយុកាលរបស់ជនជាប់ចោទ? តើសហព្រះរាជអាជ្ញាធ្លាប់បានគិតអំពីអាយុកាលរបស់ អៀង សារី ដែលមានអាយុ៨២ឆ្នាំ នៅពេលដែលខ្លួនចេញដីកាចោទប្រកាន់ដែរឬទេ? មេធាវី កាណាវ៉ាស បានបន្តទៀតថា សហព្រះរាជអាជ្ញាតែងតែព្យាយាមស្នើឲ្យអង្គជំនុំជម្រះដាក់ចូលបន្ថែមនូវភស្តុតាងថ្មី នៅពេលដែលខ្លួនស្វែងរកឃើញអង្គហេតុថ្មី បន្ទាប់មកក៏ទុកឲ្យអង្គជំនុំជម្រះសាលា

ដំបូងដោះស្រាយទៅវិញ ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាអំពីវិសាលភាពនៃការជំនុំជម្រះដោយខ្លួនឯង ថាតើត្រូវយកដីកាដំណោះស្រាយមកជំនុំជម្រះទាំងមូល ឬផ្នែកណាមួយ ពុំមែនត្រូវយកការគិតរបស់សហព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើការគិតពិចារណានោះទេ ។ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេច ព្រោះអង្គជំនុំជម្រះតុលាការកំពូលផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះសាលាដំបូងរួចហើយ គ្រាន់តែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលនេះត្រូវផ្តល់ហេតុផលឲ្យបានច្បាស់លាស់ ។ ជាចុងក្រោយ មេធាវី កាណាវ៉ាស បានស្នើឲ្យជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលតែម្តង ដើម្បីអាចឲ្យជនជាប់ចោទ អៀង សារី បានដឹងអំពីកិច្ចដំណើរការនីតិវិធីទាំងមូល ។ ការធ្វើដូច្នេះ គឺដើម្បីជៀសវាងការលើកឡើងថា ចំណុចនេះស្ថិតនៅក្នុងវិសាលភាព ហើយចំណុចនោះមិនស្ថិតនៅក្នុងវិសាលភាពដែលធ្វើឲ្យសាក្សីមានការលំបាកក្នុងការឆ្លើយតបនឹងសំណួររបស់ភាគី ។

ចំពោះក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះ ការលើកឡើងរបស់ក្រុមមេធាវីការពារក្តី អៀង សារី និង នួន ជា ប៉ុន្តែបានបញ្ជាក់ថា ខ្លួនមានជំហរផ្សេងបន្តិចពីក្រុមមេធាវីការពារក្តីទាំងពីរ ដោយបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចដោះលែង ខៀវ សំផន ជាបណ្តោះអាសន្នសិន ។ មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន គឺលោក អាកទួរ វ៉ែកកែន បានអះអាងថា ខៀវ សំផន ត្រូវការឲ្យមានការជំនុំជម្រះដោយឆាប់រហ័ស ដោយសារត្រូវការជួបជុំជាមួយនឹងប្រពន្ធកូន នៅពេលដែលអង្គជំនុំជម្រះពុំអាចរកឃើញអំពីពិរុទ្ធភាព ។ ម្យ៉ាងវិញទៀត ស្ថានភាពសុខភាពរបស់ ខៀវ សំផន មិនដូចនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទដទៃទៀតឡើយ ព្រោះ ខៀវ សំផន អាចចូលរួមក្នុងសវនាការជាង៩៩ភាគរយ ដោយបង្ហាញមុខគ្រប់ពេលវេលាដើម្បីទទួលបានការជំនុំជម្រះ និងស្វែងរកយុត្តិធម៌សម្រាប់ខ្លួន ។ មេធាវីបានបន្ថែមទៀតថា ការដែលសវនាការជំនុំជម្រះសេចក្តីមកលើរូប ខៀវ សំផន ត្រូវបានពន្យាពេលដោយសារតែបញ្ហាសុខភាពរបស់ជនជាប់ចោទផ្សេងទៀតនោះ គឺអាចនឹងប៉ះពាល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស ដោយសារ ខៀវ សំផន ត្រូវជាប់ឃុំដោយពុំទទួលបានការជំនុំជម្រះ នៅខណៈពេលដែល ខៀវ សំផន អាចចូលរួមសវនាការបាន ។

មេធាវី វ៉ែកកែន បានបញ្ជាក់ថា ដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ពុំបានផ្តល់ប្រយោជន៍អ្វី



មេធាវី អាកទួរ វ៉ែកកែន

ចំពោះ ខៀវ សំផន ទេ ហើយក៏មិនបានផ្តល់ជាសំណងសម្រាប់ ខៀវ សំផន ដែលបានទទួលរងព្យសនកម្មដោយសារការឃុំខ្លួនអស់រយៈពេលយូរដោយពុំមានការជំនុំជម្រះដែរ ។ ហេតុដូច្នេះ ដើម្បីជាការជួសជុលព្យសនកម្មដែលបានកើតចេញពីការឃុំខ្លួន ខៀវ សំផន នេះ ខ្លួនស្នើសុំឲ្យតុលាការសម្រេចដោះលែង ខៀវ សំផនឲ្យមានសេរីភាពឡើងវិញ ។

បន្ថែមពីលើការលើកឡើងរបស់សហភាគីរបស់ខ្លួន មេធាវីជាតិការពារក្តី ខៀវ សំផន គឺលោក គង់ សំអុន បានអះអាងថា ការបំបែកសំណុំរឿងដោយអង្គជំនុំជម្រះ គឺជាបុរេនិច្ឆ័យដែលបង្ហាញថា អង្គហេតុមួយមានទោស ហើយអង្គហេតុមួយផ្សេងទៀតគ្មានទោស ។ ធ្វើដូច្នេះ គឺជាការរំលោភលើគោលការណ៍សន្មត់ថាគ្មានទោស ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ អង្គជំនុំជម្រះគួរតែជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលតែម្តង ដោយពុំចាំបាច់ធ្វើការបំបែកកិច្ចដំណើរការនីតិវិធី ។

### ២) សំណួរ៤ដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យភាគីទាំងអស់ឆ្លើយបញ្ជាក់

***សំណួរទី៥ :*** *បច្ចុប្បន្ននេះ អ្នកជំនាញ លោកស្រី អេលីហ្សា-ប៉េត បេកខ័រ ត្រូវបានកំណត់កាលបរិច្ឆេទមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងអំឡុងសប្តាហ៍ ដែលចាប់ផ្តើមនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។ គ្រប់ភាគី និងអ្នកជំនាញផ្ទាល់ខ្លួនឯងបានត្រៀមខ្លួនចំពោះការផ្តល់សក្ខីកម្មនេះ ដែលស្ថិតនៅក្រោមការសន្មត់ថា វិសាលភាពនៃការផ្តល់សក្ខីកម្មនេះគួរតែត្រូវបានកម្រិតត្រឹមតែសំណុំរឿង០០២/០១ប៉ុណ្ណោះ ។ វាមិនអាចអនុវត្តទៅបានទេ នៅក្នុងដំណាក់កាលនេះ ដែលតម្រូវឲ្យអ្នកជំនាញ និងគ្រប់ភាគីទាំងអស់ ធ្វើការរៀបចំចំពោះសក្ខីកម្មនេះ ដោយឈរលើមូលដ្ឋានមួយដែលមានលក្ខណៈផ្សេងគ្នាទាំងស្រុងនោះ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមស្នើឲ្យបន្តស្តាប់សក្ខីកម្មរបស់លោកស្រី អេលីហ្សាប៉េត បេកខ័រ និងគ្រប់បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់កាលបរិច្ឆេទឲ្យមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលខាងមុខឆាប់ៗនេះ ដោយឈរលើមូលដ្ឋានវិសាលភាពនៃសវនាការ ដូចដែលបានកំណត់នៅក្នុងដីកាសម្រេចបំបែក កិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធ ។ អង្គជំនុំជម្រះស្នើឲ្យភាគីទាំងអស់ផ្តល់យោបល់លើសំណើនេះ និងផលប៉ះពាល់ជាទូទៅកើតឡើងពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងគ្រប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅមុនការចេញសេចក្តីសម្រេចកែប្រែមួយរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើវិសាលភាពនៃសវនាការនៅក្នុងសំណុំរឿង០០២/០១ ។*

ទាក់ទងនឹងសំណួរទី៥ ភាគីទាំងអស់ហាក់បីដូចជាពុំបានឆ្លើយតបចំៗនឹងសំណួរនេះទេ ទាំងភាគីសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមបានផ្តោតជាសំខាន់លើការកោះហៅសាក្សីមកផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទទៅវិញ ។ មេធាវីការពារក្តី ខៀវ សំផន បានលើកពីសាក្សីពីររូប ដែលអង្គជំនុំជម្រះគ្រោងនឹងកោះហៅមកផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ថា សក្ខីកម្មរបស់សាក្សីទាំងពីររូបនេះអាចនឹងឆ្លើយដាក់បន្ទុកដល់កូនក្តីរបស់ខ្លួន ព្រោះសក្ខីកម្មនេះពុំមែនបង្ហាញត្រឹមតែអត្តចរិតរបស់ ខៀវ សំផន ប៉ុណ្ណោះទេ ប៉ុន្តែអាចទាក់ទងនឹងអង្គហេតុដែលអាចប្រឆាំងនឹងកូនក្តីរបស់ខ្លួនថែមទៀត ។ ហេតុនេះក្រុមមេធាវីការពារក្តី ខៀវ សំផន ស្នើសុំឲ្យតុលាការគួរតែពន្យារពេលសវនាការសួរដេញដោលសាក្សីទាំងពីររូបនេះសិន ។

ឆ្លើយតបនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ឌេល លីសាក់ បានបញ្ជាក់ថា ពុំមានហេតុផលអ្វីដែលត្រូវពន្យារពេលសវនាការសួរដេញដោលសាក្សីទាំងពីររូបដែលនឹងត្រូវមកផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទទេ និងថា ខ្លួនក៏ពុំឃើញថាសក្ខីកម្មទាំងនេះអាចប៉ះពាល់អ្វីទៅដល់វិសាលភាពនៃសំណុំរឿង០០២/០១ដែរ ។ លោក លីសាក់ បន្តទៀតថា ខៀវ សំផន បានប្រឈមនឹងការចោទប្រកាន់ក្នុងសំណុំរឿង០០២ទាំងមូលហើយ សហព្រះរាជអាជ្ញាក៏ពុំបានមើលឃើញថា អត្តចរិតរបស់ ខៀវ សំផន បានផ្លាស់ប្តូរដោយផ្អែកលើមូលដ្ឋានថា តើអង្គហេតុទាក់ទងនឹងមន្ទីរស-២១ត្រូវបានដាក់បញ្ចូល ឬមិនដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿងដែរ ។ ប៉ុន្តែ ប្រសិនជាមានព័ត៌មានថ្មីដែលកើតចេញពីការផ្តល់សក្ខីកម្មរបស់សាក្សី ហើយមេធាវីគិតថា ប៉ះពាល់ដល់កូនក្តីរបស់ខ្លួន ពេលនោះមេធាវីអាចដាក់សំណើជំទាស់បាន ។ ដូច្នេះ អង្គជំនុំជម្រះគួរតែបន្តសវនាការសួរដេញដោលសាក្សីទាំងពីររូបនេះ ។

រីឯ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញអំពីជំហររបស់ខ្លួនថា ដំណើរការសវនាការគួរតែបន្តទៅតាមការគ្រោងទុករបស់អង្គជំនុំជម្រះ ដោយសារតែការពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ គឺជារឿងចាំបាច់ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីពុំគួរក្លាយជាឧបសគ្គក្នុងការសួរដេញដោលលើសាក្សីទាំងអស់នោះទេ ។

ក្រុមមេធាវីការពារក្តី អៀង សារី បានផ្តល់យោបល់ចំពោះបញ្ហានេះថា ដោយសារតែដំណាក់កាលនេះ សំណុំរឿង០០២នៅតែពុំទាន់មានការកំណត់អំពីវិសាលភាព ដូច្នេះប្រសិនបើមាន

ការបើកសវនាការសួរដេញដោលសាក្សីមុនពេលចេញសេចក្ដីសម្រេចអំពីវិសាលភាពអង្គហេតុដែលនឹងលើកយកមកសួរដេញដោលគឺត្រូវលើកយកពីដីកាដំណោះស្រាយទាំងមូល ។ ក្រុមមេធាវីការពារក្ដី អៀង សារី ស្នើថា ការសួរដេញដោលលើសាក្សីអំពីអត្តចរិតរបស់ជនជាប់ចោទ គួរតែធ្វើឡើងនៅក្រោយពេលអង្គជំនុំជម្រះ ដោះស្រាយបញ្ហាវិសាលភាពសំណុំរឿង០០២ រួចរាល់ជាមុនសិន ។

ជាចុងក្រោយ ក្រុមមេធាវីការពារក្ដី នួន ជា បានស្នើទៅអង្គជំនុំជម្រះថា ពុំគួរមានការសួរដេញដោលសាក្សីណាមួយនៅមុនពេលដែលអង្គជំនុំជម្រះចេញសេចក្ដីសម្រេចអំពីវិសាលភាពនៃសំណុំរឿង០០២ឡើយ ។ ប្រសិនបើចាំបាច់ អង្គជំនុំជម្រះអាចចេញនូវសេចក្ដីសម្រេចមួយ ហើយបន្ទាប់មកអាចផ្ដល់សំអាងហេតុពេញលេញជាក្រោយ ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះពុំគួរសាកសួរសាក្សីដែលឆ្លើយបញ្ជាក់អំពីភស្តុតាងទាំងឡាយណាដែលពុំស្ថិតនៅក្នុងអង្គហេតុដែលត្រូវបានកំណត់ ព្រោះដើម្បីឲ្យមេធាវីមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់បញ្ហាទាំងឡាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ។

**សំណួរទី៦** ៖ ទាក់ទងនឹងការពង្រីកវិសាលភាពណាមួយនៃសំណុំរឿង០០២/០១ ដែលកំពុងនៅជាសំណើ សូមលោក លោកស្រីបង្ហាញពីចំនួនឯកសារ សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប៉ុន្មាន (ដោយរួមបញ្ចូលទាំងការកោះហៅបុគ្គលដែលបានស្ដាប់សក្ខីកម្មរួចហើយផង) ដែលតម្រូវឲ្យដាក់ ឬកោះហៅដើម្បីជាការគាំទ្រ ឬបដិសេធចោលនូវសំណើសុំទាំងនេះ ។ តើពេលណាជាកាលបរិច្ឆេទឆាប់រហ័សបំផុតដើម្បីអាចឲ្យលោក លោកស្រី រៀបចំខ្លួនដើម្បីលើកឡើង និងបង្ហាញអំពីឯកសារបន្ថែមទាំងនេះនៅក្នុងសវនាការប្រសិនបើចាំបាច់?

### ៦.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

ឆ្លើយតបនឹងសំណួរទី៦របស់អង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានពន្យល់លម្អិតទាក់ទងនឹងឯកសារ និងសាក្សី ដែលសហព្រះរាជអាជ្ញាគ្រោងនឹងដាក់បញ្ចូលបន្ថែម និងកោះហៅ នៅក្នុងករណីដែលអង្គហេតុពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខស-២១ ត្រូវបានដាក់បញ្ចូលទៅក្នុងការជំនុំជម្រះដំណាក់កាលទីមួយនេះ ។ តំណាងសហព្រះរាជអាជ្ញារូបនេះបានធ្វើការបែងចែកការដាក់បង្ហាញជាពីរដំណាក់កាល ។ ទី១ គឺការបង្ហាញទាក់ទងនឹងឯកសារស-២១ ដែលនឹងដាក់បញ្ចូលបន្ថែម និងទី២ គឺចំនួនសាក្សីដែលនឹងត្រូវកោះហៅមកផ្ដល់សក្ខីកម្មទាក់ទងនឹងអង្គហេតុស្ដីពីស-២១ ។

ទាក់ទងនឹងឯកសារអាចនឹងដាក់បញ្ចូលបន្ថែម តំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា មានឯកសារថ្មីប្រមាណ២០០នឹងត្រូវដាក់បន្ថែម រីឯចំនួនសាក្សីដែលនឹងត្រូវកោះហៅគឺមានចំនួនមិនច្រើនឡើយ ។ ដូច្នេះ ចំនួនថ្ងៃនៃសវនាការដែលនឹងត្រូវធ្វើអាចនឹងត្រូវបន្ថែមចំនួន១២ថ្ងៃទៀត ។

### ៦.ខ) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ចំណែកឯសហមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ បានបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលទាក់ទងនឹងអង្គហេតុស-២១ គឺមានចំនួន១៣៨រូប ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីដែលខ្លួនមានបំណងចង់ស្នើសុំអង្គជំនុំជម្រះសួរដេញដោលមានចំនួនតិចជាងនេះ ហើយអាចនឹងចំណាយពេលពី៣ទៅ៥ថ្ងៃ ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងជូនដំណឹងអង្គជំនុំជម្រះបន្ថែមទៀតនៅក្នុងករណីដែលអង្គជំនុំជម្រះយល់ព្រមដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរស-២១ ចូលក្នុងសវនាការដំណាក់កាលដំបូងនេះ ។

### ៦.គ) ការឆ្លើយសំណួររបស់មេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុម

ឆ្លើយតបនឹងសំណួរទី៦របស់អង្គជំនុំជម្រះ ក្រុមមេធាវីការពារក្ដី នួន ជា បានបញ្ជាក់ថា ប្រសិនបើអង្គជំនុំជម្រះសម្រេចដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ចូលទៅក្នុងសំណុំរឿងដែលនឹងលើកយកមកជំនុំជម្រះ នោះនឹងត្រូវចំណាយពេលច្រើនបន្ថែមទៀតដើម្បីស្វែងយល់អ្វីដែលបានកើតឡើងនៅទីនោះ ។ មេធាវីអន្តរជាតិការពារក្ដី នួន ជា បានបញ្ជាក់ថា នៅក្នុងសំណុំរឿង០០១ ឌុច បានសារភាពថា ខ្លួនបានប្រព្រឹត្តកំហុស ដោយពុំមានការពិភាក្សាលម្អិតអំពីអ្វីដែលបានកើតឡើងនៅទីនោះឡើយ ។ បន្ថែមពីលើនេះ អ្នកស៊ើបអង្កេតនៅពេលនោះ

បានបដិសេធដោយពុំពិចារណាអំពីវត្តមាននៃខ្មាំងផ្ទៃក្នុងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានភស្តុតាងអំពីការសម្លាប់ដោយពុំមានការបញ្ជាចំពោះខ្មាំងទាំងនោះក៏ដោយ ។ សម្រាប់ចំនួនឯកសារ និងសាក្សីថ្មីៗ មេធាវីការពារក្តីនួន ជា ពុំទាន់អាចផ្តល់ការបញ្ជាក់អំពីចំនួនជាក់លាក់បាននៅឡើយទេ ដោយសារខ្លួនគិតថា សំណើនេះគ្រាន់តែស្នើឲ្យមានការបញ្ជាក់ជាបឋមអំពីចំនួនឯកសារដែលទាក់ទងតែប៉ុណ្ណោះ ។

សម្រាប់ក្រុមមេធាវីការពារក្តី អៀង សារី បានឆ្លើយបញ្ជាក់ខ្លីប៉ុណ្ណោះចំពោះសំណួរទី៦នេះ ។ មេធាវីអន្តរជាតិការពារក្តី អៀង សារី បានពន្យល់ថា ប្រសិនជាមានការពង្រីកវិសាលភាពនៃការជំនុំជម្រះមែន ការកោះហៅសាក្សីបន្ថែមទៀតដើម្បីមកផ្តល់សក្ខីកម្មគឺជារឿងចាំបាច់ដែលត្រូវតែធ្វើ ។ ប៉ុន្តែនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ពុំគួរមានការកោះហៅសាក្សីដើម្បីមកផ្តល់សក្ខីកម្មទេ ប្រសិនបើបញ្ហាវិសាលភាព នៃសំណុំរឿងពុំទាន់ត្រូវបានដោះស្រាយរួចរាល់ ។

រីឯក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់យ៉ាងខ្លីចំពោះសំណួរនេះថា ខ្លួនពុំមានសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខស-២១ទេ ប៉ុន្តែខ្លួនសុំរក្សាសិទ្ធិក្នុងការកោះហៅសាក្សី បន្ថែមប្រសិនបើចាំបាច់ ។

***សំណួរទី៧*** : *អង្គជំនុំជម្រះបានបង្ហាញអំពីចេតនារបស់ខ្លួនដើម្បីបន្តសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបញ្ចប់សំណុំរឿង០០២/០១ ។ ដោយសារតែការចោទប្រកាន់ទាំងអស់ផ្នែកអង្គហេតុ ទាក់ទងនឹងការជំនុំជម្រះតូចៗនីមួយៗ ដែលអាចកើតមាននៅក្នុងសំណុំរឿង០០២ បង្កើតបានជាដីកាបញ្ជូនរឿងទៅជំនុំជម្រះរួម តើអង្គជំនុំជម្រះអាចបន្តសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ ដែរឬទេ (ក្រោយការឈប់សម្រាករបស់តុលាការ ដែលអនុញ្ញាតឲ្យភាគីរៀបចំបានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះតូចៗជាបន្តបន្ទាប់ និងស្របគ្នានឹងការធ្វើសេចក្តីព្រាងសាលក្រមក្នុងសំណុំរឿង០០២/០១)?*

### ៧.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

ឆ្លើយតបនឹងសំណួរទី៧របស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា អេនឡូ ខេលី បានបញ្ជាក់ថា សម្រាប់ភាគីសហព្រះរាជអាជ្ញា សវនាការជំនុំជម្រះលើសំណុំរឿង០០២ទំនងជានឹងមិនអាចមាននៅដំណាក់កាលក្រោយៗបន្ទាប់ពីសំណុំរឿង០០២/០១ទេ ហើយការដំណើរការសវនាការលើសំណុំរឿង០០២/០២ ដោយពុំមានសាលក្រមលើសំណុំរឿង០០២/០១ អាចនឹងបង្កភាពលំបាកផ្នែកបច្ចេកទេសដែលនឹងត្រូវគិតអំពីលទ្ធផលនៃសាលក្រមនោះ ។ ទោះបីជាអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថាសាលក្រមលើសំណុំរឿង ០០២/០១ ជាប់ទាក់ទងនឹងសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះពុំបានពន្យល់ជាក់លាក់ថាតើសាលក្រមលើសំណុំរឿង០០២/០១ នឹងត្រូវប្រើប្រាស់ក្នុងសំណុំរឿង០០២/០២ដោយរបៀបណានោះទេ ។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះក៏ពុំទាន់បានបង្ហាញអំពីផែនការទូទៅដែលបញ្ជាក់អំពីវិធីសាស្រ្តដើម្បីដំណើរការសំណុំរឿង០០២/០២ ឬសវនាការលើសំណុំរឿង០០២ទាំងមូលនៅឡើយដែរ ។

សហព្រះរាជអាជ្ញា ខេលី បន្ថែមទៀតថា ក្រោយពីមានសាលក្រមលើសំណុំរឿង០០២/០១ ទំនងជានឹងមានបណ្តឹងឧទ្ធរណ៍ ដែលនឹងប្តឹងជំទាស់នឹងសាលក្រមនេះ ។ ដូច្នេះវ័យចាស់ជរា រួមជាមួយបញ្ហាសុខភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះគប្បីត្រូវយកមកពិចារណានូវបទចោទប្រកាន់ណាដែលតំណាងឲ្យដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះនឹងលើកយកមកបើកសវនាការនៅដំណាក់កាលដំបូងនេះ ។

### ៧.ខ) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សម្រាប់សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានបញ្ជាក់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងបញ្ហានេះ ប៉ុន្តែមានចំណុចខ្លះដែលខ្លួនចង់បន្ថែមទាក់ទងនឹងការមានអង្គជំនុំជម្រះសាលាដំបូងមួយទៀត ដើម្បីជំនុំជម្រះលើសំណុំរឿង០០២/០២ នៅអំឡុងពេលដែលអង្គជំនុំជម្រះសាលាដំបូងទីមួយកំពុងដកខ្លួនទៅពិចារណាដើម្បីសម្រេចសេចក្តីលើសំណុំរឿង០០២/០១ ទៅតាមការលើកឡើងរបស់អង្គជំនុំជម្រះតុលាការកំពូល ។ លោកស្រីមេធាវី

បានបញ្ជាក់ថា ការធ្វើដូច្នេះ គឺនឹងពុំមានប្រសិទ្ធភាពឡើយ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងទីពីរនឹងពុំយល់អំពីកិច្ចដំណើរការនីតិវិធីដែលធ្លាប់ធ្វើកន្លងមកទេ ។ ដូច្នេះនឹងត្រូវចំណាយពេលវេលាច្រើនបន្ថែមទៀត ទម្រាំអង្គជំនុំជម្រះសាលាដំបូងទី២អាចសម្របខ្លួនបានជាមួយនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ។ ដូច្នេះ ជម្រើសដែលល្អអង្គជំនុំជម្រះគប្បីទុកពេលវេលាដើម្បីចេញសាលក្រមសម្រេចសេចក្តីវិញ ។

### ៧.ក) ការឆ្លើយសំណួររបស់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម

ឆ្លើយតបនឹងសំណួរទី៧របស់អង្គជំនុំជម្រះ ក្រុមមេធាវីការពារក្តី នួន ជា បានអះអាងថា ការបន្តបើកសវនាការសំណុំរឿង



វិចទ័រ កុបប៉េ មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា

០០២/០២ មុនពេលអង្គជំនុំជម្រះចេញសាលក្រមលើសំណុំរឿង០០២/០១ គឺជារឿងដែលពុំអាចទៅរួច ដោយសារតែភាពពាក់ព័ន្ធនៃសំណុំរឿងទាំងពីរនេះ ។ អង្គជំនុំជម្រះគួរតែទុកពេលវេលាដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន ហើយភាគីទាំងអស់ក៏មានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំឯកសារសម្រាប់សំណុំរឿង០០២/០២ ។

ក្រុមមេធាវីការពារក្តី អៀង សារី បានឆ្លើយតបចំពោះសំណួរទី៧នេះថា បើតាមទ្រឹស្តី នៅពេលបញ្ចប់សំណុំរឿង០០២/០១ អង្គជំនុំជម្រះត្រូវតែបន្តជំនុំជម្រះលើសំណុំរឿងបន្ទាប់មក ទៀត ព្រោះអង្គជំនុំជម្រះពុំអាចទម្លាក់បទចោទប្រកាន់បន្ទាប់ពីខ្លួនបញ្ចប់សវនាការវគ្គដំបូងនេះទេ ។ ប៉ុន្តែអ្វីដែលជាបញ្ហាចោទ គឺការរៀបចំផែនការសម្រាប់បើកសវនាការនាវគ្គបន្តទៀត ព្រោះអង្គជំនុំជម្រះមិនត្រឹមតែត្រូវពិចារណាអំពីផែនការតែមួយប៉ុណ្ណោះទេ គឺត្រូវពិចារណាទាំងបញ្ហាហិរញ្ញវត្ថុ និងបញ្ហាសុខភាពរបស់ជនជាប់ចោទ ។

ចំពោះក្រុមមេធាវីការពារក្តី ខៀវ សំផន បានឆ្លើយសំណួរនេះយ៉ាងខ្លីថា ខ្លួនពុំគិតថា ការបន្តបើកសវនាការសំណុំរឿង០០២/០២ មុនពេលអង្គជំនុំជម្រះចេញសាលក្រមលើសំណុំរឿង០០២/០១ អាចនឹងធ្វើទៅរួចទេ ព្រោះបើមើលលើបញ្ហានានាដែលភាគីបានលើកយកមកពិភាក្សា ។

**សំណួរទី៨** ៖ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថា ការចោទប្រកាន់ដែលនៅសេសសល់ទាំងអស់នៅក្នុងសំណុំរឿង០០២ មិនមែនមិនបន្ត ដោយសារតែដីកាសម្រេចនេះទេ ប៉ុន្តែការចោទប្រកាន់ដែលនៅសេសសល់ទាំងនោះ គឺជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីនាពេលអនាគត ប្រសិនបើកាលៈទេសៈអនុញ្ញាត ។ តើផលប្រយោជន៍អ្វីខ្លះដែលបន្ថែមដល់ភាគីនានាអំពីការកំណត់កាលបរិច្ឆេទច្បាស់លាស់នៃការជំនុំជម្រះជាបន្តបន្ទាប់ទាំងនេះ នៅពេលដែលការអនុវត្តដូចនេះ ពឹងផ្អែកទាំងស្រុងលើយថាភាពដែលមិនអាចដឹងច្បាស់(រួមមានទាំងការបន្តមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទទាំងអស់ក្នុងការចូលរួមសវនាការ, ការផ្តល់ជំនួយរបស់អ្នកផ្តល់ជំនួយដើម្បីគាំទ្រដល់ការជំនុំជម្រះនាពេលអនាគត និងសម្មតិកម្មដែលថា សវនាការជាបន្តទៀតអាចត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងមួយផ្សេងទៀតនោះ) ?

### ៨.ក) ការឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញាបានឆ្លើយតបចំពោះសំណួរទី៨របស់អង្គជំនុំជម្រះ ដោយលើកឡើងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដោយពុំស្តាប់មតិយោបល់របស់ភាគី ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចេញមតិយោបល់ ។ សហព្រះរាជអាជ្ញា ខេលី បានបន្តថា ជំហររបស់ការិយាល័យសហព្រះរាជអាជ្ញា គឺចង់ឲ្យមានការដាក់ចូលនូវអង្គហេតុបន្ថែមទៅក្នុងការជំនុំជម្រះតំណាក់

កាលដំបូង ដើម្បីធ្វើយ៉ាងណាឲ្យបទចោទដែលត្រូវលើកយកមកជំនុំជម្រះក្នុងសវនាការដំណាក់កាលដំបូងនេះ អាចតំណាងសមស្របឲ្យបទចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយ ។ ចំពោះការលើកឡើងរបស់អង្គជំនុំជម្រះតុលាការកំពូលស្នើឲ្យមានអង្គជំនុំជម្រះសាលាដំបូងមួយទៀត សហព្រះរាជអាជ្ញាខេលី យល់ឃើញថា ការលើកឡើងរបស់តុលាការកំពូលនឹងពុំអាចដំណើរការបានទេនៅក្នុងកាលៈទេសៈបច្ចុប្បន្ន ដោយសារតែបញ្ហាអាយុរបស់ជនជាប់ចោទ និងបញ្ហាហិរញ្ញវត្ថុរបស់តុលាការ ។

## ៨.ខ) ការឆ្លើយសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ឆ្លើយតបចំពោះសំណួរទី៨របស់អង្គជំនុំជម្រះ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលី-ហ្សបែ៊ត ស៊ីម៉ូណូហ្វត បានបង្ហាញជំហររបស់ខ្លួនថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី មានគោលជំហរខុសពីសហព្រះរាជអាជ្ញាបន្តិច ដោយបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកំណត់ឲ្យបានជាក់លាក់ចំពោះកាលវិភាគសម្រាប់ពេលអនាគត ព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានរង់ចាំការពន្យល់របស់អង្គជំនុំជម្រះអស់រយៈពេល១៦ខែមកហើយ ទាក់ទងនឹងផែនការរបស់អង្គជំនុំជម្រះក្នុងការធ្វើសវនាការដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលបានយុត្តិធម៌ ។ មេធាវីរូបនេះបានបន្តទៀតថា ការកំណត់ឲ្យមានភាពច្បាស់លាស់ចំពោះវិសាលភាពនៃសវនាការជំនុំជម្រះសេចក្តី នឹងអាចជួយឲ្យជនរងគ្រោះរបបខ្មែរក្រហមបានទទួលយុត្តិធម៌ ។

## ៨.គ) ការឆ្លើយសំណួររបស់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម

ទាក់ទងនឹងសំណួរទី៨ ក្រុមមេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា ខ្លួនពុំមានអ្វីដែលត្រូវអត្ថាធិប្បាយ បន្ថែមលើចំណុចនេះឡើយ ។

សម្រាប់ក្រុមមេធាវីការពារក្តី អៀង សារី បានឆ្លើយតបចំពោះសំណួរនេះថា សិទ្ធិរបស់ អៀង សារី អាចនឹងត្រូវប៉ះពាល់នាពេលអនាគតប្រសិនបើតុលាការពុំមានការកំណត់កាលបរិច្ឆេទច្បាស់លាស់អំពីការបន្តសវនាការនាពេលអនាគតទេនោះ ។ ប្រហែលអាចជាការប្រសើរ ប្រសិនបើអង្គជំនុំជម្រះរៀបចំផែនការសម្រាប់ការបន្តធ្វើសវនាការនាពេលខាងមុខ ហើយអនុញ្ញាតឲ្យភាគីអាចផ្តល់យោបល់លើផែនការនោះ ។ ក្រុមមេធាវី អៀង សារី បានបន្តទៀតថា មធ្យោបាយមួយដែលអាចជៀសវាងពីការជំទាស់ពីសំណាក់ភាគី ដោយធានាឲ្យបានថា យុត្តិធម៌គឺសម្រាប់ទាំងអស់ ចាំបាច់ត្រូវតែជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលតែម្តង ដោយពុំចាំបាច់បំបែកសំណុំរឿងនេះជាផ្នែកតូចៗទេ ។

ចំពោះក្រុមមេធាវីការពារក្តី ខៀវ សំផន យល់ថា បញ្ហាពុំមែនកើតឡើងដោយសារតែការខកខាន ពុំបានកំណត់អំពីកាលវិភាគច្បាស់លាស់ និងល្អិតល្អន់ដែលរៀបរាប់អំពីសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃទេ ប៉ុន្តែ អ្វីដែលជាបញ្ហាគឺសហព្រះរាជអាជ្ញាបានធ្វើការប៉ាន់ស្មានអំពីរយៈពេលនៃសវនាការស្ងាត់ៗដោយខ្លួនឯង ។ ចំណុចដែលសំខាន់បំផុត គឺថាតើជនជាប់ចោទបានដឹងអំពីរបៀបដែលខ្លួនត្រូវបានជំនុំជម្រះដែរឬទេ? ហើយហេតុអ្វីបានជាខ្លួនត្រូវបាននាំយកមកជំនុំជម្រះ? នេះជារឿងដែលសំខាន់ជាងការកំណត់កាលវិភាគ របស់អង្គជំនុំជម្រះទៅទៀត ។

## ៣) សំណួរ១ដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យភាគីមេធាវីការពារក្តីជនជាប់ចោទឆ្លើយបញ្ជាក់

**សំណួរទី៩** : *តើមោឃភាពលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ មានផលប៉ះពាល់អ្វីខ្លះលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស? ប្រសិនបើមានផលប៉ះពាល់ តើលោក លោកស្រី យល់ឃើញថា មានវិធានការចាំបាច់អ្វីខ្លះ ដើម្បីជៀសវាង ឬដោះស្រាយចំពោះផលប៉ះពាល់ណាមួយដែលកើតឡើង ចំពោះជនជាប់ចោទ ដោយសារតែមោឃភាពលើដីកាសម្រេចបំបែកសំណុំរឿងនេះ?*

**បញ្ជាក់** : សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹង អេលី-ហ្សាបែ៊ត ស៊ីម៉ូណូហ្វត បានស្នើសុំអង្គជំនុំជម្រះឆ្លើយតបចំពោះសំណួរទី៩ ដែលអង្គជំនុំជម្រះមានបំណងចង់ឲ្យក្រុមមេធាវីការពារក្តីទាំងបីក្រុមឆ្លើយតប ។ ចំពោះការស្នើសុំនេះ លោកស្រីមេធាវីបានផ្តល់ហេតុផលថា គឺដើម្បីបង្ហាញអំពីផលប៉ះពាល់ នៃដីកាបំបែកកិច្ចដំណើរការនីតិវិធីចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។

សំណើនេះត្រូវបានអង្គជំនុំជម្រះទទួលយក ដោយអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអំពីផលប៉ះពាល់ដែលបានកើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាសំណួរទី៩ ជាសំណួរសម្រាប់តែភាគីក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទឆ្លើយក៏ដោយ ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានធ្វើការបែងចែកចម្លើយរបស់ខ្លួនជាបីផ្នែកផ្សេងៗគ្នា ដើម្បីឆ្លើយតបនឹងសំណួរទី៩របស់អង្គជំនុំជម្រះ ។ ផ្នែកទី១ នឹងបង្ហាញថា តើការបំបែកនីតិវិធីអាចអនុវត្តចំពោះការកំណត់ប្រភេទនៃបទល្មើសដែរឬទេ? រីឯផ្នែកទី២ នឹងបង្ហាញថា តើមានឥទ្ធិពល ឬមានផលប៉ះពាល់អ្វីខ្លះចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយការបំបែកកិច្ចដំណើរការនីតិវិធី ។ ចំពោះផ្នែកទី៣ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងបង្ហាញឲ្យឃើញអំពីផលប៉ះពាល់ដែលកើតមានទៅលើនីតិវិធីក្នុងការផ្តល់សំណង ដោយសារតែការបំបែកកិច្ចដំណើរការនីតិវិធី ។

ទាក់ទងនឹងផ្នែកទី១ មេធាវី ស៊ីម៉ូណូហ្វត បានពន្យល់ថា សម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ថា ការបំបែកអង្គហេតុ ដោយលើកយកតែអង្គហេតុផ្នែកណាមួយមកជំនុំជម្រះ គឺជារឿងសមហេតុផល ដោយសារក្រោយពេលបញ្ចប់ការសួរដេញដោលទាក់ទងនឹងអង្គហេតុនោះ អង្គជំនុំជម្រះអាចលើកយកបទចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយមកចោទប្រកាន់បាន ។ ប៉ុន្តែ ការដែលអង្គជំនុំជម្រះបានសម្រេចចិត្តបំបែកបទចោទប្រកាន់ ដោយជ្រើសរើសយកតែបទចោទណាមួយមកចោទប្រកាន់នៅក្នុងសវនាការដំណាក់កាលដំបូងនេះ ហើយប្រានចោលបទចោទផ្សេងទៀតដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជារឿងពុំសមស្របទេ ។

រីឯចំណុចទី២ ទាក់ទងនឹងផលប៉ះពាល់នៃការបំបែកកិច្ចដំណើរការនីតិវិធីចំពោះដើមបណ្តឹងរដ្ឋប្បវេណី មេធាវី អេលី-ហ្សាប៊ែត ស៊ីម៉ូណូហ្វត បានលើកឡើងថា ការបំបែកនីតិវិធីមិនគួរមានការបំបែកដើមបណ្តឹងរដ្ឋប្បវេណីចេញពីគ្នានោះទេ ហើយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គួរតែត្រូវបានអនុញ្ញាតឲ្យចូលរួមគ្រប់គ្នា នៅក្នុងសំណុំរឿង០០២ ។ មេធាវីបានបន្តថា ដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងបានរារាំងចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសគឺការចូលរួមជាលក្ខណៈក្រុមរួម ដែលវិធានផ្ទៃក្នុងធ្លាប់បានធ្វើវិសោធនកម្មចំពោះចំណុចនេះ ។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣៨៦៤រូប គប្បីត្រូវបានអនុញ្ញាតឲ្យចូលរួម ទោះបីជាមានដីកាបំបែកកិច្ចដំណើរការនីតិវិធីក៏ដោយ ។

លោកស្រីមេធាវី ស៊ីម៉ូណូហ្វត បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ ចំពោះបញ្ហាដែលដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនពុំត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ដោយសារដើមបណ្តឹងរដ្ឋប្បវេណីដែលពុំត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូងនេះគិតថា ខ្លួនហាក់ដូចជាត្រូវបានប្រានចោលរួចទៅហើយ ។ អង្គជំនុំជម្រះត្រូវតែបញ្ជាក់ថា មិនមានដើមបណ្តឹងរដ្ឋប្បវេណីណាមួយត្រូវបានប្រានចោលដោយសារការបំបែកនីតិវិធីទេ ។ ម្យ៉ាងវិញទៀត គឺដើម្បីបញ្ជាក់ឲ្យបានច្បាស់ចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលបានរៀបចំសំណងរួចទៅហើយ ។

ចំណុចទី៣ ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងទាក់ទងនឹងបញ្ហាសំណង ថាតើការបំបែកសំណុំរឿងអាចប៉ះពាល់ដល់សំណងដែរឬទេ? ចំពោះផ្នែកនេះ មេធាវី ស៊ីម៉ុនណូ-ហ្វត បានបញ្ជាក់អះអាងថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនពុំទទួលបានសំណងដែលនឹងចេញនៅក្នុងសាលក្រមជំនុំជម្រះសេចក្តីក្នុងដំណាក់កាលដំបូង ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ត្រូវបានអង្គជំនុំជម្រះអះអាងថា ពុំជាប់ទាក់ទងនឹងអង្គហេតុដែលត្រូវបានលើកយកមកជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។ ដូច្នេះ ដើម្បីគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដែលវិធានផ្ទៃក្នុងបានចែងឲ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវចូលរួមជាលក្ខណៈសមូហភាព អង្គជំនុំជម្រះត្រូវតែផ្តល់សំណងជូនដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ៗគ្នា ។

### ៩.ក) ការឆ្លើយសំណួររបស់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម

ឆ្លើយតបនឹងសំណួរទី៩របស់អង្គជំនុំជម្រះទាក់ទងនឹងផល

ប៉ះពាល់ចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស បន្ទាប់ពីមានការលុបចោលសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង


មេធាវី ម៉ៃឃើល កាណាវ៉ាស

០០២ ក្រុមមេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា អ្វីដែលប៉ះពាល់គឺក្រុមមេធាវី នួន ជា ពុំទាន់បានត្រៀមឆ្លើយតបទៅនឹងរាល់បទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ ។ ម្យ៉ាងវិញទៀត ក្រុមរបស់ខ្លួនចាំបាច់ត្រូវកោះហៅសាក្សីដែលធ្លាប់បានផ្តល់សក្ខីកម្មរួចហើយ ឲ្យមកផ្តល់សក្ខីកម្មសារជាថ្មីម្តងទៀត ប្រសិនបើខ្លួនយល់ថា ចម្លើយរបស់សាក្សីទាំងនោះគឺជារឿងចាំបាច់ ។

ពាក់ព័ន្ធនឹងសំណួរនេះ ក្រុមមេធាវីការពារក្តី អៀង សារី ហាក់បីដូចជាបានឆ្លើយតបនៅក្នុងចម្លើយទី៨របស់ខ្លួនរួចទៅហើយ ប៉ុន្តែបានបញ្ជាក់បន្ថែមថា នាពេលបច្ចុប្បន្ននេះក្រុមមេធាវីការពារក្តី អៀង សារី ពុំមានទទួលរងផលប៉ះពាល់អ្វីនៅឡើយទេ ហើយខ្លួនអាចបន្តនីតិវិធីជាធម្មតាចំពោះអ្វីដែលមាន ។ ប៉ុន្តែពុំមែនមានន័យថា ក្រុមមេធាវីការពារក្តី អៀង សារី ពុំទទួលរងព្យសនកម្មពីការលុបចោលដីកាបំបែកកិច្ចដំណើរការនោះទេ ដោយសារនៅមានបញ្ហាថា តើក្រុមរបស់ខ្លួននឹងត្រូវការពារក្តីដោយរបៀបណា ក្រោយពេលសំណុំរឿង០០២លែងមានការកំណត់អំពីវិសាលភាព ។

សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបចំពោះសំណួរទី៩នេះថា ការលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ ពិតជាបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ខៀវ សំផន ទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស ទាំងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយស្មើភាពចំពោះមុខច្បាប់ ព្រោះ ខៀវ សំផន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយពុំត្រូវការវិធានការ ពន្លឿនកិច្ចដំណើរការនីតិវិធីណាមួយឡើយ ។ ដើម្បីជាសំណងចំពោះផលប៉ះពាល់នេះ ក្រុមមេធាវី ខៀវ សំផន បានស្នើអង្គជំនុំជម្រះចំនួន២ចំណុច ទី១) ស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចបំបែកជនជាប់ចោទ ខៀវ សំផន ចេញពីការជំនុំជម្រះរួមគ្នាជាមួយជនជាប់ចោទដទៃផ្សេងទៀត ដោយបើកសវនាការជំនុំជម្រះ ខៀវ សំផន ដាច់ដោយឡែក ។ ទី២) ស្នើសុំឲ្យអង្គជំនុំជម្រះដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យជំនួសវិញ ។ ការស្នើសុំនេះ ត្រូវបានក្រុមមេធាវីការពារក្តី ខៀវ សំផន ផ្តល់ហេតុផលថា ស្ថានភាពសុខភាពរបស់ ខៀវ សំផន មិនដូចនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទដទៃទៀតឡើយ ព្រោះ ខៀវ សំផន អាចចូលរួមក្នុងសវនាការជាង៩៩ភាគរយ ដោយបង្ហាញមុខគ្រប់ពេលវេលាដើម្បីទទួលបានការជំនុំជម្រះ និងស្វែងរកយុត្តិធម៌សម្រាប់ខ្លួន ។ ការដែលសវនាការជំនុំជម្រះសេចក្តីមកលើរូប ខៀវ សំផន ត្រូវបានពន្យាពេលដោយសារតែបញ្ហាសុខភាពរបស់ជនជាប់ចោទផ្សេងទៀតនោះ គឺអាចនឹងប៉ះពាល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស ដោយសារ ខៀវ សំផន ត្រូវជាប់ឃុំដោយពុំទទួលបានការជំនុំជម្រះ នៅខណៈពេលដែល ខៀវ សំផន អាចចូលរួមសវនាការបាន ។

បន្ទាប់ពីបានស្តាប់មតិយោបល់ និងចម្លើយរបស់ភាគីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុពេញលេញទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២ ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីគោលបំណងរបស់ខ្លួនចង់បើកសវនាការដើម្បីស្តាប់សក្ខីកម្មសាក្សី ជំនាញ ហ្វីលីព ស៊ត និង អេលីហ្សាប៉ែត បេកក័រ មុនពេលចេញសេចក្តីសម្រេចនេះ ។ ទោះបីជាយ៉ាងណាក្តី រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅតែពុំទាន់បានស្តាប់សក្ខីកម្មរបស់សាក្សីជំនាញទាំងពីររូបនៅឡើយទេ ។

# សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែក កិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២

### *ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣*

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ បន្ទាប់ពីបានស្តាប់មតិយោបល់របស់ភាគីកាលពីខែកុម្ភៈ និងខែមីនា ឆ្នាំ២០១៣ ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនថា ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ សារជាថ្មីម្តងទៀត បន្ទាប់ពីដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចលុបចោលកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣កន្លងទៅ ។ នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីនាពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់អំពីវិសាលភាពនៃសំណុំរឿង០០២/០១ ដូចជា វិសាលភាពដែលខ្លួនបានកំណត់នៅពេលមុនពេលមានសម្រេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីដដែល ។ បទចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងសំណុំរឿង០០២/០១ នៅតែកំហិតត្រឹម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំពីភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលបន្ទាប់ (ដំណាក់កាលទី១ និងទី២) និងការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃភ្លាមៗក្រោយថ្ងៃខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ ។ អង្គជំនុំជម្រះបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំឲ្យដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ទៅក្នុងសំណុំរឿង០០២/០១ ។ ចំពោះសំណើរបស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមដែលស្នើសុំអង្គជំនុំជម្រះឲ្យបើកសវនាការជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលក៏ត្រូវបានបដិសេធដូចគ្នាដែរ ។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធរបស់ខ្លួនចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាថា ប្រសិនបើអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាពង្រីកវិសាលភាពនៃការជំនុំជម្រះដោយដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរស-២១ ចូលទៅក្នុងសំណុំរឿង០០២/០១ ខ្លួននឹងត្រូវការពេលវេលាជាច្រើនខែបន្ថែមទៀត ។ ជាងនេះទៅទៀត អង្គជំនុំជម្រះក៏នឹងត្រូវចំណាយពេលវេលារាប់ឆ្នាំដើម្បីបញ្ចប់សវនាការលើដីកាដំណោះស្រាយទាំងមូល ប្រសិនបើធ្វើតាមសំណើរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមថា បទចោទប្រកាន់ទាំងឡាយដែលត្រូវបានកំណត់វិសាលភាពនៅក្នុងសំណុំរឿង០០២/០១នាពេលនេះ គឺមិនត្រឹមតែមានទំនាក់ទំនងនឹងចំនួនជនរងគ្រោះសំខាន់ៗដ៏ច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុញ្ញាតឲ្យមានការត្រួតពិនិត្យអំពីការចូលរួមរបស់ជនជាប់ចោទនីមួយៗនៅក្នុងការបង្កើតគោលនយោបាយទាក់ទងនឹងការចោទប្រកាន់ទាំងនោះទៀតផង ។ ការកំណត់ដូច្នេះ ក៏អាចរក្សាបាននូវលំដាប់លំដោយពេលវេលាដ៏មានសារៈសំខាន់នៃសំណុំរឿងដែរ ។

អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីការព្រួយបារម្ភរបស់ខ្លួន ចំពោះបញ្ហាសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ ដោយអះអាងថា នៅពេលដែលពេលវេលាបានកន្លងផុតជាច្រើនខែ ជនជាប់ចោទកាន់តែមិនទំនងជាមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការរហូតដល់មានសេចក្តីសម្រេចស្ថាពរលើការចោទប្រកាន់ទាំងអស់ទៅលើជនជាប់ចោទទាំងអស់នោះឡើយ ។ បន្ថែមពីលើនេះ បញ្ហាធ្ងន់ធ្ងរផ្នែកថវិកាបានធ្វើឲ្យអនាគតរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមស្ថិតនៅក្នុងសភាពុំច្បាស់លាស់ ដោយសារពុំទាន់មានការធានាណាមួយពី

សំណាក់ការិយាល័យរដ្ឋបាលរបស់សាលាក្តីនៅឡើយ ។ ដូច្នេះ ប្រសិនបើសវនាការត្រូវបានពន្យាពេលដោយពុំមានការចេញសាលក្រមណាមួយសម្រាប់សំណុំរឿង០០២ទេ ជនរងគ្រោះ និងសាធារណជនច្បាស់ជានឹងអស់សង្ឃឹមយ៉ាងខ្លាំង ។ ភាពមិនប្រាកដប្រជានៃស្ថិរភាពថវិកា បញ្ហាសុខភាពរបស់ជនជាប់ចោទនួន ជា និងវ័យចាស់ជរារបស់ជនជាប់ចោទ ខៀវ សំផន ពិតជាបានជះឥទ្ធិពលលើការសម្រេចមិនធ្វើសវនាការរយៈពេលវែង និងមិនស្តាប់រាល់អង្គហេតុទាំងនោះ ។

ទាក់ទងនឹងការបោះបង់ចោលផ្នែកដែលនៅសេសសល់ក្នុងដីកាដំណោះស្រាយបន្ទាប់ពីបញ្ចប់ការជំនុំជម្រះសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះសាលាដំបូង ពុំមានសិទ្ធិអំណាចក្នុងការសម្រេចយកផ្នែកណាខ្លះនៃការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយមកពិចារណា ឬបោះបង់ចោលមិនពិចារណាផ្នែក ណាខ្លះនៃបទចោទប្រកាន់បានឡើយ ។

ចំពោះផែនការសម្រាប់ការជំនុំជម្រះនៅថ្ងៃខាងមុខ ក្រោយពេលបំបែកកិច្ចដំណើរការនីតិវិធីសារជាថ្មី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនបានរៀបចំផែនការព្រាងរួចជាស្រេចហើយ បន្ទាប់មក នឹងបើកកិច្ចប្រជុំរៀបចំផែនការសវនាការនៅក្នុងត្រីមាសទី៤នៅក្នុងឆ្នាំ២០១៣ ក្រោយពេលមានសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០១ ដើម្បីទុកឱកាសឲ្យភាគីពិភាក្សាអំពីជំហានបន្ទាប់ ។



មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា (ពីឆ្វេងទៅស្តាំរួមមាន ៖ ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ), នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា), អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស), សុន សេន (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ), វន វេត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច)) (ប្រភពរូបថត ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្ដីអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា

## ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣

បន្ទាប់ពីសវនាការត្រូវបានផ្អាកមួយរយៈចាប់ពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៣ រហូតមក ដោយសារបុគ្គលិកផ្នែកបកប្រែភាសាប្រកាសមិនចូលបម្រើការងារព្រោះតែគ្មានប្រាក់បៀវត្សជាច្រើនខែ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការឡើងវិញដើម្បីសួរដេញដោលអ្នកជំនាញពីររូបគឺលោក ចន ខាំប៊ែល និងលោក ស៊ីណា ហ្វាហ្សែល អំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា ។ ក្នុងការសួរដេញដោលនេះ គឺភាគីទាំងអស់បានផ្ដោតសំខាន់ទៅលើរបាយការណ៍ចុងក្រោយចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ដែលបានផ្ដល់ជូនអង្គជំនុំជម្រះដោយអ្នកជំនាញទាំងពីររូបនេះ ដែលបានបញ្ជាក់ថា ជនជាប់ចោទ នួន ជា មានសម្បទាទាំងផ្លូវកាយ និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។

សវនាការនេះប្រព្រឹត្តទៅដោយរលូន ដោយមានប្រជាជនកម្ពុជាចូលរួមតាមដាន ដោយផ្ទាល់ប្រមាណ២០០នាក់ មកពីខេត្តតាកែវ ដោយពុំឃើញវត្តមានរបស់ នួន ជា នៅក្នុងសាលសវនាការឡើយ ។ ពោល គឺ នួន ជា បានស្នើសុំចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ដែលត្រូវបានរៀបចំទុកក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការដោយសារបញ្ហាសុខភាព ។ ចំពោះនីតិវិធីក្នុងការសួរដេញ ដោលអ្នកជំនាញទាំងពីររូប គឺបានធ្វើតាមលំដាប់ដោយចាប់ផ្ដើមពីចៅក្រមនៃអង្គជំនុំជម្រះ ក្រុមមេធាវី ការពារក្ដីជនជាប់ចោទ នួន ជា តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។ ចុងក្រោយ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ពាក់ព័ន្ធនឹងសមត្ថភាពរបស់ នួន ជា ក្នុងការចូលរួមសវនាការ ។

### ១) សវនាការស្ដីអំពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

ក្នុងការសួរដេញដោលអ្នកជំនាញអំពីស្ថានភាពសុខភាពរបស់ នួន ជា ភាគីទាំងអស់ រួមទាំងចៅក្រមនៃអង្គជំនុំជម្រះ បានផ្ដោតសំខាន់ទាំងសម្បទាផ្លូវកាយ និងសម្បទាផ្លូវចិត្តរបស់ជនជាប់ចោទក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ ចុងក្រោយអ្នកជំនាញទាំងពីររូប គឺត្រូវបានស្នើឲ្យផ្ដល់អនុសាសន៍មួយចំនួនដើម្បីធ្វើយ៉ាងណាឲ្យសុខភាពរបស់ នួន ជា មានភាពប្រសើរឡើង និងអាចចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព ។

### ១.១) សម្បទាផ្លូវកាយរបស់ជនជាប់ចោទ នួន ជា

យោងតាមរបាយការណ៍ចុងក្រោយចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ និងសក្ខីកម្មរបស់អ្នកជំនាញនៅចំពោះមុខអង្គជំនុំជម្រះបានបង្ហាញថា ជំងឺផ្លូវកាយរបស់ នួន ជា ពាក់ព័ន្ធនឹងការរលាកទងសួត សម្ពាធឈាមឡើងខ្ពស់ ជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ជំងឺបេះដូង ការចុះខ្សោយផ្នែកសាច់ដុំ ។ល ។ គឺពុំមែនជាក្ដីបារម្ភទៀតឡើយ ។ ពោល ជំងឺមួយចំនួនដូចជា ការរលាកទងសួត ការដាច់សរសៃឈាម ក្នុងខួរក្បាល គឺត្រូវបានព្យាបាលជាសះស្បើយរួចហើយ ហើយជំងឺមួយចំនួនទៀតដូចជា សម្ពាធឈាម ឡើងខ្ពស់ ការចុះខ្សោយផ្នែកសាច់ដុំ...គឺពុំមែនបញ្ហាឡើយ បើធៀបទៅនឹងអាយុរបស់ជនជាប់ចោទ នួន ជា ។ ចំពោះជំងឺចុកចង្កេះ និងឆ្អឹងខ្នង ដែល នួន ជា តែងតែលើកឡើង និងយកជាមូលដ្ឋានក្នុងការស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្លួនចូលរួមសវនាការពីចម្ងាយ គឺត្រូវបានសាស្ត្រាចារ្យ ចន ខាំប៊ែល អះអាង ថា នេះគឺជាលក្ខណធម្មតាសម្រាប់មនុស្សដែលមានវ័យជាង ៨០ ឆ្នាំ ពោលគឺពុំមានអ្វីគួរឲ្យព្រួយបារម្ភឡើយ ។ នួន ជា អាចចូលរួមសវនាការបានយ៉ាងតិច៩០នាទី ដូច្នេះបើធៀបទៅនឹងរយៈពេលដែលអង្គជំនុំជម្រះបើកសវនាការមួយលើកៗ គឺ នួន ជា អាចចូលរួមដោយផ្ទាល់បាន ។ ទោះបីជាយ៉ាងណាក៏ដោយ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ពុំបានបដិសេធចំពោះការត្អូញត្អែររបស់ នួន ជា ឡើយ លើសពីនេះទៀតលោកថែមទាំងផ្ដល់អនុសាសន៍ថា ដើម្បីឲ្យ នួន ជា អាចចូលរួមសវនាការប្រកបដោយប្រសិទ្ធភាពអង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យជនជាប់ចោទរូបនេះចូល

រួមសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ដែលត្រូវបានរៀបចំទុកក្នុងបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ។ ចំពោះក្តីបារម្ភរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលបានបញ្ជាក់ថា កូនក្តីរបស់ខ្លួនមានការវង្វេងវង្វាយ (រហូតមានការផ្តាំ ផ្ញើរដល់កូនចៅ) បន្ទាប់ពីមានការដួលនៅមន្ទីរឃុំឃាំង លោកសាស្ត្រាចារ្យ ចន ខាំប៊ែល បានបំភ្លឺថា ការវង្វេងវង្វាយនេះគឺបណ្តាលមកពីជំងឺរលាកទងសួត ។ ប៉ុន្តែជម្ងឺនេះត្រូវបានព្យាបាលជាសះស្បើយរួចហើយ ដូច្នេះ នួន ជា ពុំមានការវង្វេងវង្វាយទៀតឡើយ ។

ក្រៅពីជំងឺដូចបានរៀបរាប់ខាងលើនេះ ក្រុមមេធាវីការពារក្តី បានលើកឡើងថា កូនក្តីរបស់ខ្លួនមានបញ្ហាភ្នែកមិនអាចអាន ឬមើលអក្សរឲ្យបានច្បាស់ ។ លើសពីនេះទៀត នួន ជា មានសភាពហេវហត់ នៅពេលដែលមានការដឹកជញ្ជូនពីមន្ទីរឃុំឃាំងមកបន្ទប់សវនាការ ។ តាមរយៈជំងឺទាំងនេះ ក្រុមមេធាវីមានការបារម្ភថា នួន ជា ពុំអាចចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព ។ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល បានទទួលស្គាល់ថា នួន ជា ពិតជាមានជម្ងឺភ្នែកប្រាកដមែន គឺជម្ងឺភ្នែកឡើងបាយទាំងសងខាង ។ អ្នកដែលកើតជម្ងឺនេះគឺពុំអាចអាន ឬមើលអក្សរដែលមានទំហំធម្មតាបានច្បាស់ឡើយ ។ ដូច្នេះដើម្បីអាចឲ្យ នួន ជា អាចអាន ឬមើលឯកសារណាមួយបាន គឺគប្បីសរសេរឲ្យធំៗ ឬអានឲ្យស្តាប់តែម្តង ។ បន្ថែមលើនេះទៀត ដើម្បីកាត់បន្ថយការនឿយហត់របស់ នួន ជា នៅពេលចាប់ផ្តើមសវនាការ គឺគប្បីនាំខ្លួនជនជាប់ចោទរូបនេះមកបន្ទប់រង់ចាំក្នុងរយៈពេលពី ១០-១៥ នាទីជាមុនសិនមុននឹងចាប់ផ្តើមបើកសវនាការ ។

ចុងក្រោយ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល បានបញ្ជាក់ថា យោងតាមរបាយការណ៍ពាក់ព័ន្ធ នឹងបញ្ហាសុខភាពរបស់ នួន ជា និងការណ៍ដែលលោកបានពិនិត្យផ្ទាល់ គឺបានបង្ហាញថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ ថ្វីត្បិតជនជាប់ចោទរូបនេះមានការចុះខ្សោយផ្នែកសាច់ដុំ ប៉ុន្តែវាពុំបានប៉ះពាល់ដល់ការចូលរួមសវនាការឡើយ ។ ទោះបីជាយ៉ាងណា លោកពុំហានអះអាងថា នៅពេលខាងមុខ សុខភាពរបស់ នួន ជា នឹងវិវត្តន៍យឺត ឬលឿនទៅជាយ៉ាងណាឡើយ ។ អនុសាសន៍ចុងក្រោយរបស់លោកនោះ គឺស្នើឲ្យ នួន ជា ធ្វើលំហាត់ប្រាណជាប្រចាំ ដើម្បីធ្វើឲ្យសាច់ដុំមានចលនា និងមានភាពល្អប្រសើរឡើងវិញ ។

### ១.២) សម្បទាផ្លូវចិត្តរបស់ជនជាប់ចោទ នួន ជា

ពាក់ព័ន្ធនឹងផ្នែកបញ្ញាស្មារតី លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បានអះអាងថា នួន ជា មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ នួន ជា អាចយល់ដឹងអំពីបទចោទប្រកាន់មកលើខ្លួន យល់ដឹងអំពីកិច្ចដំណើរការរបស់អង្គជំនុំជម្រះ មានសមត្ថភាពតាមដានសវនាការ យល់ដឹងអំពីតួនាទី របស់មេធាវីការពារក្តី អាចណែនាំ និងសហការណ៍ជាមួយមេធាវីរបស់ខ្លួនបានយល់ដឹងអំពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ... ។ ជាក់ស្តែង នួន ជា យល់ដឹងយ៉ាងច្បាស់ថា ខ្លួនគឺត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ល ។ ហើយខ្លួននឹងពុំត្រូវបានកាត់ទោសប្រហារជីវិតឡើយប្រសិនបើខ្លួនមានពិរុទ្ធភាព ព្រោះច្បាប់កម្ពុជាពុំអនុញ្ញាតឲ្យមានការប្រហារជីវិតឡើយ គឺត្រឹមតែដាក់ពន្ធនាគារតែប៉ុណ្ណោះ ។

ក្នុងការវាយតម្លៃអំពីសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា គឺ លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បានធ្វើការពិនិត្យរបាយការណ៍ប្រវត្តិសុខភាពរបស់ នួន ជា, ការធ្វើសម្ភាសន៍ជាមួយអ្នកដែលនៅមើលថែទាំ នួន ជា និងចុងក្រោយគឺការធ្វើតេស្តស្រាវជ្រាវអំពីលក្ខខណ្ឌនៃការយល់ដឹងអប្បបរមា (MMSE, Mini–Mental State ExamInation) ។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា តាមរយៈរបាយការណ៍ទាំងនោះ និងរបាយការណ៍ចុងក្រោយចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ គឺបានបង្ហាញថា នួន ជា ពុំមានបញ្ហាផ្នែកបញ្ញាស្មារតីឡើយ ពោលគឺនៅមានការចងចាំបានល្អ ។ លើសពីនេះទៀត របាយការណ៍ទាំងនេះគឺស្របគ្នាជាមួយកិច្ចសម្ភាសន៍ ដែលលោកបានធ្វើជាមួយអ្នកមើលថែទាំសុខភាពរបស់ នួន ជា ។ អ្នកមើលថែទាំនោះបានបញ្ជាក់ថា នួន ជា អាចតាមដានស្តាប់វិទ្យុបាន ហើយមានការចងចាំយ៉ាងល្អ ។ ចំពោះលទ្ធផលនៃការធ្វើតេស្តស្រាវជ្រាវអំពីលក្ខខណ្ឌនៃការយល់ដឹងអប្បបរមាគឺ នួន ជា ទទួល បានពិន្ទុ ២៨ លើ ៣០ ដែលនេះ គឺជាពិន្ទុដ៏ខ្ពស់មួយដែលមនុស្សចាស់ធម្មតាមិនងាយទទួលបាន ។ ក្នុងការធ្វើតេស្តស្រាវជ្រាវនេះ គឺលោកវេជ្ជបណ្ឌិតបានសួរសំណួរ

បីប្រភេទទៅ នួន ជា គឺសួរពាក់ព័ន្ធនឹងវ័យកុមារភាព ការរៀនសូត្រ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយចំនួន។ នួន ជា បានរៀបរាប់យ៉ាងលម្អិត ហើយតាមរយៈចម្លើយទាំងនោះគឺបានបង្ហាញថា នួន ជា មិនមានបញ្ហាក្នុងការចងចាំរយៈពេលខ្លី និងរយៈវែងឡើយ ។ ពាក់ព័ន្ធនឹងការចងចាំនេះ មេធាវីការពារក្តី នួន ជា គឺលោក សុន អរុណ បានលើកឡើង ថាកូនក្តីរបស់ខ្លួនមានការភ្លេចភ្លាំងច្រើន។ ជាក់ស្តែងសំណួរមួយចំនួន គឺត្រូវបានលោកសួរ



នួន ជា ចូលរួមសវនាការពីបន្ទប់រង់ចាំ ដោយសារបញ្ហាសុខភាព
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នួន ជា ម្តងហើយម្តងទៀត ក្នុងរយៈពេលជុតតែ៤-៥ នាទីតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងការលើកឡើងនេះ លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បញ្ជាក់ថា ស្ថានភាពនេះ គឺដូនកាលបណ្តាលមកពីអ្នកត្រូវបានគេសួរនោះពុំសូវចាប់អារម្មណ៍អំពីសំណួរទាំងនោះ ។ ប៉ុន្តែសម្រាប់ការធ្វើកោសល្យវិច័យរបស់លោក គឺបានបង្ហាញថា ក្នុងរយៈពេលនេះ គឺ នួន ជា មានការចងចាំ ។ ជាក់ស្តែងលោកបានបង្ហាញវត្ថុបីផ្សេងគ្នា ហើយរយៈពេល៥នាទីក្រោយមក នួន ជា នៅតែចាំវត្ថុទាំងបីនោះដដែល ។

ចុងក្រោយលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បានអះអាងថា តាមរយៈកិច្ចសម្ភាសន៍ដែលលោកបានធ្វើជាមួយ នួន ជា ចំនួនបីដង គឺបានបង្ហាញថា ជនជាប់ចោទរូបនេះមានការចងចាំល្អ, ពុំមានការអស់កំលាំងក្នុងអំឡុងពេលផ្តល់កិច្ចសម្ភាសន៍ និងមិនមានបញ្ហាក្នុងការផ្តង់អារម្មណ៍ឡើយ ។ ដូច្នេះ ជនជាប់ចោទ នួន ជា មានបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។

គួរបញ្ជាក់ថា លោកវេជ្ជបណ្ឌិត ចន ខាំប៊ែល និង លោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល គឺ ត្រូវបានអង្គជំនុំជម្រះចាត់តាំងឲ្យធ្វើការវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ដោយអនុលោមតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងរឿងក្តីស្រ្តូហ្គ ដែលបានសម្រេចដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ តុលាការនេះបានកំណត់ថា បុគ្គលណាម្នាក់មានសម្បទាគ្រប់គ្រាន់ចូល រួម សវនាការគឺត្រូវមាន៖

- សមត្ថភាពឆ្លើយតបទៅនឹងបទចោទ
- សមត្ថភាពយល់ដឹងអំពីលក្ខណៈនៃការចោទប្រកាន់
- សមត្ថភាពយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី
- សមត្ថភាពយល់ដឹងអំពីសេចក្តីពិស្តារនៃភស្តុតាង
- សមត្ថភាពណែនាំមេធាវីការពារក្តីរបស់ខ្លួន
- សមត្ថភាពយល់ដឹងពីផលវិបាកនៃកិច្ចដំណើរការនីតិវិធី និង
- សមត្ថភាពធ្វើសក្ខីកម្មដោយខ្លួនឯង ។

### ១.៣) សេចក្តីសន្និដ្ឋានចុងក្រោយរបស់ភាគី

នីតិវិធីនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់អំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា គឺត្រូវបានធ្វើតាមលំដាប់ដោយចាប់ពីក្រុមមេធាវីការពារក្តី តំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយចុងក្រោយអង្គជំនុំជម្រះអនុញ្ញាតក្រុមមេធាវីការពារក្តីធ្វើការឆ្លើយតបរួម ។

បន្ទាប់ពីទទួលបានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ លោក

សុន អរុណ បានលើកឡើងដោយសង្ខេបអំពីស្ថានភាពសុខភាពកូនក្តីរបស់ខ្លួន ។ មេធាវីបានអះអាងថា នួន ជា ដែលជាកូនក្តីរបស់ខ្លួនគឺ កំពុងមានជំងឺជាច្រើនប្រភេទដូចជា ឈឺចង្កេះ ឈឺខ្នង លើសឈាម ស្រវាំងភ្នែក...ដែលធ្វើឲ្យប៉ះពាល់ ដល់ការផ្ចង់អារម្មណ៍ និងការចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព ។ ដូច្នេះការដាក់ឲ្យកូនក្តីរបស់ខ្លួន តាមដានសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ គឺពុំមានផលប្រយោជន៍អ្វីទាំងអស់ ពោលគឺគ្រាន់តែធ្វើដើម្បីជាការបំពេញកិច្ចតែប៉ុណ្ណោះ ។ បន្ថែមលើនេះទៀត មេធាវីការពារក្តីបានបង្ហាញជំហរច្រានចោលរបាយការណ៍របស់អ្នកជំនាញទាំងពីររូបចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ដែលបង្ហាញថា កូនក្តីរបស់ខ្លួនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ សំណើចុងក្រោយរបស់មេធាវីការពារក្តី គឺសុំឲ្យព្យាបាលកូនក្តីរបស់ខ្លួនឲ្យបានជាសះស្បើយជាមុនសិន មុននឹងនាំមកជំនុំជម្រះក្តី បើពុំនោះទេនឹងនាំឲ្យមានការរំលោភសិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព ។

ឆ្លើយតបចំពោះការលើកឡើងទាំងនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិគឺលោក ឌេល លីសាក់ បានធ្វើការបដិសេធចោលស្ទើរតែទាំងស្រុងចំពោះអំណះអំណាង និងសំណើសុំរបស់មេធាវីការពារក្តី ។ លោកបានបញ្ជាក់ថា ជម្ងឺមួយចំនួនធំរបស់ នួន ជា ដូចជាជម្ងឺរលាកទងសួត ដាច់សរសៃឈាមក្នុងខួរក្បាល... គឺត្រូវបានព្យាបាលជាសះស្បើយរួចហើយ ពោលគឺនៅតែជម្ងឺមួយចំនួនតែប៉ុណ្ណោះ ហើយជម្ងឺទាំងនោះ គឺពុំមានការប៉ះពាល់ដល់ការចូលរួមសវនាការឡើយ ។ អំណះអំណាងនេះគឺលោកយោងទៅលើរបាយការណ៍ចុងក្រោយរបស់អ្នកជំនាញទាំងពីររូបដែលរកឃើញថាជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ។ បន្ថែមលើនេះទៀត ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រទាំងស្រុងចំពោះអំណះអំណាងរបស់តំណាងសហព្រះរាជអាជ្ញា ។ មេធាវី ហុង គីមសួន បានអះអាងថា របាយការណ៍ចុងក្រោយចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ដែលបានផ្តល់ដោយលោក វេជ្ជបណ្ឌិត ស៊ីណា ហ្វារហ្សែល និងវេជ្ជបណ្ឌិត ចន ខាំប៉ែល គឺមានភាពច្បាស់លាស់ និងអាចទុកចិត្តបាន ។ ចុងក្រោយលោកស្នើសុំអង្គជំនុំជម្រះសម្រេចបដិសេធចោលនូវអំណះអំណាង និងសំណើទាំងឡាយរបស់ក្រុមមេធាវីការពារក្តី នួន ជា ។ លើសពីនេះទៀត សហការីរបស់លោក គឺមេធាវី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត ស្នើសុំបន្ថែមថា រាល់ពេលចាប់ផ្តើមបើកសវនាការ គឺសូមឲ្យបង្ហាញវត្តមានរបស់ នួន ជា ជាមុនសិន ដើម្បីបង្ហាញឲ្យឃើញថា នួន ជា ពិតជាបានចូលរួមសវនាការយ៉ាងសកម្ម ។

ចុងក្រោយក្រុមមេធាវីការពារ នួន ជា ពុំបានធ្វើការឆ្លើយតបឡើយ គឺគ្រាន់តែលើកឡើងអំពីស្ថានភាពសុខភាពកូនក្តីរបស់ខ្លួនតែប៉ុណ្ណោះ ។ លោក សុន អរុណ បញ្ជាក់ថា កូនក្តីរបស់ខ្លួនពុំអាចអង្គុយបានយូរឡើយព្រោះមានបញ្ហាចង្កេះ គឺអាចអង្គុយបានតែ ៥-៦នាទីប៉ុណ្ណោះ ។ ដូច្នេះត្រូវធ្វើយ៉ាងណាឲ្យ នួន ជា មានសុខភាពល្អប្រសើរឡើងវិញ ដើម្បីអាចមានលទ្ធភាពចូលរួមសវនាការបានពេញលេញ ។

### ២) សេចក្តីសម្រេចស្តីពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ

បន្ទាប់ពីបញ្ចប់សវនាការសួរដេញដោលអ្នកជំនាញទាំងពីរប្រមាណ៤ថ្ងៃក្រោយមក នៅព្រឹក ថ្ងៃទី២៩ ខែមីនា អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះបានយោងទាំងស្រុងទៅលើរបាយការណ៍ និងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត ចន ខាំប៉ែល និង វេជ្ជបណ្ឌិត ស៊ីណា ហ្វារហែល ដែលអះអាងថា នួន ជា មានសមត្ថភាពចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព ។ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចជាលាយល័ក្ខអក្សរបន្ថែមទៀតទាក់ទងនឹងបញ្ហាសម្បទារបស់ នួន ជា ។ នៅក្នុងសេចក្តីសម្រេចទីពីរនេះ អង្គជំនុំជម្រះបានបញ្ជាក់ឡើងវិញថា នួន ជា មាន សម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ សេចក្តីសម្រេចនេះដែរ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសំណើរបស់មេធាវីការពារក្តីដែលសុំឲ្យមានការពិនិត្យបន្ថែមផ្នែករាងកាយ និងបញ្ញាស្មារតីរបស់ នួន ជា និងសំណើសុំអនុញ្ញាតឲ្យ នួន ជា ចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅមន្ទីរឃុំឃាំង ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

កម្មេច : វាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានន័យថា កាសម្លាប់ ឬប្រហារជីវិតបុគ្គលណាម្នាក់ ។

ភូមិភាគ : លំដាប់ខ្ពស់បំផុតនៃការគ្រប់គ្រងរដ្ឋបាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

តំបន់ : កម្រិតទីពីរនៃការគ្រប់គ្រងផ្នែករដ្ឋបាល នៅក្រោមថ្នាក់ភូមិភាគ ដែលតំបន់នីមួយៗ ត្រូវបានដាក់លេខកំណត់ការសម្គាល់មួយដោយឡែកពីគ្នា ។

ស្រុក : ថ្នាក់រដ្ឋបាលទីបីក្រោមភូមិភាគ និងតំបន់ សំដៅលើទីតាំងភូមិសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។


មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល : dccam@online.com.kh
គេហទំព័រ : www.dccam.org ឬ
www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ Bureau of Democracy, Human Rights, and Labor, U.S. Department of State ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ភាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លីម ជ័យទ័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

# ព្រះរាជាណាចក្រកម្ពុជា







**វាលពិឃាតនៅកម្ពុជា** ៖ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រក្នុងការស្វែងរក និងគូរផែនទីរណ្តៅសាកសពរួមជាមួយនឹងការចុះទៅស្រាវជ្រាវដល់ទីកន្លែងបានធ្វើការកំណត់រណ្តៅសាកសពនៅទូទាំងប្រទេស ។ រហូតមកដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញវាលពិឃាតចំនួន៣៨៨កន្លែង ដែលរួមមាន១៩៧៣៣រណ្តៅ (រណ្តៅមួយចំនួនមានសាកសព៤នាក់ ឬច្រើនជាងនេះ ហើយមួយចំនួនផ្សេងទៀត មានសាកសពរហូតដល់ទៅជាងមួយពាន់នាក់) ។ ជាងនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញទីតាំងគុកចំនួន១៩៦ និងទីតាំងបូជនីយដ្ឋានដែលសាងសង់ឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យចំនួន៨៨ ។